ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# កម្មវិធីវិនិយោគបីឆ្នាំរំកិល
# ឆ្នាំ២០២៥-២០២៧របស់ខេត្តព្រៃវែង

បានទទួលការអនុម័ត

ពីក្រុមប្រឹក្សាខេត្តក្នុងកិច្ចប្រជុំសាមញ្ញលើកទី ០៧ អាណត្តិទី ៤

ក្រុមប្រឹក្សាខេត្តព្រៃវែង

នាថ្ងៃ ព្រហស្បតិ៍ ៥កើត ខែ មិគសិរ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨

ព្រៃវែង,ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ២០២៤

# មាតិកា


សេចក្តីសម្រេចស្តីពីការដាក់ឲ្យប្រើប្រាស់កម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត.......i
អារម្ភកថា....... iii
សេចក្តីផ្តើម .......iv
ផែនទីខេត្តព្រៃវែង .......v

ជំពូកទី១៖ស្ថានភាពសេដ្ឋកិច្ចសង្គមកិច្ច ....... ១

១.១. សេចក្តីសង្ខេបទិន្នន័យសេដ្ឋកិច្ចសង្គមកិច្ច .......២

១.២. ស្ថានភាពបច្ចុប្បន្ននិងបញ្ហាប្រឈម .......១០

១.២.១. ស្ថានភាពសេដ្ឋកិច្ច ....... ១០

១.២.២. ស្ថានភាពសង្គមកិច្ច ....... ៤៦

១.២.៣. ស្ថានភាពនៃការប្រើប្រាស់ដីធ្លីការគ្រប់គ្រងធនធានធម្មជាតិនិងបរិស្ថាន ការគ្រប់គ្រងគ្រោះមហន្តរាយនិងការប្រែប្រួលអាកាសធាតុ .......៧៤

១.២.៤. ស្ថានភាពនៃការគ្រប់គ្រងរដ្ឋបាលនិងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ....... ៨១

ជំពូកទី២៖គម្រោងនៃកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត .......៨៧

២.១. តារាងសង្ខេបប្រភពមូលនិធិ ....... ៨៨

២.២. តារាងគម្រោង សកម្មភាពវិនិយោគកំពុងដំណើរការ ....... ៨៩

២.៣. តារាងគម្រោង សកម្មភាពវិនិយោគមានថវិកាគាំទ្រ .......១០៣

២.៤. តារាងគម្រោង សកម្មភាពអាទិភាពមិនទាន់មានថវិកាគាំទ្រ ....... ១២២

២.៥. តារាងកម្មវិធីប្រតិបត្តិការសេវារដ្ឋបាល ....... ១៣៩

២.៦. តារាងការដាក់ចេញលិខិតបទដ្ឋានគតិយុត្តនានា ....... ១៤២

២.៧. តារាងគម្រោង សកម្មភាពរបស់ក្រសួង ស្ថាប័នកំពុងដំណើរការ ....... ១៤៣

ជំពូកទី៣៖ការតាមដានត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិល ....... ១៤៨

២.៨. តារាងតាមដានការអនុវត្តកម្មវិធីវិនិយោគខេត្ត .......១៤៩

ឧបសម្ព័ន្ធនានា.......១៦៨

ឧបសម្ព័ន្ធទី១៖ ប្រតិទិនការងារកសាងកម្មវិធីវិនិយោគខេត្តព្រៃវែង.......១៦៩

ឧបសម្ព័ន្ធទី២៖ តារាងបូកសរុបគម្រោងវិនិយោគខេត្តព្រៃវែង.......១៧១

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## រដ្ឋបាលខេត្តព្រៃវែង

**លេខៈ ០០២/២៥ សសរ**

**សេចក្តីសម្រេច**

**ស្តីពី**

**ការដាក់ឲ្យប្រើប្រាស់កម្មវិធីវិនិយោគបីឆ្នាំរំកិល២០២៥-២០២៧ របស់ខេត្តព្រៃវែង**

**ក្រុមប្រឹក្សាខេត្តព្រៃវែង**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ចុះថ្ងៃទី២៤ខែឧសភាឆ្នាំ២០០៨ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៩/៧៥៧ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៩ ត្រាស់បង្គាប់ទទួលស្គាល់សមាសភាពក្រុមប្រឹក្សាខេត្តព្រៃវែង អាណត្តិទី៣
- បានឃើញអនុក្រឹត្យលេខ ២១៦អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទីភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ ២១៩ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១៥២ អនក្រ.បក ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការកែសម្រួលមាត្រា១២នៃអនុក្រឹត្យ ស្តីពីការកសាងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញប្រកាសអន្តរក្រសួងលេខ ០៨៨ ប្រក ចុះថ្ងៃទី០២ ខែមិនា ឆ្នាំ២០១៧ ស្តីពីផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- យោងស្មារតីនៃកិច្ចប្រជុំសាមញ្ញលើកទី ៥៤ អាណត្តិទី៣ របស់ក្រុមប្រឹក្សាខេត្តព្រៃវែង នាថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ២០២៤ ។

# សម្រេច

ប្រការ ១.-

ត្រូវបានដាក់ឲ្យប្រើប្រាស់នូវកម្មវិធីវិនិយោគបីឆ្នាំរំកិល២០២៤-២០២៦របស់ខេត្តព្រៃវែង ដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សាខេត្តនាកិច្ចប្រជុំសាមញ្ញលើកទី ០៧ នាថ្ងៃទី ០៥ ខែធ្នូ ឆ្នាំ២០២៤ ។

ប្រការ ២.-

គណៈអភិបាលខេត្តព្រៃវែង ត្រូវចាត់ចែងផ្សព្វផ្សាយកម្មវិធីវិនិយោគបីឆ្នាំរំកិលនេះដល់ប្រជាពលរដ្ឋនិងអ្នកពាក់ព័ន្ធនានានៅក្នុងដែនសមត្ថកិច្ចរបស់ខេត្ត។

គណៈអភិបាលខេត្ត ត្រូវចាត់ចែងសម្របសម្រួលនិងកៀរគរធនធាននានាក្នុងការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលនេះប្រកបដោយការចូលរួម តម្លាភាព គណនេយ្យភាពនិងប្រសិទ្ធភាពខ្ពស់។

ប្រការ ៣.-

គណៈអភិបាលខេត្ត ត្រូវរៀបចំយន្តការនិងប្រព័ន្ធសម្រាប់ការតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលនេះ ដោយមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធនានា ដើម្បីបង្កើនប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិល២០២៥-២០២៧។

គណៈអភិបាលខេត្ត ត្រូវរៀបចំរបាយការណ៍ស្តីពីលទ្ធផលនៃការតាមដានត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិល២០២៥-២០២៧ និងរបាយការណ៍ជូនអង្គភាពប្រជុំក្រុមប្រឹក្សាខេត្តអំពីវឌ្ឍនភាពនៃការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលទៅតាមកាលកំណត់។

គណៈអភិបាលខេត្ត ត្រូវរៀបចំនិងដាក់ជូនក្រុមប្រឹក្សាខេត្ត អំពីរបាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលនេះ។

ប្រការ ៤.-

គណៈអភិបាលខេត្ត ទីចាត់ការនានាចំណុះរដ្ឋបាលសាលាខេត្ត មន្ទីរ និងអង្គភាពពាក់ព័ន្ធទាំងអស់ក្នុងខេត្ត ត្រូវអនុវត្តតាមសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ១០កើត ខែបុស្ស ឆ្នាំរោង ឆស័ក ព.ស ២៥៦៨

ព្រៃវែង,ថ្ងៃទី ០៨ ខែ មករា ឆ្នាំ២០២៥

**ប្រធានក្រុមប្រឹក្សាខេត្តព្រៃវែង**

<u>ចម្លងជូន</u> ៖

-ក្រសួងមហាផ្ទៃ

-លេខាធិការដ្ឋាន គ.ជ.អ.ប

-គណៈអភិបាលខេត្ត

-ឯកសារ-កាលប្បវត្តិ

# អារម្ភកថា

ក្រុមប្រឹក្សាខេត្តព្រៃវែង បានរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិល២០២៥-២០២៧របស់ខ្លួន ដើម្បីអនុវត្តផែនការអភិវឌ្ឍន៍៥ឆ្នាំ២០២៥-២០២៩ របស់ខេត្ត សំដៅជំរុញការអភិវឌ្ឍសេដ្ឋកិច្ចនៅមូលដ្ឋាន លើកកម្ពស់គុណភាពសេវាសាធារណៈនិងលើកកម្ពស់ជីវភាពរស់នៅ ព្រមទាំងសុខុមាលភាពរបស់ប្រជាពលរដ្ឋដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្រក្នុងខេត្ត។

កម្មវិធីវិនិយោគបីឆ្នាំរំកិល២០២៥-២០២៧នេះ ត្រូវបានរៀបចំឡើងដោយស្របតាមក្របខ័ណ្ឌអភិវឌ្ឍន៍ខេត្តនិងគោលការណ៍ណែនាំនានា ព្រមទាំងបានផ្តល់ឱកាសឲ្យមានការចូលរួមដោយផ្ទាល់ពីមន្ទីរ-អង្គភាពជំនាញជុំវិញខេត្ត តំណាងក្រុមប្រឹក្សាក្រុង-ស្រុក អង្គការសង្គមស៊ីវិល វិស័យឯកជនក្នុងការលើកសំណើគម្រោងវិនិយោគនានាដែលមានឈ្មោះគម្រោងនិងថវិកាច្បាស់លាស់ សំដៅជំរុញការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមកិច្ចក្នុងន័យឆ្លើយតបទៅនឹងតម្រូវការចាំបាច់របស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

ក្នុងនាមក្រុមប្រឹក្សាខេត្តព្រៃវែងអាណត្តិទី៤ ខ្ញុំសូមថ្លែងអំណរគុណដល់គណៈអភិបាលខេត្ត គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស គណៈកម្មាធិការពិគ្រោះយោបល់ស្ត្រីនិងកុមាររបស់ក្រុមប្រឹក្សាខេត្ត មន្ទីរ-អង្គភាពជំនាញក្នុងខេត្ត ក្រុមប្រឹក្សាក្រុង-ស្រុក អង្គការសង្គមស៊ីវិល វិស័យឯកជននិងអ្នកពាក់ព័ន្ធនានា ដែលបានចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការកសាងកម្មវិធីវិនិយោគខេត្តនេះ។ ជាមួយគ្នានេះ ខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់គណៈអភិបាលខេត្ត ក្រុមការងារកសាងផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត មន្ទីរផែនការខេត្តដែលបានដឹកនាំនិងសម្របសម្រួលដំណើរការកសាងកម្មវិធីវិនិយោគខេត្តរហូតសម្រេចលទ្ធផលជាស្ថាពរ។

ក្នុងនាមក្រុមប្រឹក្សាខេត្ត ខ្ញុំសូមអំពាវនាវនិងរំពឹងថាដៃគូអភិវឌ្ឍន៍នានា អង្គការសង្គមស៊ីវិល វិស័យឯកជននិងសប្បុរសជននានា ព្រមទាំងក្រសួងស្ថាប័នថ្នាក់ជាតិប្រាកដជាជួយគាំទ្រគម្រោងសកម្មភាពឬសេវាជាអាទិភាពនានាដែលបានកំណត់នៅក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិល២០២៥-២០២៧នេះ។

ថ្ងៃ ពុធ ១០កើត ខែ បុស្ស ឆ្នាំរោង ឆស័ក ព.ស ២៥៦៨

ព្រៃវែង,ថ្ងៃទី ០៨ ខែ មករា ឆ្នាំ២០២៥

**ប្រធានក្រុមប្រឹក្សាខេត្តព្រៃវែង**

# សេចក្តីផ្តើម

នៅខែឧសភា ឆ្នាំ២០២៤ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានីខេត្តក្រុងស្រុកខណ្ឌ អាណត្តិទី៤ បានធ្វើឡើងប្រកបដោយជោគជ័យក្រោមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានីខេត្តក្រុងស្រុកខណ្ឌ។

ក្រុមប្រឹក្សាខេត្តរួមជាមួយគណៈអភិបាលខេត្ត បានអនុវត្តនូវតួនាទីភារកិច្ចរបស់ខ្លួនដើម្បីអភិបាលកិច្ច និងអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានស្របតាមច្បាប់គោលនយោបាយវិមជ្ឈការនិងវិសហមជ្ឈការ និងលិខិតបទដ្ឋានគតិយុត្តិនានា។

ក្រុមប្រឹក្សាខេត្តព្រៃវែងអាណត្តិទី៤ បានរៀបចំផែនការអភិវឌ្ឍន៍ខេត្តសម្រាប់ឆ្នាំ២០២៥-២០២៩ ដោយយោងមាត្រា៣៨ និងមាត្រា៣៩នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានីខេត្តក្រុងស្រុកខណ្ឌ អនុក្រឹត្យលេខ២១៩អនក្រ.បកចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានីខេត្តក្រុងស្រុកខណ្ឌ និងអនុក្រឹត្យលេខ១៥២អនក្រ.បកចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការកែសម្រួលមាត្រា១២នៃអនុក្រឹត្យស្តីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានីខេត្តក្រុងស្រុកខណ្ឌ។

កម្មវិធីវិនិយោគបីឆ្នាំរំកិល២០២៥-២០២៧របស់ខេត្តព្រៃវែងបានរៀបចំឡើង ស្របតាមផែនការអភិវឌ្ឍន៍ខេត្ត២០២៥-២០២៩និងសេចក្តីណែនាំនានា ដោយមានការចូលរួម និងពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធនានាមានដូចជា ក្រុមប្រឹក្សាក្រុង-ស្រុក មន្ទីរអង្គភាពជំនាញជុំវិញខេត្ត អង្គការសង្គមស៊ីវិល វិស័យឯកជន និងតំណាងក្រុមការពារផលប្រយោជន៍នានា ពិសេសក្រុមស្រ្តីនិងកុមារក្នុងការវិភាគស្ថានភាពសក្តានុពល បញ្ហាប្រឈម និងលើកឡើងនូវតម្រូវការនានា។

កម្មវិធីវិនិយោគបីឆ្នាំរំកិល២០២៥-២០២៧ របស់ខេត្តព្រៃវែងមានបីជំពូក គឺ

- **ជំពូកទី១** បរិយាយអំពី ស្ថានភាពសេដ្ឋកិច្ចសង្គមកិច្ច
- **ជំពូកទី២** បរិយាយអំពីគម្រោងនៃកម្មវិធីវិនិយោគបីឆ្នាំរំកិល
- **ជំពូកទី៣** បរិយាយអំពីការតាមដានត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិល២០២៥-២០២៧។


ផែនទីខេត្តព្រៃវែង
ខេត្តកំពង់ចាម
ខេត្តត្បូងឃ្មុំ
ស៊ីធរកណ្ដាល
កញ្ច្រៀច
ពារាំង
កំចាយមារ
ប្រទេសវៀតណាម
ពោធិ៍រៀង
ស្វាយអន្ទរ
ព្រៃវែង
ខេត្តស្វាយរៀង
មេសាង
ពាមរក៍
ខេត្តកណ្ដាល
បាភ្នំ
កំពង់ត្របែក
ព្រះស្ដេច
ពាមជរ
ប្រទេសវៀតណាម
តំណាងសំគាល់
ព្រំប្រទល់ខេត្ត
ព្រំប្រទល់ស្រុក
ព្រំប្រទល់ឃុំ
ផ្លូវជាតិ
ផ្លូវខេត្ត
ផ្លូវរថភ្លើង
ទន្លេ ស្ទឹង ព្រែក
សាលាស្រុក
សាលារៀន
មណ្ឌលសុខភាពឃុំ
មន្ទីរពេទ្យបង្អែក

# ជំពូកទី១
# ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច

# ជំពូកទី១
# ស្ថានភាពសេដ្ឋកិច្ចសង្គមកិច្ច

ខេត្តព្រៃវែងស្ថិតនៅទិសអាគ្នេយ៍នៃប្រទេសកម្ពុជា មានព្រំប្រទល់ខាងកើតទល់នឹងខេត្តស្វាយរៀង និងប្រទេសវៀតណាម ខាងលិចទល់នឹងខេត្តកណ្ដាល ខាងត្បូងទល់នឹងប្រទេសវៀតណាម ខាងជើងទល់នឹងខេត្តកំពង់ចាមនិងខេត្តត្បូងឃ្មុំ។ ខេត្តមានខ្សែបន្ទាត់ព្រំដែនជាមួយប្រទេសវៀតណាមប្រវែង ៨២,៦៧១ម៉ែត្រ ដោយមានស្រុកចំនួន៤គឺស្រុកពាមជរ ព្រះស្ដេច កំពង់ត្របែកនិងកំចាយមារ រួមមានឃុំចំនួន៨ ភូមិចំនួន១៧ដែលស្ថិតនៅតាមបណ្ដោយព្រំដែននោះ។

ខេត្តមានច្រកទ្វារព្រំដែនជាមួយវៀតណាមចំនួន៦ ក្នុងនោះច្រកទ្វារអន្តរជាតិមាន៣កន្លែង គឺច្រកបន្ទាយចក្រី កោះរកា ម៉ឺនជ័យ និងច្រកទ្វារតំបន់មាន៣កន្លែងគឺច្រកកោះសំពៅ ពាមមន្ទារ និងស្វាយអាដោង។

ខេត្តមានស្រុកចំនួន១២និងក្រុង១មានឃុំសង្កាត់ចំនួន១១៦ គឺឃុំចំនួន១១២ និងសង្កាត់ចំនួន៤ ព្រមទាំងភូមិចំនួន១,១៦៨(កើនភូមិថ្មីចំនួន១៩ ដែលបង្កើតឡើងដោយប្រកាសក្រសួងមហាផ្ទៃ លេខ ៦៨៤០ ប្រក ចុះថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ២០២២)។

ខេត្តមានផ្ទៃដីសរុប ៤,៨៨៣គម$^{២}$ (៤៨៨,៣០០ហិកតា) ក្នុងនោះផ្ទៃដីដាំស្រូវ និងដំណាំមាន ៣៣៧,០០០ហិកតា(ស្មើនឹង ៦៩%នៃផ្ទៃដីសរុប) ចែកចេញជារដូវវស្សា ២៥០,០០០ហិកតា ស្រូវរដូវប្រាំង ៧៥,០០០ហិកតា និងផ្ទៃដីដាំដំណាំមាន ១២,០០០ហិកតា (មិនទាន់គិតផ្ទៃដីដែលកាត់ពីស្រុករមាសហែកខេត្តស្វាយរៀងបញ្ចូលមកស្រុកកំចាយមារខេត្តព្រៃវែង)។

ទីរួមខេត្តមានចម្ងាយ ៩៥គីឡូម៉ែត្រពីរាជធានីភ្នំពេញ បើធ្វើដំណើរតាមផ្លូវជាតិលេខ១១និងលេខ១កាត់តាមស្ពានត្សឹបាសា(អ្នកលឿង) ហើយមានចម្ងាយ១០០គីឡូម៉ែត្រ បើធ្វើដំណើរតាមផ្លូវជាតិលេខ១១-លេខ៨ និងលេខ៦ កាត់តាមស្ពានព្រែកតាមាក់។

ខេត្តមានផ្លូវជាតិឆ្លងកាត់ចំនួន៦ខ្សែមានប្រវែងសរុប ២០៦.៩២៥ម៉ែត្រគឺៈ (១)ផ្លូវជាតិលេខ១ ប្រវែង ៤១,៤៧០ ម៉ែត្រ (២)ផ្លូវជាតិលេខ៨ប្រវែង ៧៩,២០០ ម៉ែត្រ (៣)ផ្លូវជាតិលេខ១១ប្រវែង ៦៧,៦៥០ម៉ែត្រ (៤)ផ្លូវជាតិលេខ៨៨ប្រវែង ៥,៦៣០ ម៉ែត្រ (៥)ផ្លូវជាតិលេខ១៣ប្រវែង ៤,០០០ម៉ែត្រ (៦)ផ្លូវជាតិលេខ ៧០បេ ចេញពីទន្លេបិទ ខេត្តត្បូងឃ្មុំ(ភ្ជាប់ផ្លូវជាត់លេខ៧) ឆ្លងកាត់ខេត្តកណ្ដាលមកដល់ឃុំពាមមានជ័យ និងឃុំពាមរក៍ ស្រុកពាមរក៍ ខេត្តព្រៃវែង (ភ្ជាប់ផ្លូវជាតិលេខ១១) ឆ្លងកាត់ខេត្តព្រៃវែង ប្រវែង ៨,៩៧៥ ម៉ែត្រ។

ខេត្តមានទន្លេមេគង្គប្រវែង ៥៧គីឡូម៉ែត្រ ឆ្លងកាត់ស្រុកពាមរក៍ និងស្រុកពាមជរតាមបណ្ដោយព្រំប្រទល់ខេត្តកណ្ដាល។ មានទន្លេតូច៣ខ្សែនិងទន្លេព្រំដែន១ខ្សែសរុបប្រវែង២៨១,៣០០ម៉ែត្រ ក្នុងនោះទន្លេតូចទាំង៣ខ្សែ សរុប ២៣០គីឡូម៉ែត្រ(ទន្លេពាវាំងប្រវែង ១០៣គីឡូម៉ែត្រ ទន្លេស្ទឹងស្លូតប្រវែង ៦៦ គីឡូម៉ែត្រ ទន្លេកំពង់ត្របែកប្រវែង ៦១គីឡូម៉ែត្រ) និងទន្លេតាមបណ្ដោយព្រំដែនប្រទេសវៀតណាម ប្រវែង ៥១,៣០០ម៉ែត្រ ដែលស្ថិតនៅស្រុកពាមជរ ព្រះស្ដេច និងកំពង់ត្របែក។

ប្រជាពលរដ្ឋក្នុងខេត្តគិតមកដល់ដំណាច់ឆ្នាំ២០២៤មាន ៣០០,៩៧៥ គ្រួសារ រួមមានមនុស្សសរុប ១,២៨៣,០៣៦ នាក់ (ស្រី ៦៦៣,៨៦៦ នាក់ ស្មើនឹង ៥១,៧៤%) គិតជាទំហំគ្រួសារមានជាមធ្យម ៤,២៦នាក់ក្នុង១គ្រួសារ ចំណែកដង់ស៊ីតេមាន ២៦២នាក់ក្នុង១គីឡូម៉ែត្រក្រឡា។

*សូមបញ្ជាក់ថាព័ត៌មានពាក់ព័ន្ធនឹងចំនួនប្រជាជនដែលបានរៀបរាប់ខាងលើ គឺជាស្ថិតិដែលប្រមូលបានក្នុងខែតុលា ឆ្នាំ២០២៤ ចំណែកតួលេខក្នុងតារាងខាងក្រោមគឺជាទិន្នន័យមូលដ្ឋាន(CDB)ដែលប្រមូលពីភូមិឃុំ-សង្កាត់នាចុងឆ្នាំ២០២៣(សម្រាប់ប្រើប្រាស់ឆ្នាំ២០២៤)ដូច្នេះចំនួនប្រជាជនគឺមានលំអៀងគ្នាតិចតួច។*

# ១.១.សេចក្តីសង្ខេបទិន្នន័យសេដ្ឋកិច្ចសង្គមកិច្ច ក-ព័ត៌មានសំខាន់ៗក្នុងខេត្ត

| បរិយាយ | ឯកតា | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ឆ្នាំ២០២១ | ឆ្នាំ២០២២ | ឆ្នាំ២០២៣ | ឆ្នាំ២០២៤ |
|---|---|---|---|---|---|---|---|
| ផ្ទៃដីខេត្ត | គម² | 4,883 | 4,883 | 4,883 | 4,883 | 4,883 | 4,883 |
| ចំនួនក្រុង ស្រុក | ក្រុងស្រុក | 13 | 13 | 13 | 13 | 13 | 13 |
| ចំនួនឃុំ សង្កាត់ | ឃុំសង្កាត់ | 116 | 116 | 116 | 116 | 116 | 116 |
| ចំនួនភូមិ | ភូមិ | 1,149 | 1,149 | 1,149 | 1,149 | 1,168 | 1,168 |
| ចំនួនប្រជាជនសរុប | នាក់ | 1,230,450 | 1,235,321 | 1,241,332 | 1,250,416 | 1,271,330 | 1,272,669 |
| ចំនួនស្ត្រីសរុប | នាក់ | 636,162 (51.70%) | 639,299 (51.75%) | 641,083 (51.65%) | 645,409 (51.62%) | 657,171 (51.69%) | 658,906 (51.77%) |
| អត្រាភេទ(ចំនួនមនុស្សប្រុសក្នុងស្ត្រី ១០០នាក់) | នាក់ | 93,42 | 93,23 | 93,63 | 93,74 | 93,45 | 93,15 |
| កំណើនប្រជាជនប្រចាំឆ្នាំ | % | 0.9 | 0.4 | 0.4 | 0.7 | 1.67 | 1.41 |
| ចំនួនគ្រួសារសរុប | គ្រួសារ | 284,590 | 289,287 | 292,935 | 295,594 | 298,893 | 302,687 |
| ទំហំគ្រួសារ | ន/១គ្រួសារ | 4.32 | 4.27 | 4.24 | 4.23 | 4.25 | 4.20 |
| ដង់ស៊ីតេ | ន.គម² | 251 | 252 | 254 | 256 | 260 | 260 |
| អត្រាមេគ្រួសារជាស្ត្រី | % | 17.04 | 17.62 | 17.67 | 17.43 | 17.85 | 18.10 |
| អត្រាមនុស្សមានមុខរបរកសិកម្មជាចម្បង | % | 64.8 | 63.9 | 63.5 | 62.1 | 59.9 | 59.2 |
| %គ្រួសារមានផ្ទះដំបូលប្រក់ស្លឹក | % | 2.47 | 1.6 | 1.2 | 1.0 | 0.91 | 0.78 |
| ផលធៀបចំនួនម៉ូតូនិងគ្រួសារ | ម៉ូតូ/១គ្រួសារ | 0.7 | 0.7 | 0.7 | 0.8 | 0.81 | 0.83 |
| %គ្រួសារមានទូរទស្សន៍ប្រើប្រាស់ | % | 88.12 | 89.06 | 89.76 | 89.82 | 88.99 | 86.04 |
| %ផ្ទះបំភ្លឺដោយបណ្តាញអគ្គិសនី | % | 75.41 | 83.42 | 86.33 | 90.30 | 93.04 | 94.6 |
| %កុមារអាយុ៦ឆ្នាំមិនបានចូលរៀន | % | 7.7 | 9.1 | 9.9 | 9.2 | 9.71 | 8.8 |
| %កុមារអាយុ៦-១១ឆ្នាំមិនបានចូលរៀន | % | 9.3 | 9.7 | 10.5 | 10.5 | 10.48 | 10.37 |
| %កុមារអាយុ១២-១៤ឆ្នាំមិនបានចូលរៀន | % | 10.6 | 10.7 | 10.3 | 10.9 | 9.97 | 10.37 |
| %មនុស្សមិនចេះអក្សរអាយុ១៥-៤៥ឆ្នាំ | % | 3.03 | 2.89 | 2.76 | 2.80 | 2.64 | 2.4 |
| ផលធៀបចំនួនគ្រួសារមានអំពើហឹង្សាក្នុង១០០០គ្រួសារ | គ្រួសារ | 2.9 | 2.4 | 2.2 | 1.9 | 1.76 | 1.86 |

| បរិយាយ | ឯកតា | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ឆ្នាំ២០២១ | ឆ្នាំ២០២២ | ឆ្នាំ២០២៣ | ឆ្នាំ២០២៤ |
|---|---|---|---|---|---|---|---|
| អត្រាមរណៈភាពទារកអាយុ0-១ខែក្នុង១000កំណើតរស់ | នាក់ | 1.5 | 1.0 | 0.8 | 1.6 | 1.0 | 0.9 |
| អត្រាមរណៈភាពកុមារអាយុក្រោម៥ឆ្នាំក្នុង១000កំណើតរស់ | នាក់ | 3.9 | 3.3 | 3.6 | 3.2 | 3.9 | 4.9 |
| %កុមារអាយុ៩-១២ខែមិនបានចាក់ថ្នាំបង្ការគ្រប់ចំនួន | % | 1.57 | 3.0 | 2.7 | 2.9 | 2.0 | 1.38 |
| មរណៈភាពមាតាក្រោយពេលសម្រាល(0-១ខែ)ក្នុង១000កំណើត | នាក់ | 1.6 | 4.0 | 5.5 | 7.4 | 1.8 | 3.3 |
| %ស្ត្រីសម្រាលកូនដោយប្រើប្រាស់ពេទ្យឆ្មប | % | 99.9 | 100.0 | 99.7 | 99.6 | 99.5 | 99.91 |
| ផលធៀបចំនួនទារកនិងស្ត្រីអាចបង្កើតកូនអាយុពី១៥-៤៥ឆ្នាំក្នុងស្ត្រី១000នាក់ | នាក់ | 57 | 55.2 | 55.5 | 56.8 | 49.56 | 49.68 |
| ចំនួនស្ត្រីសម្រាលកូនសរុប | នាក់ | 17,181 | 16,745 | 16,769 | 17,275 | 15.295 | 15.345 |
| ចំនួនមរណៈភាពមាតាក្រោយពេលសម្រាលកូន0-១ខែ | នាក់ | 27 | 67 | 93 | 127 | 27 | 51 |
| ចំនួនមរណៈភាពទារកអាយុ0-១ខែ | នាក់ | 26 | 16 | 13 | 28 | 16 | 14 |
| %ទារកបានចុះសំបុត្រកំណើតក្នុងឆ្នាំ | % | 96.4 | 97.2 | 98.0 | 98.1 | 97.69 | 98.61 |
| ផលធៀបគ្រួសារមានសមាជិកកើតជម្ងឺអេដស៍ក្នុង១000គ្រួសារ | គ្រួសារ | 4.3 | 3.9 | 3.9 | 3.9 | 3.93 | 3.99 |
| %គ្រួសារមានបង្គន់អនាម័យប្រើប្រាស់(ចាក់ទឹក) | % | 72.5 | 77.3 | 80.7 | 83.6 | 87.04 | 88.9 |
| %គ្រួសារប្រើទឹកអណ្តូងស្នប់និងប្រព័ន្ធធ្វើទឹកឲ្យស្អាត | % | 94.7 | 95.5 | 96.2 | 96.7 | 96.61 | 97.3 |
| ផលធៀបចំនួនទំនាស់ដីធ្លីក្នុង១000គ្រួសារ | គ្រួសារ | 2.9 | 3.4 | 3.2 | 4.1 | 4.4 | 3.7 |
| %គ្រួសារប្រើប្រាស់ជីគីមី | % | 80.51 | 79.8 | 78.5 | 78.2 | 78.33 | 77.75 |
| %គ្រួសារប្រើប្រាស់ថ្នាំគីមីសម្លាប់សត្វចង្រៃ | % | 74.08 | 74.5 | 72.9 | 72.6 | 73.40 | 73.33 |

# ខ-វឌ្ឍនភាពក្នុងការអនុវត្តពិន្ទុវិស័យរបស់ខេត្តព្រៃវែង




ភាពក្រីក្រមានពិន្ទុ៩៥,៤៥ បើគិតជាអត្រាភាពក្រីក្រឆ្នាំ២០២៣មាន ៥,៤១% កើនជាងឆ្នាំ២០២២ គឺ ០,៤០% (ឆ្នាំ២០២២មាន ៥,០១% បើគិតជាពិន្ទុមាន ១០០ពិន្ទុ គួរបញ្ជាក់ផងដែរថាពិន្ទុភាពក្រីក្រធ្លាក់អំឡុងពេលជំងឺរាតត្បាតជាសកល កូវីដ១៩)។ ចំណែកវិស័យដែលមានការរីកចម្រើនជាងឆ្នាំកន្លងទៅរួមមាន៖ វិស័យកសិកម្ម វិស័យអប់រំ និងវិស័យយេនឌ័រ។ ដោយឡែកវិស័យអាជីវកម្មមានការកើនឡើងតិចតួច ចំណែកវិស័យសុខភាព វិស័យងាយរងគ្រោះ វិស័យបរិស្ថាន និងវិស័យរដ្ឋបាលសន្តិសុខ មានការថយចុះពិន្ទុតិចតួចពីឆ្នាំកន្លងទៅ។

វិស័យកសិកម្មមាន ៧០,១៩ពិន្ទុ កើន ២,៨១ពិន្ទុ បើធៀបនឹងឆ្នាំ២០២២ដែលមាន ៦៧,៣៨ពិន្ទុ។ ទោះបីជាវិស័យកសិកម្មមានការរីកចម្រើន តែបើយើងសង្កេតមើលលើសូចនាករសមាសភាពក្នុងវិស័យកសិកម្ម មានសូចនាករមួយចំនួនមិនទាន់មានភាពល្អប្រសើរដូចជា ចំណូលពីដំណាំរយៈពេលវែងសម្រាប់មនុស្សម្នាក់ ៩៦ដុល្លាសម្រាប់មនុស្សម្នាក់ ចំណូលពីដំណាំសត្វសម្រាប់មនុស្សម្នាក់ ១៨៤ដុល្លាសម្រាប់មនុស្សម្នាក់ ផលធៀបបុគ្គលិកកសិកម្មធៀបនឹងប្រជាជន១០០,០០០នាក់ ស្មើនឹងបុគ្គលិក៥នាក់ ចំនួននេះជាចំនួនតិចតួចមិនទាន់សមស្របទៅនិងតម្រូវការរបស់ប្រជាពលរដ្ឋ។

វិស័យអាវជីកម្មមាន ៤១,៧៣ពិន្ទុ (ឆ្នាំ២០២២មាន ៤១,២៨ពិន្ទុ) វិស័យអាជីវកម្មជាវិស័យដែលទទួលរងពីឥទ្ធិពលកូវីដ១៩ទូទាំងខេត្តព្រៃវែង សហគ្រាសមួយចំនួន

ធំបានបិទទ្វារ មួយចំនួនទៀតពុំបានពង្រីកទំហំទុនអាជីវកម្ម ចំណែកសហគ្រាសថ្មីបានបង្កើតឡើងក្រោយការស្ងប់ស្ងាត់នៃជំងឺរាតត្បាត ដែលបន្តនឹងកំពុងលូតលាស់ ដែលធ្វើឲ្យវិស័យនេះមានការកើនឡើងវិញ។ បើពិនិត្យមើលលើព្យាក្រាមសំណាញ់ពីងពាងបង្ហាញថា វិស័យអាជីវកម្មមានកើនឡើងស្ទើរតែគ្រប់សមាសភាពសូចនាករក្នុងវិស័យនេះ ។

វិស័យអប់រំមាន ៦៧,៣៧ពិន្ទុ(ឆ្នាំ២០២២ មាន ៦៦,៤៤ពិន្ទុ) មានការកើនឡើង ០,៩៣ពិន្ទុ។ យើងឃើញថា សមាសភាពសូចនាករទាំងអស់ក្នុងវិស័យអប់រំមានការកើនឡើងតិចតួច។

វិស័យសុខភាពមាន ៧៥,៨២ពិន្ទុ (ឆ្នាំ២០២២មាន ៧៨,០៧ពិន្ទុ) ថយចុះ២,២៥ពិន្ទុ។ វិស័យនេះក៏ទទួលរងនូវឥទ្ធិពលនៃជំងឺកូវីដ១៩ផងដែរ។ សូចនាករមួយចំនួនដែលធ្វើឲ្យវិស័យសុខភាពមានការថយចុះរួមមាន៖ ផលធៀបបុគ្គលិកការិយាល័យសុខាភិបាល ផលធៀបបុគ្គលិកមណ្ឌលសុខភាព និងអត្រាស្លាប់ដោយសារជំងឺគ្រុនឈាម ។

វិស័យភាពងាយរងគ្រោះមាន ៦៨,២២ពិន្ទុ (ឆ្នាំកន្លងទៅមាន ៧០,៧៨ពិន្ទុ) ថយចុះ ២,៥៦ពិន្ទុ ដាក់ស្តែងសូចនាករផលធៀបកុមារកំព្រាក្រោម១៨ឆ្នាំ កំណើនមនុស្សចាស់ កំណើនជនអានាថា ផលធៀបគ្រួសាររស់នៅលើដីសាធារណៈ ធ្វើឲ្យវិស័យនេះមានការថយចុះបើធៀបនឹងឆ្នាំកន្លងទៅ។

វិស័យបរិស្ថានមាន ៨៣,៩៥ពិន្ទុ បើធៀបទៅនឹងឆ្នាំកន្លងទៅមានការថយចុះចំនួន ០,៤១ពិន្ទុ(ឆ្នាំកន្លងទៅ ៨៤,៣៦ពិន្ទុ) តួរយ៉ាងសូចនាករមួយចំនួនដែលមានបញ្ហានាំឲ្យវិស័យនេះមានការធ្លាក់ចុះដូចជា សូចនាករផលធៀបគ្រួសាររងគ្រោះដោយសារគ្រោះធម្មជាតិ ភាគរយគ្រួសារដែលបំពុលបរិស្ថាន និងភាគរយគ្រួសារប្រើប្រាស់ដីធម្មជាតិមានតិចតួច។

វិស័យរដ្ឋបាលនិងសន្តិសុខមានពិន្ទុ ៨៤,៤៥ពិន្ទុ ថយចុះ ១,៤ពិន្ទុ បើធៀបនឹងឆ្នាំកន្លងទៅដែលមាន ៨៥,៨៥ពិន្ទុ។ ជាហេតុដែលនាំឲ្យវិស័យនេះមានការថយចុះនោះគឺសូចនាករផលធៀបគ្រួសារដែលមានអ្នកប្រើប្រាស់គ្រឿងញៀន១,៥៣នាក់ ធៀបនឹង ១០០០គ្រួសារ ស្លាប់ដោយគ្រោះថ្នាក់ចរាចរណ៍១៣,០៤នាក់ធៀបនឹង១០ម៉ឺននាក់ និងករណីរំលោភផ្លូវភេទនៅតែកើតមានឡើង។

វិស័យយេនឌ័រមាន ៦២,៣១ពិន្ទុ មានការកើនឡើង ៣,៣២ពិន្ទុ បើធៀបនឹងឆ្នាំកន្លងទៅដែលមាន ៥៨,៩៩ពិន្ទុ ទន្ទឹមនឹងមានការកើនឡើង ក៏មានសូចនាករមួយ

ចំនួននៅមិនទាន់មានភាពល្អប្រសើរដូចជា សូចនាករភាគរយស្ត្រីជាបុគ្គលិកការិយាល័យកសិកម្ម ភាគរយស្ត្រីជាគ្រូអនុវិទ្យាល័យ និងភាគរយស្ត្រីរងគ្រោះដោយការចាប់រំលោភ និងភាគរយស្ត្រីរងគ្រោះដោយការជួញដូរផ្លូវភេទ។

## លំដាប់ថ្នាក់ពិន្ទុវិស័យសរុប




លំដាប់ថ្នាក់ពិន្ទុវិស័យតាមបណ្តាក្រុងស្រុកខាងលើបានបង្ហាញថា ស្រុកពាមរក៍មានការរីកចម្រើនដោយឈរលើលំដាប់ថ្នាក់ទី១ ដោយឆ្នាំកន្លងទៅឈរនៅលំដាប់លេខ២បន្ទាប់ពីក្រុងព្រៃវែង រីឯស្រុកចំនួន៥ទៀតដែលឈរលេខរៀងបន្ទាប់ និងមានពិន្ទុប្រហាក់ប្រហែលគ្នាដូចជា ស្រុកកញ្ជ្រៀច ស៊ីធរកណ្តាល ស្វាយអន្ទរ ពារាំង ក្នុងនោះមានក្រុងព្រៃវែងផងដែរ អ្វីដែលគួរឲ្យកត់សម្គាល់នោះគឺ ស្រុកស៊ីធរកណ្តាលបានឡើងមកឈរនៅលំដាប់លេខ៣ ដោយឆ្នាំកន្លងទៅឈរនៅលំដាប់ទី៧ ។

ចំណែកឯស្រុកដែលមានលំដាប់ថ្នាក់ទាបជាងគេក្នុងនោះមាន ស្រុកពាមជរឈរលំដាប់ថ្នាក់ទី១១ ស្រុកពោធិ៍រៀងឈរនៅលំដាប់ថ្នាក់ទី១២ និងស្រុកព្រះស្តេចឈរនៅលំដាប់ថ្នាក់ទី១៣ ដោយឡែកស្រុកពាមជរវិស័យដែលនាំឲ្យស្រុកឈរនៅលំដាប់ថ្នាក់ទី១១នោះគឺ អត្រាភាពក្រីក្រ វិស័យអប់រំ និងស្រុកពោធិ៍រៀងឈរលំដាប់ថ្នាក់ទី១២បណ្តាលមកពីវិស័យអាជីវកម្ម វិស័យរដ្ឋបាលសន្តិសុខ វិស័យយេនឌ័រ រីឯស្រុកដែលឈរលំដាប់ថ្នាក់ទី១៣គឺស្រុកព្រះស្តេច មាន ៥ ក្នុងចំណោម ៩ វិស័យ គឺ អត្រាភាពក្រីក្រ វិស័យអប់រំមានកម្រិតទាប វិស័យសុខភាព វិស័យងាយរងគ្រោះ វិស័យយេនឌ័រ។

បើពិនិត្យមើលក្រាហ្វិកតាមបណ្តាក្រុងស្រុកខាងលើបង្ហាញថា ក្រុងស្រុកទាំង១០មានការរីកចម្រើនខុសគ្នាតិចតួច លើកលែងតែស្រុកពោធិ៍រៀង និងស្រុកព្រះស្តេចដែលមានពិន្ទុទាប ជាងគេ។

# តារាងពិន្ទុវិស័យតាមបណ្ដាក្រុងស្រុក

| បរិយាយ | បាភ្នំ | កំចាយមារ | កំពង់ត្របែក | កញ្ជ្រៀច | មេសាង | ពាមជរ | ពាមរក៍ | ពារាំង | ព្រះស្ដេច | ព្រៃវែង | ពោធិ៍រៀង | ស៊ីធរកណ្ដាល | ស្វាយអន្ទរ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ភាពក្រីក្រ | 95.44 | 94.37 | 94.78 | 94.85 | 96.83 | 88.28 | 94.78 | 100 | 90.90 | 100 | 95.52 | 95.54 | 99.56 |
| កសិកម្ម | 52.63 | 60.63 | 46.04 | 52.32 | 45.55 | 69.95 | 56.76 | 54.23 | 61.44 | 48.73 | 59.91 | 52.68 | 63.77 |
| អាជីកម្ម | 33.94 | 31.30 | 31.86 | 39.24 | 32.69 | 34.38 | 64.02 | 29.68 | 35.27 | 48.74 | 29.74 | 35.89 | 31.79 |
| អប់រំ | 69.64 | 63.03 | 67.81 | 74.49 | 72.81 | 55.60 | 66.96 | 66.84 | 59.37 | 65.17 | 67.08 | 66.18 | 64.06 |
| សុខភាព | 75.57 | 76.17 | 74.96 | 80.77 | 80.64 | 79.73 | 84.12 | 80.24 | 68.79 | 78.56 | 81.90 | 83.64 | 74.66 |
| ភាពងាយរងគ្រោះ | 72.20 | 70.47 | 73.91 | 68.41 | 73.07 | 76.13 | 68.94 | 78.09 | 68.01 | 62.70 | 73.10 | 74.05 | 72.39 |
| បរិស្ថាន | 86.14 | 80.78 | 83.21 | 83.24 | 88.40 | 83.33 | 83.39 | 87.34 | 84.24 | 89.43 | 86.56 | 84.56 | 87.61 |
| រដ្ឋបាលនិងសន្តិសុខ | 73.86 | 84.73 | 94.59 | 91.63 | 83.99 | 73.85 | 71.16 | 83.60 | 74.59 | 78.29 | 65.89 | 86.88 | 84.95 |
| យេនឌ័រ | 68.66 | 61.88 | 56.52 | 69.43 | 56.83 | 56.41 | 66.19 | 62.37 | 56.28 | 70.23 | 51.76 | 64.86 | 65.06 |

បើយើងពិនិត្យទៅតាមវិស័យនីមួយៗក្នុងតារាងខាងលើឃើញថា៖

១ភាពក្រីក្រ៖ ស្រុកដែលមានភាពក្រីក្រខ្លាំងជាងគេគឺ ស្រុកព្រះស្ដេច(៩០)ឆ្នាំទៅស្រុកពាមជរ(៧៨)

២-វិស័យកសិកម្ម៖ មានកំរិតទាបជាងគេគឺ ស្រុកមេសាង(៤៥) ឆ្នាំទៅស្រុកកំពង់ត្របែក(៤០)

៣-វិស័យអាជីវកម្ម៖ មានកំរិតទាបជាងគេគឺ ស្រុកពោធិ៍រៀង(២៩)

៤-វិស័យអប់រំ៖ មានកំរិតទាបជាងគេគឺស្រុកពាមជរ(៥៥)

៥-វិស័យសុខភាព៖ មានកំរិតទាបជាងគេគឺ ស្រុកព្រះស្ដេច(៦៨) ឆ្នាំទៅមេសាង(៧៣)

៦-វិស័យភាពងាយរងគ្រោះ៖មានកំរិតទាបជាងគេគឺក្រុងព្រៃវែង(៦២)ឆ្នាំទៅស្រុកព្រះស្ដេច(៧០)

៧-វិស័យបរិស្ថាន៖ មានកំរិតទាបជាងគេគឺ ស្រុកកំចាយមារ(៨០) ឆ្នាំទៅស្រុកពោធិ៍រៀង និងស្រុកកញ្ជ្រៀច(៨១-៨៣)

៨-វិស័យរដ្ឋបាលនិងសន្តិសុខ៖ មានកំរិតទាបជាងគេគឺស្រុកពោធិ៍រៀង(៦៥) ឆ្នាំទៅស្រុកពាមរក៍ និងស្រុកពាមជរ(៦៩-៧៣)

៩-វិស័យយេនឌ័រ៖ មានកំរិតទាបជាងគេគឺ ស្រុកពោធិ៍រៀង(៥១) ឆ្នាំទៅមានស្រុកកំចាយមារ និងស្រុកព្រះស្ដេច(៥៤)។

# ដ្យាក្រាមសំណាញ់ពីងពាងពិន្ទុតាមវិស័យ







ស្រុកកំពង់ត្របែក
2021
2023
ភាពក្រីក្រ 94.78
កសិកម្ម 46.04
អាជីកម្ម 31.86
អប់រំ 67.81
សុខភាព 74.96
ភាពងាយរងគ្រោះ 73.91
បរិស្ថាន 83.21
រដ្ឋបាលនិងសន្តិសុខ 94.59
យេនឌ័រ 56.52


ស្រុកកញ្ជៀច
2021
2023
ភាពក្រីក្រ 94.85
កសិកម្ម 52.32
អាជីកម្ម 39.24
អប់រំ 74.49
សុខភាព 80.77
ភាពងាយរងគ្រោះ 68.41
បរិស្ថាន 83.24
រដ្ឋបាលនិងសន្តិសុខ 91.63
យេនឌ័រ 69.43


ស្រុកមេសាង
2021
2023
ភាពក្រីក្រ 96.83
កសិកម្ម 45.55
អាជីកម្ម 32.69
អប់រំ 72.81
សុខភាព 80.64
ភាពងាយរងគ្រោះ 73.07
បរិស្ថាន 88.40
រដ្ឋបាលនិងសន្តិសុខ 83.99
យេនឌ័រ 56.83


ស្រុកពាមជរ
2021
2023
ភាពក្រីក្រ 88.28
កសិកម្ម 69.95
អាជីកម្ម 34.38
អប់រំ 55.60
សុខភាព 79.73
ភាពងាយរងគ្រោះ 76.13
បរិស្ថាន 83.33
រដ្ឋបាលនិងសន្តិសុខ 73.85
យេនឌ័រ 56.41


ស្រុកពាមរក៍
2021
2023
ភាពក្រីក្រ 94.78
កសិកម្ម 56.76
អាជីកម្ម 64.02
អប់រំ 66.96
សុខភាព 84.12
ភាពងាយរងគ្រោះ 68.94
បរិស្ថាន 83.39
រដ្ឋបាលនិងសន្តិសុខ 71.16
យេនឌ័រ 66.19


ស្រុកពារាំង
2021
2023
ភាពក្រីក្រ 100
កសិកម្ម 54.23
អាជីកម្ម 29.68
អប់រំ 66.84
សុខភាព 80.24
ភាពងាយរងគ្រោះ 78.09
បរិស្ថាន 87.34
រដ្ឋបាលនិងសន្តិសុខ 83.60
យេនឌ័រ 62.37


ស្រុកព្រះស្ដេច
2021
2023
ភាពក្រីក្រ 90.90
កសិកម្ម 61.44
អាជីកម្ម 35.27
អប់រំ 59.37
សុខភាព 68.79
ភាពងាយរងគ្រោះ 68.01
បរិស្ថាន 84.24
រដ្ឋបាលនិងសន្តិសុខ 74.59
56.28 យេនឌ័រ
100
90
80
70
60
50
40
30
20
10
0


ក្រុងព្រៃវែង
2021
2023
100
ភាពក្រីក្រ
48.73
កសិកម្ម
48.74
អាជីកម្ម
អប់រំ 65.17
សុខភាព
78.56
ភាពងាយរងគ្រោះ
62.70
បរិស្ថាន
89.43
រដ្ឋបាលនិងសន្តិសុខ
78.29
70.23 យេនឌ័រ


ស្រុកពោធិ៍រៀង
2021
2023
95.52
ភាពក្រីក្រ
59.91
កសិកម្ម
29.74
អាជីកម្ម
អប់រំ
67.08
សុខភាព
81.90
ភាពងាយរងគ្រោះ
73.10
បរិស្ថាន
86.56
រដ្ឋបាលនិងសន្តិសុខ
65.89
51.76 យេនឌ័រ


ស្រុកស៊ីធរកណ្ដាល
2021
2023
95.54
ភាពក្រីក្រ
52.68
កសិកម្ម
35.89
អាជីកម្ម
អប់រំ
66.18
សុខភាព
83.64
ភាពងាយរងគ្រោះ
74.05
បរិស្ថាន
84.56
រដ្ឋបាលនិងសន្តិសុខ
86.88
64.86
យេនឌ័រ


ស្រុកស្វាយអន្ទរ
2021
2023
99.56
ភាពក្រីក្រ
63.77
កសិកម្ម
31.79
អាជីកម្ម
64.06
អប់រំ
សុខភាព
74.66
ភាពងាយរងគ្រោះ
72.39
បរិស្ថាន
87.61
រដ្ឋបាលនិងសន្តិសុខ
84.95
65.06 យេនឌ័រ

# ១.២.ស្ថានភាពបច្ចុប្បន្ននិងបញ្ហាប្រឈម

## ១.២.១. ស្ថានភាពសេដ្ឋកិច្ច

### ១.២.១.១.វិស័យកសិកម្មរុក្ខាប្រមាញ់និងនេសាទ

**១-ស្ថានភាពរួម**

ខេត្តព្រៃវែងស្ថិតនៅតំបន់វាលរាប និងវាលទំនាបត្រើយខាងកើតទន្លេមេគង្គមានផ្ទៃដីសរុបចំនួន ៤៨៨,៣០០ហិកតា គឺជាខេត្តដែលមានសក្តានុពលខ្ពស់លើផលិតកម្មដំណាំស្រូវទាំងស្រូវរដូវវស្សា និងស្រូវរដូវប្រាំង ហើយក៏ជាខេត្តដែលមានផ្ទៃដីដាំដុះដំណាំស្រូវសរុបធំជាងបណ្តាខេត្តនានានៅក្នុងព្រះរាជាណាចក្រកម្ពុជាផងដែរ។ ខេត្តបានកំណត់ផែនការផ្ទៃដីដាំដុះដំណាំសរុបចំនួន ៣៣៧.០០០ហិកតា ក្នុងនោះផ្ទៃដីដាំដុះស្រូវរដូវវស្សាចំនួន ២៥០,០០០ហិកតា ស្រូវប្រាំងចំនួន ៧៥,០០០ហិកតា និងដំណាំរួមផ្សំផ្សេងៗចំនួន ១២,០០០ហិកតា។ ប្រជាពលរដ្ឋនៅក្នុងខេត្តព្រៃវែងមានប្រមាណ ៧៨% បានពឹងផ្អែកទៅលើការងារកសិកម្មជាចម្បង។

ការអភិវឌ្ឍវិស័យកសិកម្មក្នុងខេត្តព្រៃវែងកន្លងមកមានការីកចម្រើនគួរឲ្យកត់សម្គាល់ ដែលការផលិតអាចបំពេញបាននូវតម្រូវការក្នុងខេត្ត និងបាននាំចេញទៅក្រៅខេត្ត និងប្រទេសជិតខាងផងដែរ ពិសេសផលិតកម្មដំណាំស្រូវ ដែលបរិមាណស្រូវនៅសល់លើសពីតម្រូវការក្នុងខេត្តសម្រាប់នាំចេញមានចំនួនជាង១លានតោន។ ក្រៅពីផលិតកម្មដំណាំស្រូវ ខេត្តក៏បានផលិតដំណាំរួមផ្សំ និងដំណាំកសិ-ឧស្សាកម្ម ការចិញ្ចឹមសត្វ វារីវប្បកម្មនិងការនេសាទ សម្រាប់ការហូបចុកក្នុងគ្រួសារ និងលក់បានប្រាក់ចំណូលបង្កើនកំរិតជីវភាពក្នុងគ្រួសារផងដែរ។ ការរីកចម្រើនលើវិស័យផលិតកម្មកសិកម្មនេះ គឺដោយមានការជួយគាំទ្រផ្នែកសេវាកម្មបច្ចេកទេសពីមន្ត្រីជំនាញ ដៃគូអភិវឌ្ឍន៍នានា និងមានការយកចិត្តទុកដាក់អនុវត្តន៍របស់កសិករផងដែរ។

ទោះបីការអភិវឌ្ឍវិស័យកសិកម្មបានបោះជំហ៊ានទៅមុខក៏ដោយ ក៏លទ្ធផលសម្រេចបាននៅពុំទាន់ឆ្លើយតបទៅនឹងសក្តានុពលធនធានដែលខេត្តមាន និងតាមតម្រូវការរបស់ប្រជាពលរដ្ឋនៅឡើយ ដោយសារ ការផលិតរបស់កសិករតែងតែជួបប្រទះគ្រោះធម្មជាតិ ដូចជាគ្រោះទឹកជំនន់ គ្រោះរាំងស្ងួត ការកើនកំដៅ និងកត្តាចង្រៃបំផ្លាញនានាដែលធ្វើឲ្យមានការប៉ះពាល់ និងខូចខាតផលិតផលដំណាំ និងការចិញ្ចឹមរបស់កសិករ។ ម៉្យាងទៀតការអនុវត្តរបស់កសិករមួយចំនួននៅតាមបែបទំលាប់ចាស់ និងការផ្តល់សេវាគាំទ្របច្ចេកទេសនៅមិនទាន់បានទូលំទូលាយ ហើយតំលៃផលិតផលកសិកម្មឡើងចុះពុំទៀងទាត់បានធ្វើឲ្យប៉ះពាល់ដល់ការផលិតរបស់កសិករផងដែរ។

**ក.ការងារផលិតកម្មដំណាំ**

កម្ពស់ទឹកជំនន់ទន្លេមេគង្គ២០២៣ឆ្នាំ ខែតុលា ៣០ថ្ងៃទី (ស្ថានីយ៍ព្រែកតាតាំក្រុងព្រៃវែង)៤ មានកម្ពស់ ៤,៤៤ ម៉ែត្រ ធៀបនឹងថ្ងៃម្សិលមិញទាបជាង ០,០៧ ម៉ែត្រ និងធៀបនឹងឆ្នាំ២០២៣ ទាបជាង ០,៦៦ ម៉ែត្រ (គិតរយៈពេលដូចគ្នា)។

កម្ពស់ទឹកភ្លៀងមធ្យមទូទាំងខេត្ត គិតចាប់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣០ ខែតុលា ឆ្នាំ

២០២៤ មានកម្ពស់ ១១៩៩,៤៥ មីលីម៉ែត្រ ធៀបនឹងឆ្នាំ២០២៣ ទាបជាង ៣,៧៩ មីលីម៉ែត្រ (គិតរយៈពេលដូចគ្នា)។

1. **ផលិតកម្មដំណាំស្រូវរដូវវស្សា**(គិតត្រឹមថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២៤)បញ្ចប់ការដាំដុះអនុវត្ត បានលើផ្ទៃដីព្រោះសរុប ៣០៧,៦២៤ ហិកតា ស្មើនឹង (ស្ទួងគ្មាន)១២៣,០៥%នៃផែនការ២៥០,០០០ ហិកតា ធៀបនឹងឆ្នាំមុន ខ្ពស់ជា ២២,៥៨០ ហិកតា (គិតរយៈពេលដូចគ្នា)។ ប្រមូលផលសរុប ១២៧,៥៣១ ហិកតា ស្មើនឹង ៤១,៧១% នៃផ្ទៃដីអនុវត្តបានសរុប៣០៧,៦២៤ ហិកតា បរិមាណផលសុប ៥៦៦,២៤០ តោន។
2. **ផលិតកម្មដំណាំសាកវប្បកម្ម និងដំណាំឧស្សាហកម្មរដូវវស្សា**(គិតត្រឹមថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២៤) ដំណាំសាកវប្បកម្ម មានបន្លែគ្រប់មុខ ពោតស ឪឡឹក និងម្ទេសគ្រប់មុខ សម្រេចបានលើផ្ទៃដីសរុប ១,៦០២ ហិកតា ស្មើនឹង ១៣៣,៥០% នៃផែនការ ១,២០០ ហិកតា។ ប្រមូលផលសរុប ១,៥៩៨ ហិកតា បរិមាណផលសរុប ២៦,៩៧៧ តោន។ ដំណាំឧស្សាហកម្ម មានពោតក្រហម សណ្តែកបាយ សណ្តែកដី ល្ង អំពៅ ដំឡូងមី និងឈូក សម្រេចបានលើផ្ទៃដីសរុប ៣,៩៥៨ ហិកតា ស្មើនឹង ៧៣,៣០% នៃផែនការ ៥,៤០០ ហិកតា។ ប្រមូលផលសរុប ២,៨៣០ ហិកតា បរិមាណផលសរុប ២១,៨៥៩ តោន។
3. **ផលិតកម្មដំណាំស្រូវរដូវប្រាំងឆ្នាំ២០២៤២០២៥**-(គិតត្រឹមថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២៤) អនុវត្តបានលើផ្ទៃដីព្រោះសរុប ១០,៤៣២ ហិកតា (ស្ទួងគ្មាន) ស្មើនឹង ១៣,៩១% នៃផែនការ ៧៥,០០០ ហិកតា ធៀបនឹងឆ្នាំមុនខ្ពស់ជាង ៥,៩៤៤ ហិកតា (គិតរយៈពេលដូចគ្នា)។
4. **ផលិតកម្មដំណាំសាកវប្បកម្ម និងដំណាំឧស្សាហកម្មរដូវប្រាំង**(គិតត្រឹមថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២៤) ដំណាំសាកវប្បកម្ម មានបន្លែគ្រប់មុខ ពោតស ឪឡឹក និងម្ទេសគ្រប់មុខ សម្រេចបានលើផ្ទៃដីសរុប ៨៤ ហិកតា ស្មើនឹង ១០,៨៤% នៃផែនការ ៧៩០ ហិកតា។ ដំណាំឧស្សាហកម្ម មានពោតក្រហម សណ្តែកបាយ សណ្តែកដី ល្ង អំពៅ ដំឡូងមី និងឈូក សម្រេចបានលើផ្ទៃដីសរុប ៦ ហិកតា ស្មើនឹង ០,១២% នៃផែនការ ៥,១០៥ ហិកតា។
5. **ការនាំចេញផលិតផលកសិកម្ម**

**៥.១-ការនាំចេញស្រូវ**

បរិមាណស្រូវនាំចេញ ក្រៅផ្លូវការទៅប្រទេសវៀតណាម ចាប់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២៤ សរុបមានចំនួន ២,២៨៣,៤៩៣ តោន (រួមទាំងស្រូវឆ្លងកាត់)។ តម្លៃស្រូវសើមជាមធ្យម៖ ស្រូវ IR504-04 តម្លៃ ១,០៤០រៀលក្នុង១គីឡូក្រាម ស្រូវ OM5451 តម្លៃ ១,០២០រៀលក្នុង១គីឡូក្រាម ចំណូលសរុប ៦៥៦,៣២២,៧៧៤ ដុល្លារ។ ដោយឡែកក្នុងសប្តាហ៍នេះ សរុបមានចំនួន ៤៥,៧៣០ តោន ចំណូលសរុប ១៣,១៩១,៥៣៣ ដុល្លារ។

**៥.២-ការនាំចេញផ្លែស្វាយ**

បរិមាណផ្លែស្វាយស្រស់នាំចេញ ក្រៅផ្លូវការទៅប្រទេសវៀតណាម ចាប់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី២៩ ខែ តុលា ឆ្នាំ២០២៤ សរុបមានចំនួន ១១៨,០៦៤ តោន (រួមទាំងស្វាយឆ្លងកាត់)។ តម្លៃ

ផ្លែស្វាយជាមធ្យម ៧០៧រៀលក្នុង១គីឡូក្រាម ចំណូលសរុប ១៨,៦៤៦,៨៨១ ដុល្លារ។ ដោយឡែកក្នុងសប្តាហ៍នេះ សរុបមានចំនួន ៣,៧៨៣ តោន ចំណូលសរុបមានចំនួន ៦៥២,០៣០ ដុល្លារ។

**ខ. ការងារផលិតកម្មសត្វ និងបសុព្យាបាល**

**១-ផ្នែកផលិតកម្មសត្វ**

ស្ថិតិសត្វរួមប្រចាំឆ្នាំសរុប ៤,៧៧៧,៥២១ ក្បាល៖ គោ-ក្របីសរុប ៣៩៦,៤២៩ ក្បាល គោ) ៣៧៥,៧៩២ ក្បាល ក្របី ២០,៦៣៧ ក្បាលសេះ ( ១០៤ ក្បាល ចៀម ៨៣ ក្បាល ពពែ ៣,១៤៥ក្បាល ជ្រូក ៣០,៣៨៦ ក្បាល ស្វា ៥៤ ក្បាល ឆ្កែ ៨៤,១៧៩ ក្បាល ឆ្មា ៥៧,៩២៧ ក្បាល មាន់-ទាសរុប ៤,០៩៥,១៥៤ ក្បាល (មាន់ ២,៨៧៥,១៣២ ក្បាល ទា ១,២២០,០២២ ក្បាល) និងបក្សីផ្សេងៗ សរុប ១១០,០៦០ ក្បាល។

កសិដ្ឋានចិញ្ចឹមសត្វ៖ ជ្រូកសាច់ ១កន្លែង ស្មើនឹង ១,២១១ ក្បាល ជ្រូកពូជ ១កន្លែង ស្មើនឹង ១,៨២២ ក្បាល មាន់សាច់ ១កន្លែង ស្មើនឹង ១០,០៥៥ ក្បាល និងមាន់យកស៊ុត ៣កន្លែង ស្មើនឹង ២១,០៤៣ ក្បាល។

ចុះពិនិត្យការចិញ្ចឹមសត្វបាន ៨ ដង មានគោ ២៨ ក្បាល ជ្រូក ៣២ ក្បាល មាន់យកស៊ុត ៤,៨០០ ក្បាល និងទាយកស៊ុត ៣,៥០០ ក្បាល។

ចុះបង្កាត់សិប្បនិម្មិតជ្រូក ពូជឌុយរ៉ុក ជាមួយមេកូនកាត់ក្នុងស្រុក បាន ៣ ក្បាល។

ដាំដំណាំចំណីសត្វបាន ៧០ អារ ពូជយីងក្រាស់ នៅស្រុកស៊ីធរកណ្តាល។

**២-ផ្នែកបសុព្យាបាល**

ចុះពិនិត្យអនាម័យសត្វមុន និងក្រោយពេលពិឃាត កន្លែងតាំងលក់សាច់ និងបានណែនាំម្ចាស់សត្តឃាត ក៏ដូចជាអាជីវករពិឃាតសត្វ ត្រូវធ្វើអនាម័យនៅសត្តឃាត កន្លែងតាំងលក់ និងបិទវិញ្ញាបនបត្រអនាម័យសត្វ ដែលចេញដោយបសុពេទ្យប្រចាំសត្តឃាតនៅកន្លែងតាំងលក់។

បានផ្តល់ថ្នាំសំលាប់មេរោគចំនួន ០៨លីត្រ ដល់កសិករចិញ្ចឹមសត្វ។ ព្យាបាលគោ ០១ក្បាល (សង្ស័យដុំពក) នៅស្រុកស្វាយអន្ទរ។

សហការជាមួយអាជ្ញាធរមូលដ្ឋាន ចុះចាក់វ៉ាក់សាំងការពារជំងឺសារទឹកបានគោ ៥៦០ ក្បាល និងក្របី ៧៦ ក្បាល នៅស្រុកស៊ីធរកណ្តាល ស្រុកពាមរក៍ និងស្រុកស្វាយអន្ទរ។

**៣-ចំណូលក្រៅផ្លូវការរបស់កសិករចិញ្ចឹមសត្វ និងផលិតផលសត្វ**

ចំណូលសរុប ២,០៣៨,០៦៣,០០០ រៀល ស្មើនឹង ៥០៩,៥១៥.៧៥ ដុល្លារ៖

នាំចេញស៊ុតទាស្រស់ទៅកាន់រាជធានីភ្នំពេញនិងខេត្តផ្សេងៗសរុប ១,១៩៨,៩០០ គ្រាប់ (តម្លៃមធ្យម ៤៣០រៀលក្នុង១គ្រាប់)ចំណូលសរុប ៥១៥,៥២៧,០០០ រៀល ស្មើនឹង ១២៨,៨៨១.៧៥ ដុល្លារ។

នាំចេញស៊ុតមាន់ស្រស់ទៅកាន់រាជធានីភ្នំពេញ និងខេត្តផ្សេងៗសរុប ១២២,៨០០ គ្រាប់ (តម្លៃមធ្យម ៣៧០រៀលក្នុង១គ្រាប់)ចំណូលសរុប ៤៥,៤៣៦,០០០ រៀល ស្មើនឹង ១១,៣៥៩ ដុល្លារ។

នាំចេញជ្រូករស់ទៅកាន់រាជធានីភ្នំពេញសរុប ១៤០ ក្បាល (ទម្ងន់មធ្យម ៨៥គីឡូក្រាមក្នុង១ក្បាល តម្លៃមធ្យម ៩,០០០រៀលក្នុង១គីឡូក្រាម) ចំណូលសរុប ១០៧,១០០,០០០រៀល ស្មើនឹង ២៦,៧៧៥ ដុល្លារ។

នាំចេញគោរស់ទៅប្រទេសវៀតណាមសរុប ១,៣៧០ ក្បាល (តម្លៃមធ្យម ១,០០០,០០០រៀលក្នុង១ក្បាល) ចំណូលសរុប ១,៣៧០,០០០,០០០រៀល ស្មើនឹង ៣៤២,៥០០ ដុល្លារ។

**៤. ផ្នែកផ្សព្វផ្សាយ សិក្ខាសាលា និងប្រជុំ**

ផ្សព្វផ្សាយជម្ងឺឆ្កែឆ្កួត នៅវិទ្យាល័យមេសាង(គាំទ្រកម្មវិធីដោយអង្គការ FAO) ក្រោមអធិបតីភាព លោកស្រី ហេង ម៉ូរ៉ានី អគ្គនាយករងនៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ មានការចូលរួមពី លោកអភិបាលស្រុក មេសាង តំណាងមន្ទីរអប់រំ យុវជន និងកីឡា តំណាងមន្ទីសុខាភិបាល លោកគ្រូ អ្នកគ្រូ និងសិស្សចំនួន ៥០០ នាក់។

បានចូលរួមសិក្ខាសាលា ស្តីពីភារកិច្ច និងសិទ្ធិរបស់មន្ត្រីអធិការកិច្ចសុខភាពសត្វ និងផលិតកម្មសត្វ ក្នុងការ អនុវត្តច្បាប់ នៅការិយាល័យផលិតកម្ម និងបសុព្យាបាល រៀបចំដោយអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ

ចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្គោល ស្តីពីការវាយតម្លៃជីវសុវត្ថិភាព ដើម្បីការពារជំងឺប៉េស្តជ្រូកអាហ្វ្រិក នៅខេត្តកំពត។

**គ. ការងារជលផល**

**១-ផ្នែកវារីវប្បកម្ម**

វារីវប្បករចិញ្ចឹមត្រីចម្រុះនៅខេត្តព្រៃវែងសរុបមានចំនួន ៩,៩៤០ គ្រួសារ។ ដោយឡែកវារីវប្បកម្មចំនួន ៥២ គ្រួសារ បានប្រមូលផលត្រីចិញ្ចឹម មានត្រីទីឡាព្យា ០,៧០ តោន ត្រីអណ្តែង ៣,៤៣ តោន ត្រីឆ្ពិន ១,៤៧ តោន ត្រីប្រា ១២៥,៨០ តោន ត្រីពោ ១,៣០ តោន ត្រីរ៉ស់ ០,២០ តោន និងត្រីក្រាញ់ ០,១០ តោន សរុប ១៣៣ តោន តម្លៃត្រីមធ្យម ៥,៣២០រៀលក្នុង១គីឡូក្រាម ចំណូលសរុប ៧០៧,៥៦០,០០០រៀល ស្មើនឹង ១៧៦,៨៩០ ដុល្លារ។

បរិមាណផលវារីវប្បកម្មទាំងអស់ ត្រូវបានប្រើប្រាស់ និងលក់ចេញនៅក្នុងខេត្តព្រៃវែង និងដឹកជញ្ជូនចេញទៅកាន់ខេត្តកំពង់ចាម ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តរតនៈគីរី ខេត្តមណ្ឌលគីរី រាជធានីភ្នំពេញ ខេត្តបាត់ដំបង ខេត្តកំពង់ធំ ខេត្តព្រះវិហារ ខេត្តសៀមរាប ខេត្តបន្ទាយមានជ័យ និងខេត្តឧត្តរមានជ័យ។

**២-ការពង្រឹងការអនុវត្តច្បាប់**

បានចុះស្រាវជ្រាវ ត្រួតពិនិត្យ ទប់ស្កាត់ និងបង្ក្រាបបទល្មើសជលផល នៅស្រុកពោធិ៍រៀង ស្រុកពារាំង ស្រុកស៊ីធរកណ្តាល និងស្រុកពាមរក៍ អនុវត្តបានសរុបចំនួន០៤ករណី ពីបទនេសាទដោយប្រើឧបករណ៍លូស្បៃមុង ០៣ ករណី និង ពីបទនេសាទដោយប្រើឧបករណ៍ដាយចាប់ត្រីខុសទីតាំងកំណត់របស់ឡូតិ៍ដាយចាប់ត្រី០១ករណី៖ ១-នេសាទដោយឧបករណ៍លូស្បៃមុង០៣ករណី៖ វត្ថុត្រូវបានបំផ្លាញចោលនៅនឹងកន្លែងដូចជា មានលូស្បៃមុង ៤៦មាត់ របាំងព្រួលស្បៃមុង ៣,៦០០ម៉ែត្រ បង្គោលចម្រឹង ១,៤៦០ដើម និងបានចាក់លែងកូនត្រីចម្រុះចូលទៅក្នុងធម្មជាតិវិញសរុបទម្ងន់ ១៣៥គីឡូក្រាម។ ២-នេសាទដោយប្រើឧបករណ៍ដាយចាប់ត្រីខុសទីតាំងកំណត់០១ករណី៖ វត្ថុតាងត្រូវបានឃាត់ទុកជាបណ្តោះអាសន្ន មានដូចជា ដាយត្រី១មាត់(ទំហំ១៥មគុណ២៥មគុណ៤ម) និងចាក់លែងត្រីចម្រុះចូលទៅក្នុងធម្មជាតិវិញទម្ងន់ ៤០គីឡូក្រាម។

សហការជាមួយរដ្ឋបាលស្រុកបាភ្នំ គណៈកម្មការបច្ចេកទេសបឹងស្នេហ៍ របស់គម្រោងដីសណ្តរតំបន់អាស៊ី រដ្ឋបាលឃុំសំរោង ស្រុកស្វាយអន្ទរ និងរដ្ឋបាលឃុំព្រៃកណ្តៀង ស្រុកពាមរក៍ ចុះប្រជុំផ្សព្វផ្សាយច្បាប់ស្តីពីជលផល និងលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធដល់ការគ្រប់គ្រងវិស័យជលផល ដល់ប្រជានេសាទបាន០២វគ្គ មានអ្នកចូលរួមសរុប ៩៣នាក់ (ស្រី០៩នាក់)៖ ១-នៅភូមិព្រៃឈើទាល ឃុំសំរោង ស្រុកស្វាយអន្ទរ ២-នៅភូមិព្រៃអង្គុញ ឃុំព្រៃកណ្តៀង ស្រុកពាមរក៍។

**៣-ការងារនាំចូលផលជលផល**

បានសហការជាមួយសមត្ថកិច្ចច្រកទ្វារព្រំដែនបន្ទាយចក្រី និងកោះរកា ត្រួតពិនិត្យការនាំចូល និងនាំឆ្លងកាត់ផល ផលិតផលជលផល នៅតាមច្រកទ្វារព្រំដែនទាំង២ ដោយបានត្រួតពិនិត្យលើបរិមាណផលជលផលឆ្លងកាត់ លើក្រុមហ៊ុនដឹកជញ្ជូនចំនួន៣។ សរុបស្ថិតិនាំចូលផលជលផលសរុបចំនួន ១៥៨តោន (ត្រី ១៤៧,៥០តោន បង្កង ៣,៥០តោន បង្គា ៣,៥០តោន កង្កែប ៣,៥០តោន) មកកាន់ខេត្តព្រៃវែង ខេត្តរតនៈគីរី ខេត្តមណ្ឌលគីរី រាជធានីភ្នំពេញ ខេត្តបាត់ដំបង ខេត្តកំពង់ធំ ខេត្តសៀមរាប ខេត្តបន្ទាយមានជ័យ និងខេត្តឧត្តរមានជ័យ។

**៤-ការងារបច្ចេកវិទ្យាកែច្នៃនិងគុណភាព**

មានកសិករកែច្នៃផលផលិតផលជលផលក្នុងខេត្តព្រៃវែងចំនួន ២,៣៥០គ្រួសារ បានកែច្នៃផលផលិតផលជលផលសរុប ២៧៦,៧៣៨ តោន៖ ត្រីងៀត ៦០,០០៥ តោន ប្រហុកត្រី ១១,៥៦០ តោន ផ្អកត្រី ៤,២៨៨ តោន ត្រីឆ្អើរ ០,៨៣ តោន ម៉ាំត្រី ៧,៩៥៥ តោន ត្រីប្រឡាក់ ៤២,៩៩ តោន ត្រីផ្អាប់ ៨៣,៩៦ តោន ប្រហិតត្រី ១២,៥១ តោន និងទឹកត្រី ៥២,៦៤ តោន។

**៥-ការងារប្រមូលចំណូលជលផល**

ចំណូលថ្លៃឈ្នួលដាយបង្កងនៅរដូវនេសាទឆ្នាំ២០២៤-២០២៥ សរុបមានចំនួន ៩,២៥០, ០០០រៀល (លោក គង់ អ៊ុំ អាជីវករដាយបង្កងលេខ០១អារ ៣,២៥០,០០០រៀល លោកស្រី យឹម ចាន់ទី អាជីវករដាយបង្កងលេខ០១អី ៣,៣០០,០០០រៀល លោក ឈឹម សាវួន អាជីវករដាយបង្កងលេខ០១អេហ្វ ២,២៥០ ០០០រៀល និងលោក សួន ផាន អាជីវករដាយបង្កងលេខ០១អិល ៤៥០,០០០រៀល)។

**៥-ការងារផ្សព្វផ្សាយ សិក្ខាសាលា និងប្រជុំ**

**ឃ-ការងារព្រៃឈើ**

**១-ការងារពង្រឹងការអនុវត្តច្បាប់**

បានល្បាត ទប់ស្កាត់ បង្ក្រាបបទល្មើសព្រៃឈើ និងសត្វព្រៃតាមគ្រប់រូបភាពក្នុងដែនសមត្ថកិច្ចសរុបចំនួន០៥ លើកនៅតាមគោលដៅផ្លូវជាតិលេខ១១ និងផ្លូវជាតិលេខ៨ ក្នុងភូមិសាស្ត្រស្រុកកំចាយមារ ស្រុកកញ្ច្រៀច ស្រុកស្វាយអន្ទរ និងតាមគោលដៅផ្លូវជាតិលេខ១ ក្នុងភូមិសាស្ត្រស្រុកកំពង់ត្របែក ស្រុកពាមរក៍ និងស្រុកព្រះស្តេច និងទប់ស្កាត់បទល្មើសការកាប់ រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធដីព្រៃឈើដើម្បីវាតយកដីធ្វើកម្មសិទ្ធិ(ដីស្ថានីយដាំឈើ)ក្នុងស្រុកកំចាយមារពុំមានជួបប្រទះបទល្មើសទេ។

**២-ការងារចេញលិខិតអនុញ្ញាតដឹកផលអនុផលព្រៃឈើនិងការត្រួតពិនិត្យការចរាចរផលអនុផលព្រៃឈើ**

បានសហការជាមួយក្រុមហ៊ុន YLT International Co.,Ltd ត្រួតពិនិត្យ ផ្ទៀងផ្ទាត់ផលិតផលរានទេវតា

របស់ក្រុមហ៊ុនដើម្បីដឹកជញ្ជូននាំចេញចំនួន០១ច្បាប់ តាមលិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើ លេខPRT20241017FA00051 /នច/PC/IMEC ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៤ របស់រដ្ឋបាលព្រៃឈើ មានផលិតផលរានទេវតាចំនួន ៦៩០គ្រឿង ស្មើនឹង ១៤ម៣៣០២។

**៣-ការងារដាំឈើ បណ្តុះកូនឈើ និងចែកចាយកូនឈើ**

បានបណ្តុះកូនឈើ និងថែទាំកូនឈើនៅតាមបណ្តាស្នាក់ការ (កូនឈើសល់ក្នុងស្តុកឆ្នាំ២០២៣ មានសរុបចំនួន ១២,៧៩៩ ដើម)។ ក្នុងសប្តាហ៍នេះពុំមានបណ្តុះកូនឈើបន្ថែមទេ។

**៤-ការងារគ្រប់គ្រងរោងសន្និធិ និងរោងសិប្បកម្មកែច្នៃ**

បានបន្តគ្រប់គ្រងរោងសន្និធិ និងរោងសិប្បកម្មកែច្នៃផល អនុផលព្រៃឈើចំនួន ៧៥កន្លែង ឆ្នាំ ៣០២៣ រោងសន្និធិប្រភេទធំ ច្រកចេញ-ចូលតែមួយ ចំនួន ០១កន្លែង និងរោងចក្រផលិតផលរានទេវតា របស់ក្រុមហ៊ុន TLT International Co.,Ltd ចំនួន ០១កន្លែង។

បានចុះត្រួតពិនិត្យ តាមដាន និងកាត់ស្តុក កត់ត្រាការចរាចរផល អនុផល ព្រៃឈើតាមបណ្តារោង សន្និធិ និងរោងសិប្បកម្មកែច្នៃផល អនុផលព្រៃឈើ ក្នុងស្រុកកំពង់ត្របែក ០២កន្លែង ស្រុកពាមរក៍ ០១កន្លែង និងស្រុកព្រះស្តេច ០១កន្លែង។

បានចុះពិនិត្យរោងសន្និធិម៉ុនធីណា ភូមិជាខ្លាង ឃុំជាខ្លាង ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង។

**ង-ការងារនីតិកម្មកសិកម្ម**

**តម្លៃជីកសិកម្មក្នុងខេត្តព្រៃវែង ខែតុលា ឆ្នាំ២០២៤**

| ល.រ | យថាប្រភេទ | ឯកត្តា | តម្លៃជីកសិកម្ម/បាវ | | |
|---|---|---|---|---|---|
| | | | អប្បរមា | អតិបរមា | មធ្យម |
| ១ | ជីDAP(18-46-0) | បាវ | ១៤៦ ៥៩២៛ | ១៦២ ៨៨០៛ | ១៥៤ ៧៣៦៛ |
| ២ | ជីNPK(16-16-8-13S) | បាវ | ១០៩ ៩៤៨៛ | ១៥៦ ៧៧២៛ | ១៣៣ ៤៨៥៛ |
| ៣ | ជីNPK(៤ព៌ណ) | បាវ | ១២២ ១៦០៛ | ១៥២ ៧០០៛ | ១៣៨ ៤៤៨៛ |
| ៤ | ជីUrea(46-0-0) | បាវ | ៩៣ ៦៥៦៛ | ១៣០ ៣០៤៛ | ១១១ ២១៧៛ |
| ៥ | ជីKCl | បាវ | ១១៤ ០១៦៛ | ១៥០ ៦៦៤៛ | ១៣២ ៨៩៤៛ |
| ៦ | ជីNPK(15-15-15) | បាវ | ១២៦ ២៣២៛ | ១៥៤ ៧៣៦៛ | ១៤២ ៨៩០៛ |
| ៧ | ជីសរីរាង្គ(ជីផែនដី) | បាវ | ១០១ ៨០០៛ | ១២២ ១៦០៛ | ១១២ ៣៨៧៛ |

ប្រភេទជីគីមីដែលមានលក់នៅក្នុងខេត្តព្រៃវែងតម្លៃធៀបនឹងខែធ្នូ ឆ្នាំ២០២៣៖(បាវ/តម្លៃមធ្យម)

1. ជីដេអាប៉េ(18-46-0)៖ ១៥៤,៧៣៦រៀល បើធៀបនឹងខែធ្នូ ឆ្នាំ២០២៣ មានតម្លៃខ្ពស់ជាង ៤,០០៦រៀល
2. ជីអិនប៉េកា(16-16-8-13S)៖ ១៣៣,៤៨៥រៀល បើធៀបនឹងខែធ្នូ ឆ្នាំ២០២៣ មានតម្លៃខ្ពស់ជាង៨,០៥៥រៀល
3. ជីអិនប៉េកា(4 ព៌ណ)៖ ១៣៨,៤៤៨រៀល បើធៀបនឹងខែធ្នូ ឆ្នាំ២០២៣ មានតម្លៃទាបជាង ៣,៦៩៧រៀល
4. ជីអ៊ុយរ៉េ(46-0-0)៖ ១១១,២១៧រៀល បើធៀបនឹងខែធ្នូ ឆ្នាំ២០២៣ មានតម្លៃទាបជាង ២,៨១៧រៀល
5. ជីកាសេអិល(18-46-0)៖ ១៣២,៨៩៤រៀល បើធៀបនឹងខែធ្នូ ឆ្នាំ២០២៣ មានតម្លៃខ្ពស់ជាង ១,៧៥៣រៀល
6. ជីអិនប៉េកា(15-15-15)៖១៤២,៨៩០រៀល បើធៀបនឹងខែធ្នូ ឆ្នាំ២០២៣ មានតម្លៃទាបជាង ២,២៨៩រៀល
7. ជីសរីរាង្គសញ្ញាផែនដី៖១១២,៣៨៧រៀល បើធៀបនឹងខែធ្នូ ឆ្នាំ២០២៣ មានតម្លៃទាបជាង ៤,៩៩៩រៀល

**ច-បញ្ហាប្រឈម ដំណោះស្រាយ និងសំណូមពរ**

ទឹកជំនន់បានជន់លិចនៅតាមទីតាំងមួយចំនួនក្នុងភូមិសាស្ត្រខេត្តព្រៃវែង ដែលលើកទី១ បានជន់លិចនៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២៤ នៅក្នុងស្រុកពារាំង និងស្រុកពោធ៍រៀង លើ១០ឃុំ ស្មើនឹង ៣៨១ គ្រួសារ ដែលបានប៉ះពាល់លើដំណាំស្រូវបង្កើនរដូវប្រាំងលើកទី២ នៅតាមមាត់អូរ ព្រែក សរុបចំនួន ៧៥៣ ហិកតា អន្តរាគមន៍ដោយកងកម្លាំងប្រដាប់អាវុធ និងទឹកស្រកវិញចំនួន ២៧១ ហិកតា ស្មើនឹង ៣៥,៩២%នៃផ្ទៃដីប៉ះពាល់សរុប និងផ្ទៃដីខូចខាតសរុប ៤៨២ ហិកតា។

ទឹកជំនន់ទន្លេមេគង្គបានជន់លិចលើកទី២ចាប់ពីថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២៤ លើដំណាំស្រូវនៅដំណាក់កាលដុះពន្លក សំណាប បែកគុម្ព។ ផ្ទៃដីដំណាំស្រូវរងផលប៉ះពាល់តាមបណ្តាក្រុងស្រុកទាំង ២លើក លើ ៣៤ឃុំ ស្មើនឹង ២,៤៤៨ គ្រួសារ ក្នុងស្រុកកំពង់ត្របែក ពាមជរ ពារាំង ព្រះស្តេច ពោធិ៍រៀង និងស្រុកស៊ីធរកណ្តាលសរុបមានផ្ទៃដីចំនួន ២,៨៨៧ ហិកតា ស្មើនឹង ០,៩៤% នៃផ្ទៃដីអនុវត្តបានសរុប សង្គ្រោះអន្តរាគមន៍ពេលទឹកស្រកវិញសរុបមានចំនួន ១,២៤៨ ហិកតា ស្មើនឹង ៤៣,២៣% នៃផ្ទៃដីប៉ះពាល់សរុប និងខូចខាតសរុប ១,៣៨៣ ហិកតា ស្មើនឹង ០,៤៥%នៃផ្ទៃដីអនុវត្តបានសរុប និងផ្ទៃដីដំណាំបន្លែ ៤ ហិកតា ដំណាំពោតក្រហម ៥ ហិកតា ក្នុងស្រុកពាមជរ ពាមរក៍ បានរងការខូចខាតផងដែរ។

ទិសដៅបន្ត ក្រុមការងារនឹងបន្តធ្វើការតាមដាន និងជំរុញការស្តារឡើងវិញនៅស្រុកដែលរងការខូចខាត។

បន្តតាមដាននិងស្រង់ស្ថិតិការងារប្រមូលផលដំណាំស្រូវ ដំណាំឧស្សាហកម្មរយៈពេលខ្លីរដូវវស្សា និងការងារបង្កបង្កើនផលដំណាំស្រូវ ដំណាំសាកវប្បកម្ម និងដំណាំឧស្សាហកម្មរយៈពេលខ្លីរដូវប្រាំង។ បន្តតាមដាន និងស្រង់ស្ថិតិការនាំចេញស្រូវ និងស្វាយកែវរមៀតក្រៅផ្លូវការទៅប្រទេសវៀតណាម តាមច្រកព្រំដែនក្នុងភូមិសាស្ត្រខេត្ត។

បន្តពិនិត្យអនាម័យសាច់ និងផលិតផលសត្វ នៅសត្តឃាត និងកន្លែងតាំងលក់។ បន្តចុះពិនិត្យស្ថានភាពចិញ្ចឹមសត្វនៅតាមមូលដ្ឋាន ជាពិសេសកន្លែងផ្ទុះជំងឺផ្តាសាយបក្សី។ បន្តបង្កាត់សិប្បនិម្មិតសត្វ ផ្សព្វផ្សាយការដាំដំណាំចំណីសត្វ ជំងឺឆ្លងសត្វ ការធ្វើចំបើងផ្អាប់ និងឡជីវឧស្ម័ន។ អន្តរាគមន៍ពេលសត្វមានជំងឺ។ ចូលរួមសិក្ខាសាលានៅខេត្តបាត់ដំបង៣ថ្ងៃ និងសិក្ខាសាលានៅប្រទេសថៃ២ថ្ងៃ។

បន្តចុះល្បាតទប់ស្កាត់បង្ក្រាបបទល្មើសព្រៃឈើ និងសត្វព្រៃក្នុងដែនសមត្ថកិច្ច។ ចុះល្បាតទប់ស្កាត់បង្រាបការកាប់រានដី វាតយកដីព្រៃឈើ ធ្វើជាកម្មសិទ្ធិដីស្ថានីយផ្សព្វផ្សា)យ និងស្តារព្រៃឈើតាសួស ។(បន្តចុះត្រួតពិនិត្យការចរាចរផល អនុផលព្រៃឈើតាមរោងសន្និធិ និងរោងសិប្បកម្មកែច្នៃផលអនុផលព្រៃឈើ។ បន្តថែទាំកូនឈើនៅតាមបណ្តាស្នាក់ការ ខណ្ឌ ផ្នែក និងសង្កាត់រដ្ឋបាលព្រៃឈើ និងចែកចាយកូនឈើ តាមការជាក់ស្តែង។

បន្តជំរុញការងារអភិវឌ្ឍន៍វិស័យវារីវប្បកម្ម ប្រមូលស្ថិតិ និងព័ត៌មានវារីវប្បកម្ម។ បន្តកិច្ចសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចនៅមូលដ្ឋាន ក្នុងការចាត់វិធានការទប់ស្កាត់ និងបង្ក្រាបបទល្មើសជលផល និងពង្រឹងការការពារកន្លែងអភិរក្សជលផលឲ្យបានល្អប្រសើរបន្ថែមទៀត។ ប្រមូលព័ត៌មានស្ថិតិអ្នកនេសាទ ស្ថិតិផលនេសាទ ស្ថិតិផលផលិតផលជលផល និងស្ថិតិការនាំចូលផលិតផលជលផល។ ពង្រឹង

ការគ្រប់គ្រងសហគមន៍នេសាទ និងសហគមន៍ស្រះជម្រកត្រី។ បន្តផ្សព្វផ្សាយច្បាប់ស្តីពីជលផល កម្រងលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធនឹងការគ្រប់គ្រងវិស័យជលផល និងប្រមូលស្ថិតិការកែច្នៃផលផលិតផលជលផល។

### ១.២.១.២. ទស្ស័យធនធានទឹកនិងឧតុនិយម

ខេត្តព្រៃវែងជាខេត្តដែលធ្វើកសិកម្ម ក្នុងនោះដំណាំស្រូវដើរតួរសំខាន់សម្រាប់សេដ្ឋកិច្ចខេត្ត ក៏ដូចជាប្រជាពលរដ្ឋភាគច្រើនពឹងផ្អែកប្រភពចំណូលបានមកពីការបង្កបង្កើនផលស្រូវ ក្នុងនោះប្រពន្ធ័ធារាសាស្រ្តដើរតួរចម្បងក្នុងការផ្គត់ផ្គង់ទឹកសម្រាប់ស្រោចស្រពស្រូវទាំងរដូវប្រាំងនិងរដូវវស្សា ជាក់ស្តែងតំបន់ខ្លះអាចធ្វើស្រែបាន២ដងទៅ៣ដងក្នុង១ឆ្នាំ។ ក្រោយពីធ្វើបច្ចុប្បន្នភាពប្រព័ន្ធធារាសាស្រ្តទាំងតូចទាំងធំសរុបចំនួន ១៧៧ កន្លែង មានខ្នាតធំ ៤ កន្លែង មធ្យម ១១១ កន្លែង និងខ្នាតតូច ៦២ កន្លែង។ សំណង់ធារាសាស្រ្តទាំងអស់នេះអាចផ្គត់ផ្គង់ទឹកស្រោចស្រព លើផ្ទៃដីស្រែសរុបចំនួន ១៣៧,៣៣៤ ហិកតា (ស្រូវរដូវវស្សាចំនួន ៨៨,៤០៦ហិកតា ស្រូវរដូវប្រាំង ៤៨,៩២៨ហិកតា) ស្មើ ៤២,២៥%នៃផ្ទៃដីបង្កបង្កើនផលសរុបចំនួន ៣២៥,០០០ហិកតា។

ក្រៅពីប្រពន្ធ័ធារាសាស្រ្តក៏មានប្រភពទឹកពីបឹងបួរ ព្រែកធម្មជាតិជាច្រើនទៀតផងដែរ និងមានទន្លេមេគង្គឆ្លងកាត់ស្រុកពាមរក៍ ស្រុកពាមជរ ប្រវែង ៥៧គីឡូម៉ែត្រ ព្រមទាំតន្លេតូច ៤ ខ្សែប្រវែងសរុបចំនួន ២៨១,៣គ.ម ក្នុងនោះ (ទន្លេតូចពារាំងប្រវែង ១០៣គ.ម ទន្លេតូចស្ទឹងស្លូតប្រវែង ៦៦គ.ម ទន្លេតូចកំពង់ត្របែកប្រវែង ៦១គ.ម និងទន្លេតាមបណ្តោយព្រំដែនវៀតណាមប្រវែង ៥១,៣គ.ម ។

នៅក្នុងឆ្នាំ២០២៤នេះ ខេត្តបានខិតខំប្រឹងប្រែងយកចិត្តទុកដាក់ស្តារឡើងវិញនូវប្រព័ន្ធធារាសាស្រ្ត បានចំនួន ៦កន្លែង ក្នុងនោះបានសហការជាមួយនាយកដ្ឋានធារាសាស្រ្តកសិកម្មនិងនាយកដ្ឋានវិស្វកម្ម នៃក្រសួងធនធានទឹក និងឧតុនិយម ធ្វើការស្តារប្រឡាយមេ និងជួសជុលខួបប្រព័ន្ធធារាសាស្រ្តចំនួន ០៣កន្លែងរួមមាន៖

- ជីកប្រឡាយមេស្តៅកោងចំនួន០១ខ្សែ ប្រវែង ៤.៦៥០ម និងសំណង់សិល្បៈការចំនួន ១៤កន្លែងស្ថិត នៅឃុំស្តី(ខ) ស្រុកបាភ្នំ សម្រេចលទ្ធផលបាន ១០០ ភាគរយ ។
- ជីកប្រឡាយមេទុកស្រូវចំនួន ០១ខ្សែ ប្រវែង ៧.៥០០ ម និងសំណង់សិល្បៈការចំនួន ១៧កន្លែង ស្ថិតនៅឃុំគោកគង់កើត ស្រុកកញ្រ្ជៀច សម្រេចលទ្ធផលបាន ១០០ភាគរយ ។
- ជួសជុលខួបទំនប់ផ្នុកទ្រូប្រវែង ៥.៧០០ម ស្តារប្រឡាយមេ០២ខ្សែរប្រវែង ៣.១៧០ម និងជួសជុលសំណង់សិល្បៈការចំនួន ៣២កន្លែង ស្ថិតនៅ ស្រុកពារាំង សម្រេចលទ្ធផលបាន ១០០ ភាគរយ ។
- ស្តារប្រឡាយមេកន្លោងចំនួន១ខ្សែប្រវែង៤៣០០ម និងសំណង់សិល្បិការ១៤កន្លែង នៅឃុំទឹកថ្លា ស្រុកស្វាយអន្ទរអន្ទរសម្រេចលទ្ធផលបាន ១០០ ភាគរយ ។

ក្រៅពីកិច្ចសហការជាមួយនាយកដ្ឋានធារាសាស្រ្តកសិកម្ម និងនាយកដ្ឋានវិស្វកម្ម នៃក្រសួងធនធានទឹកនិងឧតុនិយម មន្ទីរបានធ្វើការស្តារប្រឡាយរងចំនួន ០៣ខ្សែ នៅស្រុកកំចាយមារ ដែលមានដូចតទៅ៖

- ប្រឡាយរងភូមិតាដុកប្រវែង ១.៥៥០ម និងសំណង់សិល្បៈការចំនួន០២កន្លែង នៅឃុំដូនកឹង ស្រុកកំចាយមារ សម្រេចលទ្ធផលបាន ១០០ ភាគរយ ។
- ប្រឡាយរងភូមិត្រពាំងឈូកប្រវែង១.២៥០ម និងសំណង់សិល្បៈការចំនួន២កន្លែងនៅ ឃុំត្របែក ស្រុកកំចាយមារ សម្រេចលទ្ធផលបាន ១០០ ភាគរយ។
- ប្រឡាយរងភូមិធ្នង់លិចប្រវែង២.០៥០ម និងសំណង់សិល្បៈការចំនួន ០១កន្លែង នៅឃុំស្មោងជើង ស្រុកកំចាយមារ សម្រេចលទ្ធផលបាន ១០០ ភាគរយ។

នៅឆ្នាំ២០២៤កម្ពស់ទឹកជំនន់ទន្លេមេគ្គងនៅព្រែកតាតាំមានកម្ពស់ ម៉ែត្រ ទាបជាងឆ្នាំ២០២៣ មានចំនួន ០.៧៣ម៉ែត្រ (ឆ្នាំ២០២៣មានកម្ពស់ ៥.៧៤ម៉ែត្រ)។ ចំណែកទឹកភ្លៀងនៅឆ្នាំ២០២៤មាន បរិមាណជាមធ្យម.............មម ទាបជាងឆ្នាំ២០២៣ចំនួន............មម (ឆ្នាំ២០២៣មាន១៦៧៤.១៤មម)។

សីតុណ្ហភាព ក្នុងឆ្នាំ២០២៤ មានកម្រិតអតិបរមាស្មើ៣៤.0 អង្សាសេ និងអប្បបរមាស្មើ ២៣.៧ អង្សាសេបើប្រៀបធៀបឆ្នាំ២០២៣ មានកម្រិតអតិបរមាស្មើ ៣៣.៩អង្សាសេ និងកម្រិតអប្បបរមាស្មើ ២៣.០អង្សាសេ។

➢ **បញ្ហាប្រឈម**

ទោះបីជាមានការខិតខំប្រឹងប្រែងពីស្ថាប័នគ្រប់ជាន់ថ្នាក់ ក្នុងកិច្ចដំណើរការអភិវឌ្ឍវិស័យធនធានទឹក និងឧតុនិយម ក៏នៅមានជួបបញ្ហាប្រឈមដូចជា៖

- អាជ្ញាធរមូលដ្ឋាននៅតំបន់ខ្លះមិនបានជួយសម្រួលដល់ការងារសហគមន៍កសិករប្រើប្រាស់ទឹក និងឲ្យដំណើរការបានល្អ និងស្មារតីចូលរួមរបស់កសិករជាអ្នកទទួលផលពីប្រពន្ធ័ធារាសាស្ត្រនៅមានកម្រិត។
- ព្រែកធម្មជាតិ បឹងបួ ស្ទឹង អូរ បច្ចុប្បន្នមានការគោករ៉ាក់មិនទាន់បានស្តារឡើងវិញនៅឡើយ ដោយថវិការដ្ឋមានកម្រិត។
- ប្រជាពលរដ្ឋមួយចំនួនមិនទាន់យល់ដឹងអំពីការងារថែរក្សាការជួសជុលប្រព័ន្ធធារាសាស្ត្រ ខ្វះការចូលរួមពីសហគមន៍កសិករប្រើប្រាស់ទឹក ដែលជាហេតុនាំឲ្យការគ្រប់គ្រងទឹក ការចែកចាយទឹក និងការថែទាំប្រព័ន្ធមិនទាន់ មានប្រសិទ្ធភាព។
- ការទន្ទ្រានកាន់កាប់ដីមាត់ព្រែក ចាក់លុបដីបឹងបួ ដីចំណីស្ទឹង អាងទឹក អូរ ទំនប់ ប្រឡាយ ការសាងសង់សំណង់នៅលើខ្នងទំនប់ និងតាមភ្លឺប្រឡាយជាដើមដែលជាកត្តានាំឲ្យរាំងស្ទះដល់ការអភិវឌ្ឍន៍ផងដែរ។
- ការបង្កបង្កើនផលស្រូវប្រាំងលើសពីប្រភពទឹកដែលមាន ជាពិសេសស្រូវប្រាំងលើកទី២ ដែលបង្កការលំបាកក្នុងការជួយអន្តរាគមន៍សង្គ្រោះដោយខ្វះប្រភពទឹក។
- ការសហការពីអាជ្ញាធរមូលដ្ឋាននៅមានកំរិតក្នុងការទប់ស្កាត់រាល់ការរំលោភដីអាងទឹក បឹងបួ មាត់ព្រែក ស្ទឹង អូរ ប្រឡាយ និងចំណីទំនប់ដែលជាដីសម្បត្តិសាធារណៈរបស់រដ្ឋធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួន។

▪ **សំណូមពរ**

- គ្រប់ស្ថាប័នពាក់ព័ន្ធ អង្គការជាតិ អន្តរជាតិ និងសប្បុរសជនជួយគាំទ្របន្តទៀតការស្តារឡើងវិញនូវ

ប្រព័ន្ធធារាសាស្ត្រដែលមានស្រាប់នៅក្នុងខេត្ត និងជួយជំរុញ និងលើកទឹកចិត្តដល់សហគមន៍កសិករប្រើប្រាស់ទឹកចូលរួមថែរក្សាប្រព័ន្ធធារាសាស្ត្រ ដើម្បីអាចធានាបាននូវនិរន្តរភាព របស់ប្រព័ន្ធ។

- អាជ្ញាធរមូលដ្ឋានគ្រប់ជាន់ថ្នាក់ និងអ្នកពាក់ព័ន្ធជួយទប់ស្កាត់ការទន្ទ្រានកាន់កាប់ដីមាត់ព្រែក ចាក់លុបដីបឹងបួ ដីចំណីស្ទឹង អាងទឹក អូរ ទំនប់ ប្រឡាយ ការសាងសង់សំណង់នៅលើខ្នងទំនប់ និងតាមភ្លឺប្រឡាយជាដើមដែលជាកត្តានាំឲ្យរាំងស្ទះដល់ការអភិវឌ្ឍន៍។

### ១.២.១.៣. វិស័យសាធារណការនិងដឹកជញ្ជូន

ខេត្តព្រៃវែងមានផ្លូវជាតិ ៦ខ្សែ ឆ្លងកាត់គឺៈ

១-ផ្លូវជាតិលេខ១ ភ្ជាប់ពីរាជធានីភ្នំពេញទៅខេត្តស្វាយរៀង រហូតដល់ព្រំប្រទល់ប្រទេសវៀតណាម ដោយឆ្លងកាត់បណ្តាស្រុកផ្នែកខាងត្បូងចំនួន៣ គឺស្រុកពាមរក៍-ព្រះស្តេច-កំពង់ត្របែក។

២-ផ្លូវជាតិលេខ៨ បានភ្ជាប់ពីផ្លូវជាតិលេខ៦ ត្រង់ចំណុចស្ពានព្រែកតាមាក់ឆ្លងកាត់ស្រុកពារាំង-ស្វាយអន្ទរ-កំចាយមារ រហូតដល់ព្រំប្រទល់ខេត្តត្បូងឃ្មុំ និងភ្ជាប់ទៅផ្លូវជាតិលេខ៧ ក្នុងស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ។

៣-ផ្លូវជាតិលេខ១១ ភ្ជាប់ពីផ្លូវជាតិលេខ១ ត្រង់ចំណុចតំបន់ទីប្រជុំជនអ្នកលឿង (ស្រុកពាមរក៍) ទៅទីរួមខេត្ត និងឆ្លងកាត់ក្រុង ស្រុកផ្នែកខាងជើងចំនួន៤ គឺក្រុងព្រៃវែង ស្រុកស្វាយអន្ទរ-កញ្ជ្រៀច-ស៊ីធរកណ្តាល រហូតទៅដល់ស្រុកអូរាំងឪ ខេត្តត្បូងឃ្មុំ។

៤-ផ្លូវជាតិលេខ១៣ ចាប់ពីផ្លូវជាតិលេខ១ ខេត្តស្វាយរៀង ដល់ផ្លូវជាតិលេខ៨ ត្រង់ឃុំក្របៅ ស្រុកកំចាយមារ។

៥-ផ្លូវជាតិលេខ៨៨ ភ្ជាប់ពីផ្លូវជាតិលេខ៨ ឃុំក្របៅ ស្រុកកំចាយមារ ដល់ច្រកព្រំដែនម៉ឺនជ័យ ព្រំប្រទល់ប្រទេសវៀតណាម។

៦-ផ្លូវជាតិលេខ៧០បេ (ឈ្មោះចាស់ផ្លូវខេត្តលេខ៣៨០)មានប្រវែងសរុប ១៥០ គ.ម ចេញពីទន្លេបិទ ខេត្តត្បូងឃ្មុំ (ភ្ជាប់ពីផ្លូវជាតិលេខ៧) ឆ្លងកាត់ខេត្តកណ្តាល មកដល់ឃុំពាមមានជ័យ និងឃុំពាមរក៍ ស្រុកពាមរក៍ ខេត្តព្រៃវែង (ភ្ជាប់ផ្លូវជាតិលេខ១១)។ ឆ្លងកាត់ខេត្តព្រៃវែងមានប្រវែងសរុបចំនួន ៨,៩៧៥ ម៉ែត្រ ជាប្រភេទកម្រាលកៅស៊ូប្រវែង ៨,៩៧៥ម៉ែត្រ ។

ផ្លូវជាតិទាំង៦ខ្សែនេះ មានអំណោយផលល្អណាស់ក្នុងការភ្ជាប់តំបន់សេដ្ឋកិច្ច និងការធ្វើដំណើររបស់ប្រជាពលរដ្ឋ។

ការធ្វើចរាចរដឹកជញ្ជូនទំនិញផលិតផល សេវាកម្មសព្វសារពើតាមផ្លូវទឹក គឺជាសក្តានុពលភាពសំខាន់សំរាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ខេត្ត ប៉ុន្តែបច្ចុប្បន្នការដឹកជញ្ជូនតាមផ្លូវទឹកនេះកំពុងតែជួបប្រទះការលំបាកយ៉ាងខ្លាំង ដោយបណ្តាញផ្លូវទឹកមួយចំនួនត្រូវរីងរាក់ក្នុងរដូវប្រាំងពិសេស ទន្លេតូចពីស្រុកពាមរក៍ មកទីរួមខេត្ត និងទៅស្រុកពារាំង-ស៊ីធរកណ្តាល។

បច្ចុប្បន្ននេះ វិស័យសាធារណការមានការអភិវឌ្ឍន៍ និងធ្វើទំនើបកម្មជាបន្តបន្ទាប់ ដោយបណ្តាញផ្លូវសំខាន់ៗ ត្រូវបានស្តាបនា និងជួសជុលលើកកម្រិតគុណភាពផ្លូវអោយប្រសើរឡើងវិញ

ដើម្បីផ្តល់ការរស់នៅប្រកបដោយផាសុខភាពដល់ប្រជាពលរដ្ឋនៅតាមអមសងខាងផ្លូវ ក៏ដូចជាផ្តល់នូវការធ្វើដំណើរប្រកបដោយសុវត្ថភាពដល់អ្នកប្រើប្រាស់ផ្លូវផងដែរ។ បច្ចុប្បន្ន ផ្លូវខេត្តលេខ ៣១២ ប្រវែង ២៨,៣៧២គ.ម ដែលជាផ្លូវសំខាន់មួយ ភ្ជាប់ពីផ្លូវជាតិលេខ ១ ត្រង់ឃុំល្វា ស្រុកព្រះស្តេច ឆ្ពោះទៅច្រកព្រំដែនបន្ទាយចក្រី ស្រុកព្រះស្តេច (ព្រំប្រទល់ប្រទេសវៀតណាម) ត្រូវបានធ្វើពិធីប្រកាសបើកការដ្ឋានជួសជុលដោយពង្រីកទទឹងតួផ្លូវរហូតដល់ ១២ម៉ែត្រ និងលើកកម្រិតគុណភាព ពីប្រភេទផ្លូវក្រាលកៅស៊ូពីរស្រទាប់(DBST) ទៅជាប្រភេទផ្លូវក្រាលបេតុងកៅស៊ូ (AC) និងផ្នែកខ្លះក្រាលបេតុងសរសៃដែកកម្រាស់ ២៥ស.ម ដែលមានទទឹងរួម ១១ម៉ែត្រ និងមាន២គន្លងទៅ-មក ក្រោមឥណទានសម្បទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។ គម្រោងសាងសង់ និងជួសជុល អាទិភាពផ្លូវជាតិ ផ្លូវខេត្ត មួយចំនួនទៀតដែលមន្ទីរកំពុងអនុវត្ត ក្នុងឆ្នាំ២០២៤ មានដូចតទៅ:

១.ការងារថែទាំប្រចាំផ្លូវជាតិ និងផ្លូវខេត្ត ចំនួន ៣១ ខ្សែ ក្រាលកៅស៊ូ និងដីល្បាយថ្ម មានប្រវែងសរុបចំនួន ៦៥០,១៩ គ.ម ចំណាយអស់ថវិកា ៥,៦៣០ លានរៀល។

២.ការងារស្ថាបនាផ្លូវខេត្តលេខ 387A ដោយក្រាលកៅស៊ូប្រភេទ DBST ប្រវែងសរុប ៤,៥០ គ.ម ទទឹង ៧ម ចំណាយអស់ថវិកា ៣,៧០០ លានរៀល។

៣.ការងារស្ថាបនាផ្លូវបេតុងសរសៃដែកក្នុងក្រុងព្រៃវែងប្រវែងសរុប ០,៩២៣គ.ម ទទឹង ៤ម, ៥ម និង ៦ម ចំណាយ អស់ថវិកា ១,០៣៧ លានរៀល។

៤.ការងារជួសជុលផ្លូវខេត្តលេខ ៣៧០សេ និង ៣PV៧ ដោយក្រាលបេតុងសរសៃដែកកម្រាស់ ០,២៣ម ប្រវែង ១,២០គម ទទឹង ៧ម ចំណាយអស់ថវិកា ២,៧០០ លានរៀល។

មន្ទីរមានទិសដៅស្នើសុំអនុវត្តគម្រោងអាទិភាពមួយចំនួនទៀតនៅឆ្នាំបន្តបន្ទាប់ដូចខាងក្រោមៈ

១.ការងារថែទាំប្រចាំផ្លូវជាតិ និងផ្លូវខេត្តចំនួន ៣១ ខ្សែ ក្រាលកៅស៊ូ និងដីល្បាយថ្ម មានប្រវែងសរុបចំនួន ៦៥០,១៩ គ.ម ចំណាយអស់ថវិកា ៥,៦៣០ លានរៀល។

២.ការងារស្ថាបនាផ្លូវខេត្តលេខ 3110A ដោយក្រាលកៅស៊ូប្រភេទ DBST ប្រវែងសរុប ២,៧០ គ.ម ទទឹង ៧ម គ្រោងចំណាយថវិកាប្រមាណ ២,៧០០ លានរៀល។

៣.ការងារស្ថាបនាផ្លូវខេត្តលេខ 310A ដោយក្រាលកៅស៊ូប្រភេទ DBST និងក្រាលបេតុងសរសៃដែកកម្រាស់ ០,២៣ម ប្រវែងសរុប ២,០០ គ.ម ទទឹង ៧ម គ្រោងចំណាយថវិកាប្រមាណ ៣,០០០ លានរៀល។

- **បញ្ហាប្រឈមៈ**
  - កង្វះខាតការយល់ដឹង និងការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការចូលរួមថែរក្សាផ្លូវថ្នល់ ដោយនៅតែបន្តសកម្មភាពចាក់ដីរំលោភដីចំណីថ្នល់ មានកម្ពស់ខ្ពស់ជាងថ្នល់ ការចាក់ដីលុបមុខទឹកហូរ បង្កឲ្យផ្លូវរងការខូចខាតកាន់តែខ្លាំង ជាពិសេសនៅរដូវវស្សាដែលមានភ្លៀងធ្លាក់ច្រើន។
  - រថយន្តធុនធ្ងន់ដឹកទំនិញលើសទម្ងន់កម្រិតកំណត់នៅតែមាន និងបើកបរវាងស្ថានីយថ្លឹងរថយន្ត បង្កឲ្យផ្លូវថ្នល់ទទួលរងនូវការខូចខាតខ្លាំង។
  - កង្វះខាតធនធានក្នុងស្រុកដូចជាដីល្បាយថ្ម ថ្មម៉ិច សម្រាប់ធ្វើការសាងសង់ និងថែទាំផ្លូវថ្នល់ ពីព្រោះបច្ចុប្បន្នធនធានទាំងនេះមានចំនួនកាន់តែតិចទៅៗ។

- កង្វះខាតសម្ភារៈសម្រាប់ប្រើប្រាស់ក្នុងការពិសោធន៍គុណភាពសម្ភារៈសំណង់។
- កង្វះខាតកម្មករជំនាញក្នុងការបញ្ជាគ្រឿងចក្រ។
- ការកើនឡើងនៃតម្លៃសម្ភារៈប្រើប្រាស់ក្នុងការស្ថាបនា និងជួសជុលផ្លូវ។

**១.២.១.៤. វិស័យអភិវឌ្ឍន៍ជនបទ**

រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៧ ដឹកនាំប្រកបដោយថាមពល និងគតិបណ្ឌិតរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានសម្រេចដាក់ចេញនូវយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ដែលផ្តោតលើអាទិភាពគន្លឹះចំនួន៥ គឺ មនុស្ស ផ្លូវ ទឹក ភ្លើង និងបច្ចេកវិទ្យាឌីជីថល ដែលជាមូលដ្ឋានសម្រាប់រៀបចំគោលនយោបាយ និងផែនការយុទ្ធសាស្ត្រតាមវិស័យក្នុងគោលដៅអភិវឌ្ឍន៍ប្រទេសកម្ពុជា ឲ្យក្លាយជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ២០៥០។ នៅក្នុងបុព្វហេតុនៃការអភិវឌ្ឍន៍ប្រទេសឲ្យកាន់តែរីកចម្រើន រាជរដ្ឋាភិបាលកម្ពុជាបាននឹងកំពុងបន្តយកចិត្តទុក ដាក់ថែរក្សាសន្តិភាព ស្ថេរភាពនយោបាយ និងម៉ាក្រូសេដ្ឋកិច្ចក្នុងរង្វង់៧% នៅក្នុងផ្ទៃប្រទេស ព្រមទាំងពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីធានាស្ថេរភាពនយោបាយ និងការអភិវឌ្ឍន៍តទៅ អនាគត។

ដើម្បីរួមចំណែកសម្រេចបាននូវគោលបំណង គោលនយោបាយអភិវឌ្ឍន៍ជនបទឆ្នាំ២០២៤-២០២៨ ឲ្យសម្រេចបានជោគជ័យ និងមានប្រសិទ្ធភាពខ្ពស់ ក្រសួងបានរៀបចំយុទ្ធសាស្ត្រចំនួន៥ សម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទក្នុងរយៈពេល៥ឆ្នាំ (២០២៤-២០២៨) រួមមានដូច ខាងក្រោមៈ (១) បង្កើនការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្តនិងគមនាគមន៍ជនបទប្រកបដោយភាពធន់ (២)លើកកម្ពស់សុខភាពអនាម័យនិងបរិស្ថានរស់នៅរបស់សហគមន៍ជនបទប្រកបដោយនិរន្តភាព (៣)អភិវឌ្ឍន៍សហគមន៍ជនបទ ឌីជីថល និងចលនាភូមិគំរូ (៤)ពិពិធកម្មសេដ្ឋកិច្ចជនបទនិងនវានុវត្តន៍ការងារ និង(៥) ពង្រឹងស្ថាបនតាមរយៈការរៀបចំគោលនយោបាយ ហិរញ្ញវត្ថុ ឌីជីថល និង សហប្រតិបត្តិការ។

ផ្អែកលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទរបស់ក្រសួង មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត និងរដ្ឋបាលខេត្តព្រៃវែងបាននឹងកំពុងបង្កើនការយកចិត្តទុកដាក់ខ្ពស់ ក្នុងការចូលរួមចំណែកអនុវត្តស្របតាមផែនការយុទ្ធសាស្ត្ររបស់ក្រសួងអភិវឌ្ឍន៍ជនបទ ផែនការខេត្ត ដើម្បីរៀបចំផែនការវិនិយោគ៣ឆ្នាំរំកិលខេត្ត ឆ្នាំ២០២៥-២០២៧ មន្ទីរអភិវឌ្ឍន៍ជនបទខេត្តត្រូវបានរៀបចំកិច្ចប្រជុំពិភាក្សាថ្នាក់ដឹកនាំមន្ទីរ និងថ្នាក់ដឹកនាំការិយាល័យប្រមូលធាតុចូលដើម្បីវិភាគយ៉ាងស៊ីជម្រៅគ្រប់ជ្រុងជ្រោយ សម្រាប់ដោះស្រាយបញ្ហាប្រឈមនានាក្នុងវិស័យអភិវឌ្ឍន៍ជនបទក្នុងខេត្តមានរយៈពេល៣ឆ្នាំខាងមុខ ដើម្បីធានាបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈកាន់តែល្អប្រសើរឡើង ប្រកបដោយគណនេយ្យភាព ធានាបានអភិបាលកិច្ចល្អ គាំទ្រដល់កម្មវិធីកំណែទម្រង់ផ្សេងៗឲ្យកាន់តែទូលំទូលាយប្រសើរជាងមុន ស្របតាមសំណូមពរ និងតម្រូវការចាំបាច់របស់ប្រជាជន ទាំងបរិមាណ គុណភាព និងប្រសិទ្ធភាពខ្ពស់ លើកស្ទួយវិស័យហេដ្ឋារចនាសម្ព័ន្ធជនបទ និងសុខុមាលភាពរបស់ប្រជាពលរដ្ឋទូទាំងខេត្ត ធានាកម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋជនបទឲ្យមានគម្លាតខិតជិតរវាងទីក្រុង និងជនបទ។

**I-លទ្ធផលសម្រេចបាន**

ឆ្នាំ២០២៤នេះ ការងារអភិវឌ្ឍន៍ជនបទបានផ្តោតសំខាន់លើវិស័យសេដ្ឋកិច្ច ក្នុងការអភិវឌ្ឍន៍មូលដ្ឋានដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ស្របតាមគោលនយោបាយរបស់ក្រសួងអភិវឌ្ឍន៍ជនបទ និងយុទ្ធសាស្រ្តបញ្ចកោណរបស់រាជរដ្ឋាភិបាលដំណាក់កាលទី១ ក្នុងនីតិកាលទី៧នៃរដ្ឋសភាឲ្យទទួលបានជោគជ័យ មន្ទីរអភិវឌ្ឍន៍ជនបទខេត្តព្រៃវែង ក៏បានចូលរួមចំណែកយ៉ាងសកម្មក្នុងការចូលរួមកាត់បន្ថយភាពក្រីក្រ និងលើកស្ទួយកំរិតជីវភាពរស់នៅ និងគុណភាពនៃជីវភាពរបស់ប្រជាពលរដ្ឋជនបទតាមរយៈការកែលំអហេដ្ឋារចនាសម្ព័ន្ធដូចជាផ្លូវ ស្ពាន លូ ការផ្គត់ផ្គង់ទឹក និងអនាម័យជនបទ ការអប់រំផ្សព្វផ្សាយជម្រុញការថែទាំសុខភាពបឋមការលើកកម្ពស់ការប្រើប្រាស់ទឹក និងទុកដាក់ទឹកហូបប្រកបដោយសុវត្ថិភាព ការបណ្តុះបណ្តាលជំនាញមូលដ្ឋានបង្កើនមុខរបរ ការបណ្តុះ បណ្តាលពង្រឹងសមត្ថភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ(គ.អ.ភ) មានចំណេះដឹងកសាងផែនការ អភិវឌ្ឍន៍ភូមិ និងចូលរួមធ្វើជាម្ចាស់លើសមិទ្ធិផលរបស់គម្រោងនានានៅតាមមូលដ្ឋានរបស់ខ្លួន។ លទ្ធផលការងារដែលមន្ទីរសម្រេចបានគិតត្រឹមខែឧសភា ឆ្នាំ២០២៤នេះ ដោយមានការជួយគាំទ្រពីក្រសួង និងដៃគូអភិវឌ្ឍន៍នានាសម្រាប់ការអភិវឌ្ឍន៍នៅមូលដ្ឋានទទួលបានលទ្ធផលដូចខាងក្រោម៖

-បានចុះធ្វើបច្ចុប្បន្នភាពទិន្នន័យផ្លូវជនបទ បានចំនួន០១ខ្សែ មានប្រវែងសរុប ២៨.០០គ.ម នៅស្រុកស្វាយអន្ទរ និងស្រុកមេសាង។

-បានធ្វើការកែលម្អផ្លូវក្រាលកៅស៊ូពីរជាន់ ចំនួន០២ខ្សែ មានប្រវែងសរុប ៩.៥០គ.ម ទទឹង ៦ម និងលូមូលចំនួន ០៤កន្លែង ស្ថិតក្នុងស្រុកពោធិ៍រៀង ផ្លូវពីភូមិប្រាំងទទឹង ទៅភូមិព្រែកអន្ទះ មានប្រវែង ៥.៥០គ.ម ទទឹង៦ម សម្រេចបាន១៣% និងស្រុកពាមជរ ផ្លូវពីភូមិឈើទាល ទៅភូមិក្រាំងស្គរ មានប្រវែង ៤.០០គ.ម ទទឹង៦ម សម្រេចបាន ២៥% ។

-ចុះសិក្សាលើកគម្រោងលម្អិតគម្រោងអន្តរាគមន៍បន្ទាន់ចំនួន ០១កំណាត់ មានប្រវែង ៣.១០ គ.ម ទទឹង៥ម (ផ្លូវពីភូមិតាហ៊ុយ ទៅភូមិទឹកវិល ស្ថិតក្នុងឃុំកំពង់ប្រាសាទ ស្រុកពាមជរ)។

-បានធ្វើការចុះរាប់ចរាចរណ៍តាមផ្លូវជនបទ បានចំនួន០១ខ្សែ លើផ្លូវមានប្រវែង១២.៤០គ.ម នៅស្រុកព្រះស្តេច។

-បានធ្វើការកែលម្អផ្លូវក្រាលកៅស៊ូពីរជាន់ និងបេតុងរបស់ គម្រោងពង្រឹងសមត្ថភាពផលិតភាព NRRPCP ចំនួន០៤ខ្សែ មានប្រវែងសរុប ៥៩.៤៧គ.ម ទទឹង៦ម និងលូមូល២១កន្លែង នៅស្រុកបាភ្នំ ,កំពង់ត្របែក មេសាង កំចាយមារ កញ្ជ្រៀច ព្រះស្តេច និងស្រុកពាមជរ សម្រេចបានពី៧% ដល់៩៧%។

-បានធ្វើការកែលម្អផ្លូវដោយការក្រាលបេតុង របស់គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជនបទដែល ធន់នឹងការប្រែប្រួលអាកាសធាតុ CRRIDP ចំនួន០៣ខ្សែ មានប្រវែង២៦.៦៤គ.ម ទទឹង៦ម និងលូគ្រប់ប្រភេទចំនួន២៥កន្លែង នៅស្រុកពារាំង ស្រុកស៊ីធរកណ្តាល និងស្រុកកញ្ជ្រៀច សម្រេចបានពី ៧៨% ដល់ ៩៥%។

-បាននចុះធ្វើការជួសជុលអណ្តូងស្នប់អាហ្វ្រីដេវ និងអណ្តូងបំពាក់ម៉ូទ័រ បានចំនួន១២ទីតាំងនៅស្រុកពោធិ៍រៀង ស្រុកស្វាយអន្ទរ ស្រុកពាមរក៍ និងស្រុកព្រះស្តេច ដែលមានអ្នកទទួលផល ចំនួន

៣.១៧៥នាក់។

-បានចុះផ្សព្វផ្សាយស្តីពីការប្រើប្រាស់ និងបរិភោគទឹកស្អាតដោយសុវត្ថិភាពបានចំនួន៤ភូមិ ក្នុងឃុំកន្ទោមអក ស្រុកកំពង់ត្របែក មានអ្នកចូលរួមចំនួន១៨៨ នាក់ ស្រី ៩២នាក់។

-បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយពីលក្ខខណ្ឌនៃការរស់នៅស្អាត និង ការអនុវត្តគោលការណ៍ណែនាំ ស្តីពីការផ្ទៀងផ្ទាត់ស្ថានភាពបញ្ចប់ការបន្ទោរបង់ពាសវាលពាសកាលកំរិតខ្ពស់ (ODFP LUS) ចំនួន៨ឃុំ ក្នុងស្រុកកំពង់ត្របែក ពាមជរ មេសាង និងស្រុកពាមរក៍ មានអ្នកចូលរួមសរុប៣៦៥នាក់ ស្រី ១៣៦នាក់

-បានបើកវគ្គបណ្តុះបណ្តាលជំនាញមូលដ្ឋាននៅក្នុងមជ្ឈមណ្ឌលបានចំនួន២វគ្គ (១)អ៊ុតសក់និងកែសម្ផស្សនារីមានសិក្ខាកាមចំនួន៧នាក់ ស្រី៧នាក់ និងជំនាញកុំព្យូទ័រ-រដ្ឋបាល មានសិក្ខាកាមចូលរៀនសរុប ១៥នាក់ ស្រី ៦នាក់។

-បានបើកវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពគ.អ.ភ ស្តីពីតួនាទីភារកិច្ចគ.អ.ភ ផែនការសកម្មភាពអភិវឌ្ឍន៍ភូមិនិងចលនាភូមិថ្មីចំនួន០៤វគ្គ ដែលមានអ្នកចូលរួមចំនួន ១៩៨នាក់ ស្រី ៨១នាក់ មកពីភូមិចំនួន២៩ភូមិ នៅឃុំព្រៃឈរ ស្រុកកំពង់ត្របែក និងឃុំបឹងព្រះ ស្រុកបាភ្នំ (ថវិកាកម្មវិធីមន្ទីរ) ។

-បានដឹកនាំ និងសម្របសម្រួលកិច្ចប្រជុំ ដើម្បីដោះស្រាយបញ្ហាសហគមន៍សន្សំឲ្យមានដំណើរការល្អឡើងវិញ នៅឃុំបឹងព្រះ ស្រុកបាភ្នំ បានចំនួន ១០សហគមន៍ មានអ្នកចូលរួមចំនួន ២៦នាក់ ស្រី០៥នាក់។

-ការចុះតាមដាននិងពិនិត្យមើល ការបិទបញ្ជីសហគមន៍សន្សំប្រាក់ប្រចាំឆ្នាំបាន៤ស្រុកគោលដៅ ១២ឃុំ ១៤២សហគមន៍ មានអ្នកចូលរួមចំនួន ២៩២នាក់ ស្រី ៩៤នាក់។

**II-ទិសដៅអនុវត្តបន្តឆ្នាំ២០២៥**

ដើម្បីឈានទៅសម្រេចគោលបំណងគោលនយោបាយ និងយុទ្ធសាស្រ្តបញ្ចកោណដំណាក់កាល ទី១របស់រាជរដ្ឋាភិបាល គោលនយោបាយរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ក៏ដូចជាផែនការវិនិយោគ៣ឆ្នាំរំកិល២០២៥-២០២៧របស់ខេត្ត មន្ទីរនឹងបន្តចូលរួមអនុវត្តឲ្យបាននូវកម្មវិធីកំណែទម្រង់ទាំង៣ គឺកំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដែលជាកាតាលីករជម្រុញឲ្យមានកំណើនការងារ និងប្រសិទ្ធភាព នៅក្នុងខេត្តតាម រយៈសកម្មភាពសំខាន់ៗ មួយចំនួនដូចខាងក្រោម៖

-បន្តជំរុញការងារអភិវឌ្ឍមូលធនមនុស្ស តាមរយៈការបណ្តុះបណ្តាលពង្រឹងសមត្ថភាពដល់មន្ត្រីរាជការថ្នាក់ខេត្តលើការគ្រប់គ្រង ការងាររដ្ឋបាល និងបុគ្គលិក ការកសាងផែនការយុទ្ធសាស្រ្តថវិកាផែនការចំណាយថវិកាប្រចាំឆ្នាំ២០២៥ ផែនការវិនិយោគ៣ឆ្នាំរបស់ខេត្ត និងចំណេះដឹងថ្មីៗបន្ថែមទៀត។

-រៀបចំផែនការយុទ្ធសាស្រ្តថវិកាឆ្នាំ២០២៥-២០២៧ និងផែនការថវិកាឆ្នាំ២០២៥

-រៀបចំផែនការវិនិយោគ ៣ឆ្នាំរំកិលខេត្ត ២០២៥-២០២៧

-ចុះត្រួតពិនិត្យតាមដានការអនុវត្តសូចនាករសមិទ្ធិកម្មថវិកាកម្មវិធីរបស់ការិយាល័យជំនាញ

-ជួសជុលអណ្តូងស្នប់អាហ្វ្រិដេវ នៅតាមសហគមន៍ និងសាលារៀនចំនួន២៦អណ្តូង

-ប្រជុំផ្សព្វផ្សាយស្តីពីការលើកម្ពស់ការប្រើប្រាស់ទឹកស្អាតចំនួន ១១វគ្គ និងចុះធ្វើតេស្តគុណភាព

ទឹកតាមស្ថានីយ៍ផលិតទឹកពិសារតាមសហគមន៍ចំនួន២៨ស្ថានីយ៍។

-អប់រំផ្សព្វផ្សាយសហគមន៍អំពីលក្ខខណ្ឌនៃការរស់នៅស្អាតចំនួន ៣៩លើក ក្នុង២៥ឃុំ ៥០ភូមិ និងការចុះស្រង់ទិន្នន័យ និងធ្វើបច្ចុប្បន្នភាពបង្គន់អនាម័យគ្រួសារក្នុង៥ស្រុកគោលដៅ ២៥ឃុំ សម្រាប់ប្រើប្រាស់របស់មន្ទីរ។

-ជម្រុញលើកកម្ពស់ការផ្គត់ផ្គង់ទឹកស្អាត នៅតាមសហគមន៍ និងសាលារៀន និងចុះស្រង់ទិន្នន័យធ្វើបច្ចុប្បន្នភាពប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទគ្រប់ប្រភេទចំនួន២០ឃុំ ក្នុង៦ស្រុកគោលដៅ។

-បណ្តុះបណ្តាលពង្រឹងសមត្ថភាព គ.អ.ភ ស្តីពីតួនាទី ភារកិច្ចទទួលខុសត្រូវ ការរៀបចំផែនការអភិវឌ្ឍន៍ភូមិ ឲ្យបានល្អប្រសើរចំនួន០៩វគ្គ និងចុះធ្វើបច្ចុប្បន្នភាព គ.អ.ភ ចំនួន៤៥ភូមិ។

-បណ្តុះបណ្តាលពង្រឹងសមត្ថភាពសហគមន៍សន្សំប្រាក់ចំនួន ២វគ្គ និងចុះពិនិត្យសកម្មភាពសហគមន៍សន្សំប្រាក់ចំនួន ១០លើក ។

-ប្រជុំប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំរបស់មន្ទីរ ដោយមានការចូលរួមពីថ្នាក់ដឹកនាំមន្ទីរ ការិយាល័យ និងមន្ត្រីរាជការទាំងអស់ចំនួន១២លើក ដើម្បីពង្រឹងការងារគ្រប់គ្រងរដ្ឋបាល ការងារដឹកនាំរបស់ការិយាល័យជំនាញ និងការអនុវត្តថវិកាកម្មវិធីឲ្យទទួលបានប្រសិទ្ធភាពខ្ពស់។

- **បញ្ហាប្រឈម**

ទោះបីតំបន់ជនបទត្រូវបានអភិវឌ្ឍច្រើនហើយក្តី តែបញ្ហាប្រឈមនៅតែមានអាស្រ័យដោយតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។ យោងតាមវេទិកាសាធារណៈមានសំណូមពរ និងសំណើរជាច្រើនដែលប្រជាពលរដ្ឋស្នើសុំ ហើយមន្ទីរមានលទ្ធភាពដោះស្រាយបានមួយចំនួនតូចប៉ុណ្ណោះ ក្នុងនោះបញ្ហាប្រឈមរួមមាន៖

-កង្វះវត្ថុធាតុដើមដូចជា គ្រួសក្រហម ខ្សាច់ភ្នំ និងតម្លៃដឹកជញ្ជូនកើនឡើងខ្ពស់ សម្រាប់ការសាង សង់ និងជួសជុលផ្លូវជនបទ។

-កំណើនយានយន្តធ្វើចរាចរកាន់តែមានច្រើន និងការផ្ទុកលើសទំងន់ដែលបណ្តាឲ្យផ្លូវដែលបានសាងសង់ ឬជួសជុលរួច ងាយនឹងរងការខូចខាតទៅវិញដោយកង្វះវិធានការទប់ស្កាត់។

-ការកាន់កាប់ដីចំណីផ្លូវធ្វើអោយប៉ះពាល់ដល់ការងារស្តាបនា និងកែលម្អផ្លូវជនបទ

-ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទនៅតំបន់ដែលមានបរិស្ថានប្រឈម នៅមានកំរិត

-ប្រជាពលរដ្ឋដែលក្រីក្រខ្វះលទ្ធភាព មានការយល់ដឹង និងការផ្លាស់ប្តូរឥរិយាបថការរស់នៅស្អាត របស់ប្រជាពលរដ្ឋនៅជនបទនៅមានកម្រិត ត្រូវការអប់រំផ្សព្វផ្សាយបន្ថែម។

-អណ្តូងសាងសង់មួយចំនួនច ដែលសាងសង់មិនត្រូវតាមបទដ្ឋានបច្ចេកទេសងាយរងការខូចខាត និងរីងស្ងួតនៅរដូវប្រាំង ដោយសារការបម្រែបម្រួលអាសធាតុ។

-ការធ្វើចំណាកស្រុករបស់ប្រជាជនជនបទនៅតាមតំបន់ជនបទបន្តមានអត្រាខ្ពស់

-ការវិភាជន៍ថវិការបស់ឃុំ សង្កាត់លើការងារទឹកស្អាត អនាម័យ និងសាងសង់រហេដ្ឋារចនាសម្ព័ន្ធរូបវន្ត នូវពុំទាន់សមស្របតាមតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋ។

## ១.២.១.៥.វិស័យពាណិជ្ជកម្ម

វិស័យពាណិជ្ជកម្ម បានដើរតួយ៉ាងសំខាន់ក្នុងការអភិវឌ្ឍ និងបង្កើនចំណូលជាតិក៏ដូចជាកំណើនសេដ្ឋកិច្ចជាតិជារៀងរាល់ឆ្នាំ។ បច្ចុប្បន្នវិស័យនេះកំពុងមានការអភិវឌ្ឍទៅមុខ និងបានវិវឌ្ឍន៍ខ្លួនទៅតាម បរិបទសាកលភាវូបនីយកម្មនៃពាណិជ្ជកម្មបែបប្រព័ន្ធឌីជីថល ។

ដើម្បីរួមចំណែកជាមួយរាជរដ្ឋាភិបាល ក្រសួងពាណិជ្ជកម្ម មានផែនការយុទ្ធសាស្ត្រថ្មីៗ ដោយដាក់ចេញគោលនយោបាយ និងបទប្បញ្ញត្តិនានា ដូចជាច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងច្បាប់ស្តីពីការប្រកួតប្រជែងជាដើម ដើម្បីដោះស្រាយបញ្ហាទីផ្សារឲ្យមានប្រសិទ្ធភាពខ្ពស់ កាត់បន្ថយថ្លៃប្រតិបត្តិការ ដើម្បីបង្កើតបរិយាកាសអំណោយផលដល់វិនិយោគគិនក្នុងប្រទេស និងទាក់ទាញការវិនិយោគផ្ទាល់ពីក្រៅប្រទេស។ ក្រសួងពាណិជ្ជកម្ម បានខិតខំអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងការជំរុញផលិតកម្មក្នុងស្រុក ដើម្បីផ្គត់ផ្គង់តម្រូវការទីផ្សារ និងធ្វើពិពិធកម្មវិស័យនាំចេញ សំដៅពន្លឿនការធ្វើសមាហរណកម្មសេដ្ឋកិច្ចពាណិជ្ជកម្មក្នុងតំបន់ និងពិភពលោក។ ក្នុងនាមមន្ទីរពាណិជ្ជកម្មខេត្ត ដែលជាសេនាធិការនៃក្រសួងពាណិជ្ជកម្ម បានខិតខំយកចិត្តទុកដាក់ជំរុញការផ្តល់សេវាសាធារណៈឲ្យបានទូលំទូលាយ ជូនដល់អាជីវករ ពាណិជ្ជករ សេវាករ ធ្វើយ៉ាងណាបានឆាប់រហ័សទាន់ពេលវេលា មានតម្លាភាព និងមានគណនេយ្យភាព។ បានធ្វើការណែនាំដល់ផលិតករឲ្យយល់ដឹងពីអត្ថប្រយោជន៍នៃការរៀបចំសំបក់វេចខ្ចប់លើផលិតផលមានលក្ខណៈស្តង់ដា និងការចុះបញ្ជីម៉ាកសញ្ញាបានត្រឹមត្រូវ។ បានធ្វើការផ្សព្វផ្សាយផលិតផល កសិផលសក្តានុពលក្នុងខេត្ត តាមរយៈការគៀរផលិតផល កសិផល ពីអាជីវករ ពាណិជ្ជករ ក្នុងខេត្តដាក់តាំងបង្ហាញក្នុងព្រឹត្តិការណ៍ពិព័រណ៍ថ្នាក់ជាតិ និងពិព័រណ៍ថ្នាក់អន្តរជាតិនានា។ រៀបចំសិក្ខាសាលា ផ្សព្វផ្សាយ និងផ្តល់ការប្រឹក្សាយោបល់ជូនពាណិជ្ជករ អាជីវករ សេវាករ ពាក់ព័ន្ធវិស័យពាណិជ្ជកម្ម។ ទន្ទឹមនឹងការខិតខំប្រឹងប្រែងយ៉ាងនេះក្តី យើងសង្កេតឃើញថា ការធ្វើអាជីវកម្ម ពាណិជ្ជកម្មរបស់អាជីវករ ពាណិជ្ជករ ក្នុងខេត្តនៅមិនទាន់មានការយល់ដឹងទូលំទំលាយនៅឡើយក្នុងវិស័យពាណិជ្ជកម្ម ដែលទាមទារឲ្យមន្ទីរត្រូវខិតខំប្រឹងប្រែងបន្ថែមទៀតក្នុងតួនាទីភារកិច្ចរបស់ខ្លួន។ ជាលទ្ធផលតាមសកម្មភាពការងារពាណិជ្ជកម្ម គិតត្រឹមខែមេសា ឆ្នាំ២០២៤ សម្រេចបានលទ្ធផលដូចខាងក្រោម៖

- **ការងារគ្រប់គ្រងអាជីវកម្ម**

+ បានទទួលទិន្នន័យចុះបញ្ជីក្រុមហ៊ុនពីក្រសួងពាណិជ្ជកម្មចំនួន ០២ ក្រុមហ៊ុន

+ បានទទួលឯកសារចុះបញ្ជីសហគ្រាសពីក្រសួងពាណិជ្ជកម្មចំនួន ១១ សហគ្រាស

+ ទទួលទិន្នន័យការចុះបញ្ជីម៉ាកចំនួន ០២ម៉ាក

+ បានទទួលឯកសារចុះបញ្ជីផ្លាស់ប្តូរទីស្នាក់ការក្រុមហ៊ុន ផ្លាស់ប្តូរនាមករណ៍ និងផ្លាស់ប្តូរនាយកសាខាក្រុមហ៊ុនចំនួន ០៣ច្បាប់

+ បានចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ ទម្រង់ ឌី (CO Form D) សម្រាប់នាំចេញកសិផលទៅក្រៅប្រទេសចំនួន **៥០**ច្បាប់ ទៅប្រទេសវៀតណាម ៖

-ក្រុមហ៊ុន ភាង លាងសេង អ៊ីមផត អិចផត ឯ.ក នាំចេញផ្លែស្វាយស្រស់ ចំនួន **២០ ច្បាប់** បរិមាណ **៣,០០០ តោន** តម្លៃសរុប **៣៦០,០០០ ដុល្លារ** ។

-ក្រុមហ៊ុន អេង ចេង អីមផត អ៊ិចផត ឯ.ក ចំនួន **២៥ ច្បាប់** រួមមាន៖ ផ្លែស្វាយស្រស់ ចំនួន **២៥ ច្បាប់** បរិមាណ **២,៥០០ តោន** តម្លៃសរុប **៧៥០,000 ដុល្លារ** និងគ្រាប់ឈូកស្ងួត ចំនួន **០៥ ច្បាប់** បរិមាណ **៣៥០ តោន** តម្លៃសរុប **២១០,000 ដុល្លារ** ។

+ បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយពាក់ព័ន្ធការងារពាណិជ្ជកម្មបានចំនួន ០១ លើក

➢ **ការងារគ្រប់គ្រងស្ថិតិអាជីវកម្ម**

+ ទូទាំងខេត្តមានផ្សារធំ និងមធ្យម លក់ទំនិញពេញមួយថ្ងៃចំនួន៣១កន្លែង និងផ្សារតូចលក់ទំនិញតែមួយព្រឹក ឬមួយល្ងាចចំនួន២០កន្លែង

+ មានមូលដ្ឋានអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម សរុបប្រមាណ ៥,៦០៦ទីតាំង ក្នុងនោះ ប្រភេទពាណិជ្ជកម្មមានចំនួន ៣,៦០៥ទីតាំង សេវាកម្មចំនួន ១,១៦៩ទីតាំង សិប្បកម្មនិងផលិតកម្ម ចំនួន ៤៦៦ទីតាំង និងស្ថានីយ៍ប្រេងឥន្ធនៈមានចំនួន ៣៦២ស្ថានីយ៍ និងដេប៉ូហ្គាសចំនួន ០៧ដេប៉ូ

+ មានមូលដ្ឋានអាជីវកម្ម លោហធាតុត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការ ចំនួន ៣០៩ទីតាំង

+ មានក្រុមហ៊ុនដែលបានចុះបញ្ជីពីក្រសួងពាណិជ្ជកម្មរួចបានចំនួន ១៨២ ក្រុមហ៊ុន

+ សាខាក្រុមហ៊ុនដែលបានចុះបញ្ជីរួចបានចំនួន ១៨២សាខាក្រុមហ៊ុន

+ សហគ្រាសដែលបានចុះបញ្ជីរួចបានចំនួន១៩៧សហគ្រាស

+ ស្រាវជ្រាវទីតាំងក្រុមហ៊ុន សហគ្រាស ដែលបានចុះបញ្ជីរួចនៅក្រសួងពាណិជ្ជកម្ម និងណែនាំឲ្យលើកស្លាកយីហោរបស់ក្រុមហ៊ុន សហគ្រាស ចំនួន០៥លើក

➢ **គ្រប់គ្រងទីផ្សារ**

+ ចុះផ្សព្វផ្សាយសេចក្តីជូនដំណឹងស្តីពីតម្លៃលក់រាយប្រេងឥន្ធនៈរបស់ក្រសួងបានចំនួន ២២ លើក ស្មើ ៤៦៧ស្ថានីយ៍

+ ចុះផ្សព្វផ្សាយប្រកាសលេខ ២១៦ ព.ណ អវង.ប្រក ស្តីពី ការបិទស្លាកថ្លៃលើមុខទំនិញ និងសេវាកម្មគ្រប់ប្រភេទ នៅស្រុកកំពង់ត្របែក និងស្រុកពាមរក៍ ចំនួន ០២លើក

+ បានចុះស្រាវជ្រាវទិន្នន័យឈ្មួញប្រមូលទិញស្វាយ និងស្ថានភាពទីផ្សារ បានចំនួន ០១លើក

+ ចុះស្រង់តម្លៃទំនិញសម្រាប់ជីវភាពប្រចាំថ្ងៃ ១១៩មុខ និងបានរាយការណ៍ជូនថ្នាក់ដឹកនាំក្រសួង ប្រចាំថ្ងៃបានចំនួន ១២០លើក

+ ចុះស្រង់តម្លៃទំនិញសម្រាប់ជីវភាពប្រចាំថ្ងៃ៧១មុខនិងបានរាយការណ៍ជូនថ្នាក់ដឹកនាំក្រសួង ប្រចាំខែ បានចំនួន ០៤លើក

+ ចុះស្រង់តម្លៃទំនិញសម្រាប់ជីវភាពប្រចាំថ្ងៃ៣៩មុខនិងបានរាយការណ៍ជូនថ្នាក់ដឹកនាំក្រសួង រៀងរាល់ថ្ងៃធ្វើការ បានចំនួន ៨៤លើក

+ ចុះស្រង់តម្លៃទំនិញសម្រាប់ជីវភាពប្រចាំថ្ងៃ៣៨មុខនិងបានរាយការណ៍ជូនថ្នាក់ដឹកនាំក្រសួង រៀងរាល់ថ្ងៃ បានចំនួន ១២០លើក

+ ចុះស្រង់ស្ថានភាពបរិមាណការនាំចេញនាំចូលកសិផល និងស្ថានភាពតាមច្រកព្រំដែនវៀតណាម បានចំនួន ៦៣លើក ស្មើចំនួន ៧៤៤,៣០០តោន

+ ចុះស្រង់បរិមាណស្តុកផលិតផល ក្នុងស្រុកចាំបាច់សម្រាប់ជីវភាពប្រចាំថ្ងៃ បានចំនួន២៧លើក

+ បានសហការជាមួយការិយាល័យគ្រប់គ្រងអាជីវកម្ម និងសាខាការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ ខេត្តព្រៃវែង (ក ប ប) ចុះឃ្លាំពិនិត្យទំនិញ បានចំនួន ០៤លើក

- **ការងារអភិវឌ្ឍន៍ពាណិជ្ជកម្ម**

+ ចុះស្រាវជ្រាវទិន្នន័យបង្កបង្កើនផលស្រូវបានចំនួន ០៤ លើក

+ ចូលរួមតាំងពិព័រណ៍ពាណិជ្ជកម្ម បានចំនួន០៥លើក

+ ផ្តល់ព័ត៌មានទីផ្សារដល់ពាណិជ្ជករ អាជីវករ សេវាករ បានចំនួន ០១លើក

- **ការងារចលនាភូមិមួយ ផលិតផលមួយ**

+ ចូលរួមសហការ និងរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី« ការលើកកម្ពស់ផលិតផលខ្មែរ» នៅមន្ទីរពាណិជ្ជកម្មខេត្តព្រៃវែង។ នៅថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០២៤ ដែលមានអ្នកចូលរួមសរុបចំនួន ១៣៥នាក់

+ ចុះពិនិត្យ និងបំពេញពាក្យស្នើសុំចុះបញ្ជីផលិតផលភូមិមួយផលិតផលមួយខេត្ត ផលិតផលមើមឈូក នៅកសិដ្ឋានមើមឈូក ខេ ធី នៅស្រុកកំចាយមារ សម្រាប់ចុះបញ្ជីឆ្នាំ២០២៣ បានចំនួន០១លើក

+ ចូលរួមកិច្ចប្រជុំរបស់លេខាធិការដ្ឋានជំរុញចលនាភូមិមួយផលិតផលមួយខេត្តព្រៃវែង ដើម្បីប្រមូលធាតុចូល និងជ្រើសរើសផលិតផលសម្រាប់ចុះបញ្ជីផលិតផលឆ្នាំ២០២៣ នៅសាលាខេត្តព្រៃវែង បានចំនួន ០១លើក ។

- **ការងារសហការជាមួយសភាពាណិជ្ជកម្មខេត្តព្រៃវែង**

+ សហការរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារសភាពាណិជ្ជកម្មខេត្តព្រៃវែង ឆ្នាំ២០២៣ និងទិសដៅការងារឆ្នាំ២០២៤ និងពិធីចែកប្រកាសទទួលស្គាល់សមាសភាពការិយាល័យប្រតិបត្តិសភាពាណិជ្ជកម្មខេត្តព្រៃវែង អាណត្តិទី២ លើកទី២ នៅថ្ងៃទី២០ ខែមករា ឆ្នាំ២០២៤ នៅស្នាក់ការសភាពាណិជ្ជកម្មខេត្តព្រៃវែង។

+ សហការជាមួយសភាពាណិជ្ជកម្មខេត្តព្រៃវែង និងរដ្ឋបាលខេត្តព្រៃវែង ទទួលឯកអគ្គរាជទូតឥណ្ឌូណេស៊ីប្រចាំព្រះរាជាណាចក្រកម្ពុជាដើម្បីពិភាក្សាការងារកិច្ចសហប្រតិបត្តិការធុរកិច្ច និងវិនិយោគក្នុងខេត្តព្រៃវែង និងដំណើរទស្សនកិច្ចរោងម៉ាស៊ីនកិនស្រូវ ចំការអំពៅ មណ្ឌលវារីវប្បកម្មទឹកសាប នៅថ្ងៃទី ០៦-០៨ ខែ មីនា ឆ្នាំ២០២៤។

- **ការងារគម្រោងជំរុញទីផ្សារកសិកម្មខ្នាតតូច(AIMS) ៖**

+ ប្រជុំវេទិកាពហុភាគីអ្នកពាក់ព័ន្ធលើផលិតផលបន្លែ មាន់ស្រែ និងស្រូវ បានចំនួន ២៤លើក

+ ប្រជុំក្រុមផលិតរៀបចំផែនការផលិត និងការរៀបចំគណកម្មការគ្រប់គ្រង SDF លើផលិតផលបន្លែ មាន់ស្រែ និងស្រូវ បានចំនួន ១៣លើក

+ រៀបចំសំណើ SDF ( ស្នើសុំកន្លែងលាងសំអាត និងវេចខ្ចប់០១សំណើ កន្លែងប្រមូលផ្តុំផលិតផលចម្រុះ ០១សំណើ និងអណ្តូងសូឡា ០១សំណើ ) និងចំនួន០៣ទីតាំងទៀតបានសាងសង់រួចរាល់

+ សម្របសម្រួលកិច្ចសន្យាទិញលក់រវាងអ្នកផលិត និងឈ្មួញ បានចំនួន ៨១កិច្ចសន្យា

+ រៀបចំសំណើមូលនិធិនវានុវត្តខ្សែច្រវ៉ាក់តម្លៃច្រកទី១លើកញ្ចប់បច្ចេកទេសចិញ្ចឹមមាន់ស្រែ

ដោយក្រុមហ៊ុនGIC បានចំនួន ៥៤ទ្រុង

+ សហការជាមួយធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម ផ្តល់ឥណទានជូនកសិកម្មខ្នាតតូចលើអ្នកពាក់ព័ន្ធក្នុងគម្រោងអេមស៍ បានចំនួន ០៣គ្រួសារ។

សេដ្ឋកិច្ចរបស់ខេត្តព្រៃវែងជាសំខាន់គឺ កសិកម្មស្រូវ ក្នុងឆ្នាំ២០២៤នេះ ការងារបង្កបង្កើនផលមិនសូវមានភាពល្អប្រសើរដោយសារភ្លៀងធ្លាក់តិចតួច សម្រាប់តម្លៃស្រូវក្នុងឆ្នាំ២០២៤ គឺមានតម្លៃខ្ពស់ជាងឆ្នាំ២០២៣បន្តិច ដោយស្រូវអ៊ីអ៊ែរសើម(OM504) តម្លៃចន្លោះពី ១,២០០រៀល ទៅ ១,២២០រៀលក្នុង១គីឡូក្រាម ស្រូវអ៊ីអ៊ែរសើម(OM5451) តម្លៃចន្លោះពី ១,១៨០រៀល ទៅ ១,២០០រៀលក្នុង១គីឡូក្រាម។ ក្នុងខេត្តមានរោងម៉ាស៊ីនកិនស្រូវធំៗមានចំនួន ១៤កន្លែង ទន្ទឹមនេះដែរមានរោងម៉ាស៊ីនកិនស្រូវចំនួន ០៦កន្លែង បាននឹងកំពុងផលិតអង្ករប្រភេទស្តង់ដារដើម្បីនាំចេញទៅទីផ្សារអន្តរជាតិសម្រាប់ការផ្គត់ផ្គង់ក្នុងត្រីមាសទី២។

- **បញ្ហាប្រឈម**

+ ការផ្សព្វផ្សាយ ការទទួលព័ត៌មានស្តីពីការធ្វើអាជីវកម្ម និងការទទួលសេវាមិនទាន់បានដល់អាជីវករក្នុងមូលដ្ឋានគ្រប់ៗគ្នា

+ អាជីវករគិតថាការស្នើសុំលិខិតអនុញ្ញាតមិនសូវមានសារៈសំខាន់ដល់ពួកគាត់ ដែលការផ្តល់សេវា ការចេញលិខិតអនុញ្ញាតប្រកបអាជីវកម្មនៅតាមក្រុង/ស្រុកមានចំនួនតិច

+ ការគ្រប់គ្រងស្ថិតិក្រុមហ៊ុន សាខាក្រុមហ៊ុន និងសហគ្រាសនៅមានកម្រិត ដោយសារមិនអាចរកទីតាំងឃើញក្រោយពេលចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងរួច ព្រោះមិនមានការលើកស្លាកយីហោ រឺមិនបានដំណើរការអាជីវកម្ម ហើយក្រុមហ៊ុនខ្លះមានអភិបាលជាជនជាតិបរទេស ដែលធ្វើឲ្យអាជ្ញាធរមូលដ្ឋានមិនអាចស្គាល់ រឺក្តាប់ព័ត៌មានបានដិតដល់

+ ក្តាប់ព័ត៌មានទីផ្សារមិនបានគ្រប់ជ្រុងជ្រោយ

+ ការអនុវត្តកិច្ចសន្យានៅតាមក្រុមផលិតនៅមានកម្រិត

+ ខ្វះបុគ្គលិកនៅមូលដ្ឋានបើធៀបនឹងផែនការសកម្មភាព

- **ដំណោះស្រាយ**

+ជំរុញការផ្សព្វផ្សាយ និងជូនព័ត៌មានស្តីពីការធ្វើអាជីវកម្ម និងការផ្តល់សេវាវិស័យពាណិជ្ជកម្មបន្ថែមទៀតនៅតាមបណ្តាក្រុង ស្រុក

+សហការជាមួយរដ្ឋបាលស្រុក/ក្រុងឲ្យកាន់តែខ្លាំងក្នុងការជំរុញការផ្តល់សេវាសាធារណៈ វិស័យពាណិជ្ជកម្មឲ្យមានប្រសិទ្ធិភាព

+ បទបែនទៅតាមស្ថានភាពជាក់ស្តែង ដើម្បីអនុវត្តន៍ការងារឱ្យមានប្រសិទ្ធភាព

+ ពង្រឹងក្រុមផលិតឲ្យមានភាពទទួលខុសត្រូវ និងស្របតាមកិច្ចសន្យាទិញ-លក់

+ ស្នើសុំឲ្យមានការជ្រើសរើសបុគ្គលិកនៅតាមមូលដ្ឋាន ដើម្បីអាចគ្រប់គ្រង និងតាមដាននៅតាមក្រុមផលិតនីមួយៗ

+ ចូលរួមវគ្គបណ្តុះបណ្តាល និងចូលរួមក្នុងកម្មវិធីប្រជុំនានា ដើម្បីពង្រឹងសមត្ថភាព ។

### ១.២.១.៦. វិស័យឧស្សាហកម្មវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ខេត្តព្រៃវែង ជាសេនាធិការឲ្យក្រសួងមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ខេត្តព្រៃវែង និងរដ្ឋបាលខេត្តព្រៃវែង មានអាសយដ្ឋាននៅភូមិលេខ៣ សង្កាត់កំពង់លាវ ក្រុងព្រៃវែង ខាងជើងរតនាគារខេត្តព្រៃវែង។ មន្ទីរអនុវត្តការគាំទ្រអភិវឌ្ឍវិស័យឧស្សាហកម្ម សហគ្រាសធុនតូច និងមធ្យម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍រួមបញ្ចូលទាំងវិស័យសិប្បកម្ម និងទឹកស្អាត ក្នុងខេត្តព្រៃវែង។

**ក-ការគ្រប់គ្រងវិស័យឧស្សាហកម្ម និងសិប្បកម្ម**

ក្នុងឆ្នាំ២០២៤ មូលដ្ឋានឧស្សាហកម្មតូច មធ្យម និងសិប្បកម្ម កំពុងដំណើរការមានច្បាប់ចំនួន ៤៥៤ មូលដ្ឋាន ក្នុងនោះមាន៖

- មូលដ្ឋានសហគ្រាសធុនតូច និងមធ្យម ដែលបានសុំប្រកាស និងអនុញ្ញាតដំណើរការពីក្រសួងមាន ៣៥ មូលដ្ឋាន និងមន្ទីមាន ៨៣ មូលដ្ឋាន សរុបចំនួន ១១៨ មូលដ្ឋាន។
- មូលដ្ឋានសិប្បកម្ម កំពុងអនុញ្ញាតដំណើរការមានច្បាប់ពីក្រសួងមាន ១៤ មូលដ្ឋាន និងមន្ទីរមាន ៣២៨ មូលដ្ឋាន សរុបចំនួន ៣៤២ មូលដ្ឋាន។

**ខ-ការគ្រប់គ្រងវិស័យទឹកស្អាត**

- អាជីវកម្មផ្គត់ផ្គង់ទឹកស្អាតឯកជនក្នុងខេត្តព្រៃវែងមានចំនួន ៣៨ មូលដ្ឋាន ស្មើនឹង ៩៣ឃុំ មាន ៨៣១ភូមិ មានទឹកប្រើប្រាស់ចំនួន ៦៧ឃុំ ៤៨២ភូមិ ស្មើនឹង ៤៥,៥៧៣គ្រួសារ ហើយបានដាក់បណ្ដាញមេបានចំនួន ២,៣១៨ គីឡូម៉ែត្រ ហើយបរិមាណទឹកដែលផលិតបានចំនួន ៥,៦៥៤,៨៧០ម$^{៣}$។

**គ-បញ្ហាប្រឈម និងដំណោះស្រាយ (គ្មាន)**

### ១.២.១.៧. វិស័យរ៉ែ និងថាមពល

មន្ទីររ៉ែ និងថាមពលខេត្តព្រៃវែង ជាសេនាធិការឲ្យក្រសួងរ៉ែ និងថាមពល និងរដ្ឋបាលខេត្តព្រៃវែង មានអាសយដ្ឋាននៅភូមិលេខ៣ សង្កាត់កំពង់លាវ ក្រុងព្រៃវែង ខាងត្បូងផ្សារក្រុងព្រៃវែង។ មន្ទីរនេះគ្រប់គ្រងលើវិស័យធនធានរ៉ែ ថាមពល ប្រេងកាត និងឧស្ម័ន ក្នុងខេត្តព្រៃវែង។ ក្នុងការអនុវត្តការងាររបស់ខ្លួនក្នុងឆ្នាំ២០២៣ មន្ទីរសម្រេចនូវលទ្ធផលដូចតទៅ៖

**ក.ចំណុចខ្លាំង និងលទ្ធផលការងារ**

មន្ទីរបានចាត់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការចូលរួមកិច្ចប្រជុំនានានៅក្រសួង រដ្ឋបាលខេត្ត និងមន្ទីរ-អង្គភាព ជុំវិញខេត្តចំនួន៦៧លើក, វេទិកា ពិធីសំណេះសំណាល កម្មវិធីសង្គម សាសនា និងមនុស្សធម៌ចំនួន៤០លើក, វេទិការសាធាណៈ និងវេទិការពិគ្រោះយោបល់នានាចំនួន១៧លើក, សម្ពោធសមិទ្ធផល និងបើកការដ្ឋានគម្រោងអភិវឌ្ឍន៍ចំនួន០៧លើក, សហប្រតិបត្តិការជាមួយសាធារណៈរដ្ឋសង្គមនិយមវៀតណាមចំនួន០២លើក, និងចូលរួមវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាផ្សេងៗចំនួន ១៨លើក មានមន្ត្រីចូលរួម ៧០រូប។

**ក.១-ការគ្រប់គ្រងវិស័យធនធានរ៉ែ**

វិស័យធនធានរ៉ែ ជាប្រភពចំណូលដ៏សំខាន់ក្នុងការចូលរួមចំណែកអភិវឌ្ឍន៍។ អាជ្ញាបណ្ណធនធានរ៉ែ ដែលចេញដោយក្រសួងមានសរុប ១៥អាជ្ញាបណ្ណ គឺ៖ ថ្មសំណង់មាន ០៥អាជ្ញាបណ្ណ បូមខ្សាច់

សំណង់ និងដីល្បាយខ្សាច់មានចំនួន ០៩អាជ្ញាបណ្ណ។ ជាមួយគ្នានេះ លិខិតអនុញ្ញាតបូមខ្សាច់គាំទ្រប្រតិបត្តិការបោសសម្អាតយុទ្ធភណ្ឌមិនទាន់ផ្ទុះ ០១លិខិតអនុញ្ញាត។ ស្ថិតិអាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែដែលចេញដោយរដ្ឋបាលខេត្តមានចំនួន០៤ អាជ្ញាបណ្ណ (អាជីវកម្មជីកខ្សាច់ភ្នំ) អាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែសម្រាប់អាជីវកម្មវាយថ្មសំណង់ដោយដៃ ចេញដោយមន្ទីររ៉ែ និងថាមពលខេត្តព្រៃវែង មានចំនួន ០១អាជ្ញាបណ្ណ និងអាជ្ញាបណ្ណចេញដោយរដ្ឋបាលក្រុង-ស្រុកមានចំនួន ២៦អាជ្ញាបណ្ណ។

**ក.២-ការគ្រប់គ្រងវិស័យថាមពល**

ខេត្តព្រៃវែង មានអគ្គិសនីប្រើប្រាស់ ២៤ម៉ោង លើ២៤ម៉ោង។ មានអនុស្ថានីយចំនួន០២កន្លែង គឺអនុស្ថានីយស្វាយអន្ទរ និងអនុស្ថានីយកំពង់សឹង។ ផ្ទះប្រជាពលរដ្ឋមានអគ្គិសនីប្រើប្រាស់មានចំនួន ២៣៩,៥៥៤ខ្នង ស្មើនឹង ៩៣.០៤% នៃផ្ទះសរុប។

**ក.៣-ការគ្រប់គ្រងវិស័យប្រេងកាត និងឧស្ម័ន**

ស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័ន និងស្ថានីយរួមមានចំនួន ៣៦៥ស្ថានីយ។ ក្នុងឆ្នាំ២០២៣ ស្ថានីយដែលបានដាក់ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពស្ថានីយ និងបន្តសុពលភាពស្ថានីយមានចំនួន ៥៥ស្ថានីយ (បន្តសុពលភាព ២៣ស្ថានីយ)។ សរុបស្ថានីយដែលបានដាក់ពាក្យស្នើសុំលិខិតបញ្ជាក់បច្ចេកទេសសុវត្ថិភាព និងលិខិតអនុញ្ញាតដំណើរការស្ថានីយមានចំនួន ៣០៤ស្ថានីយ ស្មើនឹង ៨៣.២៨%។

**ខ-ចំណុចខ្សោយ/បញ្ហាប្រឈម**

- មិនមានមន្ត្រីរាជការក្របខណ្ឌ ឬមន្ត្រីជាប់កិច្ចសន្យាគ្រប់គ្រាន់ដើម្បីបំពេញការងារ
- ស្ថានីយប្រេងឥន្ធនៈមួយចំនួនមិនមានសុវត្ថិភាព ដែលបានសាងសង់ខុសពីស្តង់ដារសុវត្ថិភាព នៃការបង្កើតស្ថានីយ ដែលអាចធ្វើឲ្យមានហានិភ័យនៅថ្ងៃខាងមុខ
- មានតម្រូវការបណ្តុះបណ្តាលជំនាញបន្ថែមដល់មន្ត្រី ដើម្បីគ្រប់គ្រងវិស័យមន្ទីរឲ្យកាន់តែមានប្រសិទ្ធភាព

**គ-បញ្ហាអាទិភាពដែលត្រូវដោះស្រាយ**

- ស្នើសុំឲ្យមានការជ្រើសរើសមន្ត្រីក្របខណ្ឌបន្ថែម ឬបន្ថែមចំនួនមន្ត្រីជាប់កិច្ចសន្យា
- អនុវត្តវិធានការច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត និងបទដ្ឋានពាក់ព័ន្ធដល់អាជីវករ និងអាជ្ញាធរមូលដ្ឋាន ព្រមទាំងចាត់វិធានការ។
- ផ្តល់ឱកាសដល់មន្ត្រីជំនាញចូលរួមវគ្គបណ្តុះបណ្តាលបច្ចេកទេសថ្មីៗពាក់ព័ន្ធនឹងវិស័យជំនាញ

## ១.២.១.៨. វិស័យទេសចរណ៍

ខេត្តព្រៃវែង ជាខេត្តដែលពុំមានសក្តានុពលទាក់ទាញផ្នែកវិស័យទេសចរណ៍ខ្លាំងទេ ដូចតំបន់អាទិភាពទាំង៤ ក្នុងព្រះរាជាណាចក្រកម្ពុជានៅឡើយ ។

តំបន់ទេសចរណ៍ដែលខេត្តមាន ត្រូវបានធ្វើការអភិវឌ្ឍន៍ជាបន្តបន្ទាប់ និងធ្វើការសិក្សាស្រាវជ្រាវរក

តំបន់ដែលមានសក្តានុពលទេសចរណ៍ថ្មីៗបន្ថែមទៀត។ បច្ចុប្បន្ននេះដោយមានការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋបាលខេត្តផ្ទាល់ បានកំពុងធ្វើការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ បំរើអោយវិស័យដឹកជញ្ជូនផង និងទេសចរណ៍យ៉ាងសកម្មបំផុត ជាពិសេសការសាងសង់ស្ពានឆ្លងកាត់ទន្លេមេគង្គអ្នកលឿង ការកសាងផ្លូវជាតិថ្មីលេខ៨ និងផ្លូវខេត្តមួយចំនួនទៀត គឺជាសមិទ្ធផលយ៉ាងធំធេងសំរាប់ខេត្តព្រៃវែង។ ដើម្បីសំរួលដល់ការធ្វើដំណើរឆ្លងកាត់របស់ភ្ញៀវជាតិ-អន្តរជាតិ និងប្រជាជនទូទៅ ទាំងយប់ទាំងថ្ងៃបានល្អប្រសើរ។ ជាមួយគ្នានេះ ការខិតខំរបស់រដ្ឋបាលខេត្តក្រុងក្នុងការរៀបចំអភិវឌ្ឍន៍ និងតំបន់ជុំវិញក្រុង ការរៀបចំសួនច្បារ រៀបចំការីឡាចិញ្ចើមថ្នល់ ការកែរលំអរសោភ័ណភាពតាមដងផ្លូវក្នុងក្រុង ការរៀបចំរូបសំណាក និងបំផុសចលនាសំអាតទីក្រុងបានរំលេចចេញជាស្នាដៃដ៏ប្រសើររបស់ខេត្តផ្ទាល់ ដែលជាការទាក់ទាញអោយប្រជាពលរដ្ឋក្នុងខេត្តមកលេងកម្សាន្ត និងភ្ញៀវទេសចរណ៍ទីជិតទីឆ្ងាយឈប់សំចតស្នាក់អាស្រ័យនៅផងដែរ។

ក្នុងឆ្នាំ២០២៣ មានភ្ញៀវទេសចរដើរកម្សាន្ត និងស្នាក់នៅក្នុងខេត្តព្រៃវែងមានចំនួនសរុប ៥៤៨,៧៦០ នាក់ ក្នុងនោះភ្ញៀវជាតិមានចំនួន ៥៤៨,៥២៣ នាក់ និងភ្ញៀវអន្តរជាតិមានចំនួន ១៧៧នាក់។

**ខេត្តមានរមណីយដ្ឋាន សហគមន៍ គោលដៅទេសចរណ៍ និងវត្តគំរូ ចំនួន ១១កន្លែង ក្នុងនោះ ÷**

**១.ផ្នែករមណីយដ្ឋានមានចំនួន ០៤ កន្លែង**

1. រមណីយដ្ឋាននគរភ្នំ ស្ថិតនៅក្នុងភូមិ រោងដំរី ឃុំជើងភ្នំ ស្រុកបាភ្នំ
2. រមណីយដ្ឋានបារាយណ៍អណ្តែតស្ថិតនៅភូមិបារាយណ៍លិច សង្កាត់បារាយណ៍ ក្រុងព្រៃវែង
3. រមណីយដ្ឋានប្រាសាទព្រៃដើមស្រុក ស្ថិតនៅភូមិបឹងជ័រ ឃុំព្រៃទឹង ស្រុកស៊ីធរកណ្តាល
4. រមណីយដ្ឋានទេសចរណ៍ធម្មជាតិ សួនសត្វតាដាបាយ៉ាប ស្ថិតនៅភូមិបាយ៉ាប ឃុំស៊ាងឃ្វាង ស្រុកកំចាយមារ

**២.ផ្នែកសហគមន៍ទេសចរណ៍មានចំនួន ០១ កន្លែង**

1. សហគមន៍អភិរក្សសត្វស្លាបទួលព័ន្ធតាឡី (បឹងស្នេហ៍) ស្ថិតនៅភូមិទ័ពស្តេច ឃុំបាយ ស្រុកបាភ្នំ។

**៣.ផ្នែកគោលដៅទេសចរណ៍មានចំនួន ០៣ កន្លែង**

1. គោលដៅទេសចរណ៍ដីដុះ នៅភូមិសាមគ្គី ឃុំស្វាយភ្លោះ ស្រុកពាមជរ
2. គោលដៅទេសចរណ៍ស្ទឹងចារ នៅភូមិត្រពាំងរមាស ឃុំជាច ស្រុកកំចាយមារ
3. ទីលំហែរកម្សាន្តចុងប៉ម ស្ថិតនៅភូមិលេខ១ សង្កាត់កំពង់លាវ ក្រុងព្រៃវែង។

**៤.ផ្នែកវត្តទេសចរណ៍គំរូមានចំនួន ០៣ កន្លែង**

1. វត្តកំពូលឈើកាច់ ស្ថិតនៅ ភូមិឈើកាច់ ឃុំឈើកាច់ ស្រុកបាភ្នំ
2. វត្តសូរិយាវង្ស (ព្រៃវៀរ) ស្ថិតនៅភូមិញ្ចៅ ឃុំជ្រៃ ស្រុកកំបង់ត្របែក
3. វត្តសិរីសាគរ (ដូនស្តើង) ស្ថិតនៅភូមិស្នាយព្រីង ឃុំសេនារាជឧត្តម ស្រុកព្រះស្តេច។

ក្នុងរមណីយដ្ឋានទេសចរណ៍ទាំង០៨កន្លែង គឺកំពុងដំណើរការ មានភ្ញៀវទៅទស្សនាកំសាន្តគឺៈ

- តំបន់ទេសចរណ៍វប្បធម៌ប្រវត្តិសាស្រ្ត និងធម្មជាតិ១កន្លែង គឺរមណីយដ្ឋាននគភ្នំ នៅក្នុងភូមិរោងដំរី

ឃុំជើងភ្នំ ស្រុកបាភ្នំ។ រមណីយដ្ឋាននេះបានទាក់ទាញភ្ញៀវទាំងក្នុងខេត្ត និងក្រៅខេត្ត មកលេងកំសាន្ត កាន់តែមានកំណើនជារៀងរាល់ឆ្នាំ បច្ចុប្បន្ននេះកំពុងតែមានការអភិវឌ្ឍន៍ចំនួន ២គោលដៅទៀត គឺនៅលើភ្នំតូច (ឬភ្នំព្រះដំណាក់) និងភ្នំសំពៅ។ តំបន់នេះគឺជាទីតាំងដែលក្នុងប្រវត្តិសាស្ត្របានបញ្ជាក់ជារាជធានីទីពីររបស់អាណាចក្រខ្មែរមានឈ្មោះថា៖ វ្យាធបុរៈ មានន័យថា (ទីក្រុងប្រមាញ់) តាំងពីសតវត្សទី២ នាសម័យហ្វូណន។

-ទួលបារាយណ៍អណ្ដែត រមណីយដ្ឋានវប្បធម៌ និងធម្មជាតិ ស្ថិតនៅសង្កាត់បារាយណ៍ ក្រុងព្រៃវែងមានភ្ញៀវមកកំសាន្តជារៀងរាល់ថ្ងៃ មានចម្ងាយ ២គីឡូម៉ែត្រពីក្រុងព្រៃវែង។

-ទួលប្រាសាទព្រៃដើមស្រុកជារមណីយដ្ឋានវប្បធម៌ ប្រវត្តិសាស្ត្រ និងធម្មជាតិ ស្ថិតនៅស្រុកស៊ីធរកណ្ដាលដែលសព្វថ្ងៃកំពុងអភិរក្ស និងអភិវឌ្ឍន៍ដោយមន្ទីរវប្បធម៌ខេត្ត។

-រមណីយដ្ឋានធម្មជាតិសួនសត្វតាជាបាយ៉ាបស្ថិតនៅភូមិបាយ៉ាបឃុំស៊ាងឃ្វាង ស្រុកកំចាយមារ។

-សហគមន៍អភិរក្សសត្វស្លាបទួលព័ន្ធតាឡី (បឹងស្នេហ៍) ជារមណីយដ្ឋានធម្មជាតិ ស្ថិតនៅភូមិទ័ពស្ដេច ឃុំជាយ ស្រុកបាភ្នំ។

-គោលដៅទេសចរណ៍ដីដុះ នៅភូមិសាមគ្គី ឃុំស្វាយឆ្លោះ ស្រុកពាមជរ។

-គោលដៅទេសចរណ៍ស្ទឹងចារ នៅភូមិត្រពាំងរមាស ឃុំជាច ស្រុកកំចាយមារ។

-ទីលំហែរកំសាន្តចុងប៉មដែលមានតាំងពីសម័យអាណានិគមនិយមបារាំង ដែលស្ថិតនៅជិតមុខសាលាខេត្តក្នុងក្រុងព្រៃវែង។

- **ផ្នែកសេវាកម្មទេសចរណ៍នៅក្នុងខេត្តមាន៖**

| | | |
|---|---|---|
| - សណ្ឋាគារ | មានចំនួន | ០៤ កន្លែង |
| - ផ្ទះសំណាក់ | មានចំនួន | ៩០ កន្លែង |
| - បឹងហ្គាឡូត៍ | មានចំនួន | ០១ កន្លែង |
| - ផ្ទះជួល | មានចំនួន | ២៦ កន្លែង |
| - ភោជនីយដ្ឋាន | មានចំនួន | ០៣ កន្លែង |
| - អាហារដ្ឋាន | មានចំនួន | ១០១ កន្លែង |
| - គុយទាយកាហ្វេ | មានចំនួន | ៤៤ កន្លែង |
| - ខារ៉ាអូខេ | មានចំនួន | ៦៤ កន្លែង |
| - ម៉ាស្សា | មានចំនួន | ៣០ កន្លែង |
| - ស្នូកឃ័រ | មានចំនួន | ០១ កន្លែង |
| - កីឡាទេសចរណ៍ | មានចំនួន | ០១ កន្លែង |

- **ចំណុចខ្លាំង**

-ក្រសួងមានផែនការយុទ្ធសាស្ត្រជាតិអភិវឌ្ឍន៍ទេសចរណ៍ឆ្នាំ២០២៣-២០៣៥

-ក្រសួងមានគោលនយោបាយលើកស្ទួយសិស័យឯកជន

-ក្រសួងមានបទដ្ឋានស្តង់ដាអប្បបរមា (SOP) សណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន អាហារដ្ឋាន

និងរមណីយដ្ឋាន

-ថ្នាក់ដឹកនាំ និងមន្ត្រីមន្ទីរ បានខិតខំយកចិត្តទុកដាក់អនុវត្តន៍តួនាទី ភារកិច្ចរបស់ខ្លួន ទៅតាមការណែនាំរបស់លិខិតបទដ្ឋានគតិយុត្តនានាអោយបានល្អ ព្រមទាំងកំពុងបណ្តុះបណ្តាលធនធានមនុស្សលើគ្រប់ផ្នែកគ្រប់ជំនាញ និងលើកកម្ពស់សមត្ថភាពមន្ត្រីរាជការក្រោមឱវាទ ខិតខំយកចិត្តទុកដាក់រាល់ការងារអោយបានល្អប្រសើរ។

-បានផ្សព្វផ្សាយគ្រប់ លិខិតបទដ្ឋានគតិយុទ្ធ សាចរណ៍ណែនាំ ព្រមទាំងសេចក្តីជូនដំណឹងរបស់ក្រសួងទៅគ្រប់មូលដ្ឋានអាជីវកម្ម និងសេវាកម្មទេសចរណ៍ ។

-បានផ្សព្វផ្សាយ និងជំរុញដល់មូលដ្ឋានអាជីវកម្ម និងសេវាកម្មទេសចរណ៍ ដើម្បីបន្តពង្រឹងការអនុវត្តវិធានសុវត្ថិភាពទេសចរណ៍ ក្នុងការចុះបញ្ជីឈ្មោះភ្ញៀវទេសចរណ៍ តាមប្រព័ន្ធតេឡេក្រាម (Telegram BOT)

-បានអប់រំនិងណែនាំ អំពីការរៀបចំសណ្តាប់ធ្នាប់អនាម័យ និងការគ្រប់គ្រងកាកសំណល់ នៅតាមរមណីយដ្ឋាន សហគមន៍ និងគោលដៅទេសចរណ៍។

-ចូលរួមសហការណ៍ជាមួយរដ្ឋបាលខេត្តក្រុង-ស្រុក ដើម្បីគាំទ្រដល់ការធ្វើយុទ្ធនាការផ្សព្វផ្សាយ "**កម្ពុជាព្រះរាជាណាចក្រអច្ឆរិយៈ**" **និង** "**ចលនាប្រឡងប្រណាំង ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ និង បដិសណ្ឋារកិច្ចល្អ** "ជំរុញដល់ការគ្រប់គ្រងកាកសំណល់តាមដងផ្លូវ ទីប្រជុំជន និងតំបន់គោលដៅទេសចរណ៍ ដែលត្រូវតែមានភាពស្រស់ស្អាត ភាពបៃតង ដោយធ្វើការរៀបចំអោយមានរបៀបរៀបរយ និងប្រកបដោយការទទួលខុសត្រូវខ្ពស់។

- **ចំណុចខ្សោយ**

-រាល់ការផ្សព្វផ្សាយនូវលិខិតបទដ្ឋានគតិយុទ្ធ សាចរណ៍ណែនាំ ព្រមទាំងសេចក្តីជូនដំណឹងរបស់ក្រសួងទៅគ្រប់មូលដ្ឋានអាជីវកម្ម និងសេវាកម្មទេសចរណ៍នៅមានកម្រិត។

-ខ្វះមធ្យោបាយធ្វើដំណើរដល់មន្ត្រីមន្ទីរសម្រាប់បំពេញការងារតាមស្រុក

-តំបន់រមណីយដ្ឋានក្នុងខេត្តព្រៃវែងយើង មិនទទួលការចាប់អារម្មណ៍ពីទេសចរណ៍ពីសំណាកភ្ញៀវជាតិ និងអន្តជាតិឡើយ ដោយសារមិនមានអ្វី ហើយក៏មិនបានទទួលការវិនិយោគពីវិស័យឯកជនដែរ។

-ពុំមានថវិកាសម្រាប់សាងសង់អគារព័ត៌មានទេសចរណ៍ និងបង្គន់អនាម័យ នៅតាមរមណីយដ្ឋានគោលដៅ សម្រាប់បម្រើភ្ញៀវទេសចរណ៍មកលេងកំសាន្តនៅឡើយ។

- **បញ្ហាប្រឈម**

-រាល់ផែនការវិនិយោគរបស់មន្ទីរជារៀងរាល់ឆ្នាំ ពុំទាន់មានថវិកាគាំទ្រឡើយ ។

-មូលដ្ឋានអាជីវកម្មមួយចំនួនមានការយឺតយ៉ាវក្នុងការបន្តអាជ្ញាប័ណ្ណ ។

-នារីបំរើការងារតាមមូលដ្ឋានអាជីវកម្ម និងសេវាកម្មខ្លះ ពុំបានឆ្លងវគ្គបណ្តុះបណ្តាលផ្នែកបដិសណ្ឋារកិច្ច ដោយសារមានការផ្លាស់ប្តូររហូត។

-ម្ចាស់មូលដ្ឋានអាជីវកម្មមួយចំនួន នៅតែពុំសូវយកចិត្តទុកដាក់លើការគ្រប់គ្រងកាកសំណល់សំរាម សំណល់រឹង និងសំណល់រាវ អោយបានត្រឹមត្រូវនៅឡើយ។

-ម្ចាស់អាជីវកម្មមួយចំនួន មិនសូវសហការមកទទួលកាផ្សព្វផ្សាយនូវលិខិតបទដ្ឋានគតិយុទ្ធ សាចរណ៍ណែនាំ ព្រមទាំងសេចក្តីជូនដំណឹងរបស់ក្រសួង ។

- **សំណូមពរ**

-សុំបង្កើនកញ្ចប់ថវិកាប្រចាំរបស់មន្ទីរ ដើម្បីបម្រើការងារលើវិស័យទេសចរណ៍ឲ្យមានសន្ទុះខ្លាំង

-សុំការគាំទ្រឲ្យមាន និងឧបត្ថម្ភធនដល់សហគមន៍ក្នុងផលិតវត្ថុអនុស្សាវរីយជាអត្តសញ្ញាណជាតិ (ដូចជា៖ មួកសន្លឹក សម្ភារៈប្រើប្រាស់ផ្សេងៗទៀត) សម្រាប់លក់ ឬផ្តល់ជូនភ្ញៀវមកលេងកំសាន្តនៅរមណីយដ្ឋាននានា។

-ពង្រឹងសមត្ថភាពមន្ត្រីមន្ទីរ តាមរយៈការចូលសិក្ខាសាលា វគ្គបណ្តុះបណ្តាល កសាងសមត្ថភាពលើជំនាញផ្សេងៗ រយៈពេលខ្លី និងវែង ដែលផ្តល់ដោយក្រសួងទេសចរណ៍ និងដៃគូអភិវឌ្ឍន៍។

-សុំការគាំទ្រពីរដ្ឋបាលខេត្ត ក្រុង ស្រុក មានវិធានការចំពោះម្ចាស់អាជីវកម្ម និងសេវាកម្ម ក្នុងខេត្តទាំងអស់ ដែលមានការយឺតយ៉ាវ ក្នុងបន្តអាជ្ញាបណ្ណ ។

-សុំឲ្យរដ្ឋបាលខេត្ត ជួយទាក់ទាញវិស័យឯកជនមកវិនិយោគលើវិស័យទេសចរណ៍ឲ្យបានច្រើន ។

## ១.២.១.៩. ប្រៃសណីយ៍និងទូរគមនាគមន៍

មន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តព្រៃវែង មានភារកិច្ចដឹកនាំ និងគ្រប់គ្រងលើវិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ ២យោងតាមមាត្រា) នៃច្បាប់ស្តីពីការបង្កើតក្រសួងដែលដាក់អោយប្រើប្រាស់តាមព្រះរាជក្រម នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ (។

ផ្តើមចេញពីគោលនយោបាយ និងយុទ្ធសាស្ត្រចតុកោណតំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០២៥-២០២៧ មន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តព្រៃវែង បន្តការជំរុញការអភិវឌ្ឍន៍ប្រៃសណីយ៍បច្ចេកវិទ្យាទូរគមនាគមន៍ និងព័ត៌មាន អោយមានលក្ខណៈទាន់សម័យ ប្រកបដោយគុណភាពខ្ពស់ ស្របតាមស្តង់ដាអន្តរជាតិ មានតំលៃថោកសមរម្យ និងមានសេវាគ្របដណ្តប់ទូទាំងខេត្ត។

ការអភិវឌ្ឍន៍សេវាប្រៃសណីយ៍ និងទូរគមនាគមន៍ គឺសំដៅបំពេញសំណូមពរកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម

កែលំអជីវភាពរស់នៅ របស់ប្រជាពលរដ្ឋធានាកិច្ចការពារសន្តិសុខប្រទេសជាតិ និងការកាត់បន្ថយភាពក្រីក្រ។ រាជរដ្ឋាភិបាលកម្ពុជា ដោយទទួលស្គាល់នូវសារៈសំខាន់នៃការងារទូរគមនាគមន៍ ចំពោះការអភិវឌ្ឍន៍ជាតិ និងសេដ្ឋកិច្ច បានបង្កើតឡើងនូវគោលនយោបាយជាតិមួយសម្រាប់ការអភិវឌ្ឍន៍វិស័យទូរគមនាគមន៍ និងសម្រាប់ផ្តល់នូវសេវាទូរគមនាគមន៍មានប្រសិទ្ធិភាព តម្លៃថោកសមរម្យតាមតម្រូវការប្រើប្រាស់ចំពោះប្រជាពលរដ្ឋ។ សេចក្តីប្រកាសគោលនយោបាយបានដាក់ចេញនូវគោលបំណង និងយុទ្ធសាស្ត្រនានារបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់អភិវឌ្ឍន៍ និងគ្រប់គ្រងវិស័យទូរគមនាគមន៍ក្នុងប្រទេស

កម្ពុជាឲ្យមានភាពរលូនឆ្លើយតបទៅ និងផលប្រយោជន៍ជាតិគោលដៅចំបង គឺដើម្បីបង្កើនគោលនយោបាយនានាផ្សេងៗទៀតឲ្យមានភាពច្បាស់លាស់ និងតម្លាភាព សម្រាប់ការអភិវឌ្ឍន៍វិស័យប្រៃសណីយ៍ និងទូរគមនាគមន៍។

រយៈពេលពេលបច្ចុប្បន្ននេះ ព្រះរាជាណាចក្រកម្ពុជាកំពុងតែមានការអភិវឌ្ឍន៍រីកចម្រើនលើគ្រប់វិស័យដោយមានការចូលរួមចំណែកពីភាពជាដៃគូជាមួយសហគមន៍ជាតិ អន្តរជាតិ ជាពិសេសក្របខណ្ឌសហប្រជាជាតិយ៉ាងខ្លាំងក្លាបំផុត។ ដំណើរការគ្រប់គ្រងការងារមានតួនាទីយ៉ាងសំខាន់ ចំបងក្នុងការសម្របសម្រួលដល់គ្រប់ស្ថាប័នអង្គភាព និងវិស័យវិនិយោគគ្រប់ប្រភេទនៅក្នុងប្រទេសកម្ពុជា។ ម៉្យាងវិញទៀតរាជរដ្ឋាភិបាលបច្ចុប្បន្នតែងតែយកចិត្តទុកដាក់ទៅលើការអភិវឌ្ឍកម្មវិធីវិនិយោគបីឆ្នាំរំកិល និងអំពីកត្តាធនធានមនុស្ស ពីព្រោះថា ធនធានមនុស្សក៏ជាកត្តាសំខាន់មួយ ក្នុងចំណោមកត្តាផ្សេងៗទៀតដែលនាំឲ្យស្ថាប័នសម្រេចបានដល់គោលដៅរបស់អង្គភាពផងដែរ។

យ៉ាងដូច្នេះ នៅក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិល២០២៥-២០២៧នេះ ត្រូវបានរៀបចំឡើងដោយស្របតាមក្របខណ្ឌអភិវឌ្ឍខេត្ត និងគោលការណ៍ណែនាំនានាដោយមានការចូលរួមដោយផ្ទាល់ពីមន្ទីរអង្គភាពជំនាញជុំវិញខេត្ត តំណាងក្រុមប្រឹក្សាក្រុង ស្រុក អង្គការសង្គមស៊ីវិល វិស័យឯកជន ក្នុងការលើកសំណើគម្រោងវិនិយោគនានា ពិសេសក្រុមស្ត្រីនិងកុមារដែលមានឈ្មោះគម្រោង និងថវិកាច្បាស់លាស់ដើម្បីឆ្លើយតបទៅនឹងតម្រូវការចាំបាច់របស់ប្រជាពលរដ្ឋនៅមូលដ្ឋាន ដែលជាកត្តាមួយមានសារៈសំខាន់ជាខ្លាំងក្នុងការជំរុញឲ្យសេដ្ឋកិច្ចកម្ពុជាឈានទៅរកការរីកចម្រើនលើគ្រប់វិស័យ ទាន់ប្រទេសក្នុងតំបន់កំពុងអភិវឌ្ឍ និងប្រទេសអភិវឌ្ឍមួយចំនួននៅលើសកលលោកនេះ។

មន្ទីរមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តព្រៃវែង សង្ឃឹមថាការដែលបានចូលរួមយ៉ាងសកម្មនេះនៅក្នុងដំណើរការកសាងកម្មវិធីវិនិយោគខេត្ត ហើយក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត ក្រុមការងារកសាងផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត មន្ទីរផែនការខេត្ត និងទីប្រឹក្សាជ.អ.៣ខេត្ត ដែលបានដឹកនាំសម្របសម្រួលដំណើរការកសាងកម្មវិធីវិនិយោគខេត្តរហូតសម្រេចលទ្ធផលជាស្ថាពរ។

មន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តព្រៃវែង សូមអំពាវនាវនិងរំពឹងទុកថា ដៃគូអភិវឌ្ឍន៍អង្គការសង្គមស៊ីវិល វិស័យឯកជន និងសប្បុរសជននានា ព្រមទាំងក្រសួងស្ថាប័នថ្នាក់ជាតិប្រាកដជាជួយគាំទ្រគម្រោងសកម្មភាពនេះ ហើយក៏ផ្តល់ទៅលើសេវាជាអាទិភាពនានា ដែលបានកំណត់នៅក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិល២០២៥-២០២៧នេះ។

- **បេសកកម្ម និងទិសដៅការងារសម្រាប់ឆ្នាំ២០២៥-២០២៧**
  - បន្តចុះផ្សព្វផ្សាយសារាចរអន្តរក្រសួងលេខ ០០១ ស.រ មផ-បទ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៩ រវាងក្រសួងមហាផ្ទៃ និងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ស្តីពីការគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាទូរគមនាគមន៍គ្រប់ប្រភេទ និងសេចក្តីណែនាំរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

លេខ ១១០ បទ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៤ស្តីពីការលក់ ចែកចាយស៊ីមកាតគ្រប់ប្រព័ន្ធ។

- បន្តអនុវត្តសេចក្តីណែនាំរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ លេខ១៧៤ បទ.សណនចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៤ ស្តីពីការទប់ស្កាត់ការតម្លើងប្រព័ន្ធទូរស័ព្ទ និងអង់តែនគ្រប់ប្រភេទដើម្បីទាញយកសេវាមកប្រើប្រាស់ដោយមិនឆ្លងកាត់ច្រកហៅ ចេញ ចូល អន្តរជាតិ។
- បន្តអនុវត្តសេចក្តីណែនាំរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ លេខ៣១៦ បទ/ប្រក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការកំណត់មុខងារនិងភារកិច្ចបន្ថែមរបស់មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្ត។
- បន្តចុះផ្សព្វផ្សាយប្រកាសរួមអន្តរក្រសួងលេខ ៤៩៨ សហវ.ប្រក ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៨ រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ស្តីពីការផ្តល់សេវាសាធារណៈ។

- **បញ្ហាប្រឈម**
  - ប្រតិបត្តិទូរគមនាគមន៍ និងក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណេតមួយចំនួនមិនបានផ្តល់ព័ត៌មានមកមន្ទីរ អំពីការសាងសង់ដំឡើង រុះរើហេដ្ឋារចនាសម្ព័ន្ធទូរគមនាគន៍នៅក្នុងខេត្តនោះទេ។
  - ក្រុមហ៊ុនមួយចំនួនមិនបានគោរពច្បាប់អាជីវកម្មនិងពុំបានសហការផ្តល់របាយការណ៍ជូនមន្ទីរ។
  - -ក្រុមហ៊ុន និងភ្នាក់ងារលក់ ចែកចាយ ស៊ីមកាតគ្រប់ប្រភេទមួយចំនួននៅបន្តមិនយកអត្តសញ្ញាណប័ណ្ណធ្វើអោយជនល្មើសឆ្លៀតឱកាសបន្ត ប្រព្រឹត្តបទល្មើស។
  - សេវាទូរស័ព្ទនិងអ៊ិនធឺណេត មិនទាន់គ្របដណ្តប់ក្នុងភូមិសាស្ត្រទូទាំងខេត្ត។
  - ការស្នើសុំអនុញ្ញាតច្បាប់ ដំឡើងហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ ដើម្បីពង្រីកសេវាទូរគមនាគមន៍មានការយឺតយ៉ាវ។
  - ប្រតិបត្តិករទូរគមនាគមន៍មួយចំនួន មិនគោរពទៅតាមបទបញ្ញត្តិនានា និងច្បាប់ស្តីពីទូរគមនាគមន៍ និងសេចក្តីណែនាំនានារបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងនិយ័តករទូរគមនាគមន៍កម្ពុជា។
  - បរិក្ខាទូរគមនាគមន៍ថ្មីចូលមកច្រើន ដោយពុំឆ្លងកាត់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។
  - ក្រុមហ៊ុនប្រតិបត្តិករមួយចំនួនមិនព្រមផ្តល់របាយការណ៍តាមការស្នើសុំរបស់មន្ទីរ។
  - អាជីវករដែរប្រកបអាជីវកម្មលក់ទូរស័ទ្ទ កុំព្យូទ័រ និងវិទ្យុគមនាគមន៍ ពុំបានស្នើសុំលិខិតអនុញ្ញាតមកមន្ទីរ។
  - មន្ទីរមានចំនួនមន្ត្រីរាជការតិច និងមានមន្ត្រីរាជការចូលនិវត្តន៍ជាបន្តបន្ទាប់។

## ១.២.១.១០. សេដ្ឋកិច្ចហិរញ្ញវត្ថុ ពន្ធដារ និង ធនាគារជាតកម្ពុជា

### ក-ផ្នែកសេដ្ឋកិច្ចហិរញ្ញវត្ថុ

ការអនុវត្តថវិការជ្ញប្រចាំឆ្នាំ២០២៣មានដូចខាងក្រោមៈ

ក.១-ថវិកាថ្នាក់ជាតិៈ

ក/ចំណូល៖

-ច្បាប់ហិរញ្ញវត្ថុដើមឆ្នាំ 3,359,900,000 រៀល

-អនុវត្តជាក់ស្តែង 14,892,902,081 រៀល

ខ/ចំណាយ៖

-ច្បាប់ហិរញ្ញវត្ថុ 258,041,000,000 រៀល

-ស្ថានភាពឥណទានថ្មី 263,647,559,000 រៀល

-អនុវត្តជាក់ស្តែង 259,841,269,079 រៀល

ក.២-ថវិកាថ្នាក់ក្រោមជាតិៈ

I.មន្ទីរសុខាភិបាលខេត្ត៖

ក/ចំណូល៖

-ច្បាប់ហិរញ្ញវត្ថុដើមឆ្នាំ 56,727,800,000 រៀល

-អនុវត្តជាក់ស្តែង 56,290,812,388 រៀល

ខ/ចំណាយ៖

-ច្បាប់ហិរញ្ញវត្ថុ 56,727,800,000 រៀល

-ស្ថានភាពឥណទានថ្មី 56,727,800,000 រៀល

-អនុវត្តជាក់ស្តែង 56,274,402,513 រៀល

II.សាលាខេត្ត-ក្រុង-ស្រុក-ឃុំ-សង្កាត់៖

ក/ចំណូល៖

-ច្បាប់ហិរញ្ញវត្ថុ 154,715,135,311 រៀល

-ឥណទានអនុញ្ញាត 154,715,135,311 រៀល

-អនុវត្តជាក់ស្តែង 167,193,763,865 រៀល

ខ/ចំណាយ៖

-ច្បាប់ហិរញ្ញវត្ថុ 153,293,215,311 រៀល

-ឥណទានអនុញ្ញាត 166,859,392,311 រៀល

-អនុវត្តជាក់ស្តែង 151,540,148,975 រៀល

## ខ-ផ្នែកពន្ធដារ

គម្រោងផែនការចំណូលឆ្នាំ ២០២៤, ២០២៥, ២០២៦ និងឆ្នាំ២០២៧ (ឯកតាគិតជារៀល)

| អនុគណនី | មាតិកាចំណាត់ | ច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៤ | គ្រោងផែនការឆ្នាំ២០២៥ | គ្រោងផែនការឆ្នាំ២០២៦ | គ្រោងផែនការឆ្នាំ២០២៧ | គ្រ២៥/គ្រ២៤ | គ្រ២៦/គ្រ២៥ | គ្រ២៧/គ្រ២៦ |
|---|---|---|---|---|---|---|---|---|
| A | B | 1 | 2 | 3 | 4 | 5=2/1 | 6=3/2 | 7=4/3 |
| | **ចំណូលចំណាត់ថ្នាក់ក្រោមជាតិ** | 16,886,000,000 | 16,972,800,000 | 17,345,300,000 | 17,727,800,000 | 101.80% | 102.19% | 102.21% |
| | **ពន្ធលើឈ្នួលចលននិងអចលនទ្រព្យ** | 210,000,000 | 230,000,000 | 250,000,000 | 270,000,000 | 109.52% | 108.70% | 108.00% |
| 70014 | ពន្ធលើឈ្នួលចលននិងអចលនទ្រព្យ រូបវន្តបុគ្គល | 210,000,000 | 230,000,000 | 250,000,000 | 270,000,000 | 109.52% | 108.70% | 108.00% |
| 70015 | ពន្ធលើឈ្នួលចលននិងអចលនទ្រព្យ នីតិបុគ្គល | - | - | - | - | | | |
| 70035 | អាករសម្រាប់បំភ្លឺសាធារណៈ | - | - | - | - | 0.00% | | |
| 70045 | អាករលើការស្នាក់នៅ | 2,100,000 | 2,300,000 | 2,500,000 | 2,700,000 | 109.52% | 108.70% | 108.00% |
| 70046 | ពន្ធសត្តឃាត | - | - | - | - | | | |
| 70053 | ពន្ធប៉ាតង់ | 600,000,000 | 620,000,000 | 650,000,000 | 670,000,000 | 103.33% | 104.84% | 103.08% |
| 70054 | ពន្ធលើមធ្យោបាយដឹកជញ្ជូន | 12,800,000,000 | 13,000,000,000 | 13,200,000,000 | 13,410,000,000 | 101.56% | 101.54% | 101.59% |
| | **ពន្ធប្រថាប់ត្រា** | 2,698,500,000 | 2,623,600,000 | 2,744,700,000 | 2,865,800,000 | 102.38% | 104.62% | 104.41% |
| 70061 | ពន្ធប្រថាប់ត្រាលើតម្លៃអចលនទ្រព្យចំពោះការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់ | 2,537,000,000 | 2,500,000,000 | 2,600,000,000 | 2,700,000,000 | 102.04% | 104.00% | 103.85% |
| 70062 | ពន្ធប្រថាប់ត្រាលើតម្លៃមធ្យោបាយដឹកជញ្ជូនចំពោះការផ្ទេរកម្មសិទ្ធិ | 26,000,000 | 27,000,000 | 28,000,000 | 29,000,000 | 103.85% | 103.70% | 103.57% |
| 70063 | ពន្ធប្រថាប់ត្រាលើតម្លៃភាគហ៊ុនចំពោះការផ្ទេរភាគហ៊ុន | 2,500,000 | 2,600,000 | 2,700,000 | 2,800,000 | 104.00% | 103.85% | 103.70% |
| 70064 | ពន្ធប្រថាប់ត្រាលើកិច្ចសន្យាផ្គត់ផ្គង់ទំនិញ ឬសេវា | 130,000,000 | 90,000,000 | 110,000,000 | 130,000,000 | 112.50% | 122.22% | 118.18% |
| 70065 | ពន្ធប្រថាប់ត្រាលើលិខិតមានលក្ខណៈគតិយុត្តិ | 3,000,000 | 4,000,000 | 4,000,000 | 4,000,000 | 100.00% | 100.00% | 100.00% |
| | **ពន្ធលើអចលនទ្រព្យ** | 88,700,000 | 88,900,000 | 89,100,000 | 89,300,000 | 100.23% | 100.22% | 100.22% |
| 70071 | ពន្ធលើអចលនទ្រព្យ រូបវន្តបុគ្គល | 82,500,000 | 82,600,000 | 82,700,000 | 82,800,000 | 100.12% | 100.12% | 100.12% |
| 70072 | ពន្ធលើអចលនទ្រព្យ នីតិបុគ្គល | 6,200,000 | 6,300,000 | 6,400,000 | 6,500,000 | 101.61% | 101.59% | 101.56% |
| 70073 | ពន្ធលើដីធ្លីមិនបានប្រើប្រាស់ | 80,000,000 | - | - | - | 0.00% | | |
| 70081 | ពន្ធលើផ្ទាំងផ្សព្វផ្សាយ | 406,700,000 | 408,000,000 | 409,000,000 | 420,000,000 | 100.25% | 100.25% | 102.69% |

## គ-ផ្នែកធនាគារជាតិកម្ពុជា

-របាយការណ៍ស្តីពីលទ្ធផលការងារកម្មវិធីវិនិយោគបីឆ្នាំរំកិល២០២៥-២០២៧សាខាធនាគារជាតិនៃកម្ពុជាខេត្តព្រៃវែងប្រចាំខែតុលា ឆ្នាំ២០២៤។

-លិខិតជូនដំណឹងលេខ ០២០-០១៣ សជណចុះថ្ងៃទី១៤ ខែ កុម្ភៈ ឆ្នាំ២០១៣របស់ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តស្តីពីការផ្តល់ របាយការណ៍ប្រចាំខែរបស់មន្ទីរជុំវិញខេត្ត ។

ផ្អែកលើតួនាទីភារៈកិច្ច ដែលធនាគារកណ្តាលបានប្រគល់ឲសាខាធនាគារជាតិនៃកម្ពុជា ខេត្តព្រៃវែង បានប្រឹងប្រែងបំពេញតួនាទីភារកិច្ចរបស់ខ្លួនឲ្យបានសមស្រប ជាសេនាធិការរបស់ធនាគារកណ្តាលរាល់ប្រតិបត្តិការសេវាកម្ម តាមមុខជំនាញនីមួយៗ ដែលទទួលបានផលជាក់ស្តែងដូចខាងក្រោម៖

## I-ការងាររដ្ឋបាល-បុគ្គលិករបស់សាខា

- **រចនាសម្ព័ន្ធ:**
  - សាខាធនាគារជាតិនៃកម្ពុជាខេត្តព្រៃវែងមាន ០៤ ការិយាល័យ គឺ: (១)ការិយាល័យរដ្ឋបាលនិងបុគ្គលិក (២)ការិយាល័យរូបិយវត្ថុ (៣)ការិយាល័យប្រតិបត្តិការ និង(៤)ការិយាល័យគណនេយ្យ ក្នុងនោះមានមន្ត្រី-បុគ្គលិកក្របខ័ណ្ឌសរុបចំនួន ២៩នាក់(ប្រុស ១០ នាក់ ស្រី ១៩នាក់)

**តារាងក្របខ័ណ្ឌមន្ត្រីបុគ្គលិកសាខាធនាគារជាតិនៃកម្ពុជាខេត្តព្រៃវែង**

| ល.រ | បរិយាយ | តែងតាំងប្រគល់ភារកិច្ច | ផ្ទេរ/ផ្លាស់ប្តូរ | ស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស | អនុញ្ញាតឲ្យបម្រើការងារវិញ | សុំលាឈប់ | លុបឈ្មោះចេញពីក្របខ័ណ្ឌ |
|---|---|---|---|---|---|---|---|
| ០១ | នាយកសាខា | ០១ | | | | | |
| ០២ | នាយករងសាខា | ០១ | | | | | |
| ០៣ | ប្រធានការិយាល័យ | ០៤ | | | | | |
| ០៤ | អនុប្រធានការិយាល័យ | ០៦ | | | | | |
| ០៥ | មន្ត្រី បុគ្គលិក | ១៧ | | | | | |

## II-ការងារចរាចរ រូបិយវត្ថុ:

- **ជាប្រាក់រៀល:**

-ការប្រមូលប្រាក់ចំណូលក្នុងគ្រា = ២,៣៧១,៧៦៤,១៨២,១៧៨ រៀល

-ការបើកប្រាក់ចំណាយក្នុងគ្រា = ១៨៣,១០៣,៣៩២,២២៨ រៀល

- **ជាប្រាក់ដុល្លារអាមេរិច:**

-ការប្រមូលប្រាក់ចំណូលក្នុងគ្រា = ៤៨២,០៧៩,២០២.៦៥ ដុល្លារ

-ការបើកប្រាក់ចំណាយក្នុងគ្រា = ២៦,០៥៥,៦៨៨.៦៥ ដុល្លារ

+បានប្តូរប្រាក់ចាស់ទក់រហែកជាប្រាក់រៀល ដែលធ្វើចរាចរទូទាំងខេត្តធ្វើឲ្យបរិមាណសាច់ប្រាក់ទក់រហែកមានការថយចុះក្នុងទីផ្សារ និងខិតខំបន្តអនុវត្តការងារបន្ថែមទៀត។

+ធានាផ្គត់ផ្គង់សាច់ប្រាក់ជូនមន្ទីរ អង្គភាពគ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុដែលបានបើកគណនីនៅសាខាធនាគារជាតិនៃកម្ពុជាខេត្តព្រៃវែង ទាំងប្រាក់រៀល និងប្រាក់ដុល្លាអាមេរិច បានទាន់ពេលវេលា។

## III-ការងារប្រតិបត្តិការ:

-ការងារទំនាក់ទំនងអតិថិជនបានល្អប្រសើរលើការទទួលខុសត្រូវក្នុងការបង់ បើក និងផ្ទេរប្រាក់ចំពោះមន្ទីរអង្គភាព គ្រឹះស្ថាន ធនាគារពាណិជ្ជ និងមីក្រូហិរញ្ញវត្ថុដែលបានបើកគណនីនៅសាខាធនាគារជាតិនៃកម្ពុជាខេត្តព្រៃវែង ពុំមានបញ្ហាអ្វីគួរកត់សំគាល់ ដោយបំរើបានទាន់ពេលវេលា និងទំនាក់ទំនងបានល្អ

-បើកគណនីចរន្ត ជូនគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ និងស្ថាប័នរដ្ឋ សរុប **២៨**គណនី

-សាខាធនាគារពាណិជ្ជដែលបានមកបោះទីតាំងក្នុងខេត្តចំនួន**១១** គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន **១៦** ក្នុងនោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើមានចំនួន **៥** គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើមានចំនួន**១១** និងក្រុមហ៊ុនភតិសន្យាចំនួន **២**។

- **ការងារគ្រប់គ្រងអាជីវកម្មប្តូរប្រាក់ :**

| | |
|---|---|
| -លិខិតអនុញ្ញាតកំពុងមានសុពលភាពដើមគ្រា | ចំនួន ៩0 តូប |
| -លិខិតអនុញ្ញាតអស់សុពលភាពក្នុងគ្រា | ចំនួន 0 តូប |
| -លិខិតអនុញ្ញាតចេញថ្មី | ចំនួន 0 តូប |
| -ដូចនេះលិខិតអនុញ្ញាតកំពុងមានសុពលភាព | ចំនួន ៩0 តូប |

**IV-បញ្ហាប្រឈម និងដំណោះស្រាយការងារ:**

- **បញ្ហាប្រឈម:**

-មន្ត្រីបុគ្គលិករាប់ប្រាក់ ងាយនិងឆ្លងនៅជម្ងឺកូវីដ១៩

-ការទទួលសាច់ប្រាក់ពីគ្រឹះស្ថានធនាគារ និងស្ថាប័នមានការកើនឡើងពីរមួយថ្ងៃទៅមួយថ្ងៃ។

**V- ទិសដៅការងារ:**

-បង្កើតធនធានមនុស្សលើសមត្ថភាពបច្ចេកទេស និងចំណេះដឹងទូទៅ

-បង្កើតការអនុវត្តការងារទទួលខុសត្រូវបំរើអតិថជនឲ្យបានល្អ និងមានប្រសិទ្ធភាពខ្ពស់

-បន្តចូលរួមផ្សព្វផ្សាយការប្រើប្រាស់ និងលើកតំកើនប្រាក់រៀល

-បន្តចូលរួមផ្សព្វផ្សាយចុះតាមមូលដ្ឋាន នៃការប្រើប្រាស់ KH QR Cord ឲ្យបានទូលទូលាយ

-បន្តការងារប្តូរប្រាក់ ចាស់ ទក់ រហែក ជារៀលឲ្យមានការថយចុះក្នុងការចរាចរ

-បន្តកែលំអរថែរក្សាសោភ័ណ្ឌភាពបរិវេណអគារឲ្យបានស្អាតជាប្រចាំ

-ចូលរួមអនុវត្តយ៉ាងសកម្មនូវរាល់ការងារដែលធនាគារជាតិនៃកម្ពុជា ដាក់ចុះឲ្យបានត្រឹមត្រូវតាមការកំណត់

-ចូលរួមអនុវត្តរាល់ផែនការ ការងាររបស់រដ្ឋអំណាចមូលដ្ឋានជាប្រចាំ។

## ១.២.១.១១.ស្ថានភាពការវិនិយោគក្នុងខេត្ត

ខេត្តព្រៃវែងមានមានប្រព័ន្ធគមនាគមន៍ប្រទាក់ក្រឡាទាំងផ្លូវគោកនិងផ្លូវទឹក មានផ្ទៃដីដាំដុះធំទូលាយ ប្រជាពលរដ្ឋច្រើន ដែលជាសក្តានុពលសម្រាប់ការវិនិយោគនានា។ បច្ចុប្បន្នខេត្តមានសហគ្រាស គ្រឹះស្ថានចំនួន ២០៧សហគ្រាស មានកម្មករនិយោជិតសរុប ៧,៤៤៨នាក់ ស្រី ៣,៩២៥នាក់ ក្នុងនោះមាន៖

-វិស័យកាត់ដេរចំនួន ១១សហគ្រាស មានកម្មករនិយោជិតសរុបចំនួន ២,៤៦៦នាក់ ស្រី ២,១៩៩នាក់

-វិស័យក្រៅពីកាត់ដេរចំនួន ១៩៦សហគ្រាស មានកម្មករ-និយោជិតសរុបចំនួន ៤,៩៨២ នាក់ ស្រី ១,៧២៦នាក់។

បច្ចុប្បន្នខេត្តមានរោងចក្រកាត់ដេរសម្លៀកបំពាក់ចំនួន ១១កន្លែង ដែលមានដំណើរការជាប្រចាំ

(មានកម្មករសរុប ២,៤៦៦នាក់ ស្រី ២,១៩៩នាក់) គឺនៅស្រុកបាភ្នំ ០៣កន្លែង ស្រុកកំចាយមារ ០១កន្លែង ស្រុកកញ្ជ្រៀច ០១កន្លែង ស្រុកមេសាង ០១កន្លែង ស្រុកពាមរក៍ ០២កន្លែង និងស្រុកស្វាយអន្ទរ ០៣កន្លែង។

ដោយឡែកក្នុងខេត្តមានរោងម៉ាស៊ីនកិនស្រូវធំៗចំនួន ១៤ កន្លែង ទន្ទឹមនេះដែរ មានរោងម៉ាស៊ីនកិនស្រូវចំនួន ០៦ កន្លែង បាននឹងកំពុងផលិតអង្ករប្រភេទស្តង់ដារ ដើម្បីនាំចេញទៅទីផ្សារអន្តរជាតិ និងសម្រាប់ការផ្គត់ផ្គង់ក្នុងប្រទេសនៅត្រីមាសទី២។ ប៉ុន្តែទោះជាយ៉ាងនេះក្តី ក៏ការវិនិយោគរបស់វិស័យឯកជននាពេលបច្ចុប្បន្ននៅមានកម្រិតទាប មិនទាន់ឆ្លើយតបនឹងគោលដៅរបស់ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ខេត្ត ព្រមទាំងតម្រូវការរបស់ប្រជាពលរដ្ឋនៅឡើយ។

ខេត្តមានគម្រោងអភិវឌ្ឍន៍ក្រុងព្រៃវែង ដែលមានផ្ទៃដីទំហំ ២០.៦៧ ហិកតា ត្រូវចំណាយថវិកាអស់ចំនួន ១៧.០៦៨.៣២៩ ដុល្លា (ដប់ប្រាំពីរលាន ហុកសិបប្រាំបីពាន់ បីរយម្ភៃប្រាំបួនដុល្លាគត់) ដែលមានទីតាំងស្ថិតនៅភូមិលេខ៥ សង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង ហើយគម្រោងអភិវឌ្ឍន៍នេះ បានធ្វើឲ្យជីវភាពប្រជាពលរដ្ឋនៅក្នុងខេត្តព្រៃវែងទទួលបាននូវមុខរបរ និងប្រាក់ចំណូលបន្ថែមពីគម្រោងអភិវឌ្ឍន៍នេះផងដែរ។

### ១.២.១.១២. ទំនាក់ទំនង និងសហប្រតិបត្តិការអន្តរជាតិ:

ខេត្តព្រៃវែងមានព្រំប្រទល់ជាប់ជាមួយខេត្តដុងថាប់ ខេត្តឡុងអាននិងខេត្តតៃនិញនៃសាធារណរដ្ឋសង្គមនិយមវៀតណាមមានច្រកទ្វារព្រំដែនចំនួន០៦ ក្នុងនោះច្រកទ្វារអន្តរជាតិមានចំនួន០៣កន្លែង គឺច្រកទ្វារអន្តរជាតិបន្ទាយចក្រី កោះរកា និងម៊ឺនជ័យ ច្រកទ្វារតំបន់ព្រំដែនមាន០២កន្លែងគឺច្រកទ្វារតំបន់ព្រំដែនពាមមន្ទារ និងស្វាយអាង៉ោង និងច្រកទ្វារព្រំដែនទ្វេភាគីមាន ០១កន្លែងគឺកោះសំពៅ ។

ដោយអនុវត្តតាមកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការរវាងខេត្តនីមួយៗ សភាពការណ៍លើវិស័យសន្តិសុខនិងទំនាក់ទំនង ក៏ដូចជាបណ្តាវិស័យនានាមានដំណើរការល្អជាប្រក្រតីពុំមានអ្វីកើតឡើងគួរឲ្យកត់សម្គាល់ឡើយ។

### ១.២.១.១៣. វិស័យមុខងារសាធារណៈ:

មន្ទីរមុខងារសាធារណៈខេត្តព្រៃវែង ជាមន្ទីរមួយក្នុងចំណោមមន្ទីរ អង្គភាពជំនាញនានាជុំវិញខេត្ត ដែលបាននឹងកំពុងបំពេញបេសកកម្មការងារលើវិស័យមុខងារសាធារណៈ ការការពារផលប្រយោជន៍មន្ត្រីរាជការនិងការបើកផ្តល់បៀវត្សជូនមន្ត្រី រាជការប្រកបដោយតម្លាភាព និងសង្គតិភាព។ មន្ទីរមុខងារសាធារណៈខេត្តស្ថិតនៅភូមិលេខ២ សង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង ហើយត្រូវបានប្រកាសដាក់ឱ្យដំណើរការជាផ្លូវការនៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**។ មន្ទីរមានមន្ត្រីរាជការសរុបចំនួន ២០ នាក់ ស្រី ០៧ នាក់ ក្នុងនោះមាន៖ ប្រធានមន្ទីរ ០១ នាក់ អនុប្រធានមន្ទីរ ០៣នាក់ ប្រធានការិយាល័យ ០២ នាក់ អនុប្រធានការិយាល័យ ០៥ នាក់ មន្ត្រីចំនួន ០៩ នាក់ និងមន្ត្រីជាប់កិច្ចសន្យាចំនួន ០៥ នាក់ផងដែរ។

ការកកើតមន្ទីរមុខងារសាធារណៈខេត្ត ស្របពេលដែលរាជរដ្ឋាភិបាល បាននឹងកំពុងយកចិត្តទុកដាក់លើការងារកំណែទម្រង់រដ្ឋបាលសាធារណៈ ដើម្បីឈានឆ្ពោះទៅសម្រេចបានចក្ខុវិស័យ "ប្រែក្លាយរដ្ឋបាលសាធារណៈឱ្យទៅជាអ្នកផ្តល់សេវាដ៏មានប្រសិទ្ធភាព និងជាដៃគូអភិវឌ្ឍន៍ដែលអាចជឿទុកចិត្តបានសំដៅបម្រើប្រជាពលរដ្ឋឱ្យបានកាន់តែល្អប្រសើរឡើង"។

ការអនុវត្តបេសកកម្មការងារដ៏ពិសិដ្ឋរបស់មន្ទីរមុខងារសាធារណៈខេត្ត ជាផ្នែកមួយជួយលើកកម្ពស់ការផ្តល់សេវា ការពង្រឹងរបៀបរបបការងារ ការគោរពវិន័យ ការផ្លាស់ប្តូរឥរិយាបថការងាររបស់មន្ត្រី ការបើកផ្តល់បៀវត្សជូនមន្ត្រីរាជការឱ្យបានទៀងទាត់ និងទាន់ពេលវេលា ហើយបើកតាមប្រព័ន្ធធនាគារ១០០%។

ផែនការអភិវឌ្ឍន៍របស់មន្ទីរ ត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីពង្រឹងការអនុវត្តតួនាទីភារកិច្ចឱ្យទទួល បានប្រសិទ្ធភាពខ្ពស់ សំដៅចូលរួមចំណែកគាំទ្រគោលនយោបាយកែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលកម្ពុជា។

- **លទ្ធផលការងារសម្រេចបានឆ្នាំ២០២៤**

មន្ទីរមុខងារសាធារណៈខេត្ត មានតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមចំណែកផ្សព្វផ្សាយគោលនយោបាយផែនការយុទ្ធសាស្ត្រ និងសេចក្តីសម្រេចនានាលើការងារកំណែទម្រង់រដ្ឋបាលសាធារណៈជូនដល់មន្ត្រីរាជការដែលកំពុងបម្រើការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិជាអ្នកផ្តល់សេវាជូនប្រជាពលរដ្ឋទូទាំងខេត្ត។ ក្នុងនាមជាសេនាធិការជូនក្រុមប្រឹក្សាខេត្ត និងគណៈអភិបាលខេត្ត មន្ទីរមុខងារសាធារណៈខេត្តព្រៃវែង មានតួនាទីភារកិច្ចគ្រប់គ្រង និងការពារផលប្រយោជន៍របស់មន្ត្រីរាជការ និងជួយឱ្យមន្ត្រីរាជការមានការផ្លាស់ប្តូរឥរិយាបថពីការគ្រប់គ្រងទៅជាអ្នកផ្តល់សេវា ប្រកបដោយមនសិការវិជ្ជាជីវៈ ឆន្ទៈម្ចាស់ការ ភក្តីភាព និងវប្បធម៌សាធារណៈ។ ជាក់ស្តែងឆ្នាំ២០២៤ មន្ទីរបានអនុវត្តការងារទទួលបានលទ្ធផលដូចជា៖

- គិតត្រឹមខែកញ្ញា ឆ្នាំ២០២៤ មន្ត្រីរាជការស៊ីវិលនៅខេត្តព្រៃវែង មានចំនួន ១១,៣០១ នាក់ ស្រី ៤,៦០១ នាក់ មានដូចខាងក្រោម៖
  - ក្របខ័ណ្ឌប្រភេទ (ក) ចំនួន ២,០៨០ នាក់ ស្រី ៦២៤ នាក់
  - ក្របខ័ណ្ឌប្រភេទ (ខ) ចំនួន ៤,១៨៥ នាក់ ស្រី ១,៦៨៧ នាក់
  - ក្របខ័ណ្ឌប្រភេទ (គ) ចំនួន ៥,០៣៦ នាក់ ស្រី ២,២៩០ នាក់
  - សហព័ទ្ធមន្ត្រីរាជការស៊ីវិល ចំនួន ៤,០០៣ នាក់
  - កូនមន្ត្រីរាជការស៊ីវិល ចំនួន ១១,១៩៩ នាក់
  - មន្ត្រីជាប់កិច្ចសន្យា ចំនួន ៤៥២ នាក់ ស្រី ១៩៦ នាក់
- ឥណទានបៀវត្សសរុបទូទាំងខេត្តរយៈពេល៩ខែ ស្មើនឹង **១៩៦,៦២៦,២៨១,២៦៥**រៀលក្នុងនោះមាន៖
  - ឥណទានបៀវត្សមូលដ្ឋានទូទាំងខេត្ត រយៈពេល៩ខែ ស្មើនឹង ៩០,២២០,៤៧៧,៣២០រៀល

- ប្រាក់បំណាច់មុខងារទូទាំងខេត្ត រយៈពេល៩ខែ ស្មើនឹង ៧៧,១៩៣,៦៤៧,៥០០រៀល
- ប្រាក់ឈ្នួលផ្ទះ(សាលាជំបូងខេត្ត) ស្មើនឹង ៥៨,៨០០,០០០រៀល
- ប្រាក់តំបន់ ស្មើនឹង ១,២០៣,៩២០,០០០រៀល
- ប្រាក់ឧបត្ថម្ភកូន ស្មើនឹង ៩៨២,៣៥០,០០០រៀល
- ប្រាក់ឧបត្ថម្ភប្រពន្ធ ស្មើនឹង ៥៣៦,៥៥០,០០០រៀល
- ប្រាក់ពីរវេន ស្មើនឹង ៩,៦៩២,៥០៥,៥៧០រៀល
- ប្រាក់ឧបត្ថម្ភចូលនិវត្តន៍ ស្មើនឹង ៣៥១,៤២១,២០០រៀល
- ប្រាក់រំលឹក ស្មើនឹង ១៦,៣៨៦,៦០៩,៦៧៥រៀល
- ទឹកប្រាក់ដែលត្រូវបង់ពន្ធ ស្មើនឹង ១,១៤៦,៤២២,៨៦៤រៀល
- ទឹកប្រាក់ត្រូវបើក ស្មើនឹង ១៩៥,៤៧៩,៨៥៨,៤០១រៀល

- **បញ្ហាប្រឈម**
  - ខ្វះមធ្យោបាយប្រើប្រាស់ក្នុងការចុះបំពេញបេសកកម្មនៅតាមក្រុង-ស្រុក ។
  - ខ្វះខាតកញ្ចប់ថវិកា និងមន្ត្រីសម្រាប់ធ្វើការប្រជុំផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្ត និងច្បាប់ពាក់ព័ន្ធជូនដល់មន្ត្រីរាជការមន្ទីរ-អង្គភាពជុំវិញខេត្ត និងមន្ត្រីសាលាក្រុង-ស្រុកទាំង១៣។

### ១.២.១.១៤. វិស័យផែនការ

បានយកចិត្តទុកដាក់ពង្រឹងសមត្ថភាពមន្ត្រីផែនការគ្រប់ថ្នាក់ដើម្បីរៀបចំកសាងផែនការ ស្រប ទៅតាមគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាលក្នុងនោះបានចូលរួមក្នុងក្រុមការងារកសាងផែនការខេត្តរៀបចំបាននូវផែនការអភិវឌ្ឍន៍ខេត្តរយៈពេល៥ឆ្នាំ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិលក្នុងអាណត្តិទី២និងទី៣របស់ក្រុមប្រឹក្សាខេត្តដែលជាត្រីវិស័យសម្រាប់ការងារអភិវឌ្ឍន៍ខេត្ត និងជាឯកសារដ៏មានសារៈសំខាន់សម្រាប់បង្ហាញដៃគូអភិវឌ្ឍន៍នានាពីតម្រូវការរបស់ខេត្តជាអាទិភាព។

បានពង្រឹងប្រព័ន្ធស្ថិតិបានល្អដែលក្លាយជាយន្តការ ផ្តល់ព័ត៌មានបំរើដល់ការងារកសាងផែនការ ការរៀបចំគោលនយោបាយព្រមទាំងការតាមដានត្រួតពិនិត្យនិងវាយតម្លៃ ជាក់ស្តែងយើងបានចងក្រងនូវប្រព័ន្ធទិន្នន័យភូមិឃុំសង្កាត់ក្រុងស្រុកខេត្ត និងរៀបចំបានជាឯកសារព័ត៌មានស្ថានភាពខេត្តស្រុកក្រុងឃុំសង្កាត់ ព័ត៌មានពិន្ទុវិស័យខេត្ត ក្រុង ស្រុក ឃុំសង្កាត់ ដែលបង្ហាញពីវឌ្ឍនភាពនៃការអនុវត្តន៍គោលដៅវិស័យនីមួយៗ និងអាចប្រៀបធៀបពីការរីកចំរើនរបស់វិស័យមួយទៅនឹងវិស័យមួយទៀតពីស្រុកមួយទៅស្រុកមួយទៀត ពីឃុំមួយទៅឃុំមួយទៀត ព្រមទាំងមានសូចនាករបង្ហាញច្បាស់លាស់សម្រាប់វិភាគរកបញ្ហា និងដំណោះស្រាយបំរើដល់ការងារកសាងផែនការគ្រប់ផ្នែកគ្រប់ថ្នាក់។ បានដំណើរការអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ដើម្បីផ្តល់ប័ណ្ណសមធម៌ជូនដល់គ្រួសារក្រីក្រក្នុងការទទួលបាននៅកម្មវិធីឧបត្ថម្ភសាច់ប្រាក់ពីរាជរដ្ឋាភិបាល និងបានដំណើរការកំណត់ អត្តសញ្ញាណកម្មគ្រួសារងាយរងហានិភ័យ

ជាមួយគ្នានេះ យើងបានរៀបចំនូវស្ថានភាពក្រីក្រតាមបណ្តាឆ្នាំ ដែលឆ្លុះបញ្ចាំងពីការអនុវត្តគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល (មានតារាងបង្ហាញខាងក្រោម)។

ការងារប្រជាជន និងការអភិវឌ្ឍបានចាប់ផ្តើមសកម្មភាពដើម្បីតាមដានពីការអនុវត្តន៍គោលនយោបាយប្រជាជនដែលរាជរដ្ឋាភិបាលបានកំណត់។

ការងារវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាត្រូវបានដំណើរការជាបន្តបន្ទាប់តាមរយៈការបណ្តុះបណ្តាលមន្ត្រីពីគោលការណ៍ និងវិធីសាស្ត្រនានាដើម្បីជំរុញអោយវិស័យនានាយកចិត្តទុកដាក់បញ្ចូលបច្ចេកវិទ្យាទំនើបទៅក្នុងដំណើរការផលិតកម្ម អាជីវកម្ម សេវាកម្ម អភិវឌ្ឍធនធានមនុស្ស...។ល។

ការងារប្រមូលទិន្នន័យសម្រាប់រៀបចំចងក្រង GDP ត្រូវបានអនុវត្តជាបន្តបន្ទាប់ដោយមានការចូលរួមពីស្ថាប័នពាក់ព័ន្ធក្នុងខេត្តនិងសម្របសម្រួលដោយមន្ត្រីវិទ្យាស្ថានជាតិស្ថិតិក្រសួងផែនការ។

ការប្រមូលរបាយការណ៍ប្រចាំខែពីស្ថានភាពប្រែប្រួលប្រជាជន និងតម្លៃទីផ្សារសេរីព្រមទាំងការអង្កេតផ្សេងៗ ក៏ត្រូវបានអនុវត្តជាប្រចាំដែលជាព័ត៌មានដ៏សំខាន់បំរើដល់ការតាមដាន និងវិភាគពីការរីកចំរើនរបស់សេដ្ឋកិច្ចខេត្តផងដែរ។

បញ្ហាប្រឈមក្នុងការងារផែនការ គឺឯកសារកម្មវិធីវិនិយោគ៣ឆ្នាំរំកិលដែលក្រុមការងារកសាងផែនការខិតខំរៀបចំរួចនោះ មិនទទួលបាននូវការគាំទ្រពីដៃគូរអភិវឌ្ឍន៍នានាទេ ធ្វើអោយសន្ទុះនៃការអភិវឌ្ឍន៍ខេត្តមិនរីកចំរើនទៅតាមគោលដៅដែលខេត្តចង់បាន។

**តារាងបង្ហាញភាគរយភាពក្រីក្រតាមបណ្តាក្រុងស្រុកខេត្តព្រៃវែងឆ្នាំ២០១១-២០២៣**

| ក្រុង/ស្រុក | 2011 | 2012 | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 | 2020 | 2021 | 2022 | 2023 |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 1401.ស្រុកបាភ្នំ | 23.4 | 21.6 | 18.1 | 18.1 | 17.42 | 17.01 | 16.69 | 7.13 | 6.04 | 5.20 | 4.81 | 6.04 | 5.56 |
| 1402.ស្រុកកំចាយមារ | 24.8 | 22.8 | 16.4 | 16.1 | 16.17 | 16.05 | 16.07 | 9.97 | 8.06 | 7.32 | 6.04 | 8.06 | 6.03 |
| 1403.ស្រុកកំពង់ត្របែក | 25.3 | 23.7 | 18.5 | 19.6 | 19.87 | 19.25 | 18.83 | 9.09 | 7.69 | 6.89 | 6.49 | 7.69 | 5.85 |
| 1404.ស្រុកកញ្ជ្រៀច | 23.1 | 21 | 15.9 | 14.3 | 14.57 | 14.46 | 14.29 | 7.43 | 6.65 | 5.42 | 4.42 | 6.65 | 5.82 |
| 1405.ស្រុកមេសាង | 23.6 | 21.5 | 16.8 | 16 | 15.44 | 15.40 | 14.89 | 7.11 | 5.96 | 5.01 | 4.32 | 5.96 | 4.95 |
| 1406.ស្រុកពាមជរ | 27.8 | 24.3 | 21.1 | 20.8 | 20.62 | 20.14 | 19.86 | 14.22 | 12.86 | 11.28 | 10.50 | 12.86 | 8.70 |
| 1407.ស្រុកពាមរក៍ | 21.9 | 19.9 | 17.6 | 17.9 | 17.12 | 15.77 | 16.13 | 8.62 | 7.83 | 7.18 | 6.71 | 7.83 | 5.85 |
| 1408.ស្រុកពារាំង | 21.7 | 20 | 16.5 | 15.1 | 14.5 | 14.07 | 14.06 | 5.73 | 3.82 | 2.84 | 2.08 | 3.82 | 2.79 |
| 1409.ស្រុកព្រះស្តេច | 26.5 | 24.7 | 23.1 | 22.9 | 22.45 | 21.48 | 20.89 | 11.89 | 9.78 | 9.22 | 8.88 | 9.78 | 7.55 |
| 1410.ក្រុងព្រៃវែង | 9.1 | 9.2 | 10.3 | 10.1 | 10.35 | 10.85 | 10.52 | 3.49 | 4.20 | 3.29 | 2.71 | 4.20 | 2.49 |
| 1411.ស្រុកពោធិ៍រៀង | 22.5 | 20.7 | 14.7 | 13.7 | 14.32 | 14.38 | 14.66 | 8.68 | 7.83 | 6.26 | 5.93 | 7.83 | 5.52 |
| 1412.ស្រុកស៊ីធរកណ្តាល | 23.6 | 22.5 | 17.8 | 17.4 | 17.88 | 17.48 | 17.66 | 9.75 | 8.03 | 7.91 | 6.42 | 8.03 | 5.52 |
| 1413.ស្រុកស្វាយអន្ទរ | 21.3 | 20.1 | 16.6 | 17.2 | 16.05 | 15.89 | 16.30 | 8.55 | 7.49 | 6.70 | 5.66 | 7.49 | 3.76 |
| សរុបរួម | 23.7 | 21.9 | 17.8 | 17.6 | 17.33 | 16.92 | 16.77 | 8.86 | 7.40 | 6.60 | 5.85 | 5.01 | 5.41 |

ឆ្នាំ២០២៤នេះ ខេត្តព្រៃវែងមានអត្រាភាពក្រីក្រ ៥,៤១% គឺមានការកើន ០,៤០% បើធៀបនឹងឆ្នាំ២០២៣ (តួលេខតារាងលើគឺជាទិន្នន័យខែធ្នូនៃឆ្នាំនីមួយៗ ដែលសម្រាប់ប្រើប្រាស់នៅឆ្នាំបន្ទាប់ ឧទាហរណ៍ទិន្នន័យឆ្នាំ២០២៣ គឺប្រើសម្រាប់ឆ្នាំ២០២៤)។

**ក្រាហ្វិកបង្ហាញអត្រាភាពក្រីក្រឆ្នាំ២០២៤( ទិន្នន័យខែធ្នូ ឆ្នាំ២០២៣ )**




**ក្រាហ្វិកបង្ហាញអត្រាភាពក្រីក្រឆ្នាំ២០២៣( ទិន្នន័យខែធ្នូ ឆ្នាំ២០២២ )**




**ក្រាហ្វិកបង្ហាញអត្រាភាពក្រីក្រឆ្នាំ២០២២( ទិន្នន័យខែធ្នូឆ្នាំ២០២១ )**



## ១.២.២. ស្ថានភាពសង្គមកិច្ច

### ១.២.២.១. វិស័យអប់រំ

មន្ទីរអប់រំ យុវជន និងកីឡាខេត្ត មានការិយាល័យជំនាញក្រោមឪវាទមន្ទីរចំនួន ១៣ការិយាល័យ និងការិយាល័យអប់រំយុវជននិងកីឡាស្រុក-ក្រុងចំនួន១៣ ក្នុងនោះសាលារៀនសាធារណៈមានចំនួន ១,០៩២ ចែកចេញជាសាលាមត្តេយ្យសិក្សារដ្ឋចំនួន ៤១៦ ក្នុងនោះ មត្តេយ្យជាច់ដោយឡែក ៣០កន្លែង សាលាបឋមសិក្សារដ្ឋចំនួន ៥៥១កន្លែង អនុវិទ្យាល័យរដ្ឋចំនួន ៩២កន្លែង និងវិទ្យាល័យរដ្ឋចំនួន ៣៣កន្លែង សាលាឯកជនមាន ៧កន្លែង ក្នុងនោះសាលាមត្តេយ្យសិក្សាមាន ៥កន្លែង បឋមសិក្សាមាន ០៣ កន្លែង វិទ្យាល័យ ០១ កន្លែង និងមត្តេយ្យសហគមន៍ ៣៣៣ កន្លែង ក្នុងនោះជាប់មត្តេយ្យស្តង់ដាចំនួន ៨៤ កន្លែង។

ដោយមានកំណែទម្រង់របស់រាជរដ្ឋាភិបាល ក៏ដូចក្រសួងអប់រំ យុវជន និងកីឡា បានដាក់ឲ្យមន្ទីរអប់រំ យុវជន និងកីឡាអនុវត្តនូវថវិកាកម្មវិធី ដើម្បីធ្វើយ៉ាងណាឲ្យការរៀបចំថវិកាមានប្រសិទ្ធភាព តម្លាភាព និងចំគោលដៅ ឆ្លើយតបទៅនឹងកម្មវិធីកំណែទម្រង់ មន្ទីរអប់រំ យុវជន និងកីឡា បានរៀបចំនូវផែនការយុទ្ធសាស្ត្រវិស័យអប់រំ(ESP)២០២៤-២០២៨ ផែនការយុទ្ធសាស្ត្រថវិកា(BSP) ផែនការប្រតិបត្តិប្រចាំឆ្នាំ(AOP)និងរបាយការណ៍សមិទ្ធកម្មប្រចាំត្រីមាស/ឆមាស/និងប្រចាំឆ្នាំ ដើម្បីពិនិត្យតាមដានពីវឌ្ឍនភាពនៃការអនុវត្តសកម្មភាពការងារ សំដៅស្វែងរកដំណោះស្រាយ បញ្ហាប្រឈមទាំងនោះឲ្យបានទាន់ពេលវេលា។

**១-វឌ្ឍនភាពនៃការអនុវត្តសកម្មភាព**

មន្ទីរអប់រំ យុវជន និងកីឡាបានគ្រោងសកម្មភាពក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំ២០២៤ មានចំនួន ១០៩សកម្មភាព

**២-វឌ្ឍនភាពនៃការអនុវត្តថវិកា**

មន្ទីរអប់រំ យុវជន និងកីឡាបានគ្រោងថវិកាក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំ២០២៤ សរុបចំនួន ៩៦,៧៧២.៣៤ លានរៀល ក្នុងនោះថវិការដ្ឋចំនួន ៩៥,០១២.៨០ លានរៀល និងថវិកាដៃគូ ១,៧៥៩.៥ លានរៀល។

មន្ទីរបានបែងចែកកញ្ចប់ថវិកាតាមការិយាល័យជំនាញនិមួយៗ សម្រាប់យកទៅអនុវត្តកម្មវិធី អនុកម្មវិធីនិងសកម្មភាព



▪ **ផ្នែកវិស័យអប់រំកុមារតូច៖**

-ក្នុងខេត្តព្រៃវែងមានសាលារៀនមត្តេយ្យសិក្សាសរុបចំនួន ៤១៦ កន្លែង ក្នុងនោះសាលាមត្តេយ្យសិក្សាដាច់ដោយឡែកមានចំនួន ៣០ សាលា

-ក្នុងខេត្តព្រៃវែងមានសាលារៀនសហគមន៍សរុបចំនួន ៣៣៣កន្លែង

-ក្នុងខេត្តព្រៃវែងមានសាលារៀនមត្តេយ្យសិក្សាឯកជនសរុបចំនួន ០៥សាលា

- **សិស្សបានទទួលសេវាអប់រំ៖**

*ស្ថិតិផ្នែកមត្តេយ្យសិក្សា ឆ្នាំ២០២៣-២០២៤*

| បរិយាយ | ចំនួន | ផ្សេងៗ |
|---|---|---|
| មត្តេយ្យសិក្សារដ្ឋ | 416សាលា | |
| សិស្សសរុប | 19,580នាក់ | |
| ស្រី | 9,623នាក់ | |
| ថ្នាក់រៀន | 693 | |
| គ្រូបង្រៀនសរុប | 495នាក់ | |
| ស្រី | 447នាក់ | |
| មត្តេយ្យសិក្សាឯកជន | 5សាលា | |
| សិស្សសរុប | 153នាក់ | |
| ស្រី | 75នាក់ | |
| គ្រូបង្រៀនសរុប | 21នាក់ | |
| ស្រី | 18នាក់ | |
| មត្តេយ្យសិក្សាសហគមន៍ | 333កន្លែង | |
| សិស្សសរុប | 7721នាក់ | |
| ស្រី | 3945នាក់ | |
| គ្រូបង្រៀនសរុប | 355នាក់ | |
| ស្រី | 343នាក់ | |

▪ **ផ្នែកវិស័យបឋមសិក្សាមាន៖**

ខេត្តព្រៃវែងមានសាលារៀនបឋមសិក្សាសរុបចំនួន ៥៥១សាលា

-ចុះពិនិត្យតាមដានការអប់រំបឋមសិក្សានៅតាមគ្រឹះស្ថានសិក្សាការរៀននិងបង្រៀន។

-បានផលិតសម្ភារៈឧបទ្ទេសសម្រាប់រៀននិងបង្រៀន

-ចុះផ្សព្វផ្សាយដល់ថ្នាធរមូលដ្ឋានស្តីពីការចុះឈ្មោះចូលរៀននិងកុមារដល់វ័យចូលរៀន

- **សិស្សបានទទួលសេវាអប់រំ ៖**

*ស្ថិតិផ្នែកមធ្យមសិក្សា ឆ្នាំ២០២៣-២០២៤*

| បរិយាយ | ចំនួន | ផ្សេងៗ |
|---|---|---|
| កម្រង | 103 | |
| សាលារៀន | 551 | |

| | | |
|---|---|---|
| សាលាមិនគ្រប់កម្រិត | 13 | |
| ថ្នាក់រៀន | 4,604 | |
| សិស្សសរុប | 150,126 | |
| ស្រី | 70,502 | |
| បុគ្គលិកបង្រៀន | 4,150 | |
| ស្រី | 1,879 | |
| សិស្សក្រីក្រទទួលអាហារូបករណ៍ | 10,909 | |
| ស្រី | 5,692 | |
| សាលារៀនឯកជន | 2 | |
| ថ្នាក់រៀន | 11 | |
| សិស្សសរុប | 58 | |
| ស្រី | 24 | |
| បុគ្គលិកបង្រៀន | 17 | |
| ស្រី | 14 | |

**-ការលើកកម្ពស់គុណភាពអប់រំ និងភាពឆ្លើយតបះ**

## សូចនាករនៅបឋមសិក្សា(២០២២-២០២៣)

| សូចនាករ | ឡើងថ្នាក់ | ត្រួតថ្នាក់ | បោះបង់ |
|---|---|---|---|
| ថ្នាក់ទី១ | 86,6 | 9,9 | 3,4 |
| ថ្នាក់ទី២ | 88,1 | 7,1 | 4,7 |
| ថ្នាក់ទី៣ | 89,3 | 6,3 | 4,4 |
| ថ្នាក់ទី៤ | 90,5 | 5,6 | 3,9 |
| ថ្នាក់ទី៥ | 91,1 | 4,7 | 4,1 |
| ថ្នាក់ទី៦ | 85,3 | 3,3 | 11,4 |
| ថ្នាក់ទី១-៦ | 88,5 | 6,3 | 5,2 |
| អត្រាបញ្ចប់បឋមសិក្សាសរុបៈ 86,8 ស្រី85,6 ប្រុស88,0 | | | |

## សូចនាករឆ្នាំសិក្សា(២០២២-២០២៣)

| សូចនាករ | បឋម | អនុវិ. | វិទ្យាល័យ |
|---|---|---|---|
| អត្រារួមចូលរៀនថ្មី | 103,4/100,6 | | |
| អត្រាពិតចូលរៀនថ្មី | 87,5/86,0 | | |
| អត្រារួមនៃការសិក្សា | 99,9/96,2 | 62,3/66,0 | 44,1/49,7 |
| អត្រាពិតនៃការសិក្សា | 88,586,7 | 46,0/50,4 | 35,1/40,5 |
| ផលធៀបសិស្ស-គ្រូ | 54,7 | 32,3 | 27,5 |
| ផលធៀបសិស្ស-បុគ្គលិក | 37,8 | 23,6 | 24,8 |

| | | | |
|---|---|---|---|
| ផលធៀបសិស្ស-ថ្នាក់ | 32,7 | 46,4 | 48,5 |
| ផលធៀបសិស្ស-បន្ទប់រៀន | 41,7 | 48,9 | 48,6 |
| ផលធៀបថ្នាក់-បន្ទប់រៀន | 1,3 | 1,1 | 1,1 |

-ការសិក្សា ការបង្កើត និងដំណើរការគណៈកម្មការទ្រទ្រង់សាលារៀន- ថ្នាក់រៀននិងការចូលរួមរបស់សហគមន៍

-បានផ្សព្វផ្សាយ និងអនុវត្តសេចក្ដីណែនាំនានាទាក់ទងនឹងការកាត់បន្ថយអត្រាត្រួតថ្នាក់ និងបោះបង់ឆ្នាំសិក្សា២០២២-២០២៣។

-ផ្អែកតាមស្ថិតិខាងលើបង្ហាញថា៖ ចំនួនសាលាបឋមសិក្សាទូទាំងខេត្តមាន ៥៥១ សាលា

-លទ្ធផលតេស្ត៖ ថ្នាក់ជាតិប្រឡងឆមាសទី១សហកាជាមួយនាយកដ្ឋានគុណភាពអប់រំ

-បរិស្ថានសិក្សា៖ រៀបចំថ្នាក់សមស្របតាមនិយាម និងមានកាលវិភាគសម្រាប់សិស្សចូលបណ្ណាល័យ

-ការផ្គត់ផ្គង់សម្ភារៈសិក្សា៖ សិស្សមានសៀវភៅសិក្សាគោលគ្រប់មុខវិជ្ជាថ្នាក់ទី១/៣ក្បាលក្នុង១នាក់ ថ្នាក់ទី៤-៦/៤ក្បាលក្នុង១នាក់

-ការអនុវត្តម៉ោងកម្មវិធីសិក្សា៖ គ្រប់សាលា គ្រប់ថ្នាក់ បានអនុវត្តម៉ោងបង្រៀនបានត្រឹមត្រូវតាមកាលវិភាគកំណត់របស់ក្រសួងអប់រំ យុវជន និងកីឡា

-គ្រូបង្រៀនគ្រប់ថ្នាក់ បានអនុវត្តកម្មវិធីសិក្សាបង្រួញដោយផ្ដោតលើមុខវិជ្ជាបង្រៀន ភាសាខ្មែរ និងគណិតវិទ្យា តាមសេចក្តីណែនាំរបស់ក្រសួង ព្រមទាំងធ្វើបំណែងចែកកម្មវិធីសិក្សាបានច្បាស់លាស់គ្រប់កម្រិតថ្នាក់ជួយសិស្សរៀនយឺត ពីថ្នាក់ទី១ ដល់ថ្នាក់ទី៦

-អង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (ខេប) នៃគម្រោងងាយស្រួលរៀន ដែលគាំទ្រដោយអង្គការ ឆាលហ្វាន់ មាន១០សាលាគោលដៅ ព្រមទាំងជួយបណ្ណាល័យ អគារសិក្សា កែលម្អបរិស្ថានសាលា បង្កើនសមត្ថភាពដល់គ្រូ និងសម្ភារៈមួយចំនួនទៀតក្នុងខេត្តព្រៃវែង

-អង្គការរ៉ូមធូរីដបណ្តុះបណ្តាលការចុះជួយគាំទ្រគ្រូថ្នាក់ទី១-២ ជូននាយក នាយិកាសាលាគម្រោងឆ្នាំ២០១៩ក្នុងស្រុកបាភ្នំ និងស្រុកព្រះស្ដេច ចំនួន១៩នាក់ ស្រី០២នាក់

-អង្គការរ៉ូមធូរីដ បណ្តុះបណ្តាលស្តីពីកញ្ចប់អំណានថ្មីនៃកម្មវិធីកុមាររៀន កុមារចេះជូនដល់គ្រូបង្រៀនថ្នាក់ទី១ និងថ្នាក់ទី២ និងនាយក នាយិកាគម្រោងឆ្នាំ២០២១ក្នុងក្រុងព្រៃវែង-ស្រុកមេសាង-ព្រះស្ដេច និងស្រុកបាភ្នំចំនួន ២៦៩នាក់ ស្រី ១២១នាក់

-អង្គការរ៉ូមធូរីដ បណ្តុះបណ្តាលស្តីពីការគ្រប់គ្រងបណ្ណាល័យ គម្រោងឆ្នាំ២០១៨-២០១៩-២០២១ ជូនបណ្ណារក្ស និងនាយក នាយិកាក្នុងស្រុកមេសាង-ព្រះស្ដេចចំនួន ២៣៦នាក់ ស្រី ៤៨នាក់

-អង្គការ រ៉ូមធូរីដ បណ្តុះបណ្តាលស្តីពីម៉ោងបណ្ណាល័យគម្រោង២០២១ជូនគ្រូបង្រៀនថ្នាក់ទី១-៦មួយកម្រិតថ្នាក់១នាក់ និងនាយក នាយិកា ក្នុងស្រុកមេសាង-ព្រះស្ដេច ចំនួន ១៨៨នាក់ ស្រី ៩៨នាក់

-អង្គការ រ៉ូមធូរីដ ផ្តល់បណ្ណាល័យចំនួន ៣២សាលា ក្នុងស្រុកមេសាង ២៤សាលា ស្រុកព្រះស្ដេច ៨សាលា

-សាលារៀនមួយចំនួនបានចាក់ដីបំពេញទីធ្លាសាលារៀន ចាក់សាប រៀបការ៉ូក្នុងបន្ទប់ តបណ្តាញ

ភ្លើងបំពាក់កង្ហារក្នុងបន្ទប់រៀន និងចាក់បេតុងផ្លូវចូលសាលារៀន និងកែលម្អបរិស្ថានសាលារៀនជាបន្តបន្ទាប់

-បណ្តុះបណ្តាលដល់ប្រធានកម្រង នាយក គ្រូថ្នាក់ទី១-២ ស្តីពីការប្រើប្រាស់កញ្ចប់នៅផ្ទះ ដោយអង្គការ TTI ដើម្បីជួយគាំទ្រដល់ អ្នកអាណាព្យាបាលក្នុងការបង្រៀនកូននៅផ្ទះ

-សហការជាមួយអង្គការ យូនីសេហ្វ បំប៉នដល់គ្រូ នាយក និងក្រុមបំប៉ន ពិនិត្យតាមដានថ្នាក់ស្រុកក្រុង អនុវត្តកម្មវិធីវិន័យបែបវិជ្ជមាន និងការគ្រប់គ្រងថ្នាក់ឱ្យមានប្រសិទ្ធភាពនៅទូទាំងខេត្ត

-បានបណ្តុះបណ្តាលស្តីពីការប្រើប្រាស់សេចក្តីណែនាំប្រតិបត្តិកម្ម វិធីអាហារូបករណ៍ដល់សិស្សក្រីក្រនៅបឋមសិក្សា និងប្រព័ន្ធព័ត៌មានអាហារូបករណ៍ដល់មន្ទីរ ការិយាល័យ អយក ក្រុង/ស្រុក នាយកសាលា និងសហគមន៍

-កម្រង១០៣បានប្រជុំថ្ងៃព្រហស្បត៍រៀងរាល់ខែ១/ម្តង

-ចុះពិនិត្យតាមដាននិងវាយតម្លៃការងារអប់រំសុខភាពសិក្សាតាមគ្រឹះស្ថានសិក្សាសាធារណៈ

-សាលាគោលដៅ ១៤មានការគាំទ្រកម្មវិធីទឹកស្អាតនិងអនាម័យ (បន្ទប់ទឹក បង្គន់ និងបរិក្ខាលាងសម្អាតដៃ)

-យន្តការដឹកនាំ-គ្រប់គ្រងសាលារៀនមានដំណើរការល្អ និងការសិក្សាប្រកបដោយគុណភាព និងបរិយាប័ន្ន

-ចុះពិនិត្យតាមដានការអប់រំបឋមសិក្សានៅតាមគ្រឹះស្ថានសិក្សាការៀននិងបង្រៀន។

**៣-ផ្នែកវិស័យមធ្យមសិក្សា៖**

ខេត្តព្រៃវែងមានសាលារៀនសរុបចំនួន ១២៥ សាលា ក្នុងនោះ មានអនុវិទ្យាល័យ ៩២ និង វិទ្យាល័យ ៣៣៖និងមានវិទ្យាល័យគ្រឹះសាសនា(សាលាឯកជន)១កន្លែងចាប់ពីរថ្នាក់ទី១០ដល់១២

- **សិស្សបានទទួលសេវាអប់រំ** ៖

**ក-អនុវិទ្យាល័យមានចំនួន**

| បរិយាយ | ចំនួន | ផ្សេងៗ |
|---|---|---|
| សាលារៀន | 125 | |
| ថ្នាក់រៀន | 1093 | |
| សិស្សសរុប | 52,194 | |
| ស្រី | 26,878 | |
| បុគ្គលិកបង្រៀន | 1138 | |
| ស្រី | 383 | |
| សិស្សក្រីក្រទទួលអាហារូបករណ៍ | 8710 | |
| ស្រី | 5120 | |

**ខ-វិទ្យាល័យមានចំនួន**

| បរិយាយ | ចំនួន | ផ្សេងៗ |
|---|---|---|
| សាលារៀន | 33 | |
| ថ្នាក់រៀន | 1103 | |

| | | |
|---|---|---|
| សិស្សសរុប | 29,546 | |
| ស្រី | 16,110 | |
| បុគ្គលិកបង្រៀន | 1105 | |
| ស្រី | 335 | |
| សិស្សក្រីក្រទទួលអាហារូបករណ៍ | 540 | |
| ស្រី | 380 | |
| សាលារៀនឯកជន | 1 | |
| ថ្នាក់រៀន | 3 | |
| សិស្សសរុប | 135 | |
| ស្រី | 95 | |
| បុគ្គលិកបង្រៀន | 24 | |
| ស្រី | 10 | |

**-ការលើកកម្ពស់គុណភាពអប់រំ និងភាពឆ្លើយតបៈ**

**សូចនាករនៅមធ្យមសិក្សា(២០២២-២០២៣)**

| សូចនាករ | ឡើងថ្នាក់ | ត្រួតថ្នាក់ | បោះបង់ |
|---|---|---|---|
| ថ្នាក់ទី៧ | 86,0 | 0,7 | 13,2 |
| ថ្នាក់ទី៨ | 85,2 | 0,6 | 14,2 |
| ថ្នាក់ទី៩ | 78,1 | 1,8 | 20,1 |
| ថ្នាក់ទី១០ | 85,1 | 0,6 | 14,3 |
| ថ្នាក់ទី១១ | 90,6 | 0,3 | 9,1 |
| ថ្នាក់ទី១២ | 73,5 | 2,3 | 24,1 |
| ថ្នាក់ទី៧-៩ | 83,6 | 1,0 | 15,5 |
| ថ្នាក់ទី១០-១២ | 83,5 | 1,0 | 15,5 |
| អត្រាបញ្ចប់ម,បឋមភូមិ | 59,2/62,7 | | |
| អត្រាបញ្ចប់ម,ទុតិយភូមិ | 42,6/48,0 | | |

-មានសាលាមធ្យមសិក្សាបឋមភូមិតាមឃុំ-សង្កាត់ទូទាំងខេត្តមាន១១៦100%

-សាលារៀនមានបង្គន់អនាម័យ និង៩៥ % និងមានមានទឹកស្អាតប្រើប្រាស់67%

**វិទ្យាល័យមានចំនួន៣៣**

-វិទ្យាល័យមានគ្រប់ស្រុក-ក្រុង100 %មានបង្គន់អនាម័យនិង៩៨ %មានមានទឹកស្អាតប្រើប្រាស់45%

-ខេត្តមានវិទ្យាល័យគ្រប់ក្រុង/ស្រុកទាំង ១៣

-ក្នុងចំណោមវិទ្យាល័យទាំង ៣៣ មានវិទ្យាល័យធនធានចំនួន ៣ គឺស្រុកពារាំង១កន្លែង ស្រុកពាមរក៍ ១កន្លែង និងក្រុងព្រៃវែង១កន្លែង

-វិទ្យាល័យអង្គការមានចំនួន ០១ គឺវិទ្យាល័យចម្រើនវិជ្ជាស្ថិតនៅសង្កាត់បាវាយណ៍

-វិទ្យាល័យទាំងអស់នេះមានបង្គន់អនាម័យ ១០០% និងមានទឹកស្អាតប្រើប្រាស់ ៩៦,៧៧ %

-ការអនុវត្តម៉ោងសិក្សាកម្មវិធីសិក្សាៈថ្នាក់មធ្យមសិក្សាបឋមភូមិ និងទុតិយភូមិបានអនុវត្តម៉ោងជាទូទៅ ៣២ម៉ោង/សប្តាហ៍

-ការបង្រៀនតាមមុខវិជ្ជានីមួយៗបានផ្តោតទៅលើការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល និងការបង្រៀនតាមវិធីចម្រុះ(ប្រពៃណី-អនឡាញ-សន្លឹកកិច្ចការ..។) អន្តរមុខវិជ្ជាក្នុងកម្មវិធីសិក្សា ការប្រើប្រាស់សម្ភារៈឧបទ្ទេសបន្ទប់ពិសោធន៍ សម្រាប់មុខវិជ្ជាវិទ្យាសាស្ត្រទទួលបានការបណ្តុះបណ្តាលពីគម្រោង GEIP ។

-វិទ្យាល័យធនធាន៣ បានដំណើការបង្រៀន និងទទួលការបណ្តុះបណ្តាលកម្មវិធីពិសោធន៍ដល់គ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រ បំពាក់សម្ភារៈពិសោធន៍ នៅតាមបន្ទប់ពិសោធន៍នីមួយៗ។

- **សកម្មភាពសំខាន់ៗដែលសម្រេចបានសម្រាប់ការអប់រំកុមារី ៖**

១-បង្រៀនមេរៀនបំណិនជីវិត មេរៀនសុវត្ថិភាពផ្លូវដង្ហើម ដល់កុមារីថ្នាក់ទី៧-៨-៩ ចំនួន១៣,៤០

២-កុមារីថ្នាក់ទី៨ ចំនួន ១០១ នាក់ បានទទួលការបណ្តុះបណ្តាលកម្មវិធីជដែកដេញដោល។

-លទ្ធផលតេស្តៈគ្មាន

-បរិស្ថានសិក្សាៈ សាលាមានកាលវិភាគសម្រាប់ធ្វើពលកម្មជាប្រចាំ និងសម្អាតទីធ្លាសាលា/ក្នុងថ្នាក់រៀន

-ការផ្គត់ផ្គង់សម្ភារៈសិក្សាៈ សិស្សមានសៀវភៅសិក្សាគោលគ្រប់មុខវិជ្ជាថ្នាក់ទី៧/៩ក្បាលនាក់ថ្នាក់ទី១០-១២ក្បាលនាក់

-បែងចែកកញ្ចាប់ថវិកាកម្មវិធីនិង SOF ១២៥សាលារៀន សម្រាប់គាំទ្រដំណើរការបង្រៀន និងរៀន

-វិទ្យាល័យមានអគារធនធាន៣កន្លែងកំពុងដំណើរការមានថវិកាគាំទ្រ

-គ្រូបង្រៀនទាំងពីរភូមិសិក្សា និងទទួលបានចំណេះដឹងថ្មី និងបទពិសោធន៍បង្រៀនពីគ្នាតាមរយៈកិច្ចប្រជុំបច្ចេកទេសប្រចាំខែ/១ដង។

-ផ្តល់អាហារូបករណ៍សិស្សក្រីក្រមធ្យមសិក្សាបឋមភូមិ បានផ្តល់ដល់សាលាចំនួន ៧៥ មានសិស្សទទួលបានអាហារូបករណ៍សរុបចំនួន ៨,៧១០នាក់ ស្រី ៥,២០៣ នាក់ ថវិកាកម្មវិធី

-ផ្តល់អាហារូបករណ៍សិស្សក្រីក្រមធ្យមសិក្សាទុតិយភូមិ បានផ្តល់ដល់សាលាចំនួន០៦ មានសិស្សទទួលបានអាហារូបករណ៍សរុបចំនួន ៥៤០ នាក់ ស្រី ៣២៤ នាក់ ថវិកាកម្មវិធី

-បានទទួលការបំប៉នស្តីពីការគ្រប់គ្រងសាលារៀន និងរៀបចំផែនការ សម្រាប់ជួយដល់សាលារៀនពីគម្រោងកែលម្អការអប់រំមធ្យមសិក្សា។

-លោកគ្រូ អ្នកគ្រូបង្រៀនតាមវិទ្យាល័យមុខវិជ្ជាសាស្ត្រសង្គមចំនួន១៩៥នាក់ ស្តីពីការបញ្ជ្រាបមគ្គុទេសក៍អាជីព រៀបចំដោយនាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈក្រសួងអប់រំយុវជននិងកីឡា។

-លោកគ្រូអ្នកគ្រូបង្រៀនតាមវិទ្យាល័យធនធានទាំងមុខវិជ្ជាវិទ្យាសាស្ត្របានទទួលការបណ្តុះបណ្តាលស្តីពីការប្រើប្រាស់សម្ភារៈពិសោធន៍ រៀបចំដោយវិទ្យាស្ថានជាតិអប់រំ (NIE) ក្រសួងអប់រំយុវជននិងកីឡា។

**៤-ផ្នែកវិស័យអប់រំក្រៅប្រព័ន្ធ**

-គ្រូបង្រៀនជាប់កិច្ចសន្យា អប់រំក្រៅប្រព័ន្ធចំនួន ៨ នាក់ បានបណ្តុះបណ្តាលស្តីពីវិធីសាស្ត្របង្រៀនយុវជន និងកីឡាខេត្តព្រៃវែង

-កម្មវិធីសមមូលចំនួន ២៧ថ្នាក់ មានសម្ភារៈសម្រាប់ដំណើរការ

-គ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធចំនួន ៣៩នាក់ ត្រូវបានពិនិត្យ តាមដាន និងវាយតម្លៃលើការបង្រៀន និងរៀន

-ពង្រឹងគណៈគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍ទាំង១៤កន្លែង ឲ្យជាមជ្ឈមណ្ឌលស្តង់ដារ

-អនុវត្តតាមសេចក្តីណែនាំរបស់ក្រសួងស្តីពីការប្រើប្រព័ន្ធទិន្នន័យគ្រប់គ្រងអប់រំក្រៅប្រព័ន្ធ

-ពង្រឹងមន្ត្រីអប់រំឃុំ/សង្កាត់ក្នុងការប្រមូលទិន្នន័យ

-ពង្រឹងនិងលើកកម្ពស់កម្មវិធីអក្ខរកម្មឲ្យដល់មូដ្ឋាន(ជនបទ)

-មានថ្នាក់កម្មវិធីចូលរៀនឡើងវិញមានចំនួន ៤០ថ្នាក់ សិស្សសរុបចំនួន ១៨៦៧នាក់ ស្រី ៧០៨នាក់ មានសម្ភារៈគាំទ្រសម្រាប់ដំណើរការរបង្រៀននិងរៀន

-ថ្នាក់អក្ខរកម្ម ៧៨ កន្លែង មានសិស្សសរុបចំនួន ១,៤៧៥នាក់ ស្រី ១,០៥៣ នាក់ មានសម្ភារៈគាំទ្រសម្រាប់ដំណើរការរបង្រៀននិងរៀន

-ថ្នាក់សមូលមានថ្នាក់ ២៨ថ្នាក់ សិស្ស ៤៩០ នាក់ ស្រី ២៥៥ នាក់ មានសម្ភារៈគាំទ្រសម្រាប់ដំណើរការរបង្រៀននិងរៀន

-ថ្នាក់កម្មវិធីចូលរៀនឡើងវិញមាន ៣១ថ្នាក់ មានសិស្សសរុប ៥៥៩ នាក់ ស្រី ២២៨ នាក់

-ថ្នាក់បំពេញវិជ្ជាមាន ២កម្រិត ២ថ្នាក់ ទី៩ មាន១ថ្នាក់ សិស្សសរុប ១០ នាក់ ស្រី ៥ នាក់ និងថ្នាក់ទី១២ មាន ២ថ្នាក់ សិស្ស ៥៥ នាក់ ស្រី ២៦នាក់

-បណ្ណាល័យ ២កន្លែង មានឯកសារសម្ភារៈគាំទ្រសម្រាប់ដំណើរការ

-កម្មវិធី៨កញ្ញាមានប្រជាពលរដ្ឋចំនួន ៥៤០នាក់ ស្រី ២៨០នាក់ បានចូលរួមការផ្សព្វផ្សាយស្តីពីអត្ថន័យទិវាអក្ខរៈកម្មជាតិ៨កញ្ញា

**៥-ផ្នែកវិស័យកីឡា**

-ផ្សព្វផ្សាយសេចក្តីណែនាំស្តីពីការប្រកួតកីឡាសិស្ស និងកីឡាមហាជន

-បានបញ្ជូនមន្ត្រីជំនាញទៅចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្វឹក និងអាជ្ញាកណ្តាល

-មានគ្រូឯកទេសអប់រំកាយ និងកីឡានៅមធ្យមសិក្សាសរុបចំនួន ១៧១នាក់ ក្នុងនោះស្រី ១៧នាក់ កើន ១៨នាក់ ស្រី ០១នាក់ ក្នុងនោះបង្រៀននៅវិទ្យាល័យចំនួន ៩៧នាក់ ស្រី ១១នាក់ និងអនុវិទ្យាល័យចំនួន ៦៦នាក់ ស្រី ០៦នាក់ នៅមន្ទីរអប់រំយុវជននិងកីឡា ០៣នាក់ ស្រី ០នាក់ ផ្នែកកីឡាមហាជនមានគ្រូកីឡាតាមឯកទេសសរុបចំនួន ២២នាក់ ស្រី០១នាក់។

-មានទីលានបាល់ទាត់សរុប ៣៦ទីលាន បាល់ទះ ៩៤ទីលាន បាល់បោះ ១៨ទីលាន លោតកម្ពស់ និងចម្ងាយ ២១៤កន្លែង របាប្រតោង ៣២របាខ្សែ ពួរ ២១កន្លែង ប៉េតង់ ៥៧ទីលាន វាយសី ០១ទីលាន សីប៉ាក់តាក្រ(សីដក់)០៣ទីលាន និងវាយកូនឃ្លីលើតុ០៥(Table)។

-មានក្លឹបកីឡាបាល់ទាត់០២មានឈ្មោះថា ក្លិបកីឡាបាល់ទាត់ខេត្តព្រៃវែង(PVFC)ដែលមានឈ្មោះក្រៅហៅក្លិបអ្នកមានគុណនិងក្លិបវិទ្យាល័យព្រះអង្គឌួង។

-មានសម្ពន្ធ័កីឡាប៊ូល និងប៉េតង់ ដែលទទួលស្គាល់ដោយសហពន្ធ័ជាតិ

-បានរៀបចំការប្រកួតកីឡាសិស្ស និងកីឡាមហាជន ជ្រើសរើសជើងឯកថ្នាក់ខេត្ត និងដឹកនាំក្រុមកីឡាសិស្សបឋមនិងសិស្សមធ្យមសិក្សា និងកីឡាមហាជនចូលរួមប្រកួតជ្រើសរើសជើងឯកទូទាំងប្រទេស។

-ផ្សព្វផ្សាយសេចក្តីណែនាំស្តីពីការណែនាំកាលបរិច្ឆេទ នៃការប្រកួតកីឡាសិស្ស និងមហាជនជ្រើសរើសជើងឯកនៅថ្នាក់ខេត្ត ក្រុង-ស្រុក លើគ្រប់ប្រភេទវិញ្ញាសាដែលក្រសួងបានកំណត់។

-បញ្ជូនមន្ត្រីជំនាញចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្វឹកបាល់ទាត់ បាល់ទះ បាល់បោះ ប៉េតង់ វ៉ូវីណាម។

-រៀបចំសៀវភៅអប់រំកាយជូនដល់គ្រូគ្រប់កម្រិតថ្នាក់ នៅសាលាបឋមសិក្សា។

-បែងចែកសៀវភៅសិក្សាគោលលម្អិត អប់រំកាយ និងកីឡាកម្រិតមធ្យមសិក្សាបឋមភូមិ ជូនដល់គ្រប់ក្រុង-ស្រុកទូទាំងខេត្ត ពិសេសឲ្យដល់គ្រូអប់រំកាយ-កីឡាកម្រិតមូលដ្ឋាន។

-នៅថ្នាក់ខេត្តមានរចនាសម្ព័ន្ធដឹកនាំនិងគ្រប់គ្រង ការងារអប់រំកាយនិងកីឡា ឲ្យទទួលខុសត្រូវទៅតាមជំនាញអប់រំកាយនិងកីឡាសិស្ស-និស្សិតនិងកីឡាមហាជនតាមផ្នែកច្បាស់លាស់។

-បានបញ្ជូនមន្ត្រីអប់រំកាយ និងកីឡាចូលរួវគ្គបណ្តុះបណ្តាល បំប៉នការងារបច្ចេកទេសគ្រូបង្វឹក និងអាជ្ញាកណ្តាលតាមសេចក្តីជូនដំណឹងរបស់ក្រសួងបានកំណត់។

-បានចុះពិនិត្យ តាមដានសកម្មភាពអប់រំកាយនិងកីឡា នៅសាលាបឋមសិក្សា និងមធ្យមសិក្សា ០៨ស្រុក។

-បានដឹកនាំ និងចូលរួមប្រកួតកីឡាបាល់ទាត់ ពានរង្វាន់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន លើកទី១៥ ឆ្នាំ២០២១ ថ្នាក់ជាតិ។

-ចូលរួមការប្រកួតកីឡាបាល់ទាត់ពានរង្វាន់មិតហ្វូនខាបូឌាលីគ(លីគកំពូលកម្ពុជា)ឆ្នាំ២០២១

-ចូលរួមការប្រកួតកីឡាបាល់ទាត់ជ្រើសរើសជើងឯកយុវជនអាយុក្រោម ១៥ឆ្នាំ និង១៨ឆ្នាំ ថ្នាក់ជាតិ

-ការចូលរួមក្រកួតសិស្សមធ្យមថ្នាក់ខេត្តចំនួន ១២៨៨ នាក់ ស្រី ៥៤៤ នាក់ ស្មើ១០៨ក្រុម និង ៥វិញ្ញាសារបាល់ទាត់បុរស-នារី បាល់ទះបុរស-នារី បាល់បោះបុរស-នារី អត្តពលកម្មបុរស-នារី ប៉េតង់ បុរស-នារី។

-ការចូលរួមក្រកួតសិស្សមធ្យមថ្នាក់ខេត្តចំនួន ៨៤៣ នាក់ ស្រី ៣៣០ នាក់ ស្មើ ៦១ក្រុម និង ៣វិញ្ញាសារ បាល់ទាត់បុរស-នារី បាល់ទះបុរស-នារី និងអត្តពលកម្មបុរស-នារី ។

-កីឡាមហាជនថ្នាក់ជាតិ២៧នាក់ស្រី៣នាក់តទួលបានមេដាយមាសនិងប្រាក់៣នាក់

-ចូលរួមការប្រកួតកីឡាបាល់ទាត់ពានរង្វាន់ឯកឧត្តមស សុខា

-បានរៀបចំសម្ភារៈមេដាយពានប្រាក់រង្វន់សម្រាប់ក្រុមកីឡាជ័យលាភី

**៦-ផ្នែកវិស័យយុវជននិងកាយរិទ្ធ**

-រៀបចំក្រុមប្រឹក្សាយុវជននិងកុមារតាមសាលារៀនបឋមសិក្សានិងមធ្យមសិក្សាទូទាំងខេត្ត

- រៀបចំយុវជនកាកបាទក្រហមតាមសាលារៀនមធ្យមសិក្សាទូទាំងខេត្ត

-កាយរិទ្ធិ ៖ (សមាជិកពេញសិទ្ធិ) សមាជិកសរុបចំនួន ១,៦២៧ នាក់ ស្រី ៩៨០ នាក់

-នវកាយរិទ្ធិ (កាយរិទ្ធិត្រៀម) ៖ សមាជិកសរុបចំនួន ៥៩៨ នាក់ ស្រី ២៦៤ នាក់

-បើកវគ្គបណ្តុះបណ្តាល និងបំពាក់កន្សែងកាយរឹទ្ធបាន៣វគ្គ សរុប 144 ស្រី 104នាក់(គ្រូ-សិស្ស)

-ពង្រីកក្រុមប្រឹក្សាយុវជននិងកុមារតាមសាលារៀនបឋមសិក្សានិងមធ្យមសិក្សាទូទាំងខេត្ត

-ផ្តល់ប័ណ្ណសរសើរដល់កុមារពល្អ

-ក្រុមប្រឹក្សាយុវជនចំនួន២៧០នាក់ចូលរួមដំណើរ និងទស្សនកិច្ចសិក្សាក្រៅខេត្តដើម្បីផ្លាស់ប្តូរបទពិសោធន៍នៅខេត្តបាត់ដំបង-កំពតនិងសៀមរាប។

-បណ្តុះបណ្តាលសកម្មភាពយុវជន និងពិនិត្យតាមដាន និងវាយតម្លៃ តាមសាលារៀនទូទាំងខេត្ត

-បានចាត់មន្ត្រីចុះត្រួតពិនិត្យតាមដាននិងកែលម្អការងារយុវជន និងចូលរួមប្រជុំបូកសរុបចលនាពល្អនៅស្រុក និងសាលារៀនទាំងពីរកម្រិតទូទាំងខេត្ត

-មានដី០១កន្លែង សម្រាប់កសាងមជ្ឈមណ្ឌលយុវជនដែលមានអគារស្រាប់ចំនួន ០៣ អគារក្នុងនោះប្រើការបានចំនួន ០១ ខ្នង ។

-បានចូលរួមទិវាយុវជនអ្នកស្ម័គ្រចិត្តអន្តរជាតិ៥ធ្នូ នៅថ្នាក់ខេត្តក្រោមប្រធានបទ «ស្ម័គ្រចិត្តពេលនេះដើម្បីអនាគតរបស់យើងទាំងអស់គ្នា បន្តធ្វើសកម្មភាពមិនឈប់ឈរឡើយ» ក្រុមប្រឹក្សាយុវជនកាយរឹទ្ធ និងកាកបាទក្រហមចូលរួមចំនួន ១១៩ នាក់ ស្រី ៥៧ នាក់។

-បានចូលរួមទិវាយុវជនអ្នកស្ម័គ្រចិត្តអន្តរជាតិ៥ធ្នូថ្នាក់ជាតិ និងប្រកួតប្រជែងកម្មវិធីអ្នកស្ម័គ្រចិត្តដើម្បីសហគមន៍ខ្ញុំ មានអ្នកចូលរួមចំនួន ១៣ នាក់ ស្រី ៩ នាក់។

-នៅថ្នាក់ខេត្ត មានរចនាសម្ព័ន្ធគ្រប់គ្រងច្បាស់លាស់ បានបែងចែកភារកិច្ចជូនមន្ត្រីទទួលខុសត្រូវតាមផ្នែក និងមានផែនការសកម្មភាពច្បាស់លាស់។

-នៅថ្នាក់ស្រុកមានអនុប្រធានការិយាល័យ ០១ រូប និងមន្ត្រី០១រូបទទួលខុសត្រូវ។

-នៅថ្នាក់សាលារៀនរចនាសម្ព័ន្ធគ្រប់គ្រងមានគឺ ៖

**-ថ្នាក់ទី១** មានរចនាសម្ព័ន្ធជាក្រុមប្រឹក្សាភិបាល មានលោកនាយក នាយករង លោកគ្រូ អ្នកគ្រូ និងសហគមន៍ជាអ្នកគ្រប់គ្រងផ្តល់នូវចក្ខុវិស័យ និងផ្តល់ប្រឹក្សាយោបល់។

**-ថ្នាក់ទី២-៦** មានរចនាសម្ព័ន្ធជាគណៈកម្មាធិការប្រតិបត្តិប្រចាំសាលា មានសិស្សានុសិស្សជាអ្នកដឹកនាំផ្ទាល់ មានប្រធានអនុប្រធាន និងសមាជិកចំនួន៥ ទៅ ៧នាក់ ហើយបានសុំការអនុញ្ញាតពីក្រុមប្រឹក្សាភិបាលធ្វើ។

-បានរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងច្បាស់លាស់ បានបែងចែកភារកិច្ចជូនមន្ត្រីទទួលខុសត្រូវតាមផ្នែក និងមានផែនការសកម្មភាពច្បាស់លាស់។

- **ឆ្លងអនុវិស័យ**

## ៧-ការងារការិយាល័យប្រឡង

-បានផ្សព្វផ្សាយសេចក្ដីណែនាំស្ដីពីកំណែទម្រង់ការគ្រប់គ្រងការប្រឡងសញ្ញាបត្រមធ្យមសិក្សា ដោយអនុវត្តតាមគោលការណ៍ច្បាប់ យុត្តិធម៌ តម្លាភាព និងលទ្ធផលទទួលយកបាន " អ្នកចេះទើបប្រឡងជាប់ "

-ចូលរួមការពង្រឹងបន្ថែមការបញ្ចូលកម្មវិធីគ្រប់គ្រងទិន្នន័យសិស្សថ្នាក់ទី៩និងថ្នាក់ទី១២ របៀបបញ្ចូលឈ្មោះបញ្ចូលរូបថត បញ្ចូលពិន្ទុ ការកែតម្រូវ ការលុបបេក្ខភាព ការងារថតចម្លងបោះពុម្ព ខ្ចប់ Zip ឯកសារ សម្រាប់បញ្ជូនទៅក្រសួងអប់រំ យុវជន និងកីឡា។

-ទទួលពាក្យសុំប្រឡងរបស់បេក្ខជនថ្នាក់ទី១២ចំណេះទូទៅនិងស្វែរិន រួចបញ្ជូនទៅនាយកដ្ឋាន

-ចូលរួមសិក្ខាសាលាអាហារូបករណ៍ថ្នាក់ជាតិ។

-ចូលរួមសិក្ខាសាលា ការគ្រប់គ្រងទិន្នន័យការងារប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ និងកម្មវិធីបញ្ចូលឈ្មោះគណៈមេប្រយោគ។

-រៀបចំការប្រឡងសិស្សពូកែថ្នាក់ខេត្ត ។

-ធ្វើសំណើមណ្ឌលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ។

-រៀបចំនិងចុះព្រងឹងគណៈមេយោគប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិនិងទុតិយភូមិទូទាំងខេត្ត។

-ចែកសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិដល់សិស្សប្រឡងជាប់។

-ចុះពិនិត្យតាមដានការប្រឡងឆមាសថ្នាក់ទី៩និងទី១២និងការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ។

-បញ្ចូលឈ្មោះសិស្សថ្នាក់ទី៩ និងបោះពុម្ពដើម្បីឱ្យសាលាជួយពិនិត្យ និងកែតម្រូវ។

-បានរៀបចំធ្វើការប្រឡងសិស្សពូកែថ្នាក់ស្រុក។

-ដឹកនាំសិស្សពូកែទូទាំងខេត្តទៅចូលរួមប្រឡងជ្រើសរើសសិស្សពូកែថ្នាក់ជាតិ

- **លទ្ធផលទទួលបាន ៖**

### ក-ប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិៈ

- បេក្ខជនដាក់ពាក្យសរុបចំនួន ១២,៩៣៦ នាក់ ស្រី ៦,៨៥៤ នាក់
- បេក្ខជនមកប្រឡងសរុបចំនួន ១២,៨០៦ នាក់ ស្រី ៦,៧៩៩ នាក់
- បេក្ខជនប្រឡងជាប់សរុបចំនួន ១២,២៩៤ នាក់ ស្រី ៦៦៤៧ នាក់
- ត្រូវជា ៩៨.២% ស្រី៩៧.៧៩.%។

### ខ-ប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិៈ

- បេក្ខជនដាក់ពាក្យសរុប ៨,៣៧៣ នាក់ ស្រី ៤,៦២៩ នាក់
- បេក្ខជនមកប្រឡងសរុប ៨,២៧៣ នាក់ ស្រី ៤,៥៩២ នាក់
- បេក្ខជនប្រឡងជាប់សរុបចំនួន ៦,៧៨៩ នាក់ ស្រី ៤,០០០ នាក់
- ត្រូវជា ៨២,០៦% ស្រី ៨៧,១១%
- និទ្ទេស A= ១១៧ នាក់ ស្រី ៧០ នាក់
- និទ្ទេស B= ៧៦៧ នាក់ ស្រី ៤៨៣ នាក់

- និទ្ទេស C= ១៥៨២ នាក់ ស្រី ១០២៣ នាក់

- និទ្ទេស D= ២,២៩៤ នាក់ ស្រី ១,៣៤២ នាក់

- និទ្ទេស E= ២,០២៨ នាក់ ស្រី ១,០៨២ នាក់

- **ការប្រឡងសិស្សពូកែថ្នាក់ស្រុក ៖**
  - បេក្ខជនដាក់ពាក្យប្រឡងថ្នាក់ខេត្តសរុប ៤២៧ នាក់ ស្រី ២៩៨ នាក់ បានប្រឡងជាប់ ៣០ នាក់ ស្រី ២១ នាក់ ដើម្បីចូលរួមថ្នាក់ជាតិ។
  - បានបញ្ជូនសិស្សពូកែចំនួន ៣០ នាក់ ស្រី២១ នាក់ ចូលរួមប្រឡងថ្នាក់ជាតិនៅខេត្តភ្នំពេញ
- **លទ្ធផល**
  - ប្រឡងជាប់ ០៦ នាក់ ស្រី ២ នាក់ ក្នុងនោះមាន៖
  - មធ្យសិក្សាបឋមភូមិផ្នែកភាសាខ្មែរ ៣នាក់ ផ្នែកអក្សរសាស្ត្រខ្មែរ ទទួលបានលេខ ១,៣ និងផ្នែករូបវិទ្យាទទួលបានលេខ១
  - មធ្យមសិក្សាទុតិយភូមិផ្នែកគណិតវិទ្យាទទួលបានលេខ ៤ ផ្នែករូបវិទ្យាទទួលបានលេខ ១,២ ចុះពិនិត្យតាមដានគ្រឹះស្ថានមធ្យមសិក្សាចំនួន ១២ ត្រូវបានចុះពិនិត្យតាមដានការងារប្រឡងឆមាសទី១។

**៨-ការងារអធិការកិច្ច**

**ក-វឌ្ឍនភាពនៃការអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំយុវជននិងកីឡាផ្នែកលើសសរស្តម្ភ៥**

-ការដាក់ឱ្យអនុវត្តអធិការកិច្ច

-ការពង្រឹងនិងវាយតម្លៃការសិក្សា

**ខ-វឌ្ឍនភាពរបស់ការិយាល័យក៏ដូចជាការអនុវត្តអធិការកិច្ច**

-ក្នុងឆ្នាំ២០២៤ ការិយាល័យអធិការកិច្ចបានបំពេញការងារសំខាន់ៗដែលមានសកម្មភាពនិងលទ្ធផលដូចខាងក្រោម៖

-ធ្វើផែនការប្រតិបត្តិប្រចាំឆ្នាំ គម្រោងចំណាយថវិកាកម្មវិធីរៀបចំរចនាសម្ព័ន្ធ និងបំណែងចែកតួនាទីភារកិច្ចមន្ត្រីការិយាល័យ។

-ធ្វើផែនការកម្មវិធី និងឧបករណ៍អធិការកិច្ច

-បូកសរុបរបាយការណ៍អធិការកិច្ចសាលារៀនតាមការកំណត់របាយការណ៍ក្រុង/ស្រុក ឆមាសប្រចាំឆ្នាំ និងផ្តល់ដល់ក្រុង/ស្រុកដើម្បីសាលាមានមូលដ្ឋានក្នុងការកែលម្អសាលារៀន។

-ចូលរួមសិក្ខាសាលា ជាមួយនាយកដ្ឋានធានាគុណភាពអប់រំ។

**គ-ការពង្រឹងការវាយតម្លៃការសិក្សា:**

-ចូលរួមសិក្ខាសាលា ជាមួយក្រសួងនិងបានបន្តដល់សាលាគោលដៅតាមប្រព័ន្ធអនឡាញស្តីពីការប្រើប្រាស់ឧបករណ៍ពិនិត្យតាមដានសិស្សងាយរងគ្រោះ។

-ចូលធ្វើតេស្តថ្នាក់ជាតិ ថ្នាក់ទី៦លើចំនួនសាលាសំណាកចំនួន២៦ ក្នុងខេត្ត ចាប់ផ្តើមពីខែមករាឆ្នាំ២០២៤ ដោយមានការប្រជុំតាមអនឡាញពិនិត្យតាមដាន និងធ្វើបច្ចុប្បន្នភាពគ្រូសិស្សការធ្វើតេ

ស្តបន្សាំប្រចាំសប្តាហ៍តាម Link អនុរក្សតេស្តមកពីក្រសួងពីការិយាល័យអធិការកិច្ច និងមន្ត្រីការិយាល័យស្រុកដែលមានអនុរក្ស។

-ចុះផ្សព្វផ្សាយស្វ័យវាយតម្លៃតេស្តថ្នាក់ទី៨ និងថ្នាក់ទី១១

-ថ្នាក់ដឹកនាំមន្ទីរការិយាល័យអធិការកិច្ច ប្រធានការិយាល័យមធ្យមប្រធានការិយាល័យបឋមប្រធានការិយាល័យអប់រំកុមារតូចប្រធានការិយាល័យស្រុក/ក្រុងទាំង១៣រួមទាំងប្រធានកម្រង៩៨កម្រង។

-ការិយាល័យអធិការកិច្ច នាយក នាយិកាវិទ្យាល័យចំនួន ៣៣នាក់ នាយក នាយិកា អនុវិទ្យាល័យចំនួន៩២នាក់។

**៩-ការងារការិយាល័យផែនការនិងគ្រប់គ្រងជំនួយ:**

- **ការងារផែនការ-ស្ថិតិអប់រំ៖**

**-រៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ(ESP)២០២៤-២០២៨**

-បានរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ២០២៤។

-សហការរៀបចំផែនកាយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៤- ២០២៦។

-បានរៀបចំកម្មវិធីវិនិយោគ៣ឆ្នាំរំកិល ដើម្បីផ្តល់ជាធាតុចូលសម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍខេត្ត។

-ចុះសមាហរណកម្មផែនការនៅតាមក្រុង-ស្រុក។

-បានរៀបចំសិក្ខាសាលាស្តីពីការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀនដល់មន្ត្រីអប់រំថ្នាក់ក្រុង-ស្រុក និងនាយកសាលារៀនទូទាំងខេត្ត

- **កាងារស្ថិតិអប់រំ (ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ ) EMIS ៖**

-ប្រមូល និងបញ្ចូលទិន្នន័យតារាងជំរឿនសៀវភៅសិក្សាគោលតាមប្រព័ន្ធអនឡាញ (បឋម និង មធ្យមសិក្សា)។

-ប្រមូលនិងបញ្ចូលទិន្នន័យតារាងជំរឿនសាលារៀនសាធារណៈតាមប្រព័ន្ធអនឡាញសរុបចំនួន ១,០៩២ សាលា មត្តេយ្យសិក្សាចំនួន ៤១៦ បឋមសិក្សាចំនួន ៥៥១ និងមធ្យមសិក្សាចំនួន ១២៥ សាលា។

-ប្រមូល និងបញ្ចូលទិន្នន័យតារាងជំរឿនសាលារៀនឯកជនតាមប្រព័ន្ធអនឡាញ ចំនួន ០៧ សាលា។

-ប្រមូល និងបញ្ចូលទិន្នន័យតារាងជំរឿនមត្តេយ្យសិក្សាសហគមន៍តាមប្រព័ន្ធអនឡាញចំនួន ៣១៦សាលា។

-បូកសរុបស្ថិតិអប់រំគ្រប់ប្រភេទ ដើម្បីប្រើប្រាស់ផ្ទៃក្នុងអង្គភាព។

- **ការងារពិនិត្យតាមដាន និងវាយតម្លៃ៖**

-រៀបចំរបាយការណ៍សមិទ្ធកម្ម៤ដង/ឆ្នាំ(ត្រីមាស/ឆមាសនិងប្រចាំឆ្នាំ)ជូនក្រសួងអប់រំ យុវជន និងកីឡា។

-សម្របសម្រួល និងគាំទ្រដល់ការរៀបចំរបាយការណ៍សមិទ្ធកម្មប្រចាំត្រីមាស ឆមាស និង ប្រចាំឆ្នាំដល់ថ្នាក់ខេត្ត ស្រុក ក្រុង និងសាលារៀន។

-រៀបចំសិក្ខាសាលាពង្រឹកការរៀបចំរបាយការណ៍សមិទ្ធកម្មដល់ថ្នាក់ក្រុង-ស្រុកនិងសាលារៀន។

- **ការងារសំណង់៖**

-ធ្វើបច្ចុប្បន្នភាពស្ថិតិអគារសិក្សាតាមប្រភេទម្ចាស់អំណោយ។

-បញ្ជូនសំណើសុំអគារសិក្សាទៅក្រសួងអង្គភាពនានាសប្បុរសជននិងក្រុមការងារចុះជួយខេត្តព្រៃវែង។

- **ការងារគ្រប់គ្រងសៀវភៅសិក្សាគោល៖**

-បានផ្គត់ផ្គង់សៀវភៅសិក្សាគោលដល់សាលារៀនទូទាំងខេត្ត។

-ចុះពិនិត្យតាមដានការគ្រប់គ្រង និងការប្រើប្រាស់សៀវភៅសិក្សាគោលនៅតាមសាលារៀន។

-បានរៀបចំតម្រូវការសៀវភៅសិក្សាគោលសម្រាប់ឆ្នាំសិក្សា២០២២-២០២០៣។

- **ការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ២០២៤៖**

-គាំទ្រការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀនដល់ថ្នាក់ខេត្ត ស្រុក ក្រុង និងសាលារៀន។

-សម្របសម្រួលការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០២៤-២០២៨ដល់ថ្នាក់ក្រុង-ស្រុក។

-គាំទ្រ និងពង្រឹងយន្តការប្រមូលស្ថិតិទិន្នន័យអប់រំគ្រប់ប្រភេទនិងការបញ្ចូលទិន្នន័យតាមប្រព័ន្ធអនឡាញ។

-ពង្រឹងយន្តការការគ្រប់គ្រង និងការប្រើប្រាស់សៀវភៅសិក្សាគោលនៅតាមគ្រឹះស្ថានសិក្សាសាធារណៈគ្រប់ភូមិសិក្សា។

**១០-ការងារការិយាល័យបុគ្គលិកៈ**

-រៀបចំឯកសារបើកផ្តល់ប្រាក់បៀវត្សប្រចាំខែជូនបុគ្គលិកអប់រំទូទាំងខេត្ត។

-រៀបចំ និងសម្រួលក្នុងការបើផ្តល់ប្រាក់ម៉ោងបន្ថែមជូនដល់បុគ្គលិកអប់រំទូទាំងខេត្ត។

-រៀបចំឯកសារមន្ត្រីអប់រំចូលនិវត្តន៍។

-បែងចែកគ្រូចេញថ្មីទៅតាមសាលារៀនដែលខ្វះគ្រូ។

-ចុះពិនិត្យតាមដាន និងវាយតម្លៃការងារបុគ្គលិកអប់រំ យុវជន និងកីឡា។

-រៀបចំឯកសារតម្លើងថ្នាក់តាមវេនប្រចាំឆ្នាំ និងតាមសញ្ញាបត្រ។

-ចុះពិនិត្យតាមដាន និងវាយតម្លៃការងារបុគ្គលិកអប់រំ យុវជន និងកីឡាតាមគ្រឹះស្ថានសិក្សា

**១១-ការងារការិយាល័យគណនេយ្យៈនិងទ្រព្យសម្បត្តិរដ្ឋ**

-បានរៀបចំគ្រោងថវិកាBSP២០២៤-២០២៦

-បានរៀបចំគ្រោងថវិកាឆ្នាំ២០២៥

-ផ្គតផ្គង់សម្ភារដល់ការិយាល័យទាំង១៣

-បានបណ្តុះបណ្តាលគ្រូបង្រៀនជាប់កិច្ចសន្យាផ្នែកបឋមសិក្សា។

-បានជួសជុលវេទិកានិងចាក់ដីបំពេញទីលានបាល់ទាត់របស់មន្ទីរអប់រំ យុវជន និងកីឡាខេត្ត និងបរិវេណសាលាបឋមសិក្សាក្រាំងភ្កែក ក្នុងក្រុងព្រៃវែង។

-បើកវគ្គបំប៉នដល់នាយក-នាយិកា និងហេរញ្ញិកអំពីប្រព័ន្ធគ្រោងថវិកា និងរបាយការណ៍ថវិកា។

-បើកវគ្គបំប៉នដល់នាយក-នាយិកា និងមន្ត្រីការិយាល័យអប់រំយុវជននិងកីឡាក្រុង-ស្រុកអំពីកិច្ច

-ចុះអធិការកិច្ច ពិនិត្យតាមដាន និងវាយតម្លៃតាមសាលារៀន

**១២-ការងាររដ្ឋបាល**

-ផ្សព្វផ្សាយចំលិខិតបទដ្ឋាននានាដល់សាលារៀននិងអ្នកពាក់ព័ន្ធ

-រៀបចំរបាយការណ៍សន្និបាទអប់រំ២០២២-២០២៣និងលើកទិសដៅ២០២៣-២០២៤

-រៀបចំការប្រជុំអាណត្តិរៀងរាល់១/ខែ

-បញ្ជូនរបាយការណ៍១/ខែទៅសាលាខេត្ត

**១៣-ការងារសុខភាពសិក្សា**

-ផ្សព្វផ្សាយលិខិតណែនាំការសំអាតអនាម័យ ដល់សាលារៀននិងអ្នកពាក់ព័ន្ធ

-ណែនាំដល់នាយក/នាយិកាលោកគ្រូអ្នកគ្រូការអនាម័យនិងបរិស្ថានសាលា

-ណែនាំអ្នកលក់ក្នុងសាលារៀនឱ្យមានអនាម័យនិងជួយសំអាតបរិស្ថានជាប្រចាំ

-ចូលរួមសិក្ខាសាលាជាមួយថ្នាក់ជាតិ

-ផ្តល់បង្គន់អនាម័យដល់សាលាដែលខ្វះចំនួន២៤សាលា

-ចុះពិនិត្យតានដានតាមគ្រឹះស្ថានសិក្សាទាំង៣កម្រិតពីការប្រើប្រាស់ចំណីអាហារ

- **ចំណុចខ្លាំង:**

-ប្រជុំពិភាក្សាកសាងផែនការយុទ្ធសាស្ត្រវិស័យអប់រំ(ESP)២០២៤-២០២៨

-ប្រជុំពិភាក្សាកសាងផែនការប្រតិបត្តិប្រចាំឆ្នាំ(AOP)

-ប្រជុំពិភាក្សាកសាងផែនការយុទ្ធសាស្ត្រថវិកា២០២៤-២០២៦

-រៀបចំរបាយការណ៍សមិទ្ធកម្មបួនដងក្នុង១ឆ្នាំគឺប្រចាំត្រីមាស/ឆមាស/ប្រចាំឆ្នាំបញ្ជូនទៅក្រសួងអប់រំ

-សកម្មភាពកីឡាមានការចូលរួម៖សិស្សបឋម+មធ្យម+និស្សិត+មហាជន

-ក្រុមប្រឹក្សាកុមារនិងយុវជនត្រូវបានពង្រីកតាមសាលារៀនលើកកំពស់ការចូលរួមគ្រប់សកម្មភាព

-ផ្សព្វផ្សាយការបណ្តុះបណ្តាលអំពីសហគ្រិនភាពដល់យុវជនក្រៅនិងក្នុងសាលា

-ប្រជុំអាណត្តិរៀងរាល់១ខែម្តង(ប្រធាន/អនុប្រធានការិ.នាយក/នាយិកាកម្រងសាលាទូទាំងខេត្ត)

-អធិការកិច្ចការសាលារៀននិងគ្រូបង្រៀនតាមសាលាគ្រប់កម្រិតគ្រឹះស្ថានសិក្សាទាំ៣កម្រិត

-បង្កើនកិច្ចសហការជាមួយអាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងស្ថាប័នពាក់ព័ន្ធស្តីពីអនាម័យនិងចំណីអាហារ

-កៀរគរធនធាន អង្គការដៃគូអភិវឌ្ឍដើម្បីជួយលើវិស័យអប់រំ

-ជំរុញដល់អាជ្ញាធរដែនដីនិងសហគមន៍ ដើម្បីចូលរួមក្នុងការងារមត្តេយ្យសិក្សាសហគមន៍តាមភូមិ

-ចុះជួយពិនិត្យនិងកែសម្រួល លើការរៀបចំផែនការសម្រាប់អភិវឌ្ឍសាលារៀន

- **ចំណុចខ្សោយ:**

-មន្ទីរអប់រំពុំមានលទ្ធភាពជួសជុលអគារសិក្សា និងបង្គន់អនាម័យដែលមានសភាពទ្រុឌទ្រោម

-មន្ទីរអប់រំពុំមានលទ្ធភាពសាងសង់អគារសិក្សា

-មន្ទីរអប់រំពុំមានលទ្ធភាពសាងសង់បណ្ណាល័យ

- **បញ្ហាប្រឈមៈ**

-ការសិក្សារបស់សិស្សក្រីក្រគ្រប់កម្រិតថ្នាក់ មិនបានគ្រប់គ្រាន់ទាំងនៅសាលា និងនៅផ្ទះ មូលហេតុជួយធ្វើការងារឳពុកម្តាយ ស្រែចំការ និងធ្វើកម្មករសំណង់ រោងចក្រ និងកន្លែងផ្សេងៗទៀត ក្នុងប្រទេស និងចំណាកស្រុកជាដើម។

-ខ្វះអគារ និងសម្ភារៈសិក្សាមត្តេយ្យ+បឋម+មធ្យមសិក្សា

-ខ្វះគ្រូមត្តេយ្យ-គ្រូបឋម

-មត្តេយ្យសិក្សាសហគមន៍ពុំមានការគាំទ្រលើការប្រជុំបច្ចេកទេសប្រចាំខែ និងវគ្គបំប៉នបច្ចេកទេសដល់គ្រូជាប់ស្តង់ដា។

-លំបាកក្នុងការធ្វើទំនាក់ទំនងជាមួយអាណាព្យាបាលសិស្សមួយចំនួន ព្រោះចំណាកស្រុក

-អគារសិក្សាមួយចំនួនទ្រុឌទ្រោមពុំមានថវិកាជួសជុល

-កង្វះតុសិស្សបឋមសិក្សានិងមធ្យមសិក្សា

-លិខិតរុះរើអគារសិក្សាទ្រុឌទ្រោមមានការយឺតយ៉ាវ

-កង្វះគ្រូមធ្យមសិក្សាបឋមភូមិនៅតាមសាលាមួយចំនួន(ជនបទ)

-កង្វះគ្រូមធ្យមសិក្សាទុតិយភូមិនៅតាមសាលាមួយចំនួន(ជនបទ)

-ខ្វះបង្គន់អនាម័យ និងអណ្តូងទឹក កន្លែងសម្អាតលាងដៃ

-ខ្វះគ្រូអប់រំកាយនិងកីឡានៅតាមសាលាអនុវិទ្យាល័យនិងវិទ្យាល័យទូទាំងខេត្ត

-សាលាមត្តេយ្យសិក្សាមានកំណើនកើន ប៉ុន្តែខ្វះគ្រូ និងបន្ទប់រៀន

-ការអប់រំកុមារតូចតាមសហគមន៍ កំពុងជួបប្រទះការលំបាកច្រើនដូចជាៈ គ្រូបង្រៀនជាប់កិច្ចសន្យាមានថវិកាឧបត្ថម្ភទាប

-ខ្វះអគារសិក្សាមត្តេយ្យសិក្សាសហគមន៍ សម្ភារៈបង្រៀន និងសម្ភារៈល្បែងសិក្សាមានតិចតួច ឬកន្លែងខ្លះគ្មានសម្ភារៈល្បែងសិក្សា។

### ១.២.២.២. វិស័យសុខាភិបាល

មន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តព្រៃវែង ក្នុងឆ្នាំ២០២៤ បានរៀបចំពង្រីកហេដ្ឋារចនាសម្ព័ន្ធស្រុកប្រតិបត្តិ មន្ទីរពេទ្យបង្អែកខេត្ត/ស្រុក មណ្ឌលសុខភាព ទៅតាមស្រុករដ្ឋបាលទូទាំង ខេត្តមានស្រុកប្រតិបត្តិ ១២ កន្លែង គឺមន្ទីរពេទ្យបង្អែកខេត្ត ០១ កន្លែង និងមន្ទីរពេទ្យបង្អែកស្រុកប្រតិបត្តិ ១១ កន្លែង ចំណែកមណ្ឌលសុខភាពមាន ១១៤ កន្លែង ប៉ុស្តិ៍សុខភាព ០៦ កន្លែង។ បានរៀចំដាក់ក្រុមគ្រូពេទ្យនៅតាមច្រកទ្វារព្រំដែន (ក្រុមចត្តាឡីស័ក) ជាមួយប្រទេសវៀតណាមចំនួន ៦ កន្លែង។ រថយន្តគិលានសង្គ្រោះបញ្ជូនជំងឺទូទាំងខេត្តដែលដំណើរការមានចំនួន ៦០ គ្រឿង។

- **ការងារសម្រាប់ឆ្នាំ២០២៤ និងឆ្នាំបន្ទាប់៖**
  - ពង្រឹងសមត្ថភាពមន្ត្រីថ្មីនៅមណ្ឌលសុខភាព និងស្រុកប្រតិបត្តិ ស្តីអំពីសេវាមូលដ្ឋាន
  - ពង្រឹងការផ្តល់សេវាផ្តល់ថ្នាំបង្ការដល់កុមារ និងស្ត្រី
  - ពង្រឹងការទំនាក់ទំនងជាមួយអាជ្ញាធរមូលដ្ឋានបន្ថែម

- ស្រាវជ្រាវរកកុមារ និងស្ត្រីដែលនៅសេសសល់ដើម្បីផ្ដល់ថ្នាំបង្ការ
- ពង្រឹង និងពង្រីកប្រព័ន្ធតាមដាន និងឆ្លើយតបរួមគ្នា ឱ្យកាន់តែល្អប្រសើរ
- តាមដានជំងឺ១០មុខ និងជំងឺរាតត្បាតផ្សេងៗ អោយបានទៀងទាត់រាល់សប្ដាហ៍ ជាពិសេសតាមព្រំដែនច្រកចេញចូល ដែលមានចរាចរសត្វ
- ពង្រឹងរចនាសម្ព័ន្ធការគ្រប់គ្រងជំងឺមិនឆ្លង
- ពង្រឹងសមត្ថភាពមន្ត្រីទទួលបន្ទុក ជាពិសេសបណ្តុះបណ្តាលជំនាញឯកទេស
- លើកកម្ពស់ប្រុងប្រយ័ត្នទប់ស្កាត់គ្រោះមហន្តរាយ និងជំងឺមិនឆ្លងនានា ដែលមានកើតដោយចៃដន្យ
- ពង្រឹងការទុកដាក់កាកសំណល់ ក្នុងមន្ទីរពេទ្យ និងមណ្ឌលសុខភាព
- ពង្រឹងសមត្ថភាពបុគ្គលិកតាមរយៈការបណ្តុះបណ្តាលក្រមសីលធម៌វិជ្ជាជីវៈ
- ធ្វើការបែងចែកថវិកាទៅដល់មូលដ្ឋានសុខាភិបាលឱ្យស្របតាមយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល
- ពង្រឹងការទុកដាក់ឯកសារ បែបបទរដ្ឋបាល វិន័យការងារ
- ពង្រឹងប្រព័ន្ធរបាយការណ៍តាមប្រព័ន្ធអេឡិចត្រូនិចតាមរយៈការបណ្តុះបណ្តាលផ្តល់ជំនួយបច្ចេកទេសដល់មូលដ្ឋាន
- ពង្រឹងការងារបញ្ចូលទិន្នន័យរបាយការណ៍ឱ្យបានទាន់ពេលវេលា
- ពង្រឹងការប្រមូលទិន្នន័យព័ត៌មានសុខាភិបាលពីសេវាឯកជនស្របច្បាប់
- ពង្រឹងការប្រជុំរបស់លេខាធិការដ្ឋាន និងការប្រជុំប្រចាំខែរបស់ក្រុមការងារបច្ចេកទេសសុខាភិបាលខេត្តឱ្យបានទៀងទាត់
- ពង្រឹងការងារគ្រប់គ្រងកិច្ចសន្យាឲ្យកាន់តែល្អប្រសើរ ជាពិសេសការងារផ្តល់សេវាឲ្យកាន់តែមានគុណភាព និងប្រសិទ្ធភាពជូនអតិថិជន
- បន្តផ្សព្វផ្សាយអប់រំ ដើម្បីលើកកំពស់ការយល់ដឹងដល់សាធារណៈជន អំពីការប្រើប្រាស់ឱសថក្លែងក្លាយ និងសេវាសុខាភិបាលខុសច្បាប់។
- ខិតខំស្វែងរកប្រភពឱសថក្លែងក្លាយ និងសេវាឯកជនខុសច្បាប់ និងចាត់វិធានការប្រកបដោយប្រសិទ្ធិភាព
- តាមដាន និងត្រួតពិនិត្យជាប្រចាំនូវរាល់ការចែកចាយ តាំងលក់ឱសថ និងការផ្តល់សេវាក្នុងវិស័យសុខាភិបាល។

- **លទ្ធផលសម្រេចបានក្នុងឆ្នាំ២០២៤**
  - ពិនិត្យមើលទៅលើសូចនាករមួយចំនួនសម្រាប់ការវាស់វែងស្នាដៃរ លទ្ធផលការងាររបស់ប្រព័ន្ធសុខភាពនៃមន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តព្រៃវែង មានសូចនាករខ្លះបានសំរេចទៅដល់គោលដៅ និងខ្លះទៀតមិនទៅដល់គោលដៅកំណត់
  - ការផ្តល់សេវាពិគ្រោះជំងឺក្រៅទូទាំងខេត្តបានធ្លាក់ចុះ០.១៦ ភាគរយតិចជាងឆ្នាំ២០២៣ ហើយ និងមិនដល់គោលដៅកំណត់ បើប្រៀបធៀបទៅគោលដៅប្រចាំឆ្នាំ

- អត្រាប្រើប្រាស់គ្រែទូទាំងខេត្តបានតែ ៥៧.៤០% កើនឡើងជាងឆ្នាំ២០២៣ តែមិនទាន់ដល់គោលដៅបើប្រៀបធៀបទៅគោលដៅប្រចាំឆ្នាំ
- ចំនួនថ្ងៃនៃការសម្រាកពេទ្យជាមធ្យមគឺ៤.៦៣ថ្ងៃ មានលទ្ធផលប្រហាក់ប្រហែលទៅឆ្នាំ២០២៣ និងគោលដៅប្រចាំឆ្នាំ
- មានតែសូចនាករចំនួន២ ដែលបានសម្រេចដល់គោលដៅប្រចាំឆ្នាំ មានភាគរយនៃស្ត្រីមានគភ៌បានថ្នាំគ្រាប់ជាតិដែកអាស៊ីតហ្វូលីក ៩០ គ្រាប់ និងភាគរយនៃស្ត្រីក្រោយសំរាលបានទទួលថ្នាំគ្រាប់ជាតិដែកអាស៊ីតហ្វូលីក ៤២ គ្រាប់
- សូចនាករ២ផ្សេងទៀតបានគៀកគោលដៅប្រចាំឆ្នាំ មានអត្រាគ្របដណ្តប់នៃវ៉ាក់សាំង ៣ដូសបង្ការជំងឺខាន់ស្លាក់ ស្វិតដៃជើង តេតាណូស រលាកសួត និងភាគរយនៃកុមារបានទទួលការបំបៅដោយទឹកដោះម្តាយក្នុងអំឡុងពេលមួយម៉ោងដំបូងក្រោយកំណើត
- អត្រាព្យាបាលជំងឺរបេងបានជោគជ័យ ១០០%
- អត្រាស្លាប់នៃជំងឺគ្រុនចាញ់ និងអត្រាស្លាប់ដោយជំងឺគ្រុនឈាម 0%
- សេវាថែទាំ និងព្យាបាលជំងឺកាមរោគមានគ្លីនិក ២ កន្លែង បានផ្តល់សេវាពិនិត្យពិគ្រោះ និងព្យាបាលជំងឺមានចំនួនសរុប ១,៣៧០ ករណី
- សេវាថែទាំអ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍មាន៣កន្លែង បានផ្តល់សេវាពិនិត្យ ព្យាបាលអ្នកផ្ទុកមេរោគនិងអ្នកជំងឺអេដស៍លើមនុស្សពេញវ័យ និងកុមារ សរុបចំនួន ២,៩៩៩ នាក់
- ភាគរយនៃប្រជាជនអាយុពី ២៥-៦៤ឆ្នាំ មានជំងឺលើសសម្ពាធឈាមបានទទួលការព្យាបាលមានការកើនឡើង
- ភាគរយនៃស្ត្រីអាយុ ៣០-៤៩ឆ្នាំ ដែលបានទទួលការស្រាវជ្រាវរកជម្ងឺមហារីកមាត់ស្បូនយ៉ាងតិចមួយលើក ក៏មានការកើនឡើងដែរ តែនៅទាបជាងគោលដៅ
- ភាគរយនៃប្រជាជនអាយុពី ២៥-៦៤ឆ្នាំ មានជំងឺទឹកនោមផ្អែមបានទទួលការព្យាបាលមានការកើនឡើង
- ប្រជាជនពេញវ័យមានជំងឺធ្លាក់ទឹកចិត្តបានទទួលសេវាព្យាបាល ទាបជាងគោលដៅ តែមាននិន្នាការកើនឡើងជាប្រចាំ
- អត្រាវះកាត់ជម្ងឺភ្នែកឡើងបាយក្នុងប្រជាជន១០០០..០០០នាក់ មានការកើនឡើង
- មានករណីរបួសគ្រោះថ្នាក់សារចរណ៍ និងដោយសារគ្រឿងស្រវឹងមានចំនួន ៨៤៩ ករណី
- មិនមានគ្រោះធម្មជាតិនៅក្នុងខេត្តព្រៃវែងទេ ។

- **បញ្ហាប្រឈម និងឧបសគ្គចម្បងៗ៖**
  - មន្ទីរពេទ្យបង្អែកខ្លះមិនមានអគារសមស្របគ្រប់គ្រាន់សម្រាប់អ្នកជំងឺសម្រាកព្យាបាល

- គុណភាពនៃសេវាសង្គ្រោះសម្គពបន្ទាន់ និងសេវាថែទាំនិងសង្គ្រោះទារកបន្ទាន់ ទាមទារឲ្យពង្រីកបន្ថែម និងកែលម្អឲ្យកាន់តែប្រសើរថែមទៀត
- សមត្ថភាពបច្ចេកទេសនៃសេវាមន្ទីរពិសោធន៍នៅតាមមន្ទីរពេទ្យបង្អែកមានកម្រិត ក្នុងការគាំទ្រដល់ការធ្វើរោគវិនិច្ឆ័យនៅថ្នាក់ខេត្ត មន្ត្រីបច្ចេកទេសមិនគ្រប់គ្រាន់តាមតម្រូវការ ពិសេសតំបន់ដាច់ស្រយាល
- ការផ្គត់ផ្គង់បរិក្ខារពេទ្យ ដល់មូលដ្ឋា សុខាភិបាលនឆ្លើយតបទៅនឹងតម្រូវការជាមូលដ្ឋាន
- ខ្វះការចូលរួមពីសំណាក់ក្រុមប្រឹក្សាឃុំ ប៉ុស្តិ៍នគរបាល ក្នុងសកម្មភាពទប់ស្កាត់ការចែកចាយនិងទីតាំងលក់ឱសថ អ្នកប្រកបសេវាសុខាភិបាលឯកជនដែលគ្មានច្បាប់អនុញ្ញាត ជាពិសេសអ្នកដើរចាក់ថ្នាំដែលគ្មានសញ្ញាបត្រដែលធ្វើអោយប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សុខមាលភាព និងធនធានរបស់ប្រជាពលរដ្ឋ
- គ្មានថវិកាបណ្តុះបណ្តាល និងផ្តល់ជំនួយបច្ចេកទេសពីការងារប្រព័ន្ធព័ត៌មានដល់មណ្ឌលសុខភាព ការប្រមូលរបាយការណ៍ពីសេវាឯកជនមិនទាន់បានរលូននៅឡើយ
- មន្ត្រីចុះអភិបាលមានចំនួនតិច ការងារច្រើន (ស្រុកប្រតិបត្តិ១២) ការវិភាគនឹងធ្វើរបាយការណ៍មិនបានគ្រប់ជ្រុងជ្រោយ។

### ១.២.២.៣. វិស័យសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា

ដើម្បីរួមចំណែកលើកកម្ពស់សុខុមាលភាពរបស់ប្រជាជន ជាពិសេសជនរងគ្រោះ និងងាយរងគ្រោះ មន្ទីរសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តព្រៃវែង បាននឹងកំពុងអនុវត្តយុទ្ធសាស្ត្រ ៣យ៉ាង និងកម្មវិធីអាទិភាពចំនួន៨ចំណុចជំហានទី៣គឺៈ

ក-យុទ្ធសាស្ត្រ៣យ៉ាងរួមមាន (១)បង្កើនសុខុមាលភាពសង្គម (២)ពង្រឹងពង្រីកប្រព័ន្ធសន្តិសុខសង្គម និង(៣)ពង្រឹងពង្រីកសមត្ថភាពស្ថាប័ននិងកៀរគរប្រភពធនធានទាំងបច្ចេកទេសនិងហិរញ្ញវត្ថុ។

ខ-កម្មវិធីអាទិភាព៨ចំណុចគឺ (១)អភិវឌ្ឍន៍សុខុមាលភាពសម្រាប់ជនរងគ្រោះនិងងាយរងគ្រោះ និងកិច្ចការពារគ្រោះមហន្តរាយ (២)អភិវឌ្ឍន៍សុខុមាលភាពកុមារនិងយុវនីតិសម្បទា (៣)អភិវឌ្ឍន៍សុខុមាលភាពជនពិការ (៤)អភិវឌ្ឍន៍សុខុមាលភាពមនុស្សចាស់ (៥)អភិវឌ្ឍន៍របបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល (៦)អភិវឌ្ឍន៍សុខុមាលភាពអតីតយុទ្ធជន (៧)បង្កើនប្រព័ន្ធសន្តិសុខសង្គមទូលំទូលាយសម្រាប់ប្រជាជនកម្ពុជា (៨)អភិវឌ្ឍន៍សមត្ថភាពស្ថាប័ននិងពង្រឹងភាពជាដៃគូរ។

ការងារសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា ត្រូវបានរាជរដ្ឋាភិបាលកំណត់ឲ្យអនុវត្តភារកិច្ចសំខាន់ៗដែលរួមមាន ការងារសោធននិវត្តន៍ សោធនអតីតយុទ្ធជន និងការងារយុវនីតិសម្បទា ការងារសមាគមនុស្សចាស់ ការងាសមាគមអតីតយុទ្ធជនកម្ពុជា ការការពារសិទ្ធិកុមារនិងទប់ស្កាត់អំពើជួញដូរស្ត្រីនិងកុមារ។

ខេត្តព្រៃវែងមានមណ្ឌលកុមារកំព្រា ដែលគ្រប់គ្រងដោយអង្គការចំនួន ០៦ កន្លែង (មណ្ឌលរដ្ឋចំនួន ០១ កន្លែង និងមណ្ឌលដែលគ្រប់គ្រងដោយអង្គការចំនួន០៥ កន្លែង) ដែលមានកុមារកំព្រាសរុប

ចំនួន ២២២ នាក់ ស្រី ១២០ នាក់ និងមានមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទាចំនួន ០១ កន្លែង សម្រាប់ផលិតជើងសិប្បនិម្មិត ផ្តល់រទេះរុញ ជួសជុលរទេះរុញ ជួសជុលជើងរណប ផ្តល់ទុនខ្នាតតូចគ្រប់ប្រភេទដល់ជនពិការកុមារពិការ។ ឆ្នាំ២០២៤នេះ កុមារមានរបបគោលនយោបាយជាក់ស្តែងចំនួន ៥២នាក់ ស្រី ២៥នាក់ បច្ចុប្បន្នបាននឹងកំពុងពង្រឹងគុណភាពពីការគ្រប់គ្រងជីវភាពរស់នៅជាលក្ខណៈគ្រួសារធំ រស់នៅជាក្រុមដែលមានកុមារពី ១០នាក់ ទៅ ១៥នាក់ ដោយមានម៉ែដោះម្នាក់ជាអ្នកទទួលខុសត្រូវ។ កុមារម្នាក់ៗបានទទួលរបបឧបត្ថម្ភប្រចាំខែចំនួន ១៥០រៀល០០០. និងប្រាក់ឧបត្ថម្ភសម្រាប់សម្លៀកបំពាក់ និងសម្ភារដំណេកចំនួន ១២០រៀល។០០០.

ទូទាំងខេត្តមាននិវត្តជនស៊ីវិលចំនួន ៣,៤៧៣ នាក់ ស្រី ៦៨៦ នាក់ ជនបាត់បង់សម្បទាវិជ្ជាជីវៈមានចំនួន ៥៤នាក់ ស្រី ០២នាក់ អ្នកនៅក្នុងបន្ទុកសពមានចំនួន ១,០១៥នាក់ ស្រី ៩៦១នាក់។

និវត្តជនជាយោធិន និងនគរបាលជាតិមានចំនួន ១,៥២០នាក់ ជនបាត់បង់សម្បទាវិជ្ជាជីវៈជាយោធិនមានចំនួន ៧៧ នាក់ គ្រួសារជនពលីមានចំនួន ១,៥១០ នាក់ គ្រួសារជនមរណៈមានចំនួន ៥៥២នាក់ ជនពិការសរុបចំនួន ១,៤៥៤ នាក់។

- **លទ្ធផលសម្រេចបានក្នុងឆ្នាំ២០២៤**

បានចែកអំណោយរបស់រាជរដ្ឋាភិបាលកម្ពុជា ជូនដល់ប្រជាពលរដ្ឋក្រីក្ររងគ្រោះដោយគ្រោះធម្មជាតិផ្សេងៗដែលអញ្ជើញមកពីស្រុកស៊ីធរកណ្តាល និងស្រុកព្រះស្តេចសរុបចំនួន ៦៥០គ្រួសារ ដោយអំណោយក្នុង០១គ្រួសារៗទទួលបាន៖ ភួយចំនួន០១ សារ៉ុងចំនួន ០១ ស្ករស ២គីឡូក្រាម ត្រីខចំនួន ១០កំប៉ុង មីចំនួន ០១កេះតូច និងថវិកាចំនួន ២០,០០០រៀល។

គោលនយោបាយចំពោះគ្រួសារ និងជនចាស់ជរាត្រូវបានបង្កើតឡើងនិងកំពុងយកចិត្តទុកដាក់អនុវត្ត។ ជាក់ស្តែងជារៀងរាល់ឆ្នាំមន្ទីរតែងតែប្រារព្ធទិវាគ្រួសារ ១៥ឧសភា ដោយមានលោកតាលោកយាយ និងតំណាងគ្រួសារចូលរួមចំនួន ២៥០នាក់ ក្នុងម្នាក់ៗទទួលបាន៖ សារ៉ុងចំនួន០១ ក្រម៉ាអំបោះចំនួន០១ និងថវិកាចំនួន ២០,០០០រៀល។

ដោយបានការឧបត្ថម្ភពីមន្ទីរ អង្គភាពជុំវិញខេត្ត អង្គការដៃគូរអភិវឌ្ឍន៍នានា ដែលជាសមាជិកក្រុមការងារពហុវិស័យស្តីពីកុមារកំព្រា និងកុមារងាយរងគ្រោះថ្នាក់ខេត្ត។

- **បញ្ហាប្រឈម**

ទន្ទឹមនឹងសមិទ្ធផលសំខាន់ៗដែលបានលើកឡើងខាងលើក៏នៅមានបញ្ហាប្រឈមជាច្រើនទៀតដូចជា៖

- ការប្រែប្រួលអាកាសធាតុបង្កឲ្យមានគ្រោះធម្មជាតិ ទឹកជំនន់ គ្រោះរាំងស្ងួត ជាហេតុធ្វើឲ្យមានចំណាកស្រុកគ្មានសុវត្ថិភាព
- មានកើតឡើងនូវបញ្ហាអសកម្មក្នុងសង្គមនានាដូចជាការប្រើប្រាស់គ្រឿងញៀន ជនចាស់ជរាក្រីក្រគ្មានទីពឹង ជនពិការក្រីក្រ កុមារកំព្រានិងកុមារងាយរងគ្រោះ។
- កុមារកំព្រានិងកុមារងាយរងគ្រោះមួយចំនួនកំពុងប្រឈមយ៉ាងខ្លាំងទៅនឹងភាពងាយរងគ្រោះដូចជា៖ កង្វះស្បៀង អាហារូបត្ថម្ភសុខភាព វិបត្តិផ្លូវចិត្តមិនបានចូលរៀនឬចូលរៀនយឺត

ឆ្លងមេរោគអេដស៍ ការប្រើប្រាស់គ្រឿងញៀន ការជួញដូរផ្លូវភេទ និងការកេងប្រវ័ញ្ចជាដើម

- មន្ត្រីទទួលបន្ទុកកម្មវិធីកណត់អតសញ្ញាណកម្មពិការភាពនៅតាមឃុំសង្កាត់មានការផ្លាស់ប្តូ/ញឹកញាប់។
- ជនអនាថាទាំងចាស់ និងថ្មីដែលបានធ្វើសមាហរណកម្មទៅមូលដ្ឋានហើយ នៅតែត្រឡប់ទៅវិញ
- មិនទាន់មានមណ្ឌលសំចតសម្រាប់ជនរងគ្រោះ និងងាយរងគ្រោះ។
- សមាគមន៍មនុស្សចាស់ដែបានដំណើការមានតិចតួច ។

### ១.២.២.៤. វិស័យការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ

នៅក្នុងឆ្នាំ២០២៤ មន្ទីរបានអនុវត្តតាមផែនការសកម្មភាពរបស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈដែលកំណត់គោលនយោបាយចំនួនពីរគឺ (១)ការបង្កើតការងារជូនដល់យុវជនដែលត្រូវដល់អាយុចូលក្នុងទីផ្សារពលកម្មតាមរយៈការទាក់ទាញវិនិយោគនៅតាមវិស័យអាទិភាពដូចជា វិស័យកសិកម្ម កសិ-ឧស្សាហកម្ម សហគ្រាស សិប្បកម្ម ដោយធានាភាពសុខដុមរមនារវាងកម្មករ និយោជិត និងនិយោជក (២)បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដើម្បីបង្កើតការងារ បង្កើនប្រាក់ចំណូលដល់ប្រជាជនធ្វើអោយស្ថានភាពសេដ្ឋកិច្ចសង្គមនៅក្នុងខេត្តបន្តការរីកចម្រើនលើគ្រប់វិស័យ។ ជាក់ស្តែងក្នុងឆ្នាំ២០២៤នេះ សហគ្រាសវាយនភ័ណ្ឌ និងកាត់ដេរមាន ១០កន្លែង គឺនៅស្រុកស្វាយអន្ទរ ៣កន្លែង ស្រុកកំចាយមារ ១កន្លែង ស្រុកពាមរក៍ ២កន្លែង ស្រុកបាភ្នំ ៣កន្លែង ស្រុកមេសាង ១កន្លែង និងស្រុកកញ្ជ្រៀច ១កន្លែង ប៉ុន្តែសហគ្រាសដែលដំណើរការជាប់ជាប្រចាំគឺមានតែ ១១កន្លែង ក្នុងនោះនៅស្រុកស្វាយអន្ទរ ៣កន្លែង ស្រុកកំចាយមារ ១កន្លែង ស្រុកមេសាង ១កន្លែង ស្រុកបាភ្នំ ៣កន្លែង ស្រុកពាមរក៍ ២កន្លែង និងស្រុកកញ្ជ្រៀច ១កន្លែង ប្រើប្រាស់កម្មករ និយោជិតចំនួន ២,៤៦៦នាក់ ស្រី ២,១៩៩នាក់ ក្រៅពីវិស័យកាត់ដេរមានសហគ្រាសគ្រឹះស្ថាន ១៩៦កន្លែង ប្រើប្រាស់កម្មករនិយោជិតសរុបចំនួន ៤,៩៨២ នាក់ ស្រី ១,៧២៦ នាក់។

ការអនុវត្តគម្រោងឆ្នាំ២០២៤នេះ មន្ទីរសម្រេចបាននូវការងារមួយចំនួនដូចខាងក្រោម៖

**១-វិស័យការងារ**

**ក-ការងារអធិការកិច្ចការងារ**

ក្នុងឆ្នាំ២០២៤នេះ មន្ទីរបានចុះធ្វើអធិការកិច្ចការងារ លើលក្ខខណ្ឌការងារទូទៅ និងចាត់វិធានការចំពោះសហគ្រាស៖

-បានចុះអធិការកិច្ចពិសេសចំនួន ០៤លើក

-បានផ្សះផ្សាវិវាទបុគ្គលចំនួន ០ករណី លទ្ធផលសះជា ០០ករណី និងមិនសះជា ០០ករណី។

**ខ-ការព្យួរកិច្ចសន្យាការងារ**

-បានចុះសម្របសម្រួល ករណីសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន ០១លើក មានកម្មករនិយោជិតសរុប ៧៣៩ នាក់ ស្រី ៦៥៨ នាក់ ។

**គ-ផ្នែកមុខរបរ និងហត្ថពលកម្ម**

ស្ថិតិសហគ្រាស គ្រឹះស្ថានក្នុងឆ្នាំ២០២៤នេះ មានចំនួន ២០៧សហគ្រាស មានកម្មករនិយោជិតសរុប ៧,៤៤៨ នាក់ ស្រី ៣,៩២៥ នាក់ ក្នុងនោះមាន ៖

+វិស័យកាត់ដេរចំនួន ១១សហគ្រាស មានកម្មករនិយោជិតសរុប ២,៤៦៦នាក់ ស្រី ២,១៩៩នាក់

+វិស័យក្រៅពីកាត់ដេរចំនួន ១៩៦ សហគ្រាស មានកម្មករនិយោជិតសរុប ៤,៩៨២ នាក់ ស្រី ១,៧២៦នាក់ ។

- បានចុះបញ្ជីកាលើសេចក្តីប្រកាសជូនដំណឹងអំពីចលនាបុគ្គលិកចូលចំនួន 00 សហគ្រាស សំណើចំនួន 00 មានកម្មករនិយោជិតសរុប 00នាក់ ស្រី 00នាក់
- បានចុះបញ្ជីកាលើសេចក្តីប្រកាសជូនដំណឹងអំពីចលនាបុគ្គលិកចេញចំនួន ១៧សហគ្រាស សំណើចំនួន ១៨ មានកម្មករនិយោជិតសរុប ២០ នាក់ ស្រី ០៦ នាក់
- បានចុះទិដ្ឋាការចូលចំនួន ០០នាក់ ស្រី ០០នាក់
- បានចុះទិដ្ឋាការចេញចំនួន ១៦នាក់ ស្រី ០៤នាក់ ។

**២-វិស័យបណ្តុះបណ្តាលវិជ្ជាជីវៈ**

- បានចុះស្រង់ស្ថិតិការងារ និងព័ត៌មានទីផ្សារការងារចំនួន ២០គ្រឹះស្ថាន ។

**៣-គម្រោងចំនួន ១ ដែលអនុវត្តន៍បាន ១០០% រួមមាន៖**

១-បានរៀបចំកម្មវិធីអបអរសាទរខួបអនុស្សាវរីយ៍លើកទី១៣៨ ទិវាពលកម្មអន្តរជាតិ ០១ឧសភា ២០២៤នៅទីតាំងបរិវេណសាលាស្រុកស្វាយអន្ទរ មានកម្មករនិយោជិតចំនួន ៤០០នាក់ ស្រី ២៤០នាក់។

**៤-គម្រោងចំនួន ២ អនុវត្តមិនបាន ១០០% រួមមាន៖**

១-ចុះអធិការកិច្ចការងារទំហំគម្រោង ១៣០លើក អនុវត្តបានតែអធិការកិច្ចការងារពិសេស ៤លើក គម្រោងទឹកប្រាក់សរុបចំនួន ៣១,២០០,០០០រៀល

២-ផ្សព្វផ្សាយច្បាប់ស្តីពីការងារដល់និយោជក និងកម្មករនិយោជិត ៨ វគ្គ អនុវត្តបាន០០វគ្គ គម្រោងទឹកប្រាក់សរុបចំនួន ១២.០០០.០០០រៀល ។

**៥-បញ្ហាប្រឈម**

មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានអនុវត្តផែនការសកម្មភាពកន្លងមក ក៏មានបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

១-និយោជក និងសហជីពមូលដ្ឋានមួយចំនួន នៅមិនទាន់យល់អំពីច្បាប់ពាក់ព័ន្ធនឹងវិស័យការងារដូចជាច្បាប់ស្តីពីការងារ ច្បាប់ស្តីពីសហជីព ច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា ច្បាប់ស្តីពីរបបសន្តិសុខសង្គម និងមានការលាក់បាំងព័ត៌មានពីចំនួនកម្មករ។

២-អ្នកដែលបានទទួលការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈមួយចំនួន មិនបានយកជំនាញទាំងនោះ ទៅប្រកបរបរចិញ្ចឹមជីវិតនៅក្នុងមូលដ្ឋានរបស់ពួកគាត់ទេ បែរជាធ្វើចំណាកស្រុកទៅវិញ។

៣-ខ្វះថវិកាសម្រាប់ផ្សព្វផ្សាយ និងគាំទ្រគម្រោងមួយចំនួន បានធ្វើអោយមានការរាំងស្ទះ ដែលបណ្តាលអោយគម្រោងមួយចំនួន អនុវត្តមិនសម្រេច ១០០% នៅក្នុងឆ្នាំ២០២៤នេះ។

### ១.២.២.៥. វិស័យវប្បធម៌ និង វិចិត្រសិល្បៈ

ខេត្តព្រៃវែងមានសម្បត្តិវប្បធម៌ជាតិមួយចំនួនដូចជា៖ ប្រាសាទបុរាណ ០២ កន្លែង ទួលបុរាណនៅក្នុងទូទាំងខេត្តមានចំនួន ៥៧៤ ទួល។ វត្ថុបុរាណដែលតំកល់នៅសារមន្ទីរខេត្តមានចំនួន ៣០០ដុំផ្ទាំង តម្កល់នៅសាលពិពណ៌វត្ថុបុរាណស្រុកបាភ្នំចំនួន ១០៨ដុំផ្ទាំង តំកល់នៅសាលពិពណ៌វត្ថុបុរាណពោធិ៍ទង ស្រុកកញ្ជ្រៀចចំនួន ៦០ដុំ។ មានកន្លែងផលិតវត្ថុសិល្បៈសិប្បកម្មពុម្ពស៊ីម៉ង់ត៍ចំនួន ៨០ កន្លែង ឈើចំនួន ០៣ កន្លែង ផ្តៅល្អាក់វ័ល្លិចំនួន ០១ កន្លែង សិប្បកម្មតម្បាញសូត្រអំបោះចំនួន ៧៩ គឺជាងទងចំនួន ៩៥ កន្លែង គំនូរបុរាណចំនួន ៨ កន្លែង អាជីវករលក់វត្ថុសិល្បៈចំនួន ៨ កន្លែង។

ដោយបច្ចុប្បន្នជាសម័យកាលបច្ចេកវិទ្យាទំនើប បានញុំាងអោយមរតកវប្បធម៌ដ៏មានតម្លៃវត្ថុបុរាណទទួលរងនូវបញ្ហាប្រឈមមួយចំនួន រហូតអាចនឹងឈានទៅដល់ការបាត់បង់ដោយអន្លើៗជាក់ស្តែង វប្បធម៌បរទេស បានកំពុងវាយលុកមកលើទីផ្សារក្នុងប្រទេសកម្ពុជាយើងតាមប្រពន្ធ័ផ្សព្វផ្សាយទំនើបៗ ដូចជាប្រព័ន្ធអ៊ីនធ័រណេត ខ្សែភាពយន្តវីដេអូ បង្ហាញពីវប្បធម៌បរទេសដែលធ្វើ អោយវប្បធម៌ជាតិធ្លាក់ចុះ។

**១-ការងារសិល្បៈទស្សនីយភាព**

- តំឡើងឈុតអប់រំខ្លីរឿង (យើងរួមគ្នាថែរក្សាទីទួលបុរាណ) ត្រៀមអបអរសាទរទិវាវប្បធម៌ជាតិ ៣មីនា ឆ្នាំ២០២៣
- សម្តែងរបាំជូនពរ របាំភួងនារី និងរបាំត្រុដិ ក្នុងពិធីអបអរសាទរទិវាវប្បធម៌ជាតិ៣មីនា
- សម្តែងរបាំត្រុដិបានចំនួន៩លើក ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ
- សម្តែងរបាំជូនពរនៅសាលាខេត្តព្រៃវែងពិធីសម្ពោធដាក់អោយប្រើប្រាស់ជាផ្លូវការ អគាររដ្ឋបាលសាលាខេត្តព្រៃវែង និងរោងដម្កល់ទូកងរវែងជាងគេលើពិភពលោក
- សម្តែងរបាំថ្វាយព្រះពរសម្តេច **នរោត្តម សីហមុនី** ក្នុងឱកាសព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម វស្សា ថ្វាយព្រះករុណា **ព្រះបាទសម្តេចបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា គម្រប់ ៧០ យាងចូល ៧១ ព្រះវស្សា
- បន្តហ្វឹកហាត់របាំបុរាណ របាំប្រជាប្រិយ និងចម្រៀងប្រពៃណីជារៀងរាល់ថ្ងៃ។

**២-ការងារភាពយន្តនិងផ្សព្វផ្សាយវប្បធម៌**

- ចូលរួមសិក្ខាសាលាស្តីពី (សុខភាពជាចំបង ដើម្បីរក្សាសន្តិភាព និងអភិវឌ្ឍន៍វប្បធម៌ក្នុងយុគសម័យឌីជីថល)
- ចូលរួមជាមួយនាយកដ្ឋានភាពយន្តក្នុងសកម្មភាពថតរឿង (ខ្មែររស់ឡើងវិញ) របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ទីតាំងក្បាលសាឡាងអ្នកលឿង
- ចុះផ្សព្វផ្សាយច្បាប់ស្តីពីវិស័យភាពយន្តនៅស្រុកស៊ីធរកណ្តាល។

**៣-ការងារអភិវឌ្ឍន៍វប្បធម៌**

- ចុះស្រង់ស្ថិតិនិងប្រវត្តិពិធីបុណ្យប្រពៃណីបុរាណនៅមូលដ្ឋានចំនួន ៣ គឺ ស្រុកបាភ្នំ ស្រុកពារាំង និងស្រុកស៊ីធរកណ្ដាល។

**៤- ការងារសិល្បៈសូនរូប និងសិប្បកម្ម**

- សរុបភ្ញៀវជាតិ និងអន្តរជាតិចូលទស្សនាក្នុងសាលពិព័ណ៌វត្ថុសិល្បៈសិបកម្មចំនួន ១៣០នាក់
- ចុះពិនិត្យ និងស្រង់ស្ថិតិសិប្បកម្មគ្រប់ប្រភេទបានចំនួន ១០ក្រុង/ស្រុក រួមមាន៖ សិល្បៈចម្លាក់ឈើ សិប្បកម្មចាក់ពុម្ពស៊ីម៉ង់ត៍ ដំដែក តម្បាញ គំនូរ សិល្បៈរូបថត និងអាជីវកម្មលក់វត្ថុសិល្បៈ
- ចុះផ្សព្វផ្សាយសេចក្ដីណែនាំស្ដីពីការដាក់ឲ្យអនុវត្តនីតិវិធី និងទម្រង់បែបបទនៃការគ្រប់គ្រងទីតាំងលក់ចម្លាក់ពុម្ពស៊ីម៉ង់ត៍ បានចំនួន ០៥ស្រុក
- ចូលរួមសិក្ខាសាលាបានចំនួន ៣លើក និងចូលរួមមហោស្រពបាន ០១លើក ។

**៥- ការងារបេតិកភណ្ឌ**

- ចុះទទួលសិលាចារឹកនៅវត្តបឹងឡែង និងយកទៅជួសជុលនៅរោងជាងអភិរក្សវត្ថុសិល្បៈធ្វើអំពីថ្មនៃសារមន្ទីរជាតិកម្ពុជា យកមករក្សាទុកនៅសារមន្ទីរខេត្តព្រៃវែង
- ចុះបោះបង្គោលការពារស្ថានីយទួលកំព្រៅ ស្ថិតនៅភូមិកំព្រៅ ឃុំអង្គររាជ្យ ស្រុកព្រះស្ដេចខេត្តព្រៃវែង
- ចូលរួមធ្វើកំណាយសង្គ្រោះនៅស្ថានីយបុរាណទួលកុកគ្រួស នៅភូមិខ្នយ សង្កាត់តាកោក្រុងព្រៃវែង ខេត្តព្រៃវែង ជាលទ្ធផលគឺប្រទះឃើញបំណែកកុលាលភាជន៍ជាច្រើន
- លោកប្រធានមន្ទីរដឹកនាំមន្ត្រីជំនាញ ចុះពិនិត្យព្រះកេសព្រះបដិមារដែលប្រជាពលរដ្ឋប្រទះឃើញអំឡុងពេលសាងសង់ផ្ទះ ស្ថិតនៅភូមិព្រៃក្តួច ឃុំឈើកាច់ ស្រុកបាភ្នំ ខេត្តព្រៃវែង
- ចុះបោះបង្គោលការពារស្ថានីយបុរាណចំនួន ១ស្ថានីយ នៅស្រុកព្រះស្ដេច ខេត្តព្រៃវែង
- ចុះកំណត់និងពិនិត្យព្រំដីស្ថានីយទួលគោកម្រេញ ស្ថិតនៅស្រុកពោធិ៍រៀង ខេត្តព្រៃវែង
- ចុះបោះបង្គោលសំគាល់តំបន់ការពារបេតិកភណ្ឌនៅទួលវត្តចាស់ និងទួលវត្តយាយម៉ៅ ភូមិកគោ ឃុំបន្ទាយចក្រី ស្រុកព្រះស្ដេច ខេត្តព្រៃវែង។

**៦-ការងារសារមន្ទីរ**

- សរុបភ្ញៀវជាតិនិងអន្តរជាតិចូលទស្សនាវត្ថុបុរាណក្នុងសារមន្ទីរខេត្តចំនួន ១៣០នាក់
- ទៅទទួលយកសិលាចារឹកវត្តបឹងឡែង ដែលបានជួសជុលនៅរោងជាងអភិរក្សវត្ថុសិល្បៈធ្វើអំពីថ្មនៃសារមន្ទីរជាតិកម្ពុជា យកមករក្សាទុកក្នុងសារមន្ទីរខេត្តព្រៃវែង
- វត្ថុបុរាណដែលតម្កល់ទុកក្នុងសារមន្ទីរមានចំនួន ៣០៥ដុំ-ផ្ទាំង

- ចុះពិនិត្យនិងទទួលយកគំនូរបុរាណចំនួន ៤៦ សន្លឹក ស្ថិតនៅវត្តបាប្រិយ៍ ភូមិបាប្រិយ៍ ឃុំព្រៃកសង្ក្រាន ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង។

**៧-បញ្ហាប្រឈម**

១- ស្ថានីយបុរាណចំនួន ០២ កន្លែង ត្រូវប្រជាពលរដ្ឋរុករាន

២- ប្រជាពលរដ្ឋមួយចំនួននៅមិនទាន់យល់ដឹងពីច្បាប់បេតិកភណ្ឌ និងបន្តរុករានទួលបុរាណជាកម្មសិទ្ធិ

៣- ខ្វះថវិកាសម្រាប់ទិញសម្ភារៈ និងសម្លៀកបំពាក់សម្រាប់សិល្បៈករ សិល្បៈការិនី។

## **១.២.២.៦. ទស្ស័យព័ត៌មាន**

មន្ទីរព័ត៌មាន មានតួនាទីយ៉ាងសំខាន់ក្នុងការផ្សព្វផ្សាយព័ត៌មាននិងសោតទស្សន៍ក្នុងក្របខ័ណ្ឌខេត្តព្រៃវែងដែលក្នុងនោះរួមមាន៖ ព័ត៌មានតាមវិទ្យុ ទូរទស្សន៍ ទស្សនាវដ្តី ព្រឹត្តប័ត្រ សារព័ត៌មានរូបថត...។ល។

អនុវត្តតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្ន របស់រាជរដ្ឋាភិបាលកម្ពុជាដែលបានគូសបញ្ជាក់ថា "**ពង្រឹងវិសាលភាពគុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធផ្សព្វផ្សាយរបស់ជាតិគ្របដណ្តប់បានទូលំទូលាយទាំងក្នុងប្រទេស ក្នុងតំបន់ និងទីបនានា**" ក្រសួងព័ត៌មានបានយកចិត្តទុកដាក់ពង្រឹងពង្រីកបណ្តាញផ្សព្វផ្សាយទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ផ្សព្វផ្សាយតាមវិទ្យុ AM.FMជាតិ និងទូរទស្សន៍ជាតិតាមប្រព័ន្ធ Analog តាមប្រព័ន្ធផ្សាយត្រង់ទៅដល់គេហដ្ឋាន (DTH) តាមប្រព័ន្ធ T.DMB និងផ្សាយតាមប្រព័ន្ធ internet ដោយឡែកខេត្តព្រៃវែងក្រសួងបានបំពាក់ស្ថានីយ៍វិទ្យុ FM មានកំលាំង 2KW មួយគ្រឿង សំរាប់ទទួលផ្សាយបន្តព្រឹត្តិការណ៍ព័ត៌មានសំខាន់ៗពីថ្នាក់ជាតិ និងកសាងកម្មវិធីផ្សាយព័ត៌មានលើគ្រប់វិស័យរបស់ខេត្តផង។ ដោយឡែកបណ្តាញផ្សព្វផ្សាយរបស់ក្រុមហ៊ុនឯកជន និងរបស់អង្គការមិនមែនរដ្ឋាភិបាលបាននឹងកំពុងពង្រឹងពង្រីកសក្តានុពលផ្សព្វផ្សាយរបស់ខ្លួន តាមប្រព័ន្ធបែបប្រពៃណី (វិទ្យុ ទូរទស្សន៍ សារព័ត៌មាន ទាំងប្រព័ន្ធផ្សាយទំនើប(internet គេហទំព័រ ហ្វេកប៊ុក) TIK TOK( ដែលធ្វើឲ្យខេត្តយើងកាន់តែមានប្រភពផ្តល់ព័ត៌មានសំបូរបែប វិសាលភាពនៃការផ្សាយបានទូលំទូលាយគ្របដណ្តប់គ្រប់ច្រកល្ហកនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ក៏ដូចជានៅក្នុងតំបន់ និងនៅលើសកលលោក ជូនប្រជាពលរដ្ឋបានជ្រួតជ្រាបបានរហ័សទាន់ពេលវេលា និងប្រកបដោយការជឿជាក់តាមទិសស្លោក " **ប្លែក លឿន ទុកចិត្តបាន ពេលណា ទីណាក៏បាន**" ឆ្លើយតបទៅនិងការវិវត្តិនៃសភាពការណ៍នៅក្នុងប្រទេស និងសភាពការណ៍នៅលើសកលលោក។

**១-ចំណុចខ្លាំងនិងលទ្ធផលការងារ**

ដើម្បីពង្រឹងវិស័យនេះ មន្ទីរបានខិតខំកៀរគរវិនិយោគគិនដើម្បីមកវិនិយោគវិស័យនេះ ក្នុងនោះបានបង្កលក្ខណៈឲ្យក្រុមហ៊ុនឯកជនតម្លើងស្ថានីយ៍វិទ្យុ FM បានចំនួន ០៨ស្ថានីយ៍ សំរាប់ផ្សព្វផ្សាយព័ត៌មានពីថ្នាក់ជាតិ និងក្នុងខេត្តពីការអភិវឌ្ឍន៍នានា ដើម្បីបម្រើតម្រូវការប្រជាពលរដ្ឋនៅតាមមូលដ្ឋានបានទទួលព័ត៌មាន។ ការផ្សព្វផ្សាយព័ត៌មានតាមវិទ្យុ និងទូរទស្សន៍ មន្ទីរបានអនុវត្តយ៉ាងសកម្ម និងទទួលបានលទ្ធផលល្អប្រសើរ ព្រមទាំងសហការល្អគ្រប់យ៉ាងពីអជ្ញាធរខេត្ត ក្រុង ស្រុក និងមន្ទីរវិស័យនានា

នៅទូទាំងខេត្ត។

**២-ការងារព័ត៌មាននិងសោតទស្សន៍**

**ក-ស្ថានភាពការិយាល័យទូរទស្សន៍**

ក្នុងឆ្នាំ២០២៤ នេះការិយាល័យទូរទស្សន៍បានបង្កើនការយកចិត្តទុកដាក់ អនុវត្តភារកិច្ចរបស់ខ្លួនយ៉ាងសកម្ម ក្នុងការចុះយកព័ត៌មាន តាមថ្នាក់ដឹកនាំថ្នាក់ជាតិ និងថ្នាក់ដឹកនាំខេត្ត មន្ទីរអង្គភាព ក្រុងស្រុក និងក្រុមការងារថ្នាក់ជាតិមកផ្សាយតាមទូរទស្សន៍ជាតិកម្ពុជាក្នុងកម្មវិធី (ទទក ព័ត៌មានពេលព្រឹក) ទទកព័ត៌មាន ថ្ងៃសៅរ) និងកម្មវិធី ៍ និងថ្ងៃអាទិត្យ(បានចំនួន ១០៥លើក។

**ខ-ស្ថានភាពការិយាល័យវិទ្យុ**

ការិយាល័យវិទ្យុ បានយកចិត្តទុកដាក់ការងាររបស់ខ្លួនទទួលបានលទ្ធផលគួរអោយកត់សំគាល់ ដើម្បីរួមចំណែកក្នុងការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រពញ្ញកោណដំណាក់កាលទី៥ របស់រាជរដ្ឋាភិបាលកម្ពុជាបានផ្សាយព័ត៌មានសំខាន់ៗ កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ការអភិវឌ្ឍន៍របស់ប្រទេសជាតិ និងសមិទ្ធផលពីការរីកចម្រើនលើគ្រប់វិស័យរបស់ខេត្តជូនដល់ប្រជាពលរដ្ឋបានជ្រួតជ្រាប និងបានផ្តល់ចំណេះដឹង ផ្តល់ការអប់រំ ការកំសាន្ត តាមរយៈបណ្តាញផ្សព្វផ្សាយរបស់ខ្លួនគឺវិទ្យុ FM (97.30MHz) បានផ្សព្វផ្សាយព័ត៌មានជាតិ អន្តជាតិ និងចុះយកព័ត៌មានជាសម្លេង និងសរសេរអត្ថបទបានសរុបចំនួន ៧៩៨ អត្ថបទ ក្នុងនោះបានអាន និងចាក់ផ្សាយព័ត៌មានអន្តជាតិបានចំនួន ៥៨៦ លើក។ ផ្សាយបន្តផ្ទាល់ពីវិទ្យុជាតិកម្ពុជា និងទូរទស្សន៍ជាតិកម្ពុជាកម្មវិធីរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានចំនួន ៣០ លើក ។

**គ-ស្ថានភាពការងារសោតទស្សន៍**

- ចេញអាជ្ញាប័ណ្ណអាជីវកម្មផ្សព្វផ្សាយតាមប្រព័ន្ធអេឡិចត្រូនិច)Online) ០២ ប័ណ្ណ
- ចេញអាជ្ញាប័ណ្ណអាជីវកម្មផ្សព្វផ្សាយពាណិជ្ជកម្មតាមប៉ាន់ណូ ០៥ ប័ណ្ណ

**៣-ការងារទីភ្នាក់ងារសារព័ត៌មានកម្ពុជា(AKP)**

បានបង្កើនការយកចិត្តទុកដាក់អនុវត្តភារកិច្ចរបស់ខ្លួនក្នុងការចុះតាមថ្នាក់ដឹកនាំខេត្ត មន្ទីរអង្គភាពនានាជុំវិញ ខេត្ត ក្រុង ស្រុក បានបញ្ជូនអត្ថបទ និងរូបភាពសន្លឹកទៅអោយអគ្គនាយកដ្ឋានទីភ្នាក់ងារសារព័ត៌មានកម្ពុជា(AKP) បានចំនួន ១,១៨៧ លើក។

**៤-ចំណុចខ្សោយនិងបញ្ហាប្រឈម**

- ខ្វះមន្ត្រីជំនាញបំពេញការងារ
- មានការលំបាក់ដោយខ្វះសម្ភារៈបច្ចេកទេស ក្នុងការចុះយកព័ត៌មាន
- កង្វះថវិកាសម្រាប់ការស្តារ កែលំអប្រព័ន្ធបរិក្ខាវិទ្យុFM
- សមត្ថភាពមន្ត្រីខ្លះនៅមានកំរិត

**៥-បញ្ហាអាទិភាពដែលត្រូវដោះស្រាយ**

- ស្នើសុំមន្ត្រីក្របខណ្ឌជំនាញបន្ថែម

- ស្នើសុំកញ្ចប់ថវិកាបន្ថែម ដើម្បីបំពាក់សម្ភារៈបច្ចេកទេស
- បើកវគ្គបណ្តុះបណ្តាលជំនាញដល់មន្ត្រី

### ១.២.២.៧. វិស័យធម្មការនិងកិច្ចការសាសនា

ខេត្តព្រៃវែង គឺជាខេត្តដែលមានវត្តអារាមច្រើនជាងគេ ជាប់លំដាប់ថ្នាក់លេខ១ ទូទាំងប្រទេស គឺមានវត្តចំនួន ៥១៩វត្ត ក្នុងនោះវត្តគណៈមហានិកាយមានចំនួន ៥០០វត្ត និងវត្តគណៈធម្មយុត្តិកនិកាយមានចំនួន ១៩វត្ត ភាគច្រើនជាវត្តដែលមានព្រះវិហារ កុដិ និងឧបដ្ឋានសាលាត្រឹមត្រូវ។

ទូទាំងខេត្តមានព្រះសង្ឃសរុបចំនួន ៤,៥៨២អង្គ ភិក្ខុមានចំនួន ១,៣០២អង្គ សាមណេរមានចំនួន ៣,២៨០អង្គ ដែលគិតជាមធ្យមអំពីចំនួនព្រះសង្ឃដែល គង់នៅក្នុងវត្តមានព្រះសង្ឃចំនួន ៩អង្គគង់ចាំព្រះវស្សាក្នុង១វត្ត។ ចំណែកអាចារ្យសរុបមានចំនួន ១,៨០៨នាក់ គណៈកម្មការវត្តសរុបមានចំនួន ៤,២៨៨នាក់ ដូនជីស្នាក់នៅក្នុងវត្តសរុបចំនួន ៣១៥នាក់ ព្រមទាំងក្មេងវត្តសរុបចំនួន ៤៣៨នាក់។

វិស័យពុទ្ធិកសិក្សារបស់មន្ទីរធម្មការនិងសាសនាខេត្តចែកចេញជា ៤ផ្នែកគឺ៖

១-កម្រិតសាលាធម្មវិន័យមាន ៤៩សាលា ស្មើនឹង ៨៤ថ្នាក់ ដែលចែកចេញជា៣កម្រិតគឺ ថ្នាក់ត្រី ថ្នាក់ទោ និងថ្នាក់ឯក មានសមណសិស្សសរុបចំនួន ១,២២០អង្គ។

២-កម្រិតសាលាពុទ្ធិកបឋមសិក្សាមាន៤៩សាលា ស្មើនឹង៨៤ថ្នាក់ ចែកចេញជា៣កម្រិតគឺ ថ្នាក់ឆ្នាំទី១ ថ្នាក់ឆ្នាំទី២ និងថ្នាក់ឆ្នាំទី៣ មានសមណសិស្សសរុបចំនួន ១,១៧៦អង្គ។

៣-កម្រិតពុទ្ធិកវិទ្យាល័យ និងអនុវិទ្យាល័យមាន២សាលា (ពុទ្ធិកអនុវិទ្យាល័យ ហ៊ុន សែន សិរីសារពេជ្រ និងពុទ្ធិកវិទ្យាល័យព្រៃវែង) ស្មើនឹង១១ថ្នាក់ មានសមណសិស្សសរុបចំនួន ៣៧៦អង្គ។

ក្រៅពីស្ថិតិព្រះពុទ្ធសាសនាដែលបានរៀបរាប់ខាងលើ ខេត្តព្រៃវែងក៏នៅមានវិហារ និងស្នាក់ការ ៣ហិរសាសនា (សាសនាផ្សេងៗក្រៅពីព្រះពុទ្ធសាសនា)ចំនួន ៨៤កន្លែង ដែលមានសាសនិកសរុបចំនួន ៩,៧៣៦នាក់ ស្រី៥,៦០១នាក់ ក្នុងនោះរួមមាន៖

-គ្រិស្តសាសនា មាន ៦៦កន្លែង មានសាសនិកសរុប ៥,០៣៦នាក់ ស្រី ២,៩៩៩នាក់

-ឥស្លាមសាសនា មាន ៦កន្លែង មានសាសនិកសរុប ២,២៨១នាក់ ស្រី ១,១៣២នាក់

-ពុទ្ធសាសនាមហាយាន មាន ៨ន្លែង មានសាសនិកសរុប ១,៦៤៨នាក់ ស្រី ៩៧៩នាក់

-អ្នកតាចិន មាន ៣កន្លែង មានសាសនិកសរុប ៧៧១នាក់ ស្រី ៤៩១នាក់

-ព្រហ្មញ្ញសាសនា មាន ១កន្លែង (ស្ថិតនៅក្នុងឃុំច្រេស ស្រុកមេសាង)

- **បញ្ហាប្រឈម**

ទន្ទឹមគ្នានឹងការរីកចម្រើនផ្នែកវិស័យសាសនា និងវិស័យពុទ្ធិកសិក្សានៅក្នុងខេត្ត វិស័យសាសនានៅក្នុងខេត្តព្រៃវែង ក៏មានការប្រឈមមួយចំនួនផងដែរ បញ្ហាប្រឈមទាំងអស់នេះរួមមានៈ មន្ទីរពុំទាន់មានអគាររដ្ឋបាលផ្ទាល់ខ្លួនសម្រាប់ធ្វើការងារនៅឡើយ វិស័យពុទ្ធិកសិក្សាដែលបាននឹងកំពុងរីកចម្រើនក៏ជួបបញ្ហាប្រឈមមួយចំនួនដូចជាធនធានគ្រូបង្រៀនផ្នែកភាសាបាលី និងសំស្ក្រឹតនៅមានចំនួនតិច ហើយគ្រូដែលកំពុងបង្រៀននាពេលបច្ចុប្បន្នភាគច្រើនជាគ្រូពុទ្ធិកជាប់កិច្ចសន្យា ដែល

បានចូលរួមវគ្គសិក្ខាសាលា ដើម្បីចែករំលែកបទពិសោធន៍នៅក្នុងការបង្រៀនភាសាបាលីជារៀងរាល់ឆ្នាំ ដែលរៀបចំដោយមន្ទីរធម្មការ និងសាសនាខេត្តព្រៃវែង។ ចំណែកវិស័យពាហិរសាសនាវិញ មានវិហារស្នាក់ការពាហិរសាសនាមួយចំនួន មានការយឺតយ៉ាវក្នុងការចុះបញ្ជីវិញ្ញាបនបត្របន្តសុពលភាពនៅពេលដែលវិហារស្នាក់ការទាំងនេះ ត្រូវបន្តសុពលភាពរយៈពេល២ឆ្នាំម្តង។

- **សេចក្តីសន្និដ្ឋាន**

ទោះបីជាវិស័យសាសនាមានបញ្ហាប្រឈមតិចតួចក៏ពិតមែន ប៉ុន្តែការរីកចម្រើនរបស់វិស័យសាសនា គឺជាសក្តានុពលដ៏សំខាន់ក្នុងការរួមចំណែកជួយអភិវឌ្ឍដល់សហគមន៍ ការពង្រឹងធនធានមនុស្សតាមរយៈវិស័យពុទ្ធិកសិក្សា ការបំបាត់នូវអំពើហិង្សា ការជួយលុបបំបាត់ការប្រើប្រាស់គ្រឿងញៀន និងការរក្សានូវសីលធម៌រស់នៅរបស់ប្រជាពលរដ្ឋតាមរយៈការផ្សព្វផ្សាយនាទីព្រះពុទ្ធសាសនាផ្សារភ្ជាប់សង្គម ការសម្តែងធម្មទេសនានៅតាមសហគមន៍ និងជួយដល់ជនក្រីក្រ ជនពិការ ជនអនាថាកុមារកំព្រា សិស្ស និស្សិតក្រីក្រ មួយចំណែកផងដែរ។

### **១.២.២.៨. ស្ថានភាពយេនឌ័រ**

វិស័យយេនឌ័រកំពុងតែត្រូវបានយកចិត្តទុកដាក់តាមរយៈ ការដាក់ចេញនូវច្បាប់ គោលនយោបាយ វិធានការពិសេសនានា និងការផ្តល់ថវិកាពីរាជរដ្ឋាភិបាល កិច្ចសហការរបស់អង្គភាពនិងដៃគូនានា ដើម្បីកាត់បន្ថយអំពើហឹង្សាក្នុងគ្រួសារ ការជួញដូរផ្លូវភេទ អំពើរំលោភសេពសន្ថវៈលើស្ត្រីនិងកុមារ និងពលកម្មកុមារ ការបញ្ជ្រាបយេនឌ័របរិយាប័ន្ន និងសមធម៌សង្គម។

បច្ចុប្បន្នស្ថានភាពគម្លាតស្ត្រី និងបុរសត្រូវបានកាត់បន្ថយដោយមានការចូលរួមយកចិត្តទុកដាក់ពីគ្រប់អង្គភាពនានាជុំវិញខេត្ត និងគ្រួសារផ្ទាល់។ គ្រួសារភាគច្រើនដែលពីមុនការថែទាំកូនជាបន្ទុករបស់តែម្តាយ ឥឡូវត្រូវបានកែប្រែមកជាការរួមគ្នាថែទាំវិញ។ ចំពោះស្ថានភាពនៃការរៀនសូត្រវិញ បរិមាណនៃការចូលរៀនរបស់សិស្សស្ត្រីមានកំណើនជាងមុន ការបោះបង់ចោលការសិក្សារបស់សិស្សស្រីក៏ត្រូវបានកាត់បន្ថយ។ បញ្ហាកុមារីដែលនៅសេសសល់មិនបានចូលរៀនច្រើនកើតមាននៅក្នុងគ្រួសារដែលមានជីវភាពក្រីក្រ និងគ្រួសារដែលស្ត្រីជាមេគ្រួសារខ្វះកម្លាំងពលកម្ម។ ព្រមជាមួយនេះ ក៏មានគ្រួសារមួយចំនួនដែលមានជីវភាពធូរធារ ហើយមិនបានយកចិត្តទុកដាក់ផ្តល់លទ្ធភាពអោយកូនស្រីបានចូលរៀនផងដែរ ដោយសារគាត់មិនទាន់យល់ដឹងពីសារៈសំខាន់នៃការចេះអក្សរ និងការធ្វើសេចក្តីសម្រេចចិត្ត។

ជាទូទៅ ស្ត្រីនៅតែមានចំណេះដឹងទាបជាងបុរស ដោយសារឱកាសនៃការសិក្សាមានតិចជាងបុរសជាហេតុធ្វើអោយសមត្ថភាពបំពេញការងារក្នុងសហគមន៍ វិស័យឯកជនឬនៅតាមស្ថាប័នរដ្ឋាភិបាលមានចំនួនតិចជាងបុរស។ កន្លងមកនេះ ស្ត្រីនៅតាមសហគមន៍ ត្រូវបានបំពាក់បំប៉នសមត្ថភាពច្រើនបង្គួរដែលអាចបង្កលក្ខណៈឲ្យស្ត្រីមួយចំនួនធំ បានចូលប្រឡូកក្នុងការងារសហគមន៍ដូចជា ក្នុងក្រុមប្រឹក្សាឃុំ/សង្កាត់ គណៈកម្មការនានា របស់ឃុំសង្កាត់ដែលជាចំណុចដ៏ល្អក្នុងការងារពង្រឹងសមត្ថភាពដល់ស្ត្រី និងបង្កើនការចូលរួមរបស់ស្ត្រីនៅក្នុងការងារសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌។

ស្ត្រីភាគច្រើនបានដើរតួនាទីយ៉ាងសំខាន់ក្នុងការរកប្រាក់ចំណូលក្នុងគ្រួសារដោយបានចេញទៅប្រកបមុខរបរខាងក្រៅផ្ទះដូចជាធ្វើជាកម្មកររោងចក្រ កម្មករសំណង់ បុគ្គលិកក្រុមហ៊ុននានា ស្ថាប័នរដ្ឋាភិបាល ដែលអាចរកប្រាក់ចំណូលចិញ្ចឹមជីវិតផ្ទាល់ខ្លួន និងគ្រួសារទាំងមូលទៀតផង។

ដើម្បីចូលរួមក្នុងការកែលំអស្ថានភាព ជីវភាពប្រជាពលរដ្ឋទាំងប្រុស ទាំងស្រី មន្ទីរកិច្ចការនារីបាននិងកំពុងចូលរួមចំណែកយ៉ាងសកម្មក្នុងការវិនិយោគទៅលើការលើកកម្ពស់ស្ថានភាពស្ត្រី និងកុមារ ដោយផ្តោតទៅលើផ្នែកសេដ្ឋកិច្ច សង្គមរបស់ស្ត្រីតាមរយៈ ការអនុវត្តផ្ទាល់ និងជំរុញអោយគ្រប់ផ្នែកគ្រប់ថ្នាក់ ធ្វើផែនការសកម្មភាពឆ្លើយតបយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម ក្នុងការកាត់បន្ថយភាពក្រីក្រ អភិវឌ្ឍន៍តំបន់ជនបទ និងបង្កើនឱកាសការងារដល់ជនងាយរងគ្រោះនានាអោយមានមុខរបរបង្កើនប្រាក់ចំណូល ធ្វើអោយជីវភាពកាន់តែប្រសើរឡើង។

- **បញ្ហាប្រឈម**

ទោះបីជាមានការអនុវត្តគម្រោងមួយចំនួនខាងលើ ប៉ុន្តែយើងនៅមានបញ្ហាប្រឈមដូចខាងក្រោមៈ

-ដោយសារតែទម្លាប់របស់ខ្មែរយើងជាយូរលង់មកហើយ ការផ្តល់តម្លៃអោយស្ត្រីនៅមានកម្រិត ដូច្នេះវិសមភាពយេនឌ័រនៅតែមានក្នុងផ្នត់គំនិតរបស់មន្ត្រីរាជការ ប្រជាពលរដ្ឋមួយចំនួន។

-អង្គភាពមួយចំនួន ទោះបើបានរៀបចំផែនការសកម្មភាព បញ្ជ្រាបយេនឌ័រក្នុងអង្គភាពរបស់ខ្លួនហើយ ប៉ុន្តែមិនទាន់មានសកម្មភាពផុសផុលនៅឡើយ ដែលផ្តោតទៅលើតែជំនាញសុទ្ធសាទ ជាហេតុធ្វើអោយពិន្ទុយេនឌ័រមិនមានការកើនឡើង។

-ការផ្សព្វផ្សាយច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះនៅមិនទាន់ផ្សព្វផ្សាយបានទូលំទូលាយនៅតាមសហគមន៍។

-អំពើរំលោភបំពានផ្លូវភេទមកលើស្ត្រី និងកុមារនៅតែមានជាបន្តបន្ទាប់ ដែលទាមទារឲ្យគ្រប់ផ្នែកគ្រប់ស្ថាប័នសហការអប់រំផ្សព្វផ្សាយ និងបង្ក្រាបព្រមទាំងអនុវត្តច្បាប់ឲ្យបានម៉ឺងម៉ាត់បំផុតចំពោះជនល្មើស។

## ១.២.៣. ស្ថានភាពនៃការប្រើប្រាស់ដីធ្លី និងការគ្រប់គ្រងធនធានធម្មជាតិបរិស្ថាន គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ

### ១.២.៣.១. ការប្រើប្រាស់ដីធ្លី

វិស័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយិដីខេត្ត មានការរីកចម្រើនគួរឲ្យកត់សម្គាល់ទាំងការផ្សព្វផ្សាយច្បាប់ភូមិបាល ការផ្តល់ប័ណ្ណកម្មសិទ្ធិ ការគ្រប់គ្រងសំណង់ និងការរៀបចំប្លង់គោលសំខាន់ៗ ដោយរួមទាំងការទប់ស្កាត់អំពើរំលោភ ដីសាធារណៈ ដីរដ្ឋ ដីព្រៃ និងដីព្រៃលិចទឹក។ យើងមានធនធានគ្រប់គ្រាន់ក្នុងការផ្តល់ប័ណ្ណកម្មសិទ្ធិស្របច្បាប់តាមលក្ខណៈជាប្រព័ន្ធ បានចុះបញ្ជីចប់សព្វគ្រប់ ១០០% បានចំនួន០៤ស្រុក គឺស្រុកបាភ្នំ ស្វាយអន្ទរ ព្រះស្តេច និងស្រុកកំពង់ត្របែក។ ដោយឡែកស្រុកដែលកំពុងដំណើរការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធចំនួន ០៩ក្រុង/ស្រុក គឺក្រុងព្រៃវែង ស្រុកកំចាយមារ កញ្ជ្រៀច ពាមជរ ពាមរក៍ ពារាំង ពោធិ៍រៀង មេសាង និងស្រុកស៊ីធរកណ្តាល ក្រោមជំនួយគាំទ្រពីរាជរដ្ឋាភិបាលកម្ពុជា ប៉ុន្តែការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ តាមការស្នើសុំរបស់ម្ចាស់ដី

នៅមានចំនួនតិចតួចនៅឡើយ។

ឆ្នាំ២០២៤ បានបន្តធ្វើការប្រកាសបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យដូចខាងក្រោម៖

-ប្រកាសតំបន់វិនិច្ឆ័យ ចំនួនៈ ១៥៧ ភូមិ ស្មើនឹង ១៦ ឃុំ/សង្កាត់

-ប្រមូលទិន្នន័យ,បញ្ចូលទិន្នន័យ,គូរ, ចំនួនៈ ១០៦,៤៤៥ ក្បាលដី

-វាស់វែង ចំនួនៈ ១១៩,២១៤ ក្បាលដី

-បិទផ្សាយ ចំនួនៈ ១១០,៦២៨ ក្បាលដី ស្មើនឹង ៦៧ភូមិ

-ហត្ថលេខា ចំនួនៈ ១០០,៣០៣ ក្បាលដី

-ចែកប័ណ្ណ ចំនួនៈ ៨១,៨៣៧ ក្បាលដី។

+ចាប់ពីដំណើរការអនុវត្តការងារឆ្នាំ២០០៣ រហូតដល់ ឆ្នាំ២០២៤ បានធ្វើការប្រកាសបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យមានដូចខាងក្រោម៖

-ប្រកាសតំបន់វិនិច្ឆ័យ ចំនួនៈ ១,០៦០ ភូមិ ស្មើនឹង ១១៦ ឃុំ/សង្កាត់ ១៣ក្រុង/ស្រុក

-ប្រមូលទិន្នន័យ,បញ្ចូលទិន្នន័យ,គូរ, ចំនួនៈ ១,០២២,១៩០ ក្បាលដី

-វាស់វែង ចំនួនៈ ១,០៣២,០៥៩ ក្បាលដី

-បិទផ្សាយ ចំនួនៈ ៩០៥,៦៦៤ ក្បាលដី

-ហត្ថលេខា ចំនួនៈ ៨១៤,៩៤៦ ក្បាលដី

-ចែកប័ណ្ណ ចំនួនៈ ៧៨៤,៩១៣ ក្បាលដី

បានសហការជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រៀបចំប្លង់គោលទីប្រជុំជនអ្នកលឿង ស្រុកពាមរក៍ ឃុំស្វាយអន្ទរ ស្រុកស្វាយអន្ទរ និងក្រុងព្រៃវែង។

បានផ្តល់លិខិតអនុញ្ញាតសាងសង់ជូនបងប្អូនប្រជាពលរដ្ឋ វិស័យឯកជននិងវិស័យរដ្ឋ ដូចខាងក្រោមៈ

**ក.ស្នើសុំកែលំអរសាងសង់អគាររដ្ឋបាលរដ្ឋថ្មីចំនួន ១១គម្រោង សរុប ៧,៧៣៤ ម៉ែត្រក្រឡា**

- ស្នើសុំកែលំអរជួលជុលអាគាររដ្ឋបាលទំហំសរុប ២៤៣,៦៣ ម៉ែត្រក្រឡា ជួសជុលស្នាមប្រេះស្រាំ ជញ្ជាំងក្នុង ជញ្ជាំងក្រៅ កោសលាបថ្នាំថ្មីឡើងវិញទាំងអស់ កម្រាលការ៉ូរុះរើចេញក្រាលការ៉ូថ្មី
- ដំបូលអាគារ ស្នើសុំជួសជុលសរុប ៣៥៦ ម៉ែតក្រឡា៖ អំពីគ្រោងឆ្អឹងដែក ប្រកក្បឿង
- បានអនុញ្ញាតសាងសង់ជួសជុលអាគាររដ្ឋបាលចំនួន ០១ គម្រោង

**ខ.ស្នើសុំលិខិតអនុញ្ញាតសាងសង់សំណង់ឯកជន ១៤ គម្រោង ក្នុងនោះ អនុម័តចំនួន ១៤ គម្រោង ដូចខាង ក្រោមៈ**

- សាងសង់អាគារមជ្ឈមណ្ឌលកំសាន្តចំនួន ០១គម្រោង និងអនុម័តចំនួន ០១ គម្រោង
- បានអនុញ្ញាតសាងសង់ស្ថានីយ៍ប្រេង ចំនួន ០១ គម្រោង និងអនុម័តចំនួន ០១ គម្រោង
- បានអនុញ្ញាតសំណើសាងសង់ឃ្លាំង ចំនួន ០២ គម្រោង និងអនុម័តចំនួន ០២ គម្រោង
- បានអនុញ្ញាតសាងសង់អាគារផ្សេងៗចំនួន ០៣ គម្រោង និងអនុម័ត ចំនួន ០៣ គម្រោង

- បានអនុញ្ញាតសំណើសាងសង់បង្គោលអង់តែនចំនួន ០៦ គម្រោង និងអនុម័តចំនួន ០៦ គម្រោង
- បានអនុញ្ញាតសំណើសាងសង់ស្ថានីយប្រេងឥន្ធនៈចំនួន ០១គម្រោង និងអនុម័តចំនួន ០១ គម្រោង
- បានចុះពិនិត្យការងារសំណង់នៅស្រុកព្រះស្ដេច និងស្រុកបាភ្នំ

បានផ្ដល់លិខិតអនុញ្ញាតសាងសង់ជូនបងប្អូនប្រជាពលរដ្ឋ និងវិស័យឯកជនបានចំនួន ៤១ គម្រោង

ទន្ទឹមនឹងនេះ យើងពិនិត្យឃើញថា ការលំបាកមួយចំនួន គឺជុំវិញការរៀបចំលំនៅឋាន ឬសំណង់សាធារណៈផ្សេងៗភាគច្រើនមិនទាន់មានច្បាប់អនុញ្ញាត ហើយការរំលោភយកដីចំណីផ្លូវ និងដីសាធារណៈផ្សេងៗធ្វើជាកម្មសិទ្ធិនៅតែមានសកម្មភាព។ ចំពោះការងារចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធជួបការលំបាក ដោយយើងចេញប័ណ្ណឲ្យយកទៅប្រើប្រាស់រៀងៗខ្លួនហើយ នៅតែបន្តឈ្លោះដណ្ដើមព្រំប្រទល់គ្នា។ ជាមួយគ្នានេះ នៅមានបញ្ហាប្រឈមមួយទៀតគឺ ប្រជាពលរដ្ឋមានប្រតិកម្មមិនពេញចិត្តចំពោះការដែលពួកគាត់ទៅបង់ពន្ធនៅសាខាពន្ធដារខេត្ត លើដីអំណោយពីឪពុកម្ដាយទៅកូន ពីប្ដីទៅប្រពន្ធ ពីប្រពន្ធទៅប្ដី ពីតាយាយទៅចៅ ពីព្រោះកន្លងមកយើងពុំបានអនុវត្តដូច្នេះទេ ហើយពួកគាត់ត្រូវចំណាយប្រាក់ច្រើនក្នុងការធ្វើដំណើរយកប័ណ្ណទៅប្រថាប់ត្រា។

### ១.២.៣.២. ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន

ខេត្តព្រៃវែង មានលក្ខណៈសម្បត្តិអំណោយផលពីធម្មជាតិគ្រប់គ្រាន់ សម្រាប់ការរស់នៅរបស់ប្រជាពលរដ្ឋក្នុងការធ្វើអាជីវកម្ម និងផលិតកម្ម ដោយទាញយកផលពីធម្មជាតិទាំងលើដី ក្នុងដី ក្នុងទឹក ដើម្បីផលិតស្បៀងអាហារ និងសេចក្ដីត្រូវការគ្មានព្រំដែនក្នុងការរស់នៅ។ ធនធានទាំងនោះមានៈ ខ្សាច់ ថ្មភ្នំ ទន្លេ បឹងបួរ មច្ឆាជាតិ ព្រៃជម្រកត្រីពង សត្វស្លាប។ល។ ដែលបំរើឲ្យជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ និងការអភិវឌ្ឍក្នុងតំបន់។

ដោយខេត្តមានលក្ខណៈសណ្ឋានដីល្អប្រសើរ បានធ្វើឲ្យជីវិតសត្វ រុក្ខជាតិ អាចរស់នៅដុះដាលបានយ៉ាងគាប់ប្រសើរលើទឹកដីខេត្តទាំងមូល ប៉ុន្តែប្រភពទឹកធម្មជាតិសម្រាប់ប្រើប្រាស់បច្ចុប្បន្នដូចជា បឹង ទន្លេ ព្រែក កាន់តែរាក់ ហើយមិនមានភាពល្អស្អាតថ្លា អាចបរិភោគបានទេ ការហូបទឹករបស់ប្រជាពលរដ្ឋតាមដងទន្លេគឺអាស្រ័យការជីកអណ្ដូងស្នប់ និងបូមទឹកមករក្សាទុកអោយរងថ្លា សម្រាប់ប្រើប្រាស់ជំនួសទឹកធម្មជាតិ ដែលកខ្វក់ដោយសារការរីងរាក់ និងការបង្ហូរចូលកាកសំណល់នានា។

- **ចំណុចខ្លាំង**

ដើម្បីឆ្លើយតបទៅ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលខាងលើនេះ មានកត្តាដូចខាងក្រោម ៖

- បរិស្ថានគ្របដណ្ដប់កំណត់នូវក្របខណ្ឌពេញលេញ និងគ្រប់ជ្រុងជ្រោយ ដើម្បីធានាការសម្រេចបាននូវអាទិភាពនៃគោលនយោបាយនៃយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ នីតិកាលទី៧ នៃរដ្ឋសភា
- ថ្នាក់ដឹកនាំមន្ទីរ មន្ត្រីជំនាញ និងបណ្ដាការិយាល័យក្រោមឱវាទទាំងអស់បានខិតខំយកចិត្តទុកដាក់អនុវត្តតួនាទី ភារកិច្ច ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានាឲ្យបានល្អ ព្រមទាំងកំពុងបណ្ដុះបណ្ដាលធនធានមនុស្សលើគ្រប់ផ្នែក គ្រប់ជំនាញ និងលើកកម្ពស់សមត្ថភាពមន្ត្រីរាជការ ដើម្បីឲ្យស្របទៅ

តាមគោលនយោបាយយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ នីតិកាលទី៧របស់រាជរដ្ឋាភិបាល
- មានការបែងចែកភារកិច្ចច្បាស់លាស់ តាមការិយាល័យនីមួយៗ
- មានការលើកទឹកចិត្តតាមរយៈការតំឡើងថ្នាក់ ឋានៈ ចំពោះបុគ្គលិកដែលមានស្នាដៃល្អនៅក្នុងការអនុវត្តការងារ
- អនុវត្តតាមក្របខណ្ឌគោលនយោបាយកំណែទម្រង់វិមជ្ឈការនិងសហវិមជ្ឈសម្រាប់ប្រទេសកាន់របបប្រជាធិបតេយ្យ
- មន្ទីរបរិស្ថាន បានរៀបចំធ្វើផែនការរំកិល៣ឆ្នាំ ផែនការយុទ្ធសាស្ត្រឆ្នាំ២០២៥-២០២៧
- បានអនុវត្តរៀបចំផែនការថវិកាតាមកម្មវិធីសម្រាប់អនុវត្តប្រចាំឆ្នាំ២០២៥
- បានផ្សព្វផ្សាយដល់មន្ត្រី បុគ្គលិកក្នុងអង្គភាពរបស់ខ្លួន អំពីខ្លឹមសារនៃអនុក្រឹត្យលិខិតបទដ្ឋានឯកសារបច្ចេកទេសពាក់ព័ន្ធ នឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ចូលរួមសហការជាមួយរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងការផ្សព្វផ្សាយអំពីខ្លឹមសារ អនុក្រឹត្យនិងវិធានការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនប្រកបដោយប្រសិទ្ធភាពដល់អ្នកពាក់ព័ន្ធនិងប្រជាពលរដ្ឋ
- ចូលរួមពិនិត្យយន្តការ និងកិច្ចសន្យាក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដែលមានស្រាប់ដើម្បីឲ្យស្របតាមស្មារតីអនុក្រិត្យលេខ១១៣ លេខ១៦៨ សាចរអន្តរក្រសួងលេខ១០៧០ និងសេចក្តីណែនាំអន្តរក្រសួងលេខ១៤១១
- ចូលរួមសហការរៀបចំផែនការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក៏ដូចជាផ្តល់យោបល់បច្ចេកទេសពាក់ព័ន្ធ នឹងសំណើ ឬគម្រោង សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ចូលរួមសហការសិក្សា និងផ្តល់យោបល់លើការស្វែងរកទីតាំងសម្រាប់រៀបចំទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនរបស់រដ្ឋបាលរាជធានី ក្រុង ស្រុក
- តាមដានត្រួតពិនិត្យនិងវាយតម្លៃការងារបរិស្ថានពាក់ព័ន្ធការគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន
- ជំរុញការអនុវត្តវិធានការច្បាប់ពាក់ព័ន្ធ និងការគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន
- ក្រសួងបរិស្ថានបានដាក់ផែនការឲ្យមន្ទីរបរិស្ថាន រាជធានី ខេត្ត រកចំណូលបង់ចូលរដ្ឋ
- ជំរុញការដាំកូនឈើប្រណិត និងឈើហូបផ្លែ តាមបណ្តាក្រុង ស្រុក (ចែកជូនប្រជាពលរដ្ឋទូទៅក្នុង១ឆ្នាំ១០០០០ម៉ឺនដើម)
- ជំរុញការងារមេត្រីភាពបរិស្ថានតាម សាលារៀន វត្តអារ៉ាម សហគ្រាស និងវិស័យឯកជននានាឲ្យយកចិត្តទុកដាក់យុទ្ធនាការកាត់បន្ថយការប្រើប្រាស់ប្លាស្ទិកក្រោមប្រធានបទ(ថ្ងៃនេះខ្ញុំមិនប្រើថង់ប្លាស្ទិចទេ)(យើងរួមគ្នាដើម្បីការពារបរិស្ថានកម្ពុជា)និង(លាហើយប្លាស្ទិក)
- ការងារប្រលងប្រណាំង ភូមិ ឃុំ ក្រុង ស្រុក ដែលមានបរិស្ថានស្អាត សន្តិសុខ និងសុវត្ថិភាពល្អ

- ក្រសួងបរិស្ថានបានផ្តល់ឡដុតសំរាមទៅឲ្យតាមបណ្តាក្រុង ស្រុក ដែលមានទីប្រជុំជនធំៗ
- ក្រសួងបរិស្ថានបានផ្តល់ឡានដឹកសំរាមទៅឲ្យតាមបណ្តាក្រុង ស្រុក ដែលមានទីប្រជុំជនធំៗ

- **ចំណុចខ្សោយ**
  - មន្ត្រីជំនាញក្នុងការិយាល័យ សមត្ថភាពបច្ចេកទេសនៅមានកម្រិត
  - មន្ត្រីភ្នាក់ងារបរិស្ថានក្រុង ស្រុក បានចូលរួមសមាហរណកម្មទៅរដ្ឋបាលសាលា ក្រុង ស្រុកអស់
  - ការយល់ដឹងរបស់ប្រជាពលរដ្ឋ អំពីការញែកសំរាម ការទុកដាក់សំរាម សំណល់រឹងនៅមានកម្រិត
  - តាមផ្សារ និងទីប្រជុំជនមួយចំនួន គ្មានទីលានចាក់សំរាម និងអ្នកប្រមូលសំរាម
  - អ្នកដេញថ្លៃភាស៊ីផ្សារ អ្នកប្រមូលភាស៊ីផ្សារ អ្នកប្រមូលសំរាមតាមផ្សារផ្សេងៗដាច់ពីគ្នា
  - ការរៀបចំអនុវត្តតាមផែនការសកម្មភាពរបស់មន្ទីរសម្រាប់ឆ្នាំ២០២៥

- *ភាពវិចវិល និងអន់ថយលើបញ្ហាបរិស្ថានត្រូវបានកត់សម្គាល់ឃើញថាៈ*

1. ការប្រើប្រាស់ជីគីមីកំពុងតែមានសកម្មភាពយ៉ាងខ្លាំងក្លាក្នុងវិស័យកសិកម្ម។
2. ថ្នាំពុលត្រូវបាននាំចូលមកប្រើប្រាស់យ៉ាងច្រើនទាំងមានច្បាប់និងអត់ច្បាប់ ដូច្នេះការប្រើប្រាស់ជីគីមី និងថ្នាំពុលសម្លាប់សត្វល្អិតបានធ្វើឲ្យប៉ះពាល់គុណភាពដី និងគុណភាពទឹក និងបាត់បង់ជីវៈចម្រុះដែលជាចំណុចគួរឲ្យព្រួយបារម្ភ។
3. ដោយកំណើនប្រជាពលរដ្ឋកើនឡើងឆាប់រហ័ស ការបោះចោលសំណល់ រឹង រាវ ដែលមានជាតិពុល បង្កអោយមានការប៉ះពាល់ដល់ជីវិតមនុស្ស សត្វ រុក្ខជាតិ បាននិងកំពុងតែជាបញ្ហាចោទរបស់ខេត្ត។
4. ការរំខានដោយសម្លេង ផ្សែង រំញ័រ កំពុងតែកើតឡើងនៅតាមទីប្រជុំជន ដូចជាតំបន់អ្នកលឿង ស្រុកកំពង់ត្របែក ស្រុកពាមរក៍ ក្រុងព្រៃវែង ស្រុកស្វាយអន្ទរ ស្រុកពារាំង ស្រុកកំចាយមារ ជាដើម។ ប្រភពរំខានមានសិប្បកម្មផ្សារដែក សិប្បកម្មផលិតគោយន្ត អំបិលអ៊ីយ៉ូត រថយន្តធំៗ និងគោយន្តដែលធ្វើសកម្មភាពដោយសេរីក្នុងទីប្រជុំជនមិនបានគិតគូរនិងយកចិត្តទុកដាក់ពីផលប៉ះពាល់បរិស្ថាន

- **បញ្ហាអាទិភាពសំខាន់ៗ ដែលត្រូវដោះស្រាយចំពោះមុខគឺៈ**

ដើម្បីឆ្លើយតប មន្ទីរបរិស្ថានខេត្តព្រៃវែង បានរៀបចំផែនការគ្រប់គ្រងបរិស្ថាន ដោយជំរុញទៅដល់មន្ត្រីថ្នាក់ក្រោមឲ្យមានការយល់ដឹង និងអនុវត្តសកម្មភាពសំខាន់ៗ មួយចំនួនដូចជាៈ

- បើកវគ្គអប់រំផ្សព្វផ្សាយបង្ហាញពីទស្សនៈ និងបញ្ហាបរិស្ថាននៅក្នុងប្រទេសកម្ពុជា និងក្នុងខេត្ត
- ពង្រឹងសមត្ថភាពដល់មន្ត្រីឲ្យចេះបែងចែក និងការអនុវត្តច្បាប់ជាមួយមន្ទីរស្ថាប័នភាគីដែលពាក់ព័ន្ធពីផលប្រយោជន៍រួម និងធ្វើការវិភាគទៅលើហេតុផលប៉ះពាល់បរិស្ថាន
- ការចូលរួមពីដៃគូរចម្រុះអោយចេះជ្រើសរើសគម្រោង រៀបចំផែនការគ្រប់គ្រងបរិស្ថាន ដោយផ្អែកទៅលើការវិនិច្ឆ័យជាច្រើន
- ចូលរួមរៀបចំផែនការគ្រប់គ្រងបរិស្ថាននៅថ្នាក់ខេត្ត ស្របតាមគោលនយោបាយវិមជ្ឈការ និង

វិសហមជ្ឈការរបស់រាជរដ្ឋាភិបាល ដោយផ្តោតសំខាន់ទៅលើស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និង រូបវ័ន្ត អរូវ័ន្ត

- ចូលរួមបន្តសហការជាមួយអាជ្ញាធរ គ្រប់គ្រងសំរាម សំណល់រឹង រាវ នៅក្នុងខេត្ត
- រៀបចំប៉ាណូធំៗផ្សព្វផ្សាយស្តីពីបរិស្ថានដាក់តាមបណ្តាក្រុងស្រុក ដែលជាអត្ថិភាពរបស់ខេត្ត
- បច្ចុប្បន្ននេះ មន្ទីរបរិស្ថានខេត្តព្រៃវែងបានទទួលអនុក្រឹត្យលេខ១៦-១៧ អនក្រ.បក ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២១ ស្តីពីការបង្កើតតំបន់ប្រើប្រាស់ច្រើនយ៉ាងទូលំទូលាយព័ន្ធតាឡី បឹងស្នេហ៍ និងអនុក្រឹត្យលេខ១៧ អនក្រ.បកចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២១ ស្តីពីការកំណត់ និងការបែងចែកតំបន់គ្រប់គ្រងក្នុងតំបន់ប្រើប្រាស់ច្រើនយ៉ាងទូលព័ន្ធតាឡីបឹងស្នេហ៍ ដែលស្ថិតនៅភូមិទ័ពស្តេច ឃុំជាយ ស្រុកបាភ្នំខេត្តព្រៃវែង និងរៀបចំបង្កើតជាតំបន់ការពារធម្មជាតិក្នុងភូមិសាស្ត្រខេត្តព្រៃវែង ដូច្នេះហើយមន្ទីរស្នើសុំការសហការជាមួយអាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ ប្រជាពលរដ្ឋ ក្រសួងពាក់ព័ន្ធ និងជាពិសេសក្រសួងបរិស្ថាន ដើម្បីបង្កើតតំបន់ការពារធម្មជាតិក្នុងខេត្តព្រៃវែង មួយវិញទៀត ក្រសួងបរិស្ថាន ក៏ដូចជាមន្ទីរបរិស្ថាននិងទទួលបាននូវអនុក្រឹត្យលេខ២២៤អនក្រ.បកចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២៣ស្តីពីការបង្កើតតំបន់បេតិកភណ្ឌធម្មជាតិ និងកំណត់ទីតាំងបេតិកភណ្ឌវប្បធម៌ប្រវត្តិសាស្ត្រនគរភ្នំ ឈើកាច់បាភ្នំ
- យុទ្ធនាការ(ការដាំឈើ១លានដើមក្នុង១ឆ្នាំ)
- តំបន់ប្រើប្រាស់ច្រើនយ៉ាងទូលព័ន្ធតាឡីបឹងស្នេហ៍ មានផ្ទៃដីទំហំ ៣៥៥៧ ហិកតា ផ្ទៃដីព្រៃទំហំ (ស្តួល) ៨៦ ហិកតា និងផ្ទៃដីវាលស្មៅទំហំ ៣៤៧១ ហិកតា
- ប៉មសម្រាប់មើលសត្វស្លាប ដែលមានកំពស់១៦ម៉ែត្រ កាំជណ្តើរ៦៣កាំ (០១កន្លែង)
- អគារបេតុងទំហំ១៣ម៉ែត្រគុណ៨ម៉ែត្របូក៨ម៉ែត្រគុណ៤ម៉ែត្រ ដែលមានផ្ទៃក្រឡាសាងសង់សរុប ១១២ម៉ែត្រការ៉េអំពីបេតុងប្រក់ក្បឿង(០១កន្លែង)
- បន្ទប់ទឹក និងបង្គន់អនាម័យ(ទំហំ៤,៥មX៥ម)(០១កន្លែងជាប់អគារស្នាក់ការ)
- អគារស្នាក់ការសម្រាប់សហគមន៍(ធ្វើអំពីសង្កឹស័ទំហំ(៤មX៦ម)(០១កន្លែង)
- ថ្នាលបណ្តុះកូនឈើទំហំ(៨មX១២ម)(០១កន្លែង)
- មានទូកចំនួន០៣គ្រឿង
- មានមន្ត្រីស្ម័គ្រចិត្តចំនួន០៣នាក់ប្រចាំការ និងបានចុះយាមល្បាតទាំងថ្ងៃ ទាំងយប់
- ចុះប្រមូលទិន្នន័យ និងសហការជាមួយអង្គការWCSដើម្បីយកសំណាកសត្វស្លាបព្រៃនិងសត្វស្រុក
- មន្ទីរបរិស្ថានខេត្តរៀបចំសំណើសុំបន្ថែមមន្ត្រីឧទ្យានុរក្សសម្រាប់បំរើការងារក្នុងតំបន់ការពារធម្មជាតិ
- បង្កើតតំបន់បេតិកភណ្ឌធម្មជាតិ និងកំណត់ទីតាំងបេតិកភណ្ឌវប្បធម៌ប្រវត្តិសាស្ត្រនគរភ្នំ ឈើកាច់បាភ្នំ
- ដែលមានផ្ទៃដីទំហំសរុប ១២៥,២៧៧៥ (មួយរយម្ភៃប្រាំហិកតាម្ភៃប្រាំពីរអាចិតសិបសង់ទីអា) និងការកំណត់ទីតាំងបេតិកភណ្ឌវប្បធម៌ប្រវត្តិសាស្ត្រនគរភ្នំ ឈើកាច់បាភ្នំ ដែលមាន០៩ទីតាំង

ស្ថិតនៅក្នុងភូមិសាស្ត្រឃុំជើងភ្នំ ឃុំឈើកាច់ និងឃុំរោងដំរី ស្រុកបាភ្នំ ខេត្តព្រៃវែង។

- *ចំពោះវិធានការសម្រាប់រួមចំណែកសម្រេចគោលបំណង គោលនយោបាយ របស់ក្រសួងបរិស្ថាន និងការសហការជាមួយអាជ្ញាធរដែនដីដើម្បីឆ្លើយតបទៅ និងការគ្រប់គ្រងការងារខាងលើ មានដូចខាងក្រោម ៖*
    - ក្នុងការចូលរួមចំណែក អនុវត្តគោលនយោបាយតាមវិស័យ ពិសេសគោលនយោបាយរួមរបស់រាជរដ្ឋាភិបាល ក្នុងគោលដៅបង្កើនការងារ សមធម៌ តម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សំដៅសម្រេចបាននូវការកាត់បបន្ថយភាពក្រីក្រ និងលើកកម្ពស់ជីវភាពប្រជាពលរដ្ឋ ដោយក្រសួងបានកំណត់យកគោលបំណងគោលនយោបាយរួមមួយ គឺ៖ (កិច្ចគាំពារ បរិស្ថាន ការអភិរក្សជីវចម្រុះ និងការគ្រប់គ្រងធនធានធម្មជាតិឲ្យមាននិរន្តភាព)
    - បានផ្សព្វផ្សាយដល់មន្ត្រី បុគ្គលិកក្នុងអង្គភាពរបស់ខ្លួនអំពីខ្លឹមសារនៃអនុក្រឹត្យ លិខិតបទដ្ឋាន ឯកសារបច្ចេកទេសពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
    - ផ្សព្វផ្សាយចំណេះដឹងស្តីពីការការពារបរិស្ថានតាមរយៈ បណ្តាញសង្គមឲ្យប្រជាពលរដ្ឋចូលរួមក្នុងការយកចិត្តទុកដាក់សំរាម និងសុខភាពអនាម័យបរិស្ថាននាពេលអនាគត
    - ចុះត្រួតពិនិត្យ តាមដាន និងវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
    - ផ្តល់យោបល់លើការស្វែងរកទីតាំងសម្រាប់រៀបចំទីលានទុកដាក់សំរាម សំណល់រឹង ទីប្រជុំជនតាមបណ្តាស្រុកនីមួយៗបន្ថែមទៀត
    - បំផុសសិស្សានុសិស្ស និស្សិត ប្រជាពលរដ្ឋ ព្រះសង្ឃ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ឲ្យយល់ដឹងពីការងារអប់រំបរិស្ថាន
    - ការដាំដើមឈើឡើងវិញ នៅតាមសហគមន៍ សាលារៀន វត្តអារាម ទីសាធារណៈ
    - ការដាក់ផ្លាកសញ្ញា ប៉ាណូអប់រំបរិស្ថានតាមទីប្រជុំជននានា
    - ការផ្តល់ធុងសំរាមនៅតាមទីសាធារណៈ និងសាលារៀន
    - ការងារមេត្រីភាពបរិស្ថាន បានប្រគល់ឲ្យនូវបណ្ណសរសើរដល់រូបវន្តបុគ្គល និងនីតិបុគ្គល។

### ១.២.៣.៣. ស្ថានភាពគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ

ជារៀងរាល់ឆ្នាំខេត្តព្រៃវែងតែងតែជួបប្រទះជានិច្ចនូវគ្រោះមហន្តរាយផ្សេងៗដូចជា គ្រោះរាំងស្ងួត ឬគ្រោះទឹកជំនន់ខ្យល់កន្ត្រាក់ រន្ទះបាញ់ ភ្លើងឆេះផ្ទះ លង់ទឹក...។ល។ សាខាកាកបាទក្រហមខេត្តមានលក្ខណៈត្រៀមបំរុងនិងត្រៀមបង្ការជានិច្ច ចំពោះមុខសញ្ញាគ្រោះថ្នាក់ផ្សេងៗដែលអាចនិងកើតឡើង។

ខេត្តព្រៃវែង នាថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២៤នេះ (គិតត្រឹមម៉ោង ៦:០០នាទីល្ងាច)មានដូចខាងក្រោម៖

១-ស្ថានភាពអាកាសធាតុ៖ ផ្ទៃមេឃស្រឡះ

២-ស្ថានភាពខ្យល់កន្ត្រាក់៖ គ្មាន

៣-ស្ថានភាពអគ្គីភ័យ៖ ៣៥ខ្នង

៤-ស្ថានភាពរន្ទះបាញ់៖ ៩នាក់

៥-ស្ថានភាពទឹកជំនន់៖បាក់ច្រាំងទន្លេ ៤៩ខ្នង ស្មើនឹង ៤៩គ្រួសារ

**+ស្ថានភាពកម្ពស់ទឹកព្រែកតាតាំ(មុខផ្សារក្រុងព្រៃវែង)៖**

•ម្សិលមិញកម្ពស់ទឹក ៥,៧១ ម៉ែត្រ •ថ្ងៃនេះកម្ពស់ទឹក ៥,៧២ ម៉ែត្រ •ទឹកឡើង ០,០១ ម៉ែត្រ

•កម្ពស់ទឹកប្រកាសអាសន្ន ៧,៥០ ម៉ែត្រ។

៦-ស្ថានភាពផ្សេងៗ៖ គ្មាន។

ឆ្នាំ២០២៥គ្រួសាររងគ្រោះមានចំនួន ៣៧៨គ្រួសារ ក្នុងនោះផ្ទះដែលរងផលប៉ះពាល់ចំនួន ១៩៨ខ្នង ខូចផ្ទះ ១៣៣ ខ្នង ជម្លៀសទៅទីទួលសុវត្ថិភាពចំនួន ៦៥ គ្រួសារ គ្រួសារដែលខ្វះស្បៀងចំនួន ១២០គ្រួសារ និងគ្រួសារមានជម្ងឺចំនួន ២៥ គ្រួសារ។ ក្រៅពីនេះប៉ះពាល់ដល់ផ្លូវ សាលារៀន មណ្ឌលសុខភាព វត្ត អារាម អណ្តូង បង្គន់អនាម័យ ទំនប់ ប្រឡាយ និងដំណាំផ្សេងៗទៀតជាច្រើន។

-ភ្លើងឆេះផ្ទះប្រជាពលរដ្ឋចំនួន ៣៥ខ្នង

-រន្ទះបាញ់មនុស្សស្លាប់ចំនួន ៩នាក់

-លង់ទឹកស្លាប់មនុស្សចំនួន ២៦នាក់

ទន្ទឹមនឹងនេះ ខេត្តជួបប្រទះនូវបញ្ហាប្រឈមមួយចំនួនដូចជា៖(១).ការគាំទ្រធនធាននិងបច្ចេកទេស ក្នុងការសង្គ្រោះបន្ទាន់ ពុំទាន់ឆ្លើយតប១០០%(មានន័យថាមានធនធានតិចក្នុងការចែកអំណោយសង្គ្រោះ ភ្លាមៗ) (២).ប្រជាពលរដ្ឋមួយចំនួននៅមានការធ្វេសប្រហែសដែលបណ្តាលឲ្យមានកើតឡើងនូវគ្រោះថ្នាក់ ផ្សេងៗ និង(៣).ការសង្គ្រោះនៅក្រោយគ្រោះមហន្តរាយនៅមានកម្រិត។

## ១.២.៤. ស្ថានភាពនៃការគ្រប់គ្រងរដ្ឋបាលនិងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

### ១.២.៤.១. អភិបាលកិច្ចល្អ

មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភានិងអធិការកិច្ចខេត្តព្រៃវែង ជាអង្គភាពមួយស្ថិត ក្រោមការគ្រប់គ្រង ដឹកនាំបញ្ជាតាមជំនាញផ្ទាល់ពីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និង អធិការកិច្ច ព្រមទាំងក្រោមការគ្រប់គ្រងដឹកនាំបញ្ជាធ្វើសកម្មភាពផ្ទាល់ពីឯកឧត្តមអភិបាលនៃគណៈ អភិបាលខេត្តព្រៃវែង។ ក្នុងនោះបេសកកម្មរបស់មន្ទីរដែលត្រូវអនុវត្តគឺ ប្រតិបត្តិយ៉ាងខ្ជាប់ខ្ជួនហ្មត់ចត់ តាមប្រកាសលេខ ០៧៤/១៥ ទ រ ព អ. ប្រក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការកំណត់តួនាទី ភារៈកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចរាជធានី ខេត្ត សំដៅប្រឆាំងនឹងអំពើពុករលួយ ការរំលោភដោយអំណាច និងបាតុភាពអសកម្មនានាដែលមាន តួនាទីសំខាន់បីដូចខាងក្រោម៖

**I.បេសកកម្ម និងភារកិច្ចចម្បងៗសម្រាប់ឆ្នាំ២០២៥-២០២៧**

**១-ការងារទំនាក់ទំនងជាមួយសមាជិករដ្ឋសភា-ព្រឹទ្ធសភា អាជ្ញាធរផ្សព្វផ្សាយច្បាប់**

- សម្របសម្រួលទំនាក់ទំនង និងសហការជាមួយអាជ្ញាធរខេត្ត ក្រុងស្រុកបំពេញភារកិច្ច
- បង្កលក្ខណៈ និងសម្របសម្រួលជូនសមាជិករដ្ឋសភា-ព្រឹទ្ធសភាបំពេញបេសកកម្មក្នុងខេត្តព្រៃវែង
- សិក្សាស្រាវជ្រាវច្បាប់ដែលចូលជាធរមាន និងលិខិតបទដ្ឋានគតិយុត្តិនានារបស់រាជរដ្ឋាភិបាល
- រៀបចំកម្មវិធី និងចុះអប់រំផ្សព្វផ្សាយច្បាប់គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តិផ្សេងៗ

ឲ្យប្រជាពលរដ្ឋក្នុងខេត្តព្រៃវែងឲ្យយល់ដឹង និងប្រតិបត្តិតាម

- រៀបចំវេទិកាសាធារណៈ និងសិក្ខាសាលាដើម្បីទទួលសំណូមពរពីប្រជាពលរដ្ឋ
- សិក្សា ស្ទង់មតិ និងបញ្ជ្រាបការយល់ដឹងដល់ប្រជាពលរដ្ឋលើវិស័យច្បាប់។

**២-ការងារតាមដានការអនុវត្តន៍ច្បាប់ លិខិតបទដ្ឋានគតិយុត្តិ ធ្វើអធិការកិច្ច និងទទួលពាក្យបណ្ដឹង អង្កេត ដោះស្រាយ**

- ក្ដាប់សភាពការណ៍ ដើម្បីសុំការអនុញ្ញាតចុះធ្វើអធិការកិច្ចលើប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងកិច្ចប្រតិបត្តិការហិរញ្ញវត្ថុចំណូលចំណាយថវិកាជាតិ ការគ្រប់គ្រងប្រើប្រាស់ថវិកាជំនួយ និងការគ្រប់គ្រងប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ។
- ធ្វើអធិការកិច្ចលើករណីពាក់ព័ន្ធនឹងការក្លែងបន្លំ ការកិបកេងទ្រព្យសម្បត្តិរដ្ឋ និងការប្រព្រឹត្តអំពើអសកម្មផ្សេងៗដែលធ្វើឲ្យបាត់បង់ផលប្រយោជន៍ជាតិ។
- តាមដាន និងត្រួតពិនិត្យរាល់ការអនុវត្តន៍ច្បាប់ លិខិតបទដ្ឋានគតិយុត្តិ និងអនុសាសន៍របស់នាយករដ្ឋមន្ត្រី។
- អធិការកិច្ចលើការគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋតាមមន្ទីរ អង្គភាព ស្រុក ក្រុង
- ធ្វើអធិការកិច្ចលើការងារដឹកនាំ គ្រប់គ្រងចំណូល ចំណាយ ថវិកាជាតិ ស្វែងរកការកិបកេងក្លែងបន្លំយកសម្ភារៈ ថវិកា ដែលជាទ្រព្យសម្បត្តិតាមមន្ទីរ អង្គភាព ស្រុក ក្រុងទូទាំងខេត្ត
- ទទួលពាក្យបណ្ដឹងរបស់ប្រជាពលរដ្ឋពីគ្រប់មជ្ឈដ្ឋានរួមទាំងចុះក្ដាប់សភាពការណ៍ ឬបញ្ជូនទៅអង្គភាពមានសមត្ថកិច្ច។
- តាមដានជំរុញការដោះស្រាយពាក្យបណ្ដឹងរបស់ប្រជាពលរដ្ឋ ដែលបានបញ្ជូនឲ្យសមត្ថកិច្ចដោះស្រាយ។

**៣-ការងារអភិវឌ្ឍន៍ធនធានមនុស្ស បង្កើនសម្ភារៈ មធ្យោបាយ ថែទាំ និងជួសជុលអាគារ**

- បង្កលក្ខណៈ លើកទឹកចិត្តអោយមន្ត្រីរាជការបន្តការសិក្សាតាមសកលវិទ្យាល័យនានាក្នុងខេត្ត
- បណ្ដុះបណ្ដាលបំប៉ុនជំនាញរដ្ឋបាល ច្បាប់ គណនេយ្យ និងជំនាញផ្សេងទៀតពាក់ព័ន្ធនឹងការងាររបស់មន្ទីរ តាមកម្មវិធីរយៈពេលខ្លី មធ្យម វែង របស់ក្រសួង និងខេត្ត ដើម្បីឲ្យមន្ត្រីរាជការមានគ្រប់លក្ខណៈ សម្បត្តិគ្រប់គ្រងអង្គភាព ជាគ្រូឧទ្ទេសនាមផ្សព្វផ្សាយច្បាប់ លិខិតបទដ្ឋានគតិយុត្តិ ដោះស្រាយពាក្យបណ្ដឹង និងធ្វើអធិការកិច្ចក្នុងខេត្តអោយមានប្រសិទ្ធភាព។
- បង្កើនទាំងបរិមាណ គុណភាព នូវសម្ភារៈការិយាល័យ សម្ភារៈបច្ចេកទេស និងសង្ហារឹមជូនមន្ត្រីរាជការបំពេញការងារតាមតួនាទីឲ្យបានសមរម្យ
- បង្កើនមធ្យោបាយធ្វើដំណើរ ដឹកជញ្ជូន និងប្រេងឥន្ធនៈជូនមន្ត្រីរាជការបំពេញបេសកកម្មតាមដានអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្តិ ដឹកជញ្ជូនសម្ភារៈផ្សព្វផ្សាយច្បាប់តាមមូលដ្ឋាន
- ថែទាំ ជួសជុលអាគារ របងមន្ទីរ បំពាក់នូវសម្ភារៈបរិក្ខា និងសង្ហារឹម

**II.លទ្ធផលការងារសម្រេចបានក្នុងឆ្នាំ២០២៣៤**

**១-ការងាររដ្ឋបាល និងហិរញ្ញវត្ថុ**

អនុវត្តតាមអនុក្រឹត្យលេខ៦៧អនក្រ.បកចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ១៩៩៩ និងប្រកាសលេខ ០៧៤/១៥ ទ រ ព អ. ប្រក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៥ សម្រាប់ឆ្នាំ២០២៣ មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចខេត្តព្រៃវែង បានរៀបចំផែនការកម្មវិធីប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំបានច្បាស់លាស់ រួចធ្វើសកម្មភាពតាមជំហាននីមួយៗ ទទួលលទ្ធផលវិជ្ជមានជាអាទិ៍៖

- បានបញ្ជូនមន្ត្រីរាជការចំនួន២នាក់ វគ្គបណ្តុះបណ្តាលស្តីពីអធិការកិច្ច
- បានថែទាំ ជួសជុល អាគារ
- បានបំពាក់គ្រឿងសង្ហារឹម និងសំភារៈបច្ចេកទេស
- បានបង្វែរប្រាក់បៀវត្សជូនមន្ត្រីរាជការរបស់មន្ទីរយ៉ាងទៀតទាត់

**២-ការងារទំនាក់ទំនងជាមួយសមាជិករដ្ឋសភា-ព្រឹទ្ធសភា និងអាជ្ញាធរ**

សម្របសម្រួល និងទំនាក់ទំនងជាមួយសមាជិក រដ្ឋសភា ព្រឹទ្ធសភា និងអាជ្ញាធរ ដើម្បីសិក្សាស្រាវជ្រាវច្បាប់ដែលចូលជាធរមាន ព្រមទាំងលិខិតបទដ្ឋានគតិយុត្តិ របស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការផ្សព្វផ្សាយច្បាប់ជូនប្រជាពលរដ្ឋឲ្យបានយល់ និងប្រតិបត្តិតាម។ ក្នុងនោះដែរមន្ទីរបានចុះស្ទង់មតិប្រជាពលរដ្ឋនិងបញ្ជ្រាបការយល់ដឹងច្បាប់ដល់មូលដ្ឋានដោយប្រើកម្រងសំណួរ ឬសម្ភាសន៍ចំនួន ៤៨លើក និងបានសហការជាមួយក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច រៀបចំវេទិកាសាធារណៈចំនួន ១លើក ដែលមានអ្នកចូលរួមសរុបចំនួន ៤៣៩ នាក់ ស្រី ២៥២ នាក់។

**៣-ការងារអប់រំផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិ**

នៅឆ្នាំ២០២៤ មន្ទីរបានផ្សព្វផ្សាយច្បាប់ចំនួន ១៥ លើក ដែលមានអ្នកចូលរួម សរុបចំនួន ២៦៦០ នាក់ ស្រី ១២៩៩ នាក់ លើច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនចំនួន ៨លើក ច្បាប់ចរាចរណ៍ផ្លូវគោកចំនួន ៧លើក។

**៤-ការងារទទួលពាក្យបណ្តឹង អង្កេត ស្រាវជ្រាវ និងដោះស្រាយ**

- បានចុះអង្កេតស្រាវជ្រាវពាក្យបណ្តឹង និងសម្របសម្រួលវិវាទដីធ្លីចំនួន ០៣ លើក
- ទទួលពាក្យបណ្តឹងពីប្រជាពលរដ្ឋ និងពន្យល់តាមនីតិវិធីច្បាប់ចំនួន ០៣ លើក
- បានចុះស្រាវជ្រាវតាមបណ្តាស្រុក-ឃុំ ពីបណ្តឹងរបស់ប្រជាពលរដ្ឋ

**៥-ការងារអធិការកិច្ច**

- ចុះតាមដានការអនុវត្តច្បាប់ ស្តីពីការប្រមូលចំណូលពីបណ្តាអង្គភាពដែលមានប្រភពចំណូលត្រូវបង់ចូលថវិការដ្ឋឲ្យទាន់ពេលវេលា។
- ចុះតាមដាន និងត្រួតពិនិត្យការអនុវត្តកិច្ចសន្យាសម្បទាន កិច្ចសន្យាលទ្ធកម្ម ភាសុី ការគ្រប់គ្រងសត្តឃាតដ្ឋាន និងអនាម័យសត្វ-សាច់សត្វ នៅតាមបណ្តាក្រុងស្រុកជុំវិញខេត្ត។
- ចុះតាមដានប៉ុស្តិ៍ច្រកទ្វារព្រំដែនតាមអនុក្រឹត្យលេខ ៦៤ បានចំនួន ០៦ច្រក គឺច្រកទ្វារព្រំដែនអន្តរជាតិបន្ទាយចក្រី ច្រកទ្វារព្រំដែនអន្តរជាតិកោះរកា ច្រកទ្វារព្រំដែនពាមមន្ទារ ច្រកទ្វារព្រំ

ដែនកោះសំពៅ ច្រកទ្វារព្រំដែនស្វាយអាផោង និងច្រកទ្វារព្រំដែនអន្តរជាតិម៉ឺនជ័យ។

- ចុះតាមដានការអនុវត្តកិច្ចសន្យាវិនិយោគគ្រប់ប្រភេទ
- ចុះតាមដានការអនុវត្តតាមមន្ទីរ អង្គភាព ក្រុង ស្រុក ឃុំ សង្កាត់ ដោយផ្អែកតាមតួនាទី ភារកិច្ចដែលបានកំណត់។
- ចុះធ្វើអធិការកិច្ចលើផ្នែករដ្ឋបាល ហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិការិយាល័យ បរិច្ឆេទ ២០២៣បានចំនួន ៥១មន្ទីរ-អង្គភាព-ក្រុងស្រុក។

**III.បញ្ហាប្រឈម**

- សម្ភារៈមធ្យោបាយសម្រាប់អនុវត្តការងារ និងធ្វើដំណើរចុះមូលដ្ឋានមានភាពខ្វះខាត
- ការអញ្ជើញមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋចូលរួមការផ្សព្វផ្សាយច្បាប់ជួបការលំបាក ដោយពុំមានថវិកាឧបត្ថម្ភសោហ៊ុយធ្វើដំណើរ និងថ្លៃអាហារសម្រាប់ហូប។
- មន្ត្រីរាជការមានចំនួនតិចធៀបនឹងទំហំការងារ និងមានចំណេះដឹងនូវមានកម្រិត
- ពុំទាន់មានច្បាប់អធិការកិច្ចសម្រាប់មន្ទីរចុះអនុវត្ត

**IV. សេចក្តីសន្និដ្ឋាន**

មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភានិងអធិការកិច្ចខេត្តព្រៃវែងបាន និងកំពុងអនុវត្តសកម្មភាពទៅតាមគម្រោងដែលបានលើកឡើងក្នុងឆ្នាំ២០២៤ និងរៀបចំផែនការវិនិយោគខាងលើនេះ ស្របទៅតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិឆ្នាំ២០២៥-២០២៧ និងដើម្បីរួមចំណែកអនុវត្តកម្មវិធីនយោបាយយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដែលកំពុងតែមានសកម្មភាពនាពេលបច្ចុប្បន្ននេះ។ ដូចនេះដើម្បីឆ្លើយតប និងសម្រេចជោគជ័យក្នុងកម្មវិធី និងយុទ្ធសាស្ត្រអាទិភាពរបស់ខ្លួនខាងលើបន្ថែមទៀត មន្ទីរសូមធ្វើការស្នើសុំថវិកាដែលបានលើកឡើងនៅក្នុងផែនការសម្រាប់ឆ្នាំ២០២៥ ២០២៦ និង ២០២៧ ដោយក្តីអនុគ្រោះ ព្រមទាំងគោរពដ៏ខ្ពង់ខ្ពស់។

### ១.២.៤.២. ការងារសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ

ក្រុមចលនាប្រជាការពារក្នុងភូមិ-ឃុំទូទាំងខេត្តមានចំនួន ៩៦២ក្រុម សមាជិកចំនួន ១០,៣៩០នាក់ ស្រី ១៩៨ នាក់ មានសកម្មភាពប្រចាំចំនួន ៩៦២ ក្រុម។ ក្នុងឆ្នាំ២០២៥នេះ ដើម្បីពង្រឹងសន្តិសុខ និងសណ្តាប់ធ្នាប់សង្គមជូនប្រជាពលរដ្ឋ ខេត្តបានផ្សព្វផ្សាយស្តីពីការចាត់តាំងអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់អាជ្ញាធរដែនដី កម្លាំងប្រដាប់អាវុធទាំង៣ មន្ត្រីរាជការ និងប្រជាពលរដ្ឋបានចំនួន ៦,០៧៧ លើក មានអ្នកចូលរួមសរុបចំនួន ៥៩១,៨០០ នាក់ ស្រី ៣០០,៧៦៩ នាក់ និងរៀបចំប្រជុំផ្សព្វផ្សាយស្តីពីការចាត់តាំង អនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព៩យ៉ាងនៅតាមភូមិបានសរុបចំនួន ៨៤១ លើក មានអ្នកចូលរួមសរុបចំនួន ៤៣,៤១៥ នាក់ ស្រី ២២,០៤៣ នាក់ និងធ្វើការបង្ក្រាបបទល្មើសព្រហ្មទណ្ឌ បានចំនួន ១២៥ លើក និងឃាត់ខ្លួនជនសង្ស័យបានចំនួន ២០៩ នាក់ ស្រី ៩ នាក់ (ជនជាតិចិន ៥ នាក់)។

- **បញ្ហាប្រឈម**

  - ការផ្តល់ព័ត៌មានរបស់ប្រជាពលរដ្ឋពាក់ព័ន្ធការអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព

ឲ្យមានប្រសិទ្ធភាពនៅមានចំនួនតិចតួចនៅឡើយ។

- គ្រោះថ្នាក់ចរាចរណ៍មានកំណើន ដោយសារការបើកបរមិនពាក់មួកសុវត្ថិភាព ប្រើល្បឿនហួសកំណត់ ខ្វះការយោគយល់អធ្យាស្រ័យគ្នា និងមិនគោរពច្បាប់ចរាចរណ៍។
- ខ្វះការសហការពីអាណាព្យាបាលនៃអ្នកប្រើប្រាស់គ្រឿងញៀន

**១.២.៤.៣. ការងារព្រំដែន**

ខេត្តព្រៃវែង មានព្រំប្រទល់ជាមួយខេត្តចំនួនបីនៃសាធារណៈរដ្ឋសង្គមនិយមវៀតណាម គឺខេត្តដុងថាប់ ខេត្តតៃនីញ និងខេត្តឡុងអាន និងមានច្រកទ្វារព្រំដែនចំនួន ០៦ ក្នុងនោះ ច្រកទ្វារព្រំដែនអន្តរជាតិមានចំនួន ០៣កន្លែង គឺច្រកទ្វារព្រំដែនអន្តរជាតិបន្ទាយចក្រី កោះរកា និងម៉ឺនជ័យ ច្រកទ្វារតំបន់ព្រំដែនមានចំនួន ០២កន្លែង គឺ ពាមមន្ទារ និងស្វាយអាង៉ោង និងច្រកទ្វារព្រំដែនទ្វេរភាគីកោះសំពៅ។

លើការងារគ្រប់គ្រងច្រកព្រំដែន ខេត្តបានអនុវត្តស្របតាមគោលការណ៍ណែនាំក៏ដូចជាបណ្តាកិច្ចព្រមព្រៀងនានារវាងប្រទេសទាំង២(វៀតណាម-កម្ពុជា) និងរវាងខេត្តនិងខេត្តជាប់ព្រំដែនសំដៅលើកកំពស់ទំនាក់ទំនងកិច្ចសហប្រតិបត្តិការល្អលើគ្រប់វិស័យ ជាពិសេសលើការងារសន្តិសុខ សេដ្ឋកិច្ច សង្គមកិច្ចពាណិជ្ជកម្ម និងការអភិវឌ្ឍន៍តំបន់ព្រំដែន ក៏ដូចជាការបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋទាំង២ភាគីចេញចូលឆ្លងកាត់ទៅវិញទៅមក និងប្រកបមុខរបរក្នុងជីវភាពប្រចាំថ្ងៃបានល្អប្រសើរ។ ក្រៅពីនេះបានយកចិត្តទុកដាក់ទប់ស្កាត់ និងបង្ក្រាបបទល្មើសនានាតាមបន្ទាត់ព្រំដែនទទួលបានលទ្ធផលល្អជាបន្តបន្ទាប់ផងដែរ។

មានបញ្ហាប្រឈមមួយចំនួនដូចជា អគារ ឬការិយាល័យបំរើការងាររបស់សមត្ថកិច្ចការពារព្រំដែនពុំទាន់មានលក្ខណៈសមរម្យ និងច្រកទ្វារខ្លះពុំមានដីសម្រាប់សាងសង់ទីស្នាក់ការនៅឡើយ។

# ជំពូកទី២
# គម្រោងនៃកម្មវិធីវិនិយោគ
# បីឆ្នាំរំកិលខេត្ត

# ជំពូកទី២
# គម្រោងនៃកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត

អនុវត្តទៅតាមយុទ្ធសាស្ត្របញ្ចកោណតំណាក់កាលទី១ របស់រាជរដ្ឋាភិបាល ដែលមានបាវចនាៈ កំណើនការងារ សមធម៌ និងប្រសិទ្ធភាព រដ្ឋបាលខេត្តព្រៃវែងបានរៀបចំកម្មវិធីវិនិយោគ៣ឆ្នាំរំកិល ២០២៥-២០២៧ ដើម្បីរួមចំណែកអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល និងមានសង្គតិភាពទៅនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០២៤-២០២៨ដែលមានគោលដៅធំៗ៤គឺៈ

១-រួមចំណែកធានាអោយបាននូវកំណើនសេដ្ឋកិច្ចក្នុងអត្រាមធ្យមប្រចាំឆ្នាំប្រមាណ៧% ប្រកបដោយចីរភាព បរិយាប័ន្ន សមធម៌ និងធន់នឹងវិបត្តិ តាមរយៈការធ្វើពិពិធកម្មនៃមូលដ្ឋានសេដ្ឋកិច្ចអោយបានទូលាយនិងមានសមត្ថភាពប្រកួតប្រជែងជាងមុនក្នុងបរិការណ៍អតិផរណាមានកម្រិតទាប អាចគ្រប់គ្រងបានអត្រាប្តូរប្រាក់មានស្ថិរភាពនិងទុនបម្រុងមានកំណើនជារៀងរាល់ឆ្នាំ។

២-បង្កើតការងារអោយបានកាន់តែច្រើនឡើងជូនដល់ប្រជាជន ជាពិសេសសម្រាប់ស្រទាប់យុវជន តាមរយៈការបន្តខិតខំកែលម្អ និងបង្កើនភាពប្រកួតប្រជែងរបស់កម្ពុជាក្នុងការទាក់ទាញ និងការជម្រុញលើកទឹកចិត្តដល់សកម្មភាពវិនិយោគទាំងវិនិយោគក្នុងប្រទេស ទាំងវិនិយោគមកពីក្រៅប្រទេស។

៣-សម្រេចអោយបាននូវគោលដៅនៃការកាត់បន្ថយភាពក្រីក្រក្នុងអត្រាជាង១%ក្នុង១ឆ្នាំ ក៏ដូចជាគោលដៅផ្សេងៗទៀតដែលត្រូវបានកំណត់ក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ទន្ទឹមនឹងការផ្តោតអាទិភាពកាន់តែខ្លាំងឡើងលើការអភិវឌ្ឍន៍ធនធានមនុស្ស ការគ្រប់គ្រងបរិស្ថាន និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព។

៤-បន្តពង្រឹងសមត្ថភាពនិងអភិបាលកិច្ចនៃស្ថាប័នរដ្ឋ ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដើម្បីធានាអោយបាននូវប្រសិទ្ធភាពនិងភាពស័ក្តិសិទ្ធនៃសេវាសាធារណៈ សំដៅបម្រើប្រជាជនអោយកាន់តែប្រសើរឡើង។

គម្រោងវិនិយោគទាំងថ្នាក់ខេត្តនិងក្រុងស្រុកដែលបានលើកឡើងរយៈពេល៣ឆ្នាំ២០២៥-២០២៧មានចំនួន ៥២៤ គម្រោង ដែលត្រូវចំណាយថវិកាសរុបចំនួន ២,៦០១,៥៧០ លានរៀល។ ថវិកាដែលអាចសង្ឃឹមថា មានការគាំទ្រ គឺមាន ៥៣៦,៥៣២ លានរៀល គឺស្មើនឹង ២០,៦២ ភាគរយ នៃគម្រោងដែលថ្នាក់ខេត្តនិងក្រុងស្រុកលើកឡើងសរុប គឺគម្រោងកំពុងដំណើរការមាន ១៤៣ គម្រោង ប៉ាន់ស្មានថវិកាចំនួន ១៣៨,១៧១ លានរៀល និងគម្រោងមានការសន្យាគាំទ្រ ១៧៧ គម្រោង ប៉ាន់ស្មានថវិកាចំនួន ៣៩៨,៣៦១ លានរៀល ក្នុងនោះ៖

➡ចំពោះថវិការបស់មន្ទីរវិស័យក្នុងខេត្តមាន ៤៥៨,០៥៩ លានរៀល អនុវត្តគម្រោងចំនួន ៣០៨ ក្នុងនោះគម្រោងកំពុងដំណើរការមាន ១៤០ គម្រោង ប៉ាន់ស្មានថវិកាចំនួន ១២២,៨៣៤ លានរៀល និងគម្រោងដែលមានការសន្យាគាំទ្រមាន ១៦៨ គម្រោង ប៉ាន់ស្មានថវិកាចំនួន ៣៣៥,២២៥ លានរៀល។ ដោយឡែកគម្រោងកំពុងដំណើរការរបស់រដ្ឋបាលខេត្តមាន ០៣គម្រោង ប៉ាន់ស្មានថវិកា ១៥,៣៣៦ លានរៀល និងគម្រោងមានការសន្យាគាំទ្ររបស់រដ្ឋបាលខេត្ត ០៩គម្រោង ប៉ាន់ស្មានថវិកាចំនួន ៦៣,១៣៧ លានរៀល (សរុបរួមមានចំនួន ៣២០ គម្រោង ប៉ាន់ស្មានថវិកាចំនួន ៥៣៦,៥៣២ លានរៀល)។

ក្រៅពីគម្រោងទាំង ៣២០ ដែលមានថវិកាខាងលើ គឺមានគម្រោងចំនួន ២០៤ទៀតដែលមិនទាន់មានថវិកាគាំទ្រគឺរដ្ឋបាលខេត្ត ១៣គម្រោង ប៉ាន់ស្មានថវិកាចំនួន ១១០,៤៤៦ លានរៀល និងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារមាន ៣គម្រោង ប៉ាន់ស្មានថវិកាចំនួន ៦៣ លានរៀល និងមន្ទីរវិស័យមានចំនួន ៩៥គម្រោង ប៉ាន់ស្មានថវិកាចំនួន ៧០១,៣៩៩ លានរៀល និងតាមបណ្តាក្រុងស្រុកមានចំនួន ៩៣ គម្រោង ប៉ាន់ស្មានថវិកាចំនួន ១,២៥៣,១៣០ លានរៀល (សរុបរួមចំនួន ២,០៦៥,០៣៨ លានរៀល)។

# តារាង ២.១ ៖ តារាងសង្ខេបប្រភពមូលនិធិ

| ល.រ | ស្ថាប័ន | ចំនួនគម្រោង | សរុបតម្លៃគម្រោង (លានរៀល) | ប្រភពមូលនិធិ | ចំនួនគម្រោង | តម្លៃគម្រោង (លានរៀល) |
|---|---|---|---|---|---|---|
| **១-រដ្ឋបាលខេត្ត** | | | | | | |
| ១ | រដ្ឋបាលខេត្ត | 9 | 63,136.90 | រដ្ឋបាលខេត្ត | 9 | 63,136.90 |
| | | | | ដៃគូអភិវឌ្ឍន៍ | - | - |
| **សរុប** | | **9** | **63,136.90** | | **9** | **63,136.90** |
| **២-ការគាំទ្រតាមបណ្តាមន្ទីរ អង្គភាព** | | | | | | |
| ១ | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | 13 | 879.48 | មន្ទីរ | 13 | 879.48 |
| | | | | ដៃគូអភិវឌ្ឍន៍ | - | - |
| ២ | មន្ទីរធនធានទឹក និងឧតុនិយម | 3 | 786.20 | មន្ទីរ | 3 | 786.20 |
| | | | | ដៃគូអភិវឌ្ឍន៍ | - | - |
| ៣ | មន្ទីរសាធារណៈការ និងដឹកជញ្ជូន | 5 | 200,700.00 | មន្ទីរ | 5 | 200,700.00 |
| | | | | ដៃគូអភិវឌ្ឍន៍ | - | - |
| ៤ | មន្ទីរអភិវឌ្ឍន៍ជនបទ | 7 | 1,123.70 | មន្ទីរ | 7 | 1,123.70 |
| | | | | ដៃគូអភិវឌ្ឍន៍ | - | - |
| ៥ | មន្ទីរពាណិជ្ជកម្ម | 6 | 264.00 | មន្ទីរ | 5 | 114.00 |
| | | | | ដៃគូអភិវឌ្ឍន៍ | 1 | 150.00 |
| ៦ | មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | 4 | 45.80 | មន្ទីរ | 4 | 45.80 |
| | | | | ដៃគូអភិវឌ្ឍន៍ | - | - |
| ៧ | មន្ទីររ៉ែ និងថាមពល | 3 | 8.60 | មន្ទីរ | 3 | 8.60 |
| | | | | ដៃគូអភិវឌ្ឍន៍ | - | - |
| ៨ | មន្ទីរទេសចរណ៍ | 9 | 650.00 | មន្ទីរ | 9 | 650.00 |
| | | | | ដៃគូអភិវឌ្ឍន៍ | - | - |
| ៩ | មន្ទីរប្រៃសណីយ៍ | 1 | 152.00 | មន្ទីរ | 1 | 152.00 |
| | | | | ដៃគូអភិវឌ្ឍន៍ | - | - |
| ១០ | មន្ទីរមុខងារសាធារណៈ | 1 | 67.50 | មន្ទីរ | 1 | 67.50 |
| | | | | ដៃគូអភិវឌ្ឍន៍ | - | - |
| ១១ | មន្ទីរអប់រំ យុវជន និងកីឡា | 21 | 96,370.00 | មន្ទីរ | 1 | 1,200.00 |
| | | | | ដៃគូអភិវឌ្ឍន៍ | 20 | 95,170.00 |
| ១២ | មន្ទីរសុខាភិបាល | 60 | 18,394.36 | មន្ទីរ | 27 | 17,615.70 |
| | | | | ដៃគូអភិវឌ្ឍន៍ | 33 | 778.66 |
| ១៣ | មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | 3 | 400.00 | មន្ទីរ | 3 | 400.00 |
| | | | | ដៃគូអភិវឌ្ឍន៍ | - | - |
| ១៤ | មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | 7 | 376.25 | មន្ទីរ | 7 | 376.25 |
| | | | | ដៃគូអភិវឌ្ឍន៍ | - | - |
| ១៥ | មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ | 1 | 200.00 | មន្ទីរ | 1 | 200.00 |
| | | | | ដៃគូអភិវឌ្ឍន៍ | - | - |
| ១៦ | មន្ទីរព័ត៌មាន | 1 | 260.00 | មន្ទីរ | 1 | 260.00 |
| | | | | ដៃគូអភិវឌ្ឍន៍ | - | - |
| ១៧ | មន្ទីរធម្មការ និងកិច្ចការសាសនា | 4 | 286.00 | មន្ទីរ | 4 | 286.00 |
| | | | | ដៃគូអភិវឌ្ឍន៍ | - | - |
| ១៨ | មន្ទីរកិច្ចការនារី | 10 | 126.00 | មន្ទីរ | 10 | 126.00 |
| | | | | ដៃគូអភិវឌ្ឍន៍ | - | - |
| ១៩ | មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត | 1 | 14,050.00 | មន្ទីរ | 1 | 14,050.00 |
| | | | | ដៃគូអភិវឌ្ឍន៍ | - | - |
| ២០ | មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | 8 | 84.90 | មន្ទីរ | 8 | 84.90 |
| | | | | ដៃគូអភិវឌ្ឍន៍ | - | - |
| **សរុប** | | **168** | **335,224.79** | | **168** | **335,224.79** |
| **សរុបរួម** | | **177** | **398,361.69** | | **177** | **398,361.69** |

# តារាង ២.២ ៖ គម្រោង សកម្មភាពខេត្តកំពុងដំណើរការ

| ល.រ | ឈ្មោះគម្រោង | ឆ្លើយតបគោលដៅ | ទីតាំង | លទ្ធផលគ្រោង | | រយៈពេលអនុវត្ត | តម្លៃប៉ាន់ស្មាន (លានរៀល) | ប្រភពមូលនិធិ | អ្នកទទួលផល | | កម្រិតទុនវិនិយោគ (លានរៀល) | | | | អង្គភាពអនុវត្ត |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | បរិមាណ | ឯកតា | | | | សរុប | ស្រី | ២០២៥ | ២០២៦ | ២០២៧ | សរុប | |
| **ក. គម្រោង សកម្មភាពរបស់រដ្ឋបាលខេត្ត** | | | | | | | | | | | | | | | |
| **១. ផ្នែកសេដ្ឋកិច្ច** | | | | | | | | | | | | | | | |
| ១ | ការងារជួសជុលផ្លូវពហុឆ្នាំ០៧គម្រោង (យោងលិខិត១១៤៩០សហវ.អហក) | ១.១.១ | ខេត្តព្រៃវែង | ៧ | កន្លែង | ១០ឆ្នាំ | 42,123.00 | រដ្ឋ | ១២៥៥៨៦២ | ៦៤៨៨៥៩ | 4,212.30 | 4,212.30 | 4,212.30 | 12,636.90 | រដ្ឋបាលខេត្ត |
| ២ | ការងារជួសជុលស្លាបនាសួនច្បារតេជោសន្តិភាពភូមិលេខ២សង្កាត់កំពង់លាវក្រុងព្រៃវែងនិងការងារសាងសង់រោងទូក | ១.១.១ | ក្រុងព្រៃវែង | ១ | កន្លែង | ១ឆ្នាំ | 1,700.00 | រដ្ឋ | ១២៥៥៨៦២ | ៦៤៨៨៥៩ | 1,700.00 | - | - | 1,700.00 | |
| **សរុប** | | | | | | | **43,823.00** | | | | **5,912.30** | **4,212.30** | **4,212.30** | **14,336.90** | |
| **២. ផ្នែកសង្គមកិច្ច** | | | | | | | | | | | | | | | |
| ១ | សាងសង់អគារមណ្ឌលកុមារកំព្រាខេត្ត (ដំណាក់កាលទី២)និងសណ្ឋាគារខេត្ត | ១.១.១ | ក្រុងព្រៃវែង | ១ | កន្លែង | ១ឆ្នាំ | 1,000.00 | រដ្ឋ | ៦០ | ២៨ | 1,000.00 | - | - | 1,000.00 | រដ្ឋបាលខេត្ត |
| **សរុប** | | | | | | | **1,000.00** | | | | **1,000.00** | **-** | **-** | **1,000.00** | |
| **សរុបរួម** | | | | | | | **44,823.00** | | | | **6,912.30** | **4,212.30** | **4,212.30** | **15,336.90** | |

| ល.រ | ឈ្មោះគម្រោង | ឆ្លើយតបគោលដៅ | ទីតាំង | លទ្ធផលគ្រោង | | រយៈពេលអនុវត្ត | តម្លៃប៉ាន់ស្មាន (លានរៀល) | ប្រភពមូលនិធិ | អ្នកទទួលផល | | កម្រិតទុនវិនិយោគ (លានរៀល) | | | | អង្គភាពអនុវត្ត |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | បរិមាណ | ឯកតា | | | | សរុប | ស្រី | ២០២៥ | ២០២៦ | ២០២៧ | សរុប | |
| **ខ.គម្រោង សកម្មភាពរបស់មន្ទីរ អង្គភាព និងអ្នកពាក់ព័ន្ធ** | | | | | | | | | | | | | | | |
| **១-ផ្នែកសេដ្ឋកិច្ច** | | | | | | | | | | | | | | | |
| ១ | បណ្តុះបណ្តាលផលិតកម្មកសិកម្ម | ១.១.១ | ខេត្តព្រៃវែង | ៣៨ | វគ្គ | ៣ឆ្នាំ | 34.86 | រដ្ឋ | ៩៦០ | ៥៧៦ | 11.62 | 11.62 | 11.62 | 34.86 | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ២ | ផ្សព្វផ្សាយបច្ចេកទេសកសិកម្ម | ១.១.១ | ខេត្តព្រៃវែង | ៧ | វគ្គ | ៣ឆ្នាំ | 39.84 | រដ្ឋ | ១៨៥ | ១១១ | 13.28 | 13.28 | 13.28 | 39.84 | |
| ៣ | បណ្តុះបណ្តាលពង្រឹងសម្ថភាពថ្នាក់ដឹកនាំសហគមន៍កសិកម្ម | ១.១.១ | ខេត្តព្រៃវែង | ៣ | វគ្គ | ៣ឆ្នាំ | 32.94 | រដ្ឋ | ៦៦ | ៤០ | 10.98 | 10.98 | 10.98 | 32.94 | |
| ៤ | បណ្តុះបណ្តាលបច្ចេកទេសគ្រឿងយន្តកសិកម្ម | ១.១.១ | ខេត្តព្រៃវែង | ២ | វគ្គ | ៣ឆ្នាំ | 15.24 | រដ្ឋ | ៥០ | ៣០ | 5.08 | 5.08 | 5.08 | 15.24 | |
| ៥ | បណ្តុះបណ្តាលបច្ចេកវិទ្យាក្រោយប្រមូលផល | ១.១.១ | ខេត្តព្រៃវែង | ២ | វគ្គ | ៣ឆ្នាំ | 15.60 | រដ្ឋ | ៦០ | ៣៦ | 5.20 | 5.20 | 5.20 | 15.60 | |
| ៦ | បណ្តុះបណ្តាលបច្ចេកទេសដំណាំកៅស៊ូ | ១.១.១ | ខេត្តព្រៃវែង | ២ | វគ្គ | ៣ឆ្នាំ | 15.00 | រដ្ឋ | ៥០ | ៣០ | 5.00 | 5.00 | 5.00 | 15.00 | |
| ៧ | បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វ | ១.១.២ | ខេត្តព្រៃវែង | ៤ | វគ្គ | ៣ឆ្នាំ | 30.00 | រដ្ឋ | ១០០ | ៦០ | 10.00 | 10.00 | 10.00 | 30.00 | |
| ៨ | ចំនួនសត្វដែលបានការចាក់ថ្នាំវ៉ាក់សាំង(គោ ក្របី) | ១.១.២ | ខេត្តព្រៃវែង | ៣៥០០០ | ក្បាល | ៣ឆ្នាំ | 81.00 | រដ្ឋ | ១៥០០ | ៨០០ | 27.00 | 27.00 | 27.00 | 81.00 | |
| **សរុបរួម** | | | | | | | **264.48** | | | | **88.16** | **88.16** | **88.16** | **264.48** | |
| ៩ | ស្តាបនាផ្លូវក្រាលកៅស៊ូ DBST | ១.៧.២ | ផ.ខ 3110A | ២.៧០ | គ.ម | ១ឆ្នាំ | 2,500.00 | រដ្ឋ | ៣៦៨១៣០ | ១៩១៥៦៦ | 2,500.00 | - | - | 2,500.00 | មន្ទីរសាធារណការ និងដឹកជញ្ជូន |
| ១០ | ថែទាំប្រចាំផ្លូវក្រាលកៅស៊ូ/ដីល្បាយថ្ម | ១.៧.២ | ផ្លូវជាតិ ផ្លូវខេត្ត ៣១ខ្សែ | ៦៥០.១៩ | គ.ម | ១ឆ្នាំ | 5,600.00 | រដ្ឋ | ១២១២៣៩៧ | ៦២៥៨៣៣ | 5,600.00 | - | - | 5,600.00 | |
| **សរុបរួម** | | | | | | | **8,100.00** | | | | **8,100.00** | **-** | **-** | **8,100.00** | |
| ១១ | ការសាងសង់បង្គន់អនាម័យ/បដិភាគសម្ភារអនាម័យ | ១.៨.១ | ស្រុកកំចាយមារ កញ្ជ្រៀច,ពារាំង | ១០០ | បង្គន់ | ១ឆ្នាំ | 1,100.00 | ក្រសួង | ៦១០ | ៦៨ | 1,100.00 | - | - | 1,100.00 | មន្ទីរអភិវឌ្ឍន៍ជនបទ |
| **សរុបរួម** | | | | | | | **1,100.00** | | | | **1,100.00** | **-** | **-** | **1,100.00** | |
| ១២ | គម្រោងជម្រុញទីផ្សារសម្រាប់កសិកម្មខ្នាតតូច(AIMS) | ១.៨.១ | ៧ស្រុក | ១០០ | លើក | ៣ឆ្នាំ | 150.00 | រដ្ឋ+IFAD | ១៦៥០ | ៨៥០ | 50.00 | 50.00 | 50.00 | 150.00 | មន្ទីរពាណិជ្ជកម្ម |
| **សរុបរួម** | | | | | | | **150.00** | | | | **50.00** | **50.00** | **50.00** | **150.00** | |

| ល.រ | ឈ្មោះគម្រោង | ឆ្លើយតបគោលដៅ | ទីតាំង | លទ្ធផលគ្រោង | | រយៈពេលអនុវត្ត | តម្លៃប៉ាន់ស្មាន (លានរៀល) | ប្រភពមូលនិធិ | អ្នកទទួលផល | | កម្រិតទុនវិនិយោគ (លានរៀល) | | | | អង្គភាពអនុវត្ត |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | បរិមាណ | ឯកតា | | | | សរុប | ស្រី | ២០២៥ | ២០២៦ | ២០២៧ | សរុប | |
| ១៣ | មូលដ្ឋានផលិតកម្មដែលត្រូវបានចុះពិនិត្យ និងពង្រឹងការអនុវត្តច្បាប់ | ១.១១.១ | ទូទាំងខេត្ត | ១៥០ | នាក់ | ៣ឆ្នាំ | 12.00 | រដ្ឋ | ៦០ | ៨ | 4.00 | 4.00 | 4.00 | 12.00 | មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |
| ១៤ | បណ្តុះបណ្តាលអំពីការងារគ្រប់គ្រង សហគ្រាស ធុនតូច មធ្យម ដល់សិប្បកម្មម្ចាស់ និងបុគ្គលិករបស់មូលដ្ឋានផលិតកម្មត្រូវបាន | ១.៩.២ | មន្ទីរ | ៦ | វគ្គ | ៣ឆ្នាំ | 12.00 | រដ្ឋ | ១០០ | ១១ | 4.00 | 4.00 | 4.00 | 12.00 | |
| ១៥ | ចុះធ្វើអធិការកិច្ចការងារគ្រប់គ្រងរបស់ប្រតិបត្តិករទឹកស្អាត | ១.៩.២ | ទូទាំងខេត្ត | ៣៨ | មូលដ្ឋាន | ៣ឆ្នាំ | 11.00 | រដ្ឋ | ៣០ | ១៥ | 3.67 | 3.67 | 3.67 | 11.00 | |
| ១៦ | បណ្តុះបណ្តាលអំពីការគ្រប់គ្រង និងសុវត្ថិភាពផ្គត់ផ្គង់ទឹកស្អាតដល់ម្ចាស់ និងបុគ្គលិកអាជីវកម្មទឹកស្អាត | ១.៩.២ | មន្ទីរ | ១៥០ | នាក់ | ៣ឆ្នាំ | 12.00 | រដ្ឋ | ៦០ | ១១ | 4.00 | 4.00 | 4.00 | 12.00 | |
| ១៧ | កោសលាបថ្នាំអាគារ ជួសជុលសាលប្រជុំមន្ទីរ | ១.៩.១ | មន្ទីរ | ១ | ខ្នង | ១ឆ្នាំ | 100.00 | រដ្ឋ | ២១ | ៨ | 33.33 | 33.33 | 33.33 | 100.00 | |
| **សរុបរួម** | | | | | | | **147.00** | | | | **49.00** | **49.00** | **49.00** | **147.00** | |
| ១៨ | ផ្សព្វផ្សាយបទដ្ឋានពាក់ព័ន្ធនឹងការគ្រប់គ្រងវិស័យប្រេងកាត | ១.១២.១ | ស្រុកកំពង់ត្របែក, ពាមរក៍,ព្រះស្តេច, ក្រុងព្រៃវែង, ស្វាយអន្ទរ, | ៥ | លើក | ១ឆ្នាំ | 3.30 | រដ្ឋ | ៧០ | ២០ | 3.30 | - | - | 3.30 | មន្ទីររ៉ែ និងថាមពល |
| **សរុបរួម** | | | | | | | **3.30** | | | | **3.30** | **-** | **-** | **3.30** | |
| ១៩ | ជុសជុលមន្ទីរ | ១.១៥.១ | ក្រុងព្រៃវែង | ៥៣៥ | ម$^2$ | ១ឆ្នាំ | 300.00 | រដ្ឋ | ១៨ | ៩ | 300.00 | - | - | 300.00 | មន្ទីរទេសចរណ៍ |
| **សរុបរួម** | | | | | | | **300.00** | | | | **300.00** | **-** | **-** | **300.00** | |
| **សរុបរួម (១-ផ្នែក សេដ្ឋកិច្ច )** | | | | | | | **10,064.78** | | | | **9,690.46** | **187.16** | **187.16** | **10,064.78** | |

| ល.រ | ឈ្មោះគម្រោង | ឆ្លើយតបគោលដៅ | ទីតាំង | លទ្ធផលគ្រោង | | រយៈពេលអនុវត្ត | តម្លៃប៉ាន់ស្មាន (លានរៀល) | ប្រភពមូលនិធិ | អ្នកទទួលផល | | កម្រិតទុនវិនិយោគ (លានរៀល) | | | | អង្គភាពអនុវត្ត |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | បរិមាណ | ឯកតា | | | | សរុប | ស្រី | ២០២៥ | ២០២៦ | ២០២៧ | សរុប | |
| **២-ផ្នែកសង្គមកិច្ច** | | | | | | | | | | | | | | | |
| ១ | ការពង្រីកការអប់រំកុមារតូច | ២.១.២ | ១៣ក្រុង/ស្រុក | ៤១៦ | សាលា | ១ឆ្នាំ | 52.70 | PB | ១៩៥៨០ | ៩៦២៣ | 52.70 | - | - | 52.70 | |
| ២ | ការពង្រឹងគុណភាពនិងប្រសិទ្ធភាពនៃការអប់រំនៅបឋមសិក្សា | ២.១.២ | ១៣ក្រុង/ស្រុក | ៥៥១ | សាលា | ១ឆ្នាំ | 288.60 | PB | ១៥០១២៦ | ៧០៥០២ | 288.60 | - | - | 288.60 | |
| ៣ | ផ្តល់មូលនិធិដំណើរការសាលាមធ្យមសិក្សាសាធារណៈ | ២.១.២ | ១៣ក្រុង/ស្រុក | ១២៥ | សាលា | ១ឆ្នាំ | 3,658.90 | PB | ៨១៧៤០ | ៤២៩៨៨ | 3,658.90 | - | - | 3,658.90 | |
| ៤ | ការចូលរៀនប្រកបដោយសមធម៌ ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការអប់រំនៅមធ្យមសិក្សា | ២.១.២ | ១៣ក្រុង/ស្រុក | ១២៥ | សាលា | ១ឆ្នាំ | 205.10 | PB | ៨១៧៤០ | ៤២៩៨៨ | 205.10 | - | - | 205.10 | |
| ៥ | ការពង្រីកការអប់រំក្រៅប្រព័ន្ធ | ២.១.២ | ១៣ក្រុង/ស្រុក | ១៣ | ក្រុង/ស្រុក | ១ឆ្នាំ | 108.00 | PB | ១៥០០ | ៩២០ | 108.00 | - | - | 108.00 | |
| ៦ | លើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីអប់រំបច្ចេកទេស | ២.១.២ | ១៣ក្រុង/ស្រុក | ១៥ | សាលា | ១ឆ្នាំ | 159.70 | PB | ២៨០ | ១៦០ | 159.70 | - | - | 159.70 | មន្ទីរ អប់រំ យុវជន និង កីឡា |
| ៧ | ពង្រឹងពង្រីកកម្មវិធីលើកកំពស់សុខភាពសិក្សា | ២.១.២ | ១៣ក្រុង/ស្រុក | ៧០៦ | សាលា | ១ឆ្នាំ | 350.00 | PB | ១៤៨៧៣១ | ៦៩៤២០ | 350.00 | - | - | 350.00 | |
| ៨ | ផ្តល់អាហារូបករណ៍សិស្សក្រីក្រ បឋមសិក្សា១០១៧៥នាក់ស្រី៥២៥៣នាក់ | ២.១.២ | ១៣ក្រុង/ស្រុក | ១០១៧៥ | នាក់ | ១ឆ្នាំ | 2,618.20 | PB | ១១០០០ | ៦០០០ | 2,618.20 | - | - | 2,618.20 | |
| ៩ | ផ្តល់អាហារូបករណ៍សិស្សក្រីក្រមធ្យមសិក្សាបឋមភូមិ-ទុតិយភូមិចំនួន ៨៣១០ នាក់ ស្រី ៤៩៤៥នាក់ | ២.១.២ | ១៣ស្រុក/ក្រុង | ៨៣១០ | នាក់ | ១ឆ្នាំ | 2,284.80 | PB | ១២០០០ | ៦៥០០ | 2,284.80 | - | - | 2,284.80 | |
| ១០ | ផ្គត់ផ្គង់សៀវភៅសិក្សាគោលដល់សិស្ស | ២.១.២ | ១៣ក្រុង/ស្រុក | ៦៧៦ | សាលា | ១ឆ្នាំ | 16.00 | PB | ២២២០០៣ | ១០៩១៣២ | 16.00 | - | - | 16.00 | |
| ១១ | អភិវឌ្ឍកីឡា មហាជន និងការប្រកួតកីឡាសិស្ស-និសិត្ស | ២.១.២ | ១៣ក្រុង/ស្រុក | ១៩៦៧ | នាក់ | ១ឆ្នាំ | 1,007.90 | PB | ១៦៨០ | ៧៥០ | 1,007.90 | - | - | 1,007.90 | |
| ១២ | ការអភិវឌ្ឍសកម្មភាពយុវជន-មជ្ឈមណ្ឌលយុវជន-ការអភិវឌ្ឍកាយវប្បកម្ម | ២.១.២ | ១៣ក្រុង/ស្រុក | ១៨៩២៥ | នាក់ | ១ឆ្នាំ | 281.80 | PB | ៦៥៥០ | ២៥០០ | 281.80 | - | - | 281.80 | |

| ល.រ | ឈ្មោះគម្រោង | ឆ្លើយតបគោលដៅ | ទីតាំង | លទ្ធផលគ្រោង | | រយៈពេលអនុវត្ត | តម្លៃប៉ាន់ស្មាន (លានរៀល) | ប្រភពមូលនិធិ | អ្នកទទួលផល | | កម្រិតទុនវិនិយោគ (លានរៀល) | | | | អង្គភាពអនុវត្ត |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | បរិមាណ | ឯកតា | | | | សរុប | ស្រី | ២០២៥ | ២០២៦ | ២០២៧ | សរុប | |
| ១៣ | ការអភិវឌ្ឍនិងពង្រឹងប្រព័ន្ធផែនការអប់រំ | ២.១.២ | ១៣ក្រុង/ស្រុក | ៧៥ | សាលា | ១ឆ្នាំ | 38.70 | PB | ៦៧២ | ១៥៦ | 38.70 | - | - | 38.70 | មន្ទីរ អប់រំ យុវជន និងកីឡា |
| ១៤ | ការគ្រប់គ្រងនិងពង្រឹងប្រសិទ្ធភាពធនធានមនុស្ស | ២.១.២ | ១៣ក្រុង/ស្រុក | ៨៧៥០ | នាក់ | ១ឆ្នាំ | 78,662.00 | PB | ៨៧៥០ | ៣៦៤០ | 78,662.00 | - | - | 78,662.00 | |
| ១៥ | ការគ្រប់គ្រងហិរញ្ញវត្ថុ ការអភិវឌ្ឍសមត្ថភាព ការគាំទ្រការលើកកម្ពស់គុណភាពអប់រំ និងមូលដ្ឋានសម្ភារៈ | ២.១.២ | ១៣ក្រុង/ស្រុក | ៦៧៦ | សាលា | ១ឆ្នាំ | 4,510.10 | PB | ៦៧២ | ១១៥ | 4,510.10 | - | - | 4,510.10 | |
| ១៦ | ការពិនិត្យតាមដាន វាយតម្លៃ និងអធិការកិច្ចប្រព័ន្ធធានាគុណភាពអប់រំ | ២.១.២ | ១៣ក្រុង/ស្រុក | ៦៧២ | សាលា | ១ឆ្នាំ | 54.30 | PB | ១៨៥០០ | ៨២០០ | 54.30 | - | - | 54.30 | |
| ១៧ | ការពង្រឹងការគ្រប់គ្រងការផ្គត់ផ្គង់សម្ភារៈ និងទ្រព្យសម្បត្តិរដ្ឋ | ២.១.២ | ១៣ក្រុង/ស្រុក | ១២ | ការិ. | ១ឆ្នាំ | 11.00 | PB | ១២ | ៣ | 11.00 | - | - | 11.00 | |
| ១៨ | ការអភិវឌ្ឍ និងពង្រឹងប្រសិទ្ធភាពការគ្រប់គ្រង និងការធានាភាពស័ក្តិសិទ្ធនៃសេវារដ្ឋបាល | ២.១.២ | ១៣ក្រុង/ស្រុក | ១៣៥ | សាលា | ១ឆ្នាំ | 33.50 | PB | ៦៧២ | ១១៥ | 33.50 | - | - | 33.50 | |
| ១៩ | ការពង្រឹងគុណភាព និងប្រសិទ្ធភាពការងារប្រឡងនៅមធ្យមសិក្សា និងអប់រំបច្ចេកទេស | ២.១.២ | ១៣ក្រុង/ស្រុក | ១២៥ | សាលា | ១ឆ្នាំ | 818.20 | PB | ៤៧៤៩៤ | ២៥៣៣៥ | 818.20 | - | - | 818.20 | |
| ២០ | ការអភិវឌ្ឍប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំនិងការអភិវឌ្ឍពង្រឹងប្រព័ន្ធពិនិត្យ តាមដាននិងវាយតម្លៃ | ២.១.២ | ១៣ក្រុង/ស្រុក | ៨០ | សាលា | ១ឆ្នាំ | 10.50 | PB | ៦៧២ | ១១៥ | 10.50 | - | - | 10.50 | |
| **សរុបរួម** | | | | | | | **95,170.00** | | | | **95,170.00** | **-** | **-** | **95,170.00** | |
| ២១ | ចុះផ្តល់ជំនួយបច្ចេកទេសការងារអាហារូបត្ថម្ភ | ២.២.១ | ១មន្ទីរ/៩ស្រុក | ១០០ | លើក | ១ឆ្នាំ | 19.30 | រដ្ឋ | ១៥ | ៩ | 19.30 | - | - | 19.30 | មន្ទីរសុខាភិបាល |
| ២២ | គាំទ្របច្ចេកទេស និង បង្រៀននៅនឹងកន្លែងការងារសុខភាពបន្តពូជ | ២.២.២ | ១មន្ទីរ/៩ស្រុក | ៩០ | លើក | ១ឆ្នាំ | 15.90 | រដ្ឋ | ១២ | ៩ | 15.90 | - | - | 15.90 | |
| ២៣ | ចុះផ្តល់ជំនួយបច្ចេកទេការងារសុខភាពមាតា-ទារក | ២.២.៣ | ១មន្ទីរ/៩ស្រុក | ៧០ | លើក | ១ឆ្នាំ | 14.50 | រដ្ឋ | ១៤ | ១០ | 14.50 | - | - | 14.50 | |
| ២៤ | តាមដានស្ត្រីបានរៀបការនិងមានដៃគូមកមណ្ឌលសុខភាពបន្ទាប់ពីបាត់រដូវក្នុងកំឡុងខែទី១ | ២.២.៣ | ១មន្ទីរ/៩ស្រុក | ៥៥ | លើក | ១ឆ្នាំ | 10.10 | រដ្ឋ | ១១ | ៨ | 10.10 | - | - | 10.10 | |
| ២៥ | តាមដានការងារ ស ព ជ ក នៅមន្ទីរពេទ្យ និងមណ្ឌលសុខភាព | ២.២.៤ | ១មន្ទីរ/៩ស្រុក | ៤០ | លើក | ១ឆ្នាំ | 7.50 | រដ្ឋ | ១៤ | ៤ | 7.50 | - | - | 7.50 | |

| ល.រ | ឈ្មោះគម្រោង | ឆ្លើយតបគោលដៅ | ទីតាំង | លទ្ធផលគ្រោង | | រយៈពេលអនុវត្ត | តម្លៃប៉ាន់ស្មាន (លានរៀល) | ប្រភពមូលនិធិ | អ្នកទទួលផល | | កម្រិតទុនវិនិយោគ (លានរៀល) | | | | អង្គភាពអនុវត្ត |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | បរិមាណ | ឯកតា | | | | សរុប | ស្រី | ២០២៥ | ២០២៦ | ២០២៧ | សរុប | |
| ២៦ | តាមដានសមាហរណកម្មនៃការទទួលបន្ទុកពិនិត្យ និងព្យាបាលជំម្ងឺកុមារនៅសហគមន៍ C.IMCI | ២.២.៤ | ១មន្ទីរ/៩ស្រុក | ៣៥ | លើក | ១ឆ្នាំ | 4.30 | រដ្ឋ | ១៥ | ៥ | 4.30 | - | - | 4.30 | មន្ទីរសុខាភិបាល |
| ២៧ | ចុះអភិបាលការងារផ្តល់ថ្នាំបង្ការ | ២.២.៤ | ១មន្ទីរ/៩ស្រុក | ៩៥ | លើក | ១ឆ្នាំ | 18.30 | រដ្ឋ | ២៤ | ៦ | 18.30 | - | - | 18.30 | |
| ២៨ | ចុះអភិបាលការងារសារពើភ័ណ្ឌ និងថែទាំប្រព័ន្ធត្រជាក់ | ២.៦.៣ | ១មន្ទីរ/៩ស្រុក | ៤៥ | លើក | ១ឆ្នាំ | 9.40 | រដ្ឋ | ២៤ | ៦ | 9.40 | - | - | 9.40 | |
| ២៩ | តាមដានវាយតំលៃក្រោយសកម្មភាពសេវាមូលដ្ឋានដល់ភូមិ | ២.៥.១ | ១មន្ទីរ/៩ស្រុក | ៧៥ | លើក | ១ឆ្នាំ | 13.40 | រដ្ឋ | ២៤ | ៦ | 13.40 | - | - | 13.40 | |
| ៣០ | ចុះស្រាវជ្រាវជំងឺរបស់កម្មវិធីផ្តល់ថ្នាំបង្ការ | ២.២.៤ | ១មន្ទីរ/៩ស្រុក | ៤០ | លើក | ១ឆ្នាំ | 5.60 | រដ្ឋ | ២៤ | ៦ | 5.60 | - | - | 5.60 | |
| ៣១ | ចូលរួមប្រជុំ និងបើកសម្ភារៈ និងវ៉ាក់សាំងនៅមន្ទីរសុខាភិបាល | ២.៥.១ | ១មន្ទីរ/៩ស្រុក | ៤៥ | លើក | ១ឆ្នាំ | 8.40 | រដ្ឋ | ២៤ | ៦ | 8.40 | - | - | 8.40 | |
| ៣២ | អភិបាលលើការងារគ្រប់គ្រងទិន្នន័យកម្មវិធីអេដស៍ | ២.៣.១ | ១មន្ទីរ/៩ស្រុក | ៣៥ | លើក | ១ឆ្នាំ | 4.50 | រដ្ឋ | ១១ | ០ | 4.50 | - | - | 4.50 | |
| ៣៣ | ចុះអប់រំស្រ្តីបម្រើសេវាកំសាន្ត មកទទួលសេវាព្យាបាលនៅមន្ទីរពេទ្យ | ២.៣.១ | ១មន្ទីរ/៩ស្រុក | ២៦ | លើក | ១ឆ្នាំ | 6.60 | រដ្ឋ | ១១ | ០ | 6.60 | - | - | 6.60 | |
| ៣៤ | អភិបាលការងារកម្មវិធីអេដស៍ | ២.៣.១ | ១មន្ទីរ/៩ស្រុក | ៣០ | លើក | ១ឆ្នាំ | 5.70 | រដ្ឋ | ១១ | ០ | 5.70 | - | - | 5.70 | |
| ៣៥ | តាមដាននិងពិនិត្យគុណភាពមន្ទីរពិសោធន៍របេង | ២.៣.២ | ១មន្ទីរ/៩ស្រុក | ៥០ | លើក | ១ឆ្នាំ | 10.80 | រដ្ឋ | ១២ | ២ | 10.80 | - | - | 10.80 | |
| ៣៦ | ចុះស្រាវជ្រាវហាង់សិនពីមន្ទីរទៅស្រុកប្រតិបត្តិ | ២.៣.២ | ១មន្ទីរ/៩ស្រុក | ២៦ | លើក | ១ឆ្នាំ | 7.00 | រដ្ឋ | ១២ | ២ | 7.00 | - | - | 7.00 | |
| ៣៧ | ផ្តល់ជំនួយបច្ចេកទេសការងារគ្រុនចាញ់ | ២.៣.៣ | ១មន្ទីរ/៩ស្រុក | ៤០ | លើក | ១ឆ្នាំ | 9.40 | រដ្ឋ | ១២ | ០ | 9.40 | - | - | 9.40 | |
| ៣៨ | ចុះអប់រំ និងផ្សព្វផ្សាយ ជំងឺគ្រុនឈាម | ២.៣.៣ | ១មន្ទីរ/៩ស្រុក | ១៥០ | លើក | ១ឆ្នាំ | 31.80 | រដ្ឋ | ១២ | ០ | 31.80 | - | - | 31.80 | |
| ៣៩ | ចុះផ្តល់បច្ចេកទេសការងារប្រព័ន្ធរបាយការណ៍សូន្យ | ២.៥.៣ | ១មន្ទីរ/៩ស្រុក | ៥០ | លើក | ១ឆ្នាំ | 10.90 | រដ្ឋ | ១២ | ០ | 10.90 | - | - | 10.90 | |
| ៤០ | អប់រំផ្សព្វផ្សាយ ស្តីពីជម្ងឺឆ្លង ១០មុខនៅតាមសហគមន៍ | ២.៣.៤ | ១មន្ទីរ/៩ស្រុក | ៧០ | លើក | ១ឆ្នាំ | 14.30 | រដ្ឋ | ២០ | ៩ | 14.30 | - | - | 14.30 | |
| ៤១ | អប់រំផ្សព្វផ្សាយស្តីពីជំងឺឆ្លងនៅតាមសហគមន៍ | ២.៣.៤ | ១មន្ទីរ/៩ស្រុក | ៩៥ | លើក | ១ឆ្នាំ | 18.50 | រដ្ឋ | ៤០ | ១៨ | 18.50 | - | - | 18.50 | |
| ៤២ | អប់រំផ្សព្វផ្សាយ ស្តីពីជំងឺឆ្លងថ្មី (Covid-19) តាមរយៈខិតប័ណ្ណនៅសហគមន៍ | ២.៣.៤ | ១មន្ទីរ/៩ស្រុក | ៩០ | លើក | ១ឆ្នាំ | 89.60 | រដ្ឋ | ៥០ | ២០ | 89.60 | - | - | 89.60 | |

| ល.រ | ឈ្មោះគម្រោង | ឆ្លើយតបគោលដៅ | ទីតាំង | លទ្ធផលគ្រោង | | រយៈពេលអនុវត្ត | តម្លៃប៉ាន់ស្មាន (លានរៀល) | ប្រភពមូលនិធិ | អ្នកទទួលផល | | កម្រិតទុនវិនិយោគ (លានរៀល) | | | | អង្គភាពអនុវត្ត |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | បរិមាណ | ឯកតា | | | | សរុប | ស្រី | ២០២៥ | ២០២៦ | ២០២៧ | សរុប | |
| ៤៣ | ចុះអង្កេតស្រាវជ្រាវ និង ឆ្លើយតបបន្ទាន់ការផ្ទុះជំងឺឆ្លងរាតត្បាត | ២.៣.៤ | ១មន្ទីរ/៩ស្រុក | ៨០ | លើក | ១ឆ្នាំ | 90.80 | រដ្ឋ | ៥០ | ២០ | 90.80 | - | - | 90.80 | មន្ទីរសុខាភិបាល |
| ៤៤ | ចុះអប់រំសុខភាពភ្នែក | ២.៤.៤ | ១មន្ទីរ/ស្រុកពាមរក៍ | ២៨ | លើក | ១ឆ្នាំ | 5.90 | រដ្ឋ | ៥ | ២ | 5.90 | - | - | 5.90 | |
| ៤៥ | ចុះពិនិត្យការបិតតាំងរូបភាព និងគ្រឿងញៀននៅ តាមមន្ទីរពេទ្យ និងមណ្ឌលសុខភាព | ២.៤.៣ | ១មន្ទីរ/៩ស្រុក | ៣៥ | លើក | ១ឆ្នាំ | 4.50 | រដ្ឋ | ៥ | ១ | 4.50 | - | - | 4.50 | |
| ៤៦ | អប់រំផ្សព្វផ្សាយ ដល់សហគមន៍ពីផលប៉ះពាល់នបារីនិងថ្នាំជក់ | ២.៤.៣ | ១មន្ទីរ/៩ស្រុក | ២០ | លើក | ១ឆ្នាំ | 3.50 | រដ្ឋ | ៥ | ១ | 3.50 | - | - | 3.50 | |
| ៤៧ | ចុះអភិបាលការងារសុខភាពមាត់-ធ្មេញនៅមន្ទីរពេទ្យ និងមណ្ឌលសុខភាព | ២.៤.៥ | ១មន្ទីរ | ៣១ | លើក | ១ឆ្នាំ | 7.90 | រដ្ឋ | ៣ | ១ | 7.90 | - | - | 7.90 | |
| ៤៨ | អប់រំផ្សព្វផ្សាយស្តីពីជំងឺឆ្លងនៅតាមសហគមន៍ | ២.៣.៤ | ១មន្ទីរ/៩ស្រុក | ៤៨ | លើក | ១ឆ្នាំ | 1.50 | រដ្ឋ | ៩ | ២ | 1.50 | - | - | 1.50 | |
| ៤៩ | ចុះគាំទ្របច្ចេកទេសការងារជំងឺមិនឆ្លង | ២.៤.២ | ១មន្ទីរ/៩ស្រុក | ១០ | លើក | ១ឆ្នាំ | 1.70 | រដ្ឋ | ៣ | ១ | 1.70 | - | - | 1.70 | |
| ៥០ | ចុះអន្តរាគមន៍ពិនិត្យព្យាបាលជំងឺរាតត្បាត ពេលជួបគ្រោះមហន្តរាយ និងការបម្រែ បម្រួលអាកាសធាតុ | ២.៣.៤ | ១មន្ទីរ/៩ស្រុក | ២១ | លើក | ១ឆ្នាំ | 3.80 | រដ្ឋ | ១០ | ២ | 3.80 | - | - | 3.80 | |
| ៥១ | ចុះត្រួតពិនិត្យភោជនីដ្ឋាន និងអាហារដ្ឋាន ស្តីពីសុវត្ថិភាពចំណីអាហារ | ២.៤.៥ | ១មន្ទីរ/៩ស្រុក | ៥១ | លើក | ១ឆ្នាំ | 13.30 | រដ្ឋ | ២០ | ៩ | 13.30 | - | - | 13.30 | |
| ៥២ | ចុះផ្តល់បច្ចេកទេសការងារគ្រប់គ្រងឱសថ និងមន្ទីរពិសោធន៍ | ២.៥.១ | ១មន្ទីរ/៩ស្រុក | ៣៥ | លើក | ១ឆ្នាំ | 5.20 | រដ្ឋ | ១០ | ២ | 5.20 | - | - | 5.20 | |
| ៥៣ | ចុះពិនិត្យការងារផ្តល់សេវាសុខភាពនៅមន្ទីរពេទ្យ និងមណ្ឌលសុខភាព | ២.៥.១ | ១មន្ទីរ/៩ស្រុក | ៣៣ | លើក | ១ឆ្នាំ | 8.70 | រដ្ឋ | ១០ | ២ | 8.70 | - | - | 8.70 | |
| ៥៤ | ទំនាក់ទំនងការងាររដ្ឋបាលនៅមន្ទីរសុខាភិបាល | ២.៥.៤ | ១មន្ទីរ/៩ស្រុក | ៤០ | លើក | ១ឆ្នាំ | 4.60 | រដ្ឋ | ១០ | ០ | 4.60 | - | - | 4.60 | |
| ៥៥ | ចុះតាមដានការចំណាយថវិកានៅស្រុកប្រតិបត្តិ មន្ទីរពេទ្យ និងមណ្ឌលសុខភាព | ២.៦.៣ | ១មន្ទីរ/៩ស្រុក | ៦០ | លើក | ១ឆ្នាំ | 10.10 | រដ្ឋ | ១៥ | ៨ | 10.10 | - | - | 10.10 | |

| ល.រ | ឈ្មោះគម្រោង | ឆ្លើយតប គោលដៅ | ទីតាំង | លទ្ធផលគ្រោង | | រយៈពេល អនុវត្ត | តម្លៃប៉ាន់ស្មាន (លានរៀល) | ប្រភព មូលនិធិ | អ្នកទទួលផល | | កម្រិតទុនវិនិយោគ (លានរៀល) | | | | អង្គភាពអនុវត្ត |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | បរិមាណ | ឯកតា | | | | សរុប | ស្រី | ២០២៥ | ២០២៦ | ២០២៧ | សរុប | |
| ៥៦ | ចុះផ្តល់ជំនួយបច្ចេកទេសការងារព័ត៌មានវិទ្យា | ២.៥.២ | ១មន្ទីរ/៩ស្រុក | ២៥ | លើក | ១ឆ្នាំ | 4.50 | រដ្ឋ | ១១ | ១ | 4.50 | - | - | 4.50 | មន្ទីរសុខាភិបាល |
